នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-May-2019, 13:24
CMS/CFO: Ly Bunloung

**បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹង**
**ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត** (D266)

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Nicholas KOUMJIAN

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
អង្គបុរេជំនុំជម្រះ
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី
ទាំងអស់ក្នុងសំណុំរឿង០០៣

សហមេធាវី មាស មុត
លោក អាង ឧត្ដម
លោក Michael KARNAVAS

# មាតិកា

I. សេចក្តីផ្តើម.........1
II. ប្រវត្តិនីតិវិធី.........2
III. ច្បាប់ជាធរមាន.........2
ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍.........2
ខ. បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះសេចក្តីសម្រេចលើយុត្តាធិការបុគ្គល.........2
គ. បទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម.........5
ឃ. លក្ខខណ្ឌតម្រូវឲ្យមានការស៊ើបអង្កេត និងចេញសេចក្តីសម្រេចលើអង្គហេតុនានាដែលស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះ.........7
ង. លក្ខខណ្ឌតម្រូវចំពោះការសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ចំពោះឧក្រិដ្ឋកម្មដែល បានប្រព្រឹត្ត និងលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ.........9
ច. បទដ្ឋាននៃភស្តុតាងសម្រាប់ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ.........12
IV. សារណាបណ្តឹងឧទ្ធរណ៍.........13
ក. កំហុសអង្គច្បាប់ស្តីពីការខកខានមិនបានមានការសន្និដ្ឋានផ្នែកអង្គច្បាប់ និង អង្គហេតុទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនោះ.........13
១. ការគ្មានការសន្និដ្ឋានពាក់ព័ន្ធនឹងថាតើឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្ត និងថាតើ មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះណាមួយឬទេ.........13
២. ការគ្មានសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ដែលផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់.........18
ខ. កំហុសផ្នែកអង្គច្បាប់ស្តីពីការខកខានមិនពិចារណាលើភស្តុតាងដែលបានដាក់នៅ ក្នុងសំណុំរឿង០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១.........25
គ. កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើរាល់ អង្គហេតុទាំងអស់ក្នុងវិសាលភាពនៃសំណុំរឿង ០០៣.........57
ឃ. កំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការប្រព្រឹត្តិនៃការបង្ខិតបង្ខំ ការគាបសង្កត់ និង បញ្ហាថ្នាក់លើនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ នៅពេលធ្វើការកំណត់អំពី កម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត.........74

១. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្តល់ទម្ងន់ហួសហេតុទៅលើបញ្ជាថ្នាក់លើ និងការគាបសង្កត់នៅក្នុងការវិភាគអំពីយុត្តាធិការបុគ្គល ...... 74
២. មាស មុត ប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានឆន្ទៈ និងចំណាប់អារម្មណ៍ ដោយគ្មានការ បង្ខំ និងគាបសង្កត់ ...... 84
៣. សុន សេន បានប្រគល់ឲ្យ មាស មុត នូវអំណាចចាប់ខ្លួន និងកម្មោសជនបរទេស ដែលចាប់បាននៅសមុទ្រ ...... 89
៤.មាស មុត បានបង្កើត និងចូលរួមក្នុងយន្តការកំណត់អត្តសញ្ញាណអ្នកដែលត្រូវចាត់ទុកថាជាខ្មាំង បញ្ជាឲ្យចាប់ខ្លួនទាំងនោះ និងបញ្ជូនអ្នកខ្លះទៅ ស-២១ ...... 94
៥. ការអនុវត្តខុសគ្នាតាមអំពើចិត្តចំពោះការបញ្ជាថ្នាក់លើ ការបង្ខំ និងការគំរាមកំហែង នៅក្នុង សំណុំរឿង ០០១ និងសំណុំរឿង ០០៣...... 98
ង. កំហុសអង្គច្បាប់ និងអង្គហេតុនៅក្នុងដីកាលើកលែងចោទប្រកាន់ពាក់ព័ន្ធនឹងការ ពិនិត្យទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលកំណត់កម្រិត នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ...... 101
១. ដីកាលើកលែងចោទប្រកាន់ ឲ្យតម្លៃហួសហេតុទៅលើការចូលរួមដោយផ្ទាល់ និងការ នៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងការវិភាគអំពីយុត្តាធិការបុគ្គល ...... 101
២. មាស មុត បានដើរតួនាទីដោយផ្ទាល់ និងយ៉ាងសកម្មនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ...... 108
ច. ការសន្និដ្ឋានលើអង្គហេតុដោយខុសឆ្គង មានផលប៉ះពាល់ក្នុងការសម្រេចទៅលើ បញ្ហាយុត្តាធិការ បុគ្គល ...... 118
១. មាស មុត គឺជាលេខាកងពលធំ ១៦៤ (អតីតកងពលធំលេខ ៣) និងជាលេខាតំបន់ស្វយ័តកំពង់ សោម ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ...... 119
២. មាស មុត គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៥ និងជា អនុលេខាអគ្គសេនាធិការ ចាប់ពីចុងឆ្នាំ ១៩៧៨...... 123
៣. មាស មុត គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីខែមករា ឆ្នាំ ១៩៧៦ ...... 130
ឆ. កំហុសឆ្គងអង្គហេតុ នៅក្នុងផ្នែកការពិនិត្យទៅលើជនរងគ្រោះក្នុងដីកាសម្រេចលើកលែង ចោទប្រកាន់ ...... 136
ជ. កំហុសអង្គច្បាប់ដោយការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវជាន់ខ្ពស់តែម្នាក់ គត់ ...... 150
១. ការលើកឡើងថា ឌុច ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ផ្ទុយទៅនឹង ភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ...... 152

២. ការសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ មិនស៊ីសង្វាក់គ្នាជាមួយ ការយល់ដឹងជាក់លាក់អំពីយុត្តាធិការបុគ្គលរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប នៅពេលបង្កើត អ.វ.ត.ក ........ 154

៣. ការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ផ្ទុយពីការសន្និដ្ឋានដោយផ្ទាល់របស់ ស.ច.ស.ជ នៅក្នុងដីកាលើកលែងការចោទប្រកាន់ ព្រមទាំង ដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/០១ និងដីកាលើកលែងការចោទប្រកាន់របស់សំណុំរឿង ០០៤/០២ ........ 162

V. **សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងដីកាដំណោះស្រាយខ្វែងគ្នា** ........ 164

VI. **សេចក្តីសន្និដ្ឋាន** ........ 168

VII. **ដំណោះស្រាយដែលស្នើឡើង** ........ 171

# I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ចោទប្រកាន់ មាស មុត ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ លើកលែងចោទប្រកាន់ មាស មុត ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយផ្អែកលើមូលដ្ឋានថា "អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ មាស មុត ឡើយ"[2]។

2. ដីកាសម្រេចលើកលែងចោទប្រកាន់ ផ្អែកលើការសន្និដ្ឋានថា មាស មុត មិនស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានា និងការរំលោភយ៉ាងធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ យ៉ាងណាក៏ដោយ ដូចបានបង្ហាញយ៉ាងពិស្តារខាងក្រោមនេះ ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់នេះ ផ្អែកលើកំហុសឆ្គងផ្នែកអង្គហេតុ និងអង្គច្បាប់ជាច្រើន ដែលបានធ្វើឱ្យសេចក្ដីសន្និដ្ឋានរបស់ ស.ច.ស.ជ ស្ដីពីយុត្តាធិការបុគ្គល គ្មានសុពលភាពនោះទេ។

3. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ឥឡូវនេះ ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អនុលោមតាមវិធាន[3] ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង។ ស.ព.អ សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បដិសេធដីកាសម្រេចលើកលែងចោទប្រកាន់ និងសន្និដ្ឋានថា មាស មុត ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់

---

[1] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[2] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៤២៩-៣០។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ. លើកទី ៩) ដែលបានពិនិត្យសារឡើងវិញ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

បំផុតចំពោះឧក្រិដ្ឋកម្មនានារបស់ខ្មែរក្រហម ដូច្នេះ គាត់ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ស.ព.អ ក៏ស្នើសុំឱ្យ អ.ប.ជ សម្រេចថា សំណុំរឿងប្រឆាំងនឹង មាស មុត ត្រូវបន្តទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ចៅ.ស.អ[4]។

## II. ប្រវត្តិនីតិវិធី

4. ឧបសម្ព័ន្ធ I បង្ហាញពីប្រវត្តិនីតិវិធីដែលពាក់ព័ន្ធក្នុងរឿងក្ដីនេះ។

## III. ច្បាប់ជាធរមាន

### ក. ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

5. វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង បានចែងថា សហព្រះរាជអាជ្ញា "អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត" ហើយវិធាន ៦៧(៥) ចែងថា ដីកាដំណោះស្រាយនេះ "បើកផ្លូវប្ដឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤"។

### ខ. បទដ្ឋាននៃការពិនិត្យឡើងវិញចំពោះសេចក្ដីសម្រេចលើយុត្តាធិការបុគ្គល

6. ទោះបីជាសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") អាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការកំណត់ថាតើជនត្រូវចោទស្ថិតនៅក្នុងប្រភេទជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានានៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ ឆន្ទានុសិទ្ធិនេះមិនមែនថាគ្មានដែនកំណត់នោះ

[4] សំណើនេះសុំឱ្យដោះស្រាយត្រូវបានបង្កើតឡើងបន្ទាប់ពីមានស្ថានភាពថ្មីនៃដីកាដំណោះស្រាយចំនួនពីរដែលប្រឆាំងគ្នា ដោយមួយជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមួយទៀតជា ដីកាសម្រេចលើកលែងចោទប្រកាន់ នៅក្នុងសំណុំរឿងតែមួយ ដែលត្រូវយកមកពិចារណាជាមួយគ្នា។ សំណើសុំឱ្យដោះស្រាយនេះផ្អែកលើការប៉ាន់ស្មានដែលថាបណ្ដឹងឧទ្ធរណ៍ណាក៏ដោយប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានអនុញ្ញាតទេ។ នៅក្នុងស្ថានភាពនោះ កាលណាមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដ៏មានសុពលភាពរួចហើយ វិធាន ៧៧(១៣)(ខ) តម្រូវឱ្យ អ.ប.ជ ប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ។

ទេ ហើយក៏ "មិនអនុញ្ញាតឲ្យបំពេញកិច្ចតាមអំពើចិត្តទេ"[5]។ អ.ប.ជ អាចពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់ ស.ច.ស.ជ លើរឿងនេះ[6]។

7. លើសពីនេះទៀត ច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ថា នៅពេលមានភ័ស្តុតាងបង្ហាញថា សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិពឹងផ្អែកលើសំអាងហេតុ ឬសំអាងច្បាប់ខុស អង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវតែមោឃភាពសេចក្តីសម្រេចនោះ ដោយត្រូវបញ្ជូនត្រឡប់ទៅតុលាការកម្រិតទាបវិញ ដើម្បីឲ្យអនុវត្តបទដ្ឋានត្រឹមត្រូវ ឬក៏ចេញសេចក្តីសម្រេចផ្ទាល់ខ្លួនលើបញ្ហានោះ[7]។ ដូចដែល អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទនាពេលថ្មីៗនេះថា៖

---

[5] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម") កថាខណ្ឌ ២០ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកាលើករណីរបស់ *ឌុច*") កថាខណ្ឌ ៦២-៧៤, ៧៩។

[6] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២០ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។

[7] *S. Milošević* សំណុំរឿង IT 02-54-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងក្រុមប្រឹក្សាមេធាវី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ១០ *បានដកស្រង់*ក្នុងសំណុំរឿង០០២-ឯកសារ **D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរក ភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ("សាលដីកាលើឃ្លាំងផ្ទុករួម") កថាខណ្ឌ ២៥។ *S. Milošević* សំណុំរឿង IT-99-37-AR73, IT-01-50-AR73, IT-01-51-AR73 សំអាងហេតុសម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់អយ្យការពីការជំទាស់ និងការបដិសេធទៅនឹងដីកាសម្រេចឲ្យចូលរួម ចុះថ្ងៃ ទី១៨ ខែមេសា ឆ្នាំ២០០២ កថាខណ្ឌ ៥-៦។ *Šešel* សំណុំរឿង IT-03-67-AR73.5 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ បន្ទាន់បន្ទំរបស់ Vojislav Šešelj ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីទម្រង់នៃការដាក់បង្ហាញ ចុះថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០០៧ កថាខណ្ឌ ១៤។ *Halilović* សំណុំរឿង IT-01-48-AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយជនជាប់ចោទពីតុមេធាវី ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ កថាខណ្ឌ ៥, ៦៤។ *Karemera និងគូកន* សំណុំរឿង ICTR-98-44-AR73 សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ III សេចក្តីសម្រេចចុះថ្ងៃទី០៨ ខែ តុលា ឆ្នាំ២០០៣ ដែលបានបដិសេធលើការអនុញ្ញាតដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ៥។ *Uwinkindi* សំណុំរឿង ICTR-01-75-AR72(C) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចបដិសេធញត្តិ ដែលចោទប្រកាន់អំពីវិការៈនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ ជម្រះ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ កថាខណ្ឌ ៦។ *Katanga & Ngudjolo Chui* សំណុំរឿង ICC-01/04-01/07-1718 អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់

សេចក្តីសម្រេចមួយអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្តីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (*គឺ* កំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (*គឺ* កំហុសអង្គហេតុ) ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុមិនសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋានដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុស ឬមានការបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[8]។

8. អ.ប.ជ បានសម្រេចថា យុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា នៅពេលមានបណ្តឹងឧទ្ធរណ៍ "ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើង ត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ ហើយការភ័ន្តច្រឡំអង្គហេតុ ត្រូវបានពិនិត្យមើលស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បីកំណត់ថា ពុំមានអ្នកវិនិច្ឆ័យលើអង្គហេតុដែលសមស្របបានធ្វើសេចក្តីសម្រេចលើអង្គហេតុដែលបានលើកឡើងនេះទេ"[9]។

---

រដ្ឋអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើ លេខ ១.២០០ របស់រដ្ឋអាជ្ញាសុំការហាមឃាត់ និងវិធានការតឹងរ៉ឹងប្រឆាំងនឹង Mathieu Ngudjolo ទាក់ទងនឹងទំនាក់ទំនង ទាំងខាងក្នុង និងទាំងខាងក្រៅមន្ទីរឃុំឃាំង" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ១, ៤១-៤៣។

[8] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២១ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។

[9] សំណុំរឿង ០០២-**D427/1/30** អ.ប.ជ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ១១៣។

## គ. បទដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណជននាំមុខឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម

9. ការកំណត់អត្តសញ្ញាណមន្ត្រីខ្មែរក្រហមទាំងអស់នោះ[10] "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃមួយទាំងទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[11]។ ការវាយតម្លៃនេះត្រូវតែធ្វើឡើងដោយ "ផ្អែកទាំងស្រុងលើអង្គសេចក្ដីនៃរឿងក្ដីនីមួយៗ"[12] ហើយដោយសារ ស.ច.ស ទាំងពីរបានទទួលស្គាល់នាពេលថ្មីៗនេះ "ពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការ បង្កើត អ.វ.ត.ក នាំឲ្យមានការយល់ឃើញតាមផ្លូវច្បាប់រួមថា មានតែបុគ្គល (មានឈ្មោះ) មួយចំនួនប៉ុណ្ណោះដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ"[13]។

10. កត្តាដែលពាក់ព័ន្ធក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត រួមមាន (១) ចំនួនជនរងគ្រោះ[14] (២) វិសាលភាពភូមិសាស្ត្រ និងពេលវេលា និង របៀបដែលឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តតាមការចោទប្រកាន់ ហើយនឹង (៣) ចំនួនព្រឹត្តិការណ៍ដាច់ដោយឡែកនានា[15]។

---

[10] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៥២, ៦១។

[11] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៧១, ៨០។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រមរបស់ *ឌុច*") កថាខណ្ឌ ២២។ ឯកសារ **D261** ដីកាដំណោះ ស្រាយ (សំអាងហេតុ) នៅក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ("ដីកាដំណោះស្រាយលើសំណុំ រឿង ០០៤/១") កថាខណ្ឌ ៣៧-៤១។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ស្ដីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២១។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣, ៣៦៥-៣៦៧ [ទទួលស្គាល់ថា ចំណុចនេះគឺជាបទដ្ឋានដែលអាចអនុវត្តបាន]។ *សូមអាន ផងដែរ* *Lukić & Lukić* សេចក្ដីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៦-២៨។

[12] ឯកសារ **D261** សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ កថាខណ្ឌ ៣៧។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ ស្ដីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២១ (ចៅក្រម Beauvallet និង Baik)។

[13] ឯកសារ **D261** សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ កថាខណ្ឌ ៣៧-៣៨។

[14] ទម្ងន់នៃឧក្រិដ្ឋកម្មត្រូវបានកំណត់មួយផ្នែកដោយការយោងទៅដល់ភាពងាយរងគ្រោះរបស់ពួកជនរងគ្រោះទាំងនោះ។ *សូមអាន* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៣៧៥។

11. ចំពោះកម្រិតនៃការទទួលខុសត្រូវ កត្តាពាក់ព័ន្ធរួមមាន (១) កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម រួមទាំងកម្រិតនៃការចូលរួមនៅក្នុងការបង្កើតគោលនយោបាយ និង/ឬ ការអនុវត្តគោលនយោបាយ (២) ឋានន្តរស័ក្តិ ឬ មុខតំណែង តាមឋានានុក្រមរបស់ជនជាប់ចោទ រួមទាំង (៣) ចំនួនអ្នកនៅក្រោមបង្គាប់ និងថ្នាក់ឋានានុក្រមនៅពីលើគាត់ និងមុខតំណែងអចិន្ត្រៃយ៍[16]។ កត្តាពាក់ព័ន្ធផ្សេងៗទៀតរួមមាន សិទ្ធិអំណាចជាក់ស្តែង[17] និងលទ្ធភាពក្នុងការចេញបញ្ជា[18] វិសាលភាពពេលវេលានៃការគ្រប់គ្រងរបស់ពួកគាត់[19] ហើយនឹង ថាតើជនដែលមានឋានន្តរស័ក្តិជាន់ខ្ពស់ទាំងនោះត្រូវបានផ្តន្ទាទោសរួចហើយឬនៅ[20]។ មុខងារជាក់លាក់របស់បុគ្គលម្នាក់មិនត្រូវវាយតម្លៃតែឯង ឬ ត្រូវបានកំណត់ជាមុនដោយផ្អែកខ្លាំងពេកទៅលើផ្នែកផ្លូវការនោះទេ[21]។

---

[15] ឯកសារ **D261** សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៧។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៦ [ទទួល ស្គាល់ថា ចំណុចនេះគឺជាបទដ្ឋានដ៏សមស្រប]។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២៧ (ចៅក្រម Beauvallet និង Baik)។ *Janković* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ១៩។ *Todović* សាលដីកាបញ្ជូនរឿង កថាខណ្ឌ ១៣, ១៦។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៣៧៥។ *Tolimir* សាលដីកា កថាខណ្ឌ ៦៣៣។

[16] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។ ឯកសារ **D261** សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩-៤១។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣៣២, ៣៣៥ (ចៅក្រម Beauvallet និង Baik)។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៧, ៣៦៩។ ឯកសារ **D10.1.101** ដីកា ដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយលើសំណុំរឿង ០០២") កថាខណ្ឌ ១៣២៨។ *Ademi* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៩។ *Kovačević* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២០។ *D. Milošević* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៣។ *Lukić* សាលដីកា កថាខណ្ឌ ២១។

[17] *Lukić & Lukić* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៨។ *Ademi* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៩។

[18] *Ademi* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៩។

[19] *D. Milošević* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៣។

[20] *Kovačević* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២០។

[21] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២៤។ *សូមអានផងដែរ* *Ntaganda* សំណុំរឿង ICC-01/04-169-US-Exp សាលក្រមស្តីពីបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី I មានចំណងជើងថា "សេចក្តីសម្រេចលើលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំដីកាចាប់ខ្លួន តាមមាត្រា ៥៨" ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ៧៦។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពី ដីកាដំណោះស្រាយលើករណី អ៊ឹម ចែម កថាខណ្ឌ ៣២១, ៣៣៤ (ចៅក្រម Beauvallet និង Baik)។

12. ការអនុវត្តគោលការណ៍ទាំងពីរនេះមិនតម្រូវឲ្យមានការប្រៀបធៀប និងការចាត់ចំណាត់ថ្នាក់ទៅលើការទទួលខុសត្រូវរបស់អ្នកដែលអាចជាចារីទាំងអស់នោះទេ[22] ប៉ុន្តែ ត្រូវគិតគូរទៅលើរឿងក្តីផ្សេងៗដែលតុលាការបានជំនុំជម្រះ និងកាលៈទេសៈ និងបរិបទដោយឡែក ដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត[23]។ មិនត្រូវផ្តល់ទម្ងន់ដោយមិនត្រឹមត្រូវទៅលើលក្ខណៈឧក្រិដ្ឋកម្មនៅមូលដ្ឋាននោះទេ ដោយហេតុថា មេដឹកនាំថ្នាក់មូលដ្ឋានអាចមានឥទ្ធិពលសំខាន់ និង/ឬដើរតួសំខាន់នៅក្នុងការអនុវត្តគោលនយោបាយទូទាំងប្រទេស ដែលត្រូវដាក់គាត់ទៅក្នុងប្រភេទនៃជនដែលទទួលខុសត្រូវខ្ពស់បំផុត[24]។

## ឃ. លក្ខខណ្ឌតម្រូវឲ្យមានការស៊ើបអង្កេត និងចេញសេចក្តីសម្រេចលើអង្គហេតុនានាដែលស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះ

13. អនុលោមតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ស.ច.ស មានកាតព្វកិច្ចស៊ើបអង្កេតឲ្យបានពេញលេញ និងត្រឹមត្រូវ *តាមផ្លូវច្បាប់* ទៅលើអង្គហេតុសំខាន់ៗ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយ[25]។

---

[22] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៦២។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២៤។

[23] *Ademi* សេចក្តីសម្រេចបញ្ជូនរឿង កថាខណ្ឌ ២៨។

[24] *Lukić* សាលដីកា កថាខណ្ឌ ២២។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពី ដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២៩, ៣៣៥-៣៣៦ (ចៅក្រម Beauvallet និង Baik)។

[25] វិធានផ្ទៃក្នុង ៥៣, ៥៥(១), ៥៥(២)។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា") មាត្រា ១២៥។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ ឌុច") កថាខណ្ឌ ៣៥។ សំណុំរឿង ០០៤-ឯកសារ **D365/3/1/5** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ("សាលដីការបស់ អ.ប.ជ ទាក់ទងអំពើហិង្សាផ្លូវភេទ") កថាខណ្ឌ ៣៩។ *សូមអានផងដែរ* សំណុំរឿង ០០២-ឯកសារ **D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ("ដីកា សម្រេចរបស់ ក.ស.ច.ស") កថាខណ្ឌ ៦ កំណត់សម្គាល់ជើងទំព័រលេខ ១។ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ១៩៧៧ លេខ ៧៦-៩១.៤៤២ ["le juge

ស.ច.ស មិនត្រូវបានអនុញ្ញាតឱ្យបដិសេធការស៊ើបអង្កេតនោះទេ[26] ហើយអាចបំពេញកិច្ចស៊ើបសួរបាន តែនៅពេលដែលគាត់បានអនុវត្តការយកចិត្តទុកដាក់ត្រឹមត្រូវរបស់ខ្លួន នៅក្នុងការប្រមូលសម្ភារទាំងអស់ដែលចាំបាច់ក្នុងការកំណត់ថាតើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬកំណត់ពីយុត្តាធិការ[27]។ ស.ច.ស មានកាតព្វកិច្ចបន្ថែមទៀតក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងដីកាដំណោះស្រាយ ថាតើជាដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ[28] ទៅលើអង្គហេតុនីមួយៗដែលចៅក្រមស៊ើបសួរបានទទួលបណ្តឹងយ៉ាងត្រឹមត្រូវនោះ[29]។

---

d'instruction est tenu d'informer sur tous les faits dont il a été régulièrement saisi."។ ការបកប្រែក្រៅផ្លូវការ៖ "សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចក្នុងការស៊ើបអង្កេតគ្រប់អង្គហេតុទាំងអស់ ដែលគាត់ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវ"]។

[26] *សូមមើល* Guéry & Chambon, *Droit et Pratique de l'Instruction préparatoire* (បោះពុម្ពលើកទី ៧) ឆ្នាំ២០១០-២០១១ ទំព័រ ១៥៨ s. 51.02 ("Guéry") *ដោយលើកឡើងពី* Cass. Crim ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ១៩៨៧ លេខ ៨៦-៩០.៧៦៩ ["Attendu que, […] le juge d'instruction n'est autorisé à rendre une ordonannce disant qu'il n'y a lieu à informer que si, pour des causes affectant l'action publique elle-même, les faits ne peuvent légalement comporter une poursuite ou si, à supposer les faits démontrés, ils ne peuvent admettre une qualification pénale."។ ការបកប្រែក្រៅផ្លូវការ៖ "តាមមាត្រា ៨៦ កថាខណ្ឌ ៣ នៃក្រមព្រហ្មទណ្ឌ កាលណាចៅក្រមស៊ើបអង្កេត មានសិទ្ធិចេញដីកាបដិសេធស៊ើបអង្កេត តែនៅពេលណាដែល ចំពោះហេតុផលនានាដែលប៉ះពាល់ដល់ការចោទប្រកាន់ខ្លួនវា អង្គហេតុមិនអាចត្រូវបានចោទប្រកាន់ ឬនៅពេលណាដែលអង្គហេតុត្រូវបានបង្កើតឡើង មិនមានការកំណត់បទឧក្រិដ្ឋណាមួយឡើយ"។ Voir aussi: "Le juge d'instruction, saisi par réquisitoire supplétif du procureur de la République ne peut […] refuser d'informer"។ ការបកប្រែក្រៅផ្លូវការ៖ "នៅពេលដែលបានប្តឹងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចៅក្រមស៊ើបអង្កេតមិនអាច […] បដិសេធការស៊ើបអង្កេតបានទេ"]។

[27] *សូមអាន* Guéry ទំព័រ ៨៥៣, s. 212.11 ["La procédure est complète lorsqu'elle réunit les éléments nécessaires pour décider s'il y a lieu de prononcer la mise en prévention de l'inculpé et pour déterminer la jurisdiction compétente. la loi n'a pas déterminé le delai; le juge d'instruction est seulement tenu de procéder avec diligence, comme tout juge."។ ការបកប្រែក្រៅផ្លូវការ៖ "នីតិវិធីគឺចប់សព្វគ្រប់ កាលណាវាត្រូវទៅនឹងគ្រប់ធាតុផ្សំចាំបាច់ទាំងអស់ ដើម្បីសម្រេចថាតើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងជនត្រូវចោទ និងត្រូវកំណត់ពីយុត្តាធិការមានសមត្ថកិច្ច។ ច្បាប់មិនភ្ជាប់កាតព្វកិច្ចចៅក្រមស៊ើបអង្កេតទៅនឹងការកម្រិតពេលវេលាទេ។ គាត់គ្រាន់តែមានកាតព្វកិច្ចដំណើរការប្រកបទៅដោយភាពហ្មត់ចត់ ដូចជាគ្រប់ចៅក្រមទាំងអស់ដូច្នោះដែរ។"]។

[28] ដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាំងពីរនេះគឺជា ដីកាដំណោះស្រាយ និងមានលក្ខខណ្ឌតម្រូវខាងនីតិវិធីដូចគ្នា។ *សូមអាន* វិធានផ្ទៃក្នុង ៦៧(១) ["[ស.ច.ស] ត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"]។ វិធាន ផ្ទៃក្នុង ៦៧(៤) ["ដីកានេះ[ដីកាដំណោះស្រាយ]អាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬ ប្រឆាំងនឹង បុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត"] សទ្ទានុក្រម [ដីកាដំណោះស្រាយ "សំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត […] នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់"។ ហើយ ដីកាលើកលែងចោទប្រកាន់ "សំដៅទៅលើដីកាដំណោះស្រាយដែលធ្វើឡើង

## ខ. លក្ខខណ្ឌតម្រូវចំពោះការសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ

14. អនុលោមតាមបទដ្ឋានអន្តរជាតិដែលថា គ្រប់សេចក្តីសម្រេចទាំងអស់នៃអង្គភាពតុលាការ ត្រូវតែមានសំអាងហេតុនោះ[30] "សេចក្តីសម្រេចរបស់ ស.ច.ស ក្នុង *ការលើកលែងការចោទប្រកាន់*

---

ដោយសហចៅក្រមស៊ើបអង្កេត ឬ សេចក្តីសម្រេចរបស់អង្គបុរេជំនុំ ជម្រះ លើកលែងចោទប្រកាន់ចំពោះជនត្រូវចោទ"។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧។

[29] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី របស់ ឌុច កថាខណ្ឌ ២៩, ៣៣, ៣៧-៣៨, ១១៥។ សំណុំរឿង ០០២-ឯកសារ **D198/1** ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១០។ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៦-៩១.៤៤២ ["Le juge d'instruction avait l'obligation d'instruire, puis de statuer par une ordonnance de règlement sur l'ensemble des faits" […] "Le juge est tenu de statuer par ordonnance du règlement sur tous les faits dont il a été régulièrement saisi"។ ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេត ហើយបន្ទាប់មក ត្រូវចេញដីកាមួយ គ្របដណ្តប់លើគ្រប់អង្គហេតុទាំងអស់។ […] ចៅក្រមនេះត្រូវមានកាតព្វកិច្ចប្រកាសគ្រប់អង្គហេតុទាំងអស់ដែលគាត់ ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវ"]។ Cass. Crim. ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៤ លេខ ០៣-៨៥.៩៨៣ ["le juge d'instruction n'a pas statué, comme il en a le devoir, dans son ordonnance de renvoi, sur tous les faits dont il est saisi"។ ការបកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបអង្កេតមិនវិនិច្ឆ័យនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ដូចដែលគាត់មានកាតព្វកិច្ចនោះទេ នៅលើគ្រប់អង្គហេតុទាំងអស់ដែលគាត់ត្រូវបានប្តឹង"]។ *សូមអានផងដែរ* សំណុំ រឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ១១៦, ១២៩ (ចៅក្រម Beauvallet និង Baik)។

[30] *សូមអាន* សំណុំរឿង ០០២-ឯកសារ **D55/I/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ២១ (និងករណីយុត្តិសាស្ត្រនៅក្នុងនោះ) ["អង្គបុរេជំនុំជម្រះយល់ឃើញថា "សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឱ្យផ្តល់សម្អាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ""]។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំ ជម្រះលើករណីរបស់ ឌុច កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ របស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ២៥ ["រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថា ជាសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុង ការផ្តល់សំអាងហេតុគ្រប់គ្រាន់"] (*បានលើកឡើងដោយ* មាស មុត នៅក្នុងឯកសារ **D256/11** ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩)។ សំណុំរឿង ០០២-ឯកសារ **E50** សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ("សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការដោះលែងបន្ទាន់") កថាខណ្ឌ ២៣-២៧ (និងករណីយុត្តិសាស្ត្រនៅក្នុងនោះ)។ *សូមអានបន្ថែមទៀត ឧទា. Milutinović* សំណុំរឿង IT-99-37-AR65.3 អង្គជំនុំ ជម្រះសាលាឧទ្ធរណ៍ សសាលដីកាបដិសេធ

ចំពោះអំពើទាំងឡាយ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ត្រូវផ្តល់សំអាងហេតុ ដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង"[31]។ ហេតុដូច្នេះ ដីកាដំណោះស្រាយត្រូវតែ "ជាអប្បបរមា [...] ផ្តល់សំអាងហេតុដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន ពាក់ព័ន្ធនឹងការពិចារណាដ៏សំខាន់ទាក់ទងនឹងសេចក្តីសម្រេចរបស់ខ្លួន"[32]។

15. ដោយសារការកំណត់ថាតើជនជាប់ចោទម្នាក់ស្ថិតនៅក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឱ្យមានការវាយតម្លៃទាំងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិត នៃការទទួលខុសត្រូវរបស់ជនសង្ស័យ[33] ផ្អែកលើគ្រប់អង្គហេតុទាំងអស់ដែល ស.ច.ស ត្រូវបានប្តឹង[34] ហើយការ

---

ការអនុញ្ញាតឱ្យ Milutinović ប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ២២ ["ជាផ្នែកនៃការធានាថាសវនាការមានយុត្តិធម៌ អង្គជំនុំជម្រះត្រូវតែផ្តល់នូវសម្អាងហេតុ។ លក្ខខណ្ឌតម្រូវនេះ តម្រូវឱ្យអង្គជំនុំជម្រះមានកាតព្វកិច្ច ជាអាទិ៍ បញ្ជាក់នូវទស្សនះរបស់ខ្លួនអំពី [...] គ្រប់កត្តាពាក់ ព័ន្ធទាំងអស់នោះ ដែលអង្គជំនុំជម្រះសាលាដំបូងដ៏សមហេតុសមផលមួយនឹងត្រូវបានរំពឹងទុកថានឹងយកចិត្តទុកដាក់ មុននឹងឈានទៅដល់សេចក្តីសម្រេច"]។ *Lubanga* សំណុំរឿង ICC-01/04-01/06-773 អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជុះនុំជម្រះ ទី I ក្រោមចំណងជើងថា "សាលដីកាដំបូងស្តីពីសំណើសុំរបស់អយ្យការ និងសំណើសុំឱ្យកែប្រែចំពោះការកោសលុប តាមវិធាន ៨១" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ ("សាលដីកាស្តីពីការកោសលុបក្នុងករណីរបស់ *Lubanga*") កថាខណ្ឌ ២០ ["សាលដីការបស់អង្គបុរេជំនុំជម្រះ សម្រេចមិនឱ្យដាក់បង្ហាញចំពោះមេធាវីការពារក្តីនូវអត្តសញ្ញាណកម្មរបស់សាក្សីរបស់រដ្ឋអាជ្ញា ត្រូវតែបានគាំទ្រដោយសំអាងហេតុយ៉ាងគ្រប់គ្រាន់"]។

[31] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី របស់ ឌុច កថាខណ្ឌ ៣៨ (សង្កត់ន័យបន្ថែម*ដោយអក្សរទ្រេត*) ១១៥។ វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង ["ដីកាដំណោះ ស្រាយត្រូវតែមានសំអាងហេតុ"]។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពី ដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ)។ ក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា មាត្រា ២៤៧ ["[ដីកាដំណោះស្រាយ] អាចជា ដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់ [...]។ ដីកាដំណោះស្រាយជានិច្ចជាកាលត្រូវតែមានសំអាងហេតុ"]។

[32] *Milutinović និងគូកន* សំណុំរឿង IT-05-87-AR65.1 អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ថំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតដោះលែងជាបណ្តោះអាសន្នលើលោក Nebojsa Pavkovic ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ១១។ សាលដីកាកោសលុបក្នុងករណីរបស់ *Lubanga* កថាខណ្ឌ ២០។

[33] *សូមអាន ខាងលើ* កថាខណ្ឌ ៩-១២។

[34] *សូមអាន ខាងលើ* កថាខណ្ឌ ១៣។

សម្រេចលើកលែងការចោទប្រកាន់រឿងក្តីមួយដោយសារតែបញ្ហាយុត្តាធិការបុគ្គល ត្រូវមានការសន្និដ្ឋានលើផ្នែកអង្គហេតុ និងអង្គច្បាប់ ដែលចាំបាច់ដើម្បីធ្វើសេចក្តីសម្រេចនោះ។

16. ដូច្នេះ ស.ច.ស ត្រូវ "ធ្វើការសម្រេចចុងក្រោយពាក់ព័ន្ធនឹងការកំណត់ប្រភេទបទល្មើសនៃអំពើនានាដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងសម្រេចថាតើ អំពើទាំងនោះត្រូវចាត់ទុកថាជាបទឧក្រិដ្ឋនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ"[35]។ តាមពិតទៅ អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា ត្រូវមានការសន្និដ្ឋានទាំងនេះ។ ដើម្បីអនុវត្តអំណាចរបស់ខ្លួនដោយត្រឹមត្រូវក្នុងការពិនិត្យមើលឡើងវិញទៅលើសេចក្តីសម្រេចទៅលើយុត្តាធិការបុគ្គល "*ត្រូវអាច* ពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែបនេះ រួមទាំង សេចក្តីសន្និដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់[ជនសង្ស័យ]"[36]។ ដីកាដំណោះស្រាយលើសំណុំរឿង០០៤/១ ដែលថាគ្មានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម មានការសន្និដ្ឋានអំពីឧក្រិដ្ឋកម្មដែលត្រូវបានបង្ហាញភ័ស្តុតាង ហើយនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ។ ពិតមែនទៅ ការសន្និដ្ឋានទាំងនេះមាន

---

[35] សំណុំរឿង ០០២-ឯកសារ **D427/3/15** អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ("សាលដីការបស់ អ.ប.ជ ស្តីពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៧៩។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២១-៣៤០ (ចៅក្រម Beauvallet និង Baik)។ *សូមអានបន្ថែមទៀត* សាលដីកាស្តីពីការកោសលុបក្នុងករណីរបស់ *Lubanga* កថាខណ្ឌ ២០ ["សេចក្តីសម្រេចត្រូវតែកំណត់អត្តសញ្ញាណថា តើអង្គហេតុមួយណាត្រូវបានរកឃើញថា មានជាប់ទាក់ទង ក្នុងការបានឈានទៅដល់សេចក្តីសន្និដ្ឋានរបស់ខ្លួននេះ"]។ រហូតមកដល់ពេលនេះ ដីកាដំណោះស្រាយនីមួយៗដែលបានចេញនៅ អ.វ.ត.ក លើកលែងតែចំពោះដីកាសម្រេចលើកលែងចោទប្រកាន់ និង សំណុំរឿង ០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤/២") មានការសន្និដ្ឋានទាំងនេះ។

[36] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២៦ (សេចក្តីសម្រេចជាឯកច្ឆ័ន្ទ) (សង្កត់ន័យបន្ថែម*ដោយអក្សរទ្រេត*)។ *សូមអានបន្ថែមទៀត* សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៥។

សារៈសំខាន់ចំពោះការវិភាគរបស់ ស.ច.ស ទៅលើបញ្ញាយុត្តាធិការបុគ្គលទាក់ទងនឹង អ៊ឹម ចែម[37]។

17. ជាងនេះទៀត ត្រូវតែច្បាស់លាស់ថាតើ ស.ច.ស វាយតម្លៃលើភស្តុតាងដោយរបៀបណា ដើម្បីមានការសន្និដ្ឋានផ្អែកអង្គហេតុ រួមទាំង ការបង្ហាញពីភស្តុតាងណា ដែលត្រូវបានទទួលយកជាភស្តុតាងនៃធាតុផ្សំទាំងអស់របស់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[38]។ តាមការសន្មត ស.ច.ស បានវាយតម្លៃយ៉ាងត្រឹមត្រូវលើគ្រប់ភស្តុតាងទាំងអស់ដែលមាននៅចំពោះមុខពួកគាត់ ដរាបណាមិនមានការបង្ហាញថា ពួកគាត់មិនបានយកចិត្តទុកដាក់ទៅលើភស្តុតាងពាក់ព័ន្ធជាក់លាក់នោះ[39]។ សូម្បីតែក្នុងករណីដែលការវិភាគខ្លួនឯងត្រូវមានសំអាងហេតុក៏ដោយ "ការវិភាគដែលត្រូវបានកម្រិតចំពោះតែផ្នែកដែលជ្រើសរើសនៃកំណាត់ត្រាភស្តុតាងពាក់ព័ន្ធ គឺមិនគ្រប់គ្រាន់ចាំបាច់ក្នុងការបង្កើតជាទស្សនៈមួយដែលមានសំអាងហេតុនោះទេ"[40]។

## ច. បទដ្ឋាននៃភស្តុតាងសម្រាប់ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ

18. អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ត្រូវតែមាន "ភស្តុតាងគ្រប់គ្រាន់ [...] នៃបទចោទ" ដើម្បីចេញដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងជនត្រូវចោទ[41]។ ស.ច.ស និង អ.ប.ជ បានបញ្ជាក់ថា តម្រូវឱ្យមាន "ភវនីយភាព" នៃពិរុទ្ធភាព ដែលលើសពី "គ្រាន់តែអាចកើតមានឡើង" ប៉ុន្តែតិចជាងបទដ្ឋាន "ហួសពីវិមតិសង្ស័យ" ដែលបានប្រើប្រាស់

---

[37] *សូមអាន* ឯកសារ **D261** សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ កថាខណ្ឌ ២៨១-៣២៥ កំណត់សម្គាល់ជើងទំព័រ លេខ ៧៣៥។

[38] *សូមអាន ឧទា.* *Bemba* សាលដីកា កថាខណ្ឌ ៥២។ *Kordić & Čerkez* សាលដីកា កថាខណ្ឌ ៣៨៥។ *Kunarac* សាលដីកា កថាខណ្ឌ ៤១។

[39] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាលើសំណុំរឿង ០០២/០១") កថាខណ្ឌ ៣០៤ (និងការលើកឡើងនៅក្នុងនោះ)។

[40] *Perišić* សាលដីកា កថាខណ្ឌ ៩៥។

[41] ស.ច.ស បានអនុវត្តបទដ្ឋាននេះនៅក្នុងសំណុំរឿង ០០១ (សំណុំរឿង ០០១-ឯកសារ **D99** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេអ៊ាវ *ហៅ* ឌុច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ("ដីកាដំណោះស្រាយលើករណីរបស់ ឌុច") កថាខណ្ឌ ១៣០ ហើយនិង សំណុំរឿង ០០២ (ឯកសារ **D10.1.101** កាដំណោះស្រាយលើសំណុំរឿង ០០២ កថាខណ្ឌ ១៣២១)។

នៅពេលជំនុំជម្រះ[42]។ លើសពីនេះទៀត "ភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភស្តុតាងបន្ទាល់ (ភស្តុតាងដែលត្រូវយកជាបានការរហូតដល់មានភស្តុតាងផ្ទុយ)"[43]។

## IV. សារណាបណ្តឹងឧទ្ធរណ៍

19. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ ក្នុងការសន្និដ្ឋានថា មាស មុត មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ កំហុសនេះផ្អែកលើកត្តាជាច្រើនដែលត្រូវបានពិភាក្សាខាងក្រោមនេះ។

### ក. កំហុសអង្គច្បាប់ស្តីពីការខកខានមិនបានមានការសន្និដ្ឋានផ្នែកអង្គច្បាប់ និងអង្គហេតុនៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនោះ

#### ១. ការគ្មានការសន្និដ្ឋានពាក់ព័ន្ធនឹងថាតើឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្ត និងថាតើ មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះណាមួយឬទេ

20. ដូចដែលដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទាល់ បានទទួលស្គាល់ ការវាយតម្លៃថាតើ នរណា "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃមួយស្តីពីទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[44]។ ចៅក្រម អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា ដើម្បីអនុវត្តតួនាទីឲ្យបានត្រឹមត្រូវក្នុងការពិនិត្យទៅលើបញ្ហាយុត្តាធិការបុគ្គល ពួកគាត់ "*ប្រាកដជាត្រូវអាច*

---

[42] ឯកសារ **D10.1.101** កាដំណោះស្រាយលើសំណុំរឿង ០០២ កថាខណ្ឌ ១៣២៣។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៦០-៦២។

[43] ឯកសារ **D10.1.101** កាដំណោះស្រាយលើសំណុំរឿង ០០២ កថាខណ្ឌ ១៣២៣។

[44] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣, ៣៦៥-៧។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរបស់ *ឌុច* កថាខណ្ឌ ២២។ *សូមអានផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២១។

ពិនិត្យមើលលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែបនេះ រួមទាំង សេចក្តីសន្និដ្ឋានទាំងឡាយណាដែលពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់[ជនសង្ស័យ]"[45]។ ចំណុចនេះគឺជាការពិត ពាក់ព័ន្ធនឹងគ្រប់អង្គហេតុទាំងអស់ដែល ស.ច.ស ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[46]។ ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុស ដោយខកខានមិនមានការសន្និដ្ឋានលើអង្គហេតុជាច្រើនដែលជាលក្ខខណ្ឌតម្រូវ ហើយក៏គ្មានការសន្និដ្ឋានលើអង្គច្បាប់ទាល់តែសោះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែល ស.ច.ស ត្រូវបានប្តឹង។

21. ជាឧទាហរណ៍ ផ្ទុយទៅនឹងការមានការសន្និដ្ឋានលើអង្គហេតុអំពីប្រតិបត្តិការនៅវត្តឥន្ទញ្ញាណ[47] និងឧក្រិដ្ឋកម្មនានាដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានចោទប្រកាន់ថាបានកើតឡើងនៅទីនោះ ដីកាសម្រេចលើកលែងចោទប្រកាន់គ្រាន់តែពិភាក្សាទៅលើភស្តុតាងជាផ្នែកចេញពីសាក្សីមួយចំនួនប៉ុណ្ណោះ។ ទោះបីជាទូទៅ មានការទទួលស្គាល់ថា វត្តឥន្ទញ្ញាណគឺជាមន្ទីរសន្តិសុខមួយរបស់កងពល ១៦៤ ក៏ដោយ ក៏ដីកានេះមិនបានធ្វើការសន្និដ្ឋានណាមួយទៅលើចំណុចនេះទេ[48]។ សំខាន់ដោយសារការលើកឡើងពីវត្តឥន្ទញ្ញាណនៅក្នុងផ្នែក "សំអាងហេតុ និងសេចក្តីសន្និដ្ឋាន" នៃដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចកំណត់បានថា អ្វីទៅ បើសិនជាមាន ជាឧក្រិដ្ឋកម្មដែល ស.ច.ស.ជ យល់ថាបានកើតឡើងនៅទីនោះ ថាតើ និង នៅក្នុងកម្រិតណា ដែលគាត់យល់ថា មាស មុត ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ហើយនឹង អ្វីទៅ បើសិនជាមាន ជាផលប៉ះពាល់ដែលមានទៅលើការវាយតម្លៃរបស់គាត់ស្តីពីយុត្តាធិការបុគ្គល។ បើសិនជាគាត់យល់ថា មិនមានឧក្រិដ្ឋកម្មណាកើតឡើងនៅទីនោះដែលអាចកំណត់ថា មាស មុត ទទួលខុសត្រូវគាត់ត្រូវតែពន្យល់ថា មកពីហេតុអ្វី។

---

[45] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ២៦ (សង្កត់ន័យបន្ថែម*ដោយអក្សរទ្រេត*)។

[46] វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៣, ៣៧-៣៨។ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ ៧៦-៩១.៤៤២។

[47] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៨-៩៧។

[48] *សូមអាន ជាពិសេស* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៩, ២៩២-៣។

22. នេះគឺជាការខកខានមិនបានផ្តល់ទស្សនៈដែលមានសំអាងហេតុមួយទៅលើគ្រប់អង្គហេតុទាំងអស់ដែល ស.ច.ស ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវ។ គ្រប់ភាគីទាំងអស់នៃសំណុំរឿង០០៣ បានទទួលរងការប៉ះពាល់ ដោយសារតែមិនអាចដឹងពីមូលដ្ឋានដែលដីកាសម្រេចលើកលែងចោទប្រកាន់មានក្នុងការធ្វើសេចក្តីសន្និដ្ឋានដូច្នេះ[49]។ លើសពីនេះទៀត សាធារណជនត្រូវតែដឹងផងដែរថា ហេតុអ្វីបានជា ស.ច.ស.ជ មិនចាត់ទុក មាស មុត ថាជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[50]។

23. ចំពោះការកំណត់ប្រភេទបទល្មើស ដីកាសម្រេចលើកលែងចោទប្រកាន់បានលើកឡើងយ៉ាងច្បាស់ថា ដីការនេះនឹងមិន "បរិយាយនូវប្រភេទបទល្មើស ការចាត់ថ្នាក់នៃបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវឡើយ"[51]។ ដូចដែលបានកត់សម្គាល់នៅខាងលើ អ.ប.ជ បានតម្រូវឱ្យមានការសន្និដ្ឋានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអ្វី ដែលអាចត្រូវបានប្រព្រឹត្ត និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះ និងការទទួលខុសត្រូវរបស់ជនសង្ស័យ ឬជនត្រូវចោទ នៅពេលពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចលើយុត្តាធិការបុគ្គលនៃដីកាសម្រេចលើកលែងចោទប្រកាន់។ ការខកខានមិនបានធ្វើការសន្និដ្ឋានលើអង្គច្បាប់អំពីទម្រង់នៃការទទួលខុសត្រូវ ធ្វើឱ្យមិនអាចវាយតម្លៃថាតើឧក្រិដ្ឋកម្មណាមួយដែល មាស មុត ត្រូវ "ទទួលខុសត្រូវ" ផ្នែកព្រហ្មទណ្ឌ ក៏ដូចជាកម្រិតនៃការចូលរួមរបស់

---

[49] សំណុំរឿង ០០២-ឯកសារ **D365/2/10** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ២៤-៥ [ដីកាដំណោះស្រាយមួយដែលមានសំអាងហេតុ មានចុះភាគីអ្នកប្តឹង ដែលអាចជាភាគីណាមួយក៏ដោយនៃកិច្ចដំណើរការនីតិវិធី "ស្ថិតក្នុង ស្ថានភាពមួយដែលអាចកំណត់បានថាតើនឹងដាក់ប្តឹងឧទ្ធរណ៍ដែរ ឬយ៉ាងណា និងប្តឹងលើមូលដ្ឋានអ្វី។ ដូចគ្នានេះដែរ ភាគីដែលឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍មានសិទ្ធិទទួលបានការជូនដំណឹងអំពីសំអាងហេតុ ដើម្បីឱ្យខ្លួនអាចត្រៀមរៀបចំការឆ្លើយតបរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងពាក់ព័ន្ធ។ [...] ពុំមានតុលាការសាលាឧទ្ធរណ៍ណាមួយអាចធ្វើសេចក្តីសម្រេចដោយមានសំអាងហេតុដូច្នេះបាននោះទេ ដោយដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះពុំមានបង្ហាញយុត្តិកម្ម និងភាពសមហេតុផលរបស់ខ្លួនផងនោះ"]។

[50] សំណុំរឿង ០០២-ឯកសារ **E50** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីការដោះលែងបន្ទាន់ កថាខណ្ឌ ២៦។ *Suominen ទល់នឹង ប្រទេសហ្វាំងឡង់* កថាខណ្ឌ ៣៧។ *Khudoyorov ទល់នឹង ប្រទេសរុស្ស៊ី* កថាខណ្ឌ ១៧៥។

[51] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣។

គាត់ផងដែរ[52]។ ឆន្ទានុសិទ្ធិរបស់ ស.ច.ស ផ្អែកលើការកំណត់ថាតើនរណាជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" *ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការជាសារវ័ន្តរបស់ អ.វ.ត.ក*[53]។ ការកំណត់នេះអាចធ្វើឡើង តែនៅពេលដែលអង្គហេតុនានាត្រូវបានកំណត់បទចោទតែប៉ុណ្ណោះ[54]។ លើសពីនេះទៀត ឧក្រិដ្ឋកម្មជាក់លាក់មានសារៈសំខាន់ចំពោះការវាយតម្លៃពីភាពធ្ងន់ធ្ងរ ដោយហេតុថា លក្ខណៈ និងវិសាលភាពនៃឧក្រិដ្ឋកម្ម ក៏ដូចជាផលប៉ះពាល់ទៅលើជនរងគ្រោះសុទ្ធតែជាសញ្ញាណនៃភាពធ្ងន់ធ្ងរនៃអំពើដែលបានប្រព្រឹត្ត[55]។ ការមិនកំណត់ប្រភេទបទល្មើសគឺជាការខកខានមិនបានវិនិច្ឆ័យទៅលើវិសាលភាពទាំងស្រុងនៃអំពើល្មើសរបស់ មាស មុត[56]។

---

[52] *សូមអាន* សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៥។

[53] *សូមអាន ឧទា.* ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦), ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ("ច្បាប់ អ.វ.ត.ក") មាត្រា ១ ["ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"]។

[54] សំណុំរឿង ០០២-ឯកសារ **D427/3/15** អ.ប.ជ សាលដីការបស់ អ.ប.ជ ស្តីពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៩ [ស.ច.ស បានធ្វើការ "សម្រេចចុងក្រោយពាក់ព័ន្ធនឹងការកំណត់ផ្លូវច្បាប់នៃអំពើនានាដែលបានចោទប្រកាន់ [...] និងសម្រេចលើបញ្ហាថាតើ អំពើទាំងនោះចាត់ទុកថាជាបទឧក្រិដ្ឋនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរ ឬទេ"]។

[55] ស្ថានភាពស្តីពីនាវាដែលបានចុះបញ្ជីរបស់សហភាពកូម៉ូរ៉ូស, សាធារណៈរដ្ឋ Hellenic និង ព្រះរាជាណាចក្រកម្ពុជា, សំណុំរឿង ICC-01/13-34 អង្គបុរេជំនុំជម្រះទី I សេចក្តីសម្រេចលើសំណើរបស់សហភាពកូម៉ូរ៉ូស សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់រដ្ឋអាជ្ញា មិនឱ្យចាប់ផ្តើមកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ២១។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៣៧៥។ *សូមអានបន្ថែមទៀត* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយលើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២៧ (ចៅក្រម Beauvallet និង Baik)។

[56] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ២៩៥, ២៩៩។ *សូមអានផងដែរ Jelisić* សាលដីកាមតិខ្វែងយោបល់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤២។

24. ជាឧទាហរណ៍ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលរួមមានធាតុផ្សំនានាដែលការធ្វើមនុស្សឃាតមាន។ ទីមួយ ចំនួនមនុស្សជាច្រើនត្រូវបានសម្លាប់[57] និងទីពីរ គឺថា អ្នកដែលទទួលខុសត្រូវមានចេតនាជាក់លាក់នៅក្នុងការសម្លាប់ជាទ្រង់ទ្រាយធំ[58]។ ការធ្វើទុក្ខបុកម្នេញ សូម្បីតែផ្អែកលើការប្រព្រឹត្តិជាមូលដ្ឋានដូចគ្នានេះដែរក៏ដោយ ក៏តម្រូវឱ្យមានចេតនាជាក់លាក់ក្នុងការរើសអើង ដោយផ្អែកលើ នយោបាយ ពូជសាសន៍ ឬសាសនា[59]។ ជាការសំខាន់ ការកំណត់អំពើប្រព្រឹត្តថាជាអំពើប្រល័យពូជសាសន៍ យល់ឃើញពីភាពធ្ងន់ធ្ងរខុសគេនៃឧក្រិដ្ឋកម្មនេះ[60] ដែលជា ការវាយប្រហារមួយទៅលើក្រុមគ្រួសាររបស់មនុស្សទាំងមូល ក៏ដូចជាជនរងគ្រោះខ្លួនគាត់ផ្ទាល់ផងដែរ[61]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃរឿងក្តី *Krstić* បានពន្យល់៖

> ដូច្នេះ អនុសញ្ញានេះ [...] ព្យាយាមការពារសិទ្ធិក្នុងការរស់នៅរបស់ក្រុមមនុស្សជាតិ។ ចរិកលក្ខណៈនេះបានធ្វើឱ្យអំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មមួយធ្ងន់ធ្ងរខ្លាំង ដែលខុសពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរដទៃៗទៀត ជាពិសេស ការធ្វើទុក្ខបុក

---

[57] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៥២៥។ *Seromba* សាលដីកា កថាខណ្ឌ ១៨៩។ *Ntakirutimana* សាលដីកា កថាខណ្ឌ ៥១៦។

[58] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៥២១-២, ៥២៥។

[59] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ៣១៦, ៣២៣។ *Naletilić & Martinović* សាលដីកា កថាខណ្ឌ ៥៨៩-៩០ (ដោយអនុញ្ញាតឱ្យមានការកាត់ទោសត្រួតលើគ្នាចំពោះការធ្វើទុក្ខបុកម្នេញ និង ការធ្វើទារុណកម្ម)។ *Stakić* សាលដីកា កថាខណ្ឌ ៣៦៤, ៣៦៦-៧ (ដោយអនុញ្ញាតឱ្យមានការកាត់ទោសត្រួតលើគ្នាចំពោះការធ្វើទុក្ខបុកម្នេញ ការធ្វើមនុស្សឃាត និង អំពើទារុណកម្ម ផ្សេងៗទៀត)។ *Nahimana* សាលដីកា កថាខណ្ឌ ១០២៦។

[60] *Rukundo* សាលក្រម កថាខណ្ឌ ៥៩៧ ["តាមនិយមន័យ អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មមួយដែលធ្ងន់ធ្ងរជាងគេបំផុត ដែលប៉ះពាល់ដល់គ្រឹះសំខាន់របស់សង្គម និងធ្វើឱ្យរន្ធត់ដល់សតិសម្បជញ្ញៈមនុស្សជាតិ"]។

[61] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ បុព្វកថា ["អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មមួយនៅក្រោមច្បាប់អន្តរជាតិដែលផ្ទុយទៅនឹងខ្លឹមសារ និងគោលបំណងរបស់អង្គការសហប្រជាជាតិ និងត្រូវបានផ្តន្ទាទោសដោយពិភពលោកដែលមានអារ្យធម៌ខ្ពង់ខ្ពស់ [...] អំពើប្រល័យពូជសាសន៍បានធ្វើឱ្យមានការបាត់បង់មនុស្សជាតិដ៏មហិមា [...] ក្នុងគោលបំណងដើម្បីរំដោះមនុស្សជាតិពីទុក្ខទោសដ៏គួរឱ្យស្អប់ខ្ពើមនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិមួយត្រូវបានតម្រូវឱ្យមានឡើង"]។ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ៩៦(I) *ឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍* ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ A/RES/96(I) ទំព័រ ១៨៨-៩ ["អំពើប្រល័យពូជសាសន៍ គឺជាការបដិសេធសិទ្ធិនៃអត្ថិភាពនៃក្រុមមនុស្ស ជាតិទាំងមូលដែលធ្វើឱ្យរន្ធត់ដល់សតិសម្បជញ្ញៈមនុស្សជាតិ [...] គឺផ្ទុយទៅនឹងស្មារតីនៃច្បាប់ និងផ្ទុយទៅនឹងខ្លឹមសារ និងគោលបំណងរបស់អង្គការសហប្រជាជាតិ។ [...] ការផ្តន្ទាទោសលើឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍នេះ គឺជា បញ្ហាមួយស្តីពីកង្វល់អន្តរជាតិ"]។ *Tolimir* សាលក្រម កថាខណ្ឌ ៧៤៦, ១២១៦។

ម្មេញ ដោយអ្នកប្រព្រឹត្តបទល្មើសជ្រើសរើសជនរងគ្រោះដោយសារតែ សមាជិកភាពរបស់ពួកគេនៅក្នុងសហគមន៍មួយជាក់លាក់ ប៉ុន្តែមិនជាព្យាយាមបំផ្លាញសហគមន៍នោះទេ។ [...] នៅក្នុងន័យនេះ បើទោះជាអំពើឧក្រិដ្ឋផ្ទាល់មានអំពើប្រល័យពូជសាសន៍ អាចមិនខុសពីអំពើឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម។ ដោយសារតែចេតនាជាក់លាក់នេះ បុគ្គលដែលត្រូវបានផ្តន្ទាទោស ហាក់ដូចជាត្រូវបានបន្ទោសជាខ្លាំង[62]។

25. គោលការណ៍នេះក៏អនុវត្តនៅក្នុងធាតុផ្សំរួមនៃឧក្រិដ្ឋកម្មដែរ។ ការសន្និដ្ឋានទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឆ្លុះបញ្ចាំងពីបរិបទ និងការដឹងឮរបស់ មាស មុត ពីការ "វាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល"[63] ដោយឧក្រិដ្ឋកម្មនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវបង្ហាញពីការរំលោភទៅលើកិច្ចព្រមព្រៀងរបស់រដ្ឋក្នុងការលើកស្ទួយច្បាប់មនុស្សធម៌អន្តរជាតិ។

## ២. កង្វះគ្មានសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ដែលផ្អែកលើការសន្និដ្ឋានផ្នែកអង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់

26. ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានពិនិត្យឲ្យបានច្រើនទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងនោះទេ (ដោយមិនពិនិត្យទៅលើភស្តុតាងដែលបានដាក់នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ហើយធ្វើការពិនិត្យតិចតួចប៉ុណ្ណោះទៅលើភស្តុតាងជាច្រើននៅមុនខែមេសា ឆ្នាំ២០១១) ហើយមិនមានការសន្និដ្ឋានផ្នែកអង្គហេតុដែលបានមកពីការវិភាគលើភស្តុតាងយ៉ាងល្អិតល្អន់ទេ។ យ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពមួយចំនួន ពិតជាមានការពិនិត្យខ្លះប៉ុណ្ណោះទៅលើភស្តុតាង និងការសន្និដ្ឋានផ្នែកអង្គហេតុតិចតួច ដូចបានលើកឡើងលម្អិតក្នុងផ្នែកនេះ។ សូម្បីតែដូច្នេះក៏

[62] *Krstić* សាលក្រម កថាខណ្ឌ ៥៥៣, ៧០០។ *សូមអានបន្ថែមទៀត* *Karadžić* សាលក្រម កថាខណ្ឌ ៦០៤៦ [ឧក្រិដ្ឋកម្មរបស់ Karadžić "គឺនៅក្នុងចំណោមឧក្រិដ្ឋកម្មជាក់ស្តែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងរួមបញ្ចូលទាំងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើប្រល័យពូជសាសន៍"]។

[63] ច្បាប់ អ.វ.ត.ក មាត្រា ៥។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើករណីរបស់ *ឌុច* កថាខណ្ឌ ១០៦។ សំណុំ រឿង ០០២-ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៥២។

ដោយ មិនមានសេចក្ដីសន្និដ្ឋានផ្នែកអង្គច្បាប់ទៅលើការប្រព្រឹត្តិបទឧក្រិដ្ឋ និងការទទួលខុសត្រូវរបស់ មាស មុត ដែលចេញពីការសន្និដ្ឋានផ្នែកអង្គហេតុ របស់ដីកាសម្រេចលើកលែងការចោទប្រកាន់។

27. ជាសំខាន់ ដីកាសម្រេចលើកលែងចោទប្រកាន់បានធ្វើសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុមួយចំនួនដែលបង្ហាញថា មាស មុត បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងការបោសសម្អាត ឃុំឃាំង និងសម្លាប់ខ្មាំងផ្ទៃក្នុង និងខាងក្រៅ ហើយនឹងធ្វើឱ្យយោធា និងប្រជាជនស៊ីវិល នៅតាមការដ្ឋាននានាក្លាយជាទាសករ។ មាស មុត ទទួលខុសត្រូវចំពោះការប្រព្រឹត្តិស្ទើរតែគ្រប់ឧក្រិដ្ឋកម្មនីមួយៗនៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣[64] ដោយសារតែការរួមចំណែកយ៉ាងសំខាន់ (ហើយតាមពិត ទៅមិនអាចខ្វះបាន) របស់គាត់ចំពោះសហឧក្រិដ្ឋកម្មរួមនេះ។

## ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ

28. ដីកាសម្រេចលើកលែងចោទប្រកាន់មានការសន្និដ្ឋានផ្នែកអង្គហេតុខាងក្រោម ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ (i) ប.ក.ក មានគោលនយោបាយបោសសម្អាតមជ្ឈិមមួយ ឃុំឃាំង និងសម្លាប់ចោលពួកខ្មាំងរបស់ខ្លួន[65] (ii) គោលនយោបាយនេះត្រូវបានអនុវត្តចំពោះកងពលនានានៃ ក.ប.ក រួមទាំង កងពល ១៦៤ (កងទ័ពជើងទឹក) ផងដែលជាអ្នកទទួលខុសត្រូវនៅទូទាំងប្រទេសចំពោះសន្តិសុខខាងក្រៅប្រឆាំងនឹងអ្នកដែលសន្មតថាជាខ្មាំង[66] (iii) អគ្គសេនាធិការបានចេញបញ្ជានានាឱ្យទៅកងពលនីមួយៗ រួមទាំង កងពល ១៦៤ ផង ឱ្យរក្សាគោលជំហរដាច់ខាតដើម្បីកម្ទេចពួកខ្មាំងទាំងនៅលើដីគោក និងទាំងនៅក្នុងព្រំដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ (iv) ពួកខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ រួមមាន ជនទាំងឡាយដែលមានទំនាក់ទំនងជាមួយនឹងពួកវៀតណាម[67] (v) មាស មុត បានប្ដេជ្ញា "ការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត ដោយបោសសម្អាតគ្មានស្នាក់ស្ទើរ

[64] ដោយមានការលើកលែងតែអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។

[65] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៨៥, ៩៤-៥, ៩៧, ១០០, ២៨៣។

[66] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៨, ២៣០, ២៥៥, ៤១៣។

[67] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៥, ៨៧-៨, ២៣៤, ២៣៧, ២៤១, ២៤៣។

សមាសភាពបង្កប់របស់ខ្មាំង ជាយួន និង ខ្មាំងដទៃទៀត"[68] (vi) មាស មុត បានបញ្ជាកងពល ១៦៤ រួមទាំង កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យផង[69] (vii) មាស មុត (និង ពួកអ្នកនៅក្រោមបង្គាប់របស់គាត់ម្តងម្កាល) បានរាយការណ៍ទៅ សុន សេន អំពីការចាប់ខ្លួន និងបញ្ជូនពួកជនបរទេសដែលបានចាប់ខ្លួននៅតាមសមុទ្រ និងអនុវត្តបញ្ជារបស់ សុន សេន ឧទាហរណ៍ ដោយកម្ទេចពួកជនបរទេសដែលត្រូវបានចាប់ខ្លួននៅតាមសមុទ្រ និងនៅតាមកោះ[70] (viii) ប្រជាជនមួយចំនួនដែលត្រូវបានចាប់ខ្លួននៅតាមសមុទ្រ រួមមាន វៀតណាម និង ថៃ ត្រូវបានបញ្ជូនពីកំពង់សោមទៅកាន់ ស-២១[71] (ix) គោលបំណងសំខាន់នៃ ស-២១ គឺត្រូវទាញយកចម្លើយសារភាព ហើយចម្លើយសារភាព ស-២១ ជាច្រើនជារបស់កងកម្លាំងវៀតណាមដែលត្រូវបានចាប់ខ្លួននៅតាមបណ្តោយព្រំដែនគោក និងព្រំដែនសមុទ្រកម្ពុជាប្រជាធិបតេយ្យ[72] (x) មិនមានប្រព័ន្ធតុលាការទេនៅក្នុងកម្ពុជាប្រជាធិបតេយ្យ[73] (xi) មិនមានអ្នកជាប់ឃុំឃាំង ស-២១ ណាម្នាក់ត្រូវបានដោះលែង ហើយទាំងអស់គ្នាត្រូវបានសម្លាប់ចោល[74] ហើយ (xi) កម្ពុជាប្រជាធិបតេយ្យបានចូលរួម ហើយ មាស មុត ក៏បានដឹពី ជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាម[75]។

## *ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយអនុលោមតាមគោលនយោបាយខ្មាំងផ្ទៃក្នុងរបស់ ក.ប.ក និង គោលនយោបាយធ្វើឱ្យទៅជាទាសករ*

[68] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៦ *ដោយបានលើកឡើងពី* ឯកសារ **D1.3.34.60** ទូរលេខ ០០ ពី មុត (មាស មុត) គោរពជូនគណៈ ម.៨៧០, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

[69] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦០, ១៨៧-៨, ២៤៣, ២៥៦, ៤១៦។

[70] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៧, ២១០-២, ២១៥-៦, ២២២, ២៥១-២, ២៥៥, ២៥៧, ៣០៨, ៣១៣-៤, ៣១៦, ៣២១-២។

[71] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២១, ៣០៧, ៣១៩, ៣២៦, ៣២៨។ *សូមអានផងដែរ* កថាខណ្ឌ ៣១២ ពាក់ព័ន្ធនឹងការចាប់ទូកឈ្មោះ ស្ត្រីកញ្ច្រោង (Foxy Lady)។

[72] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២២១, ២៦៩។

[73] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៩៤។

[74] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦៩។

[75] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៨, ១២១-២, ១៧៥, ១៩៤, ២០៤, ២១១, ២៣៧, ២៤៣, ៣២៣-៦, ៣២៨។

29. *គោលនយោបាយខ្មាំង* ៖ ដីកាសម្រេចលើកលែងចោទប្រកាន់មានការសន្និដ្ឋានផ្នែកអង្គហេតុ ដែលបង្ហាញពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការបោសសម្អាតខ្មាំងផ្ទៃក្នុង។ ដីកានេះសន្និដ្ឋានថា (i) ប.ក.ក មានគោលនយោបាយមួយក្នុងការបោសសម្អាត ឃុំឃាំង និងសម្លាប់ខ្មាំងផ្ទៃក្នុង[76] (ii) គោលនយោបាយបោសសម្អាតនេះត្រូវបានអនុវត្តចំពោះកងពលនានានៃ ក.ប.ក រួមទាំង កងពល ១៦៤ ផង ដែលត្រូវទទួលខុសត្រូវផងដែរចំពោះសន្តិសុខផ្ទៃក្នុងប្រឆាំងនឹងពួកខ្មាំង រួមទាំងកងទ័ពផង បក្ស និងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ[77] (iii) ពួកខ្មាំង មាន "សមាសភាពមិនល្អ" "អតីតកងទ័ព អតីតមន្ត្រីរដ្ឋការរបបមុនៗ សេអ៊ីអា [ភ្នាក់ងារ]កាហ្សេបេ និងខ្មាំង*យួន* បង្កប់[ស៊ីរូងផ្ទៃក្នុង]" និង ប្រជាជន ១៧ មេសា[78] (iv) អគ្គសេនាធិការបានចេញបញ្ជា និងសេចក្តីណែនាំដល់គ្រប់អង្គភាពយោធាទាំងអស់ឲ្យអនុវត្តគោលនយោបាយបោសសម្អាត ដោយមានការផ្សព្វផ្សាយ រួមទាំងតាមរយៈវគ្គរៀនសូត្រនានា ដោយពិនិត្យពិច័យទៅលើប្រវត្តិរូប និងកំណត់អត្តសញ្ញាណពួកខ្មាំង ការរាយការណ៍ទៅលើស្ថានភាពខ្មាំង និង សម្របសម្រួលការចាប់ខ្លួន បញ្ជូនខ្លួន និងការសម្លាប់ចោល[79] ហើយ (v) របបនេះបានបង្កើតមន្ទីរសន្តិសុខជាច្រើន ដើម្បីឃុំឃាំង លត់ដំ អប់រំ កសាង និងធ្វើទារុណកម្មមនុស្សក្នុងគោលបំណងដើម្បីកំណត់អត្តសញ្ញាណបណ្តាញក្បត់ និង/ឬដើម្បីសម្លាប់ចោលពួកជនសង្ស័យ និងក្រុមគ្រួសាររបស់ពួកគេ[80]។ ដូចដែលបានកត់សម្គាល់ខាងលើ ដីកាសម្រេចលើកលែងចោទប្រកាន់យល់ឃើញថា មិនមានប្រព័ន្ធយុត្តិធម៌ទេនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គោលបំណងសំខាន់នៃ ស-២១ នោះគឺការទាញយកចម្លើយសារភាព ហើយគ្រប់អ្នកជាប់ឃុំទាំងអស់នៅ ស-២១ ត្រូវបានសម្លាប់ចោល[81]។

30. ចំពោះការចូលរួមចំណែករបស់ មាស មុត នៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា (i) មាស មុត បានចូលរួមនៅក្នុងការគាំទ្រគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្ក្រាបខ្មាំងស៊ីរូងផ្ទៃក្នុង និង ការផ្សព្វផ្សាយ

[76] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៨៥, ៩៤-៥, ៩៧, ១០០, ២៣៥, ៤១៣។

[77] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៨, ២៣០, ២៣២-៣, ២៣៥, ២៤៥-៩, ៤២៤។

[78] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៨៥, ៨៧, ៨៩, ២៣០, ២៤៧-៩, ៤១៥។

[79] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៧, ១៥០, ២១២, ២៣៣, ២៤៧-៥០, ៤២០។

[80] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៧, ៤១៣។

[81] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៤, ២៦៩-៧០។

គោលនយោបាយដល់យុទ្ធជនកងពល ១៦៤[82] (ii) ក្នុងឋានៈជាលេខាកងពល ១៦៤ ជាញឹកញាប់ គាត់ចូលរួមប្រជុំរបស់អគ្គសេនាធិការស្ដីពីផែនការបោសសម្អាតកងពលនានានៃ ក.ប.ក. និងផ្ញើទូរលេខដែលនៅក្នុងនោះគាត់បានបញ្ជាក់ពីភាពស្មោះត្រង់របស់គាត់ចំពោះបក្ស ហើយគាំទ្រគោលនយោបាយខ្មាំងនេះ[83] (iii) គាត់បានចូលរួមនៅក្នុងការប្រជុំមួយនៅទីបញ្ជាការយោធានៅភ្នំពេញនៅដើមឆ្នាំ១៩៧៨ ដែលនៅទីនោះ សេចក្ដីសម្រេចមួយត្រូវបានធ្វើ ឡើងក្នុងការបោសសម្អាតពួកភូមិភាគបូព៌ា[84] (iv) គាត់បានទទួលរបាយការណ៍ និងបានរាយការណ៍យ៉ាងទៀងទាត់ពីការចាប់ខ្លួនពួកខ្មាំងផ្ទៃក្នុងនៅកំពង់សោម និងអនុវត្តបញ្ជានានាពី សុន សេន អំពីការវាយប្រហារ និងការចាប់ខ្លួនបន្ថែមចំពោះពួកខ្មាំងផ្ទៃក្នុង រួមទាំង "អង្គភាពឃ្លាំង មួយអនុសេនាតូច" ហើយនឹងជនទាំងឡាយដែលបានបញ្ជូនទៅ ស-២១[85] (v) គាត់បានបញ្ជូនយោធា ដោយបញ្ជូនពួកគាត់ទៅកាន់ការដ្ឋានបង្កបង្កើនផល រួមទាំង ការនេសាទ ឬកសិកម្ម និងមាន "ការបាត់ខ្លួនមេអង្គភាព នៅពេលមានការបោសសម្អាត"[86] (vi) មាស មុត បានតាមឃ្លាំមើលអ្នកដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ស-២១ និងបានស្នើសុំសេចក្ដីសម្រេចរបស់ សុន សេន ស្ដីពីការចាប់ខ្លួន[87] (vii) ស-២១ និង កងពល បានធ្វើការជាមួយគ្នាដើម្បីចាប់មនុស្ស[88] ហើយ (vii) ចាប់ពីឆ្នាំ១៩៧៧ កងពល និងក្រសួងនានា ទទួលខុសត្រូវចំពោះការដឹកជញ្ជូនអ្នកទោសពីអង្គភាពរបស់ពួកគេទៅកាន់ ស-២១ (លើកលែងតែពួកកម្មាភិបាលជាន់ខ្ពស់)[89]។

31. <u>*គោលនយោបាយធ្វើឱ្យទៅជាទាសករ*</u> ៖ ដីកាសម្រេចលើកលែងចោទប្រកាន់មានការសន្និដ្ឋានលើអង្គហេតុដែលដែលបង្ហាញពីគោលនយោបាយមួយ ដែលត្រូវបានអនុវត្តដោយ ក.ប.ក. និង

[82] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២២។

[83] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៦, ២៥៦, ៤២២-៣។

[84] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៣៨។

[85] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៧, ២០២, ២១១-២, ២១៥-៦, ២១៨, ២២២, ២៥១-២, ២៥៥-៧, ២៨៥-៦, ៤២៣។

[86] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៨។

[87] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៣។

[88] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៧១។ *សូមអានផងដែរ* កថាខណ្ឌ ១៧០ [ការដកស្រង់ដោយមានការយល់ព្រមពី ឌុច ដោយបានថ្លែងថា "សុន សេន តែងតែស្នើសុំមតិទាក់ទង និងជំនួយពីប្រធានកងពល" មុនការចាប់ខ្លួនត្រូវបានធ្វើឡើងដើម្បីបញ្ជូនមនុស្សទៅ ស-២១]។

[89] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៥-៦។

មាស មុត ក្នុងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ ដែលពួកយោធា និងប្រជាជនស៊ីវិលត្រូវបានធ្វើឱ្យទៅជាទាសករ។ (i) ប.ក.ក មានគោលនយោបាយមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមួយដោយផ្អែកលើកសិកម្មទ្រង់ទ្រាយធំដែលមានគោលដៅផលិតកម្មមិនសមស្រប តាមរយៈដំណើរការសហករណ៍ និងការដ្ឋាន ដែលនៅក្នុងនោះ ប្រជាជនត្រូវបាន "ចាត់ទុកជាទាសករ" បង្ខំឱ្យធ្វើពលកម្ម (សំខាន់នៅក្នុងគម្រោងធ្វើស្រែ ការស្រោចស្រព និងសំណង់) ជាច្រើនម៉ោង ដោយមិនមានអាហារ អនាម័យ ឬការថែទាំសុខភាពមិនគ្រប់គ្រាន់ និងមិនបានទទួលប្រាក់ ឬមិនមានសេរីភាពក្នុងការដើរហើរ[90] (ii) ក.ប.ក ទទួលខុសត្រូវ *ជាអាទិ៍* "ការជួយកសាងកសិកម្ម" សម្រេចផែនការបួនឆ្នាំ ក្នុងការផលិតស្រូវឱ្យបានបីតោនក្នុងមួយហិកតា និងបង្កើតការដ្ឋានក្រោមការគ្រប់គ្រងរបស់យោធា[91] (iii) ការដ្ឋាននានាត្រូវបានប្រើប្រាស់ដោយ ក.ប.ក រួមទាំង កងពល ១៦៤ ផង ដើម្បី "លត់ដំ" កម្មាភិបាលដែលត្រូវបោសសម្អាត[92] និង (iv) ក្នុងឋានៈជាលេខាកងពល ១៦៤ និងជាលេខាតំបន់ស្វយ័តកំពង់សោម មាស មុត បានទទួលរបាយការណ៍ និងរាយការណ៍យ៉ាងទៀងទាត់ទៅកាន់សេនាធិការ និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងផលិតកម្មស្រូវ និងប្រតិបត្តិការតាមការដ្ឋាននានា រួមទាំង ស្ទឹងហាវផង[93]។

32. យោងតាមគោលនយោបាយស្តីពីខ្មាំងផ្ទៃក្នុង និងគោលនយោបាយស្តីពីការដាក់ឱ្យទៅជាទាសករ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា (i) មាស មុត សារភាពថា សមាជិកនៃកងពល ១៦៤ ត្រូវបានបញ្ជូនទៅ ស-២១[94] (ii) យោធាកងពល ១៦៤ ចំនួនពី ៤២ ទៅ ៦៧នាក់ ត្រូវបានបញ្ជូនទៅកាន់ ស-២១ ដែលជាកន្លែងដែលពួកគាត់ត្រូវបាន "សួរចម្លើយ ដើម្បីទាញយកចម្លើយសារភាព" និងត្រូវបានសម្លាប់ចោល[95] (iii) សរុបទៅ សមាជិក ក.ប.ក ចំនួន "ជាង ៥.000 នាក់" ត្រូវបានចាប់ខ្លួន និងត្រូវបានបញ្ជូនទៅកាន់ ស-២១ រួមទាំងពីកងពល ៥០២ និង

[90] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨-៧៨, ៨០-២, ៨៤-៥, ១០០, ១០២។

[91] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៨, ១៥០។

[92] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៤១, ២៤៤, ២៥៨, ២៨៦។

[93] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៥-៧, ២១៥, ២១៨, ២៥៧, ៣០៥។

[94] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩។

[95] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩-៨០, ៤២៤, ៤២៦ និង កថាខណ្ឌ ២៨៧ ផងដែរ។

កងពល ៨០១ ផង[96] និង (iv) នៅស្ទឹងហាវ ក្រោមការគ្រប់គ្រងរបស់កងវរសេនាតូច ៤៥០/១៦៥ របស់កងពល ១៦៤ ការដ្ឋានវាយថ្មមួយកន្លែងត្រូវបានបង្កើតឡើង ដើម្បីផលិតសម្ភារសាងសង់សម្រាប់ការសាងសង់កំពង់ផែ និងផ្លូវថ្នល់ថ្មី។ អ្នកដែលត្រូវបានបង្ខំឱ្យធ្វើពលកម្មផ្ទាល់ដៃធ្ងន់ធ្ងរ គឺជាយោធាកងពល ១៦៤ និងជនស៊ីវិល រួមទាំង ប្រជាជនដែលមាននិន្នាការមិនល្អ ពួកសមាជិកក្រុមគ្រួសារទាហាន ពួកអតីតសមាជិករបប លន់ នល់ និង ពួកស្ត្រី[97]។

33. យ៉ាងហោចណាស់ ការសន្និដ្ឋានផ្នែកអង្គហេតុទាំងនេះបង្ហាញថា មាស មុត ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល តាមរយៈសមាជិកភាពរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម និងដោយការធ្វើផែនការ និងការបញ្ជា ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ (ដោយមូលហេតុនយោបាយ ឬពូជសាសន៍) ហើយនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការប្រព្រឹត្តិអមនុស្សធម៌) ក៏ដូចជា អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ (ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម និងការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់)។

34. ដើម្បីឱ្យច្បាស់លាស់ ស.ព.អ រក្សាទស្សនៈរបស់ខ្លួនថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបង្ហាញថា មាស មុត ទទួលខុសត្រូវចំពោះគ្រប់ឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ រួមទាំង អំពើប្រល័យពូជសាសន៍ពួកជនជាតិវៀតណាម ហើយនឹងមិនត្រឹមតែឧក្រិដ្ឋកម្មដែលបង្ហាញនៅក្នុងការសន្និដ្ឋានផ្នែកអង្គហេតុតិចតួចនោះទេ។ យ៉ាងណាក៏ដោយ ដីកានេះមានកំហុសផ្នែកអង្គច្បាប់ដែលមិនមានការសន្និដ្ឋានស្តីពីការចូលរួម និងការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងនេះ។

[96] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៤៣, ៣៤៥-៦, ៤២៦។

[97] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៩-៣០៥។ ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញបន្ថែមទៀតថា កងវរសេនាតូច ៤៥០/១៦៥ គឺនៅក្រោមការគ្រប់គ្រងរបស់ មាស មុត និងគណៈកងពល ១៦៤ (សូមអាន កថាខណ្ឌ ២០១)។

## ខ. កំហុសផ្នែកអង្គច្បាប់ស្ដីពីការខកខានមិនពិចារណាលើភស្តុតាងដែលបានដាក់នៅក្នុង សំណុំរឿង០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១

35. ដីកាសម្រេចលើកលែងចោទប្រកាន់បញ្ជាក់យ៉ាងច្បាស់ថា ដីកាពឹងផ្អែកតែទៅលើ "ឯកសារដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែល ស.ច.ស ទាំងពីរ បានឯកភាពប្រកាសបិទការស៊ើបសួរ" ប៉ុណ្ណោះ[98]។ សូម្បីតែឯកសារដែលត្រូវបានបង្កើតឡើងពីមុន ក៏មិនត្រូវបានពិចារណាដែរ ប្រសិនបើមិនត្រូវបានដាក់ទៅក្នុងសំណុំរឿងនៅកាលបរិច្ឆេទនោះ[99]។ យ៉ាងណាក៏ដោយ ការពឹងផ្អែករបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅលើសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ឆ្នាំ២០១១ មិនមានសុពលភាពដោយសារហេតុផលពីរយ៉ាង។ ទីមួយ ការស៊ើបសួរត្រូវបានបើកឡើងវិញដោយមានសុពលភាពដោយ ស.ច.ស.អ បម្រុង ហើយ

[98] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២។ *សូមអានបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨, ៣៩, ៤១-២។ ឯកសារ **D13** សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ចុះថ្ងៃ ទី២៩ ខែមេសា ឆ្នាំ២០១១ ("សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ")។

[99] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២, ៣៥៩, ៤០៨។ ស.ព.អ កត់សម្គាល់ថាមានឯកសារមួយដែលបានដាក់ចូលក្នុងសំណុំរឿងដោយចៅក្រម Kasper-Ansermet ត្រូវបានប្រើប្រាស់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ កំណត់សម្គាល់ជើងទំព័រលេខ ៩៤២៖ ឯកសារ **D22.1.14** ទូរលេខអន្តរជាតិ *ការចាប់បានបុគ្គលិកអាមេរិកកាំង* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨ បានភ្ជាប់ទៅនឹងឯកសារ **D22** សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដែលត្រូវបានច្រានចោលពីរដងដោយចៅក្រម Blunk និង យូ ប៊ុនឡេង ហើយបានដាក់ចូលសំណុំរឿងដោយ ស.ច.ស.អ Kasper-Ansermet នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានពឹងផ្អែកផងដែរទៅលើភស្តុតាងនៅក្នុងប្រតិចារឹកចំនួនប្រាំ នៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ ដែលត្រូវបានដាក់ចូលទៅក្នុសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ សំណុំរឿង ០០១-ឯកសារ **E1/19.1** ប្រតិចារឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (ឯកសារយោងក្នុងសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D54/6.1.9** និងឯកសារ **D98/3.1.86**)។ សំណុំរឿង ០០១-ឯកសារ **E1/20.1** ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (ឯកសារយោងក្នុងសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D54/6.1.10** និងឯកសារ **D98/1.2.1**)។ សំណុំរឿង ០០១-ឯកសារ **E1/27.1** ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ (ឯកសារយោងក្នុងសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D55/8.1.3** និងឯកសារ **D98/1.2.7**)។ សំណុំរឿង ០០១-ឯកសារ **E1/29.1** ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារយោងក្នុងសំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D55/8.1.4** និងឯកសារ **D98/3.2.90**)។ សំណុំរឿង ០០២-ឯកសារ **E1/129.1** ប្រតិចារឹក ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ (ឯកសារយោងក្នុង សំណុំរឿង ០០៣ នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D98/3.2.177**)។

ត្រូវបានបន្តដោយ ស.ច.ស.អ Harmon និង Bohlander ដែលបានធ្វើឲ្យសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរនោះត្រូវបានមោឃភាពតាមផ្លូវច្បាប់។ ទីពីរ ការស៊ើបសួរលើសំណុំរឿង ០០៣ ត្រូវបានបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយរំលោភទៅលើកាតព្វកិច្ចរបស់ ស.ច.ស ក្នុងការស៊ើបសួរយ៉ាងត្រឹមត្រូវ មិនលម្អៀង និងដោយប្រសិទ្ធភាព ទៅលើឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[100]។ ការខកខានមិនបានពឹងផ្អែកលើភស្តុតាងដែលបានដាក់ចូលទៅក្នុងសំណុំរឿងនៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ គឺជាកំហុសអង្គច្បាប់មួយ ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើការវាយតម្លៃភស្តុតាងរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ហើយធ្វើឲ្យការសន្និដ្ឋានផ្នែកអង្គហេតុមានកំហុស ដែលមានផលប៉ះពាល់សំខាន់ទៅលើការកំណត់យុត្តាធិការបុគ្គល។

## *<u>វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ស្តីពី សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ មិនបានរារាំងសំណុំរឿងមិនឲ្យបើកឡើងវិញនោះទេ</u>*

36. វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ស្តីពី សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ដែលត្រូវបានចេញដោយ ស.ច.ស កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មិនគ្រប់គ្រាន់ទេក្នុងការបញ្ចប់កិច្ចស៊ើបសួរដោយមិនអាចកែប្រែបានឡើយ។ នៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជា ច្បាប់នីតិវិធីរបស់ប្រទេសកម្ពុជា និងប្រទេសបារាំងផងដែរ សេចក្តីជូនដំណឹងគ្រាន់តែជាសេចក្តីជូនដំណឹងផ្នែកនីតិវិធី ដែលសហចៅក្រមស៊ើបអង្កេតយល់ថា ការស៊ើបសួរត្រូវបានបញ្ចប់ នៅពេលណាដែលភាគីនានាមានឱកាសដាក់សំណើសុំឲ្យស៊ើបអង្កេតបន្ថែមទៀត[101]។ សេចក្តីជូនដំណឹងនេះមិនបានបិទការស៊ើបសួរនោះទេ។ មានតែនៅក្រោយពេលដែលការស៊ើបសួរដែលបានស្នើសុំដោយភាគីនានា ត្រូវបានបំពេញ ឬការបដិសេធត្រូវបានប្តឹងផ្តល់ ហើយនីតិវិធីឧទ្ធរណ៍ត្រូវបានបញ្ចប់ប៉ុណ្ណោះ ទើប ស.ច.ស បញ្ជូនសំណុំរឿងទៅកាន់សហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[102]។

[100] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ” ឬ “IS”)។

[101] វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៦។ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង មាត្រា ១៧៥។

[102] វិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៦។

37. ដូចដែល អ.ប.ជ បានរម្លឹកសំណុំរឿងនេះឡើងវិញជាឯកច្ឆ័ន្ទក្នុងពេលថ្មីៗនេះ ការស៊ើបសួរត្រូវបានបញ្ចប់ តែជាមួយនឹង ដីកា*ដំណោះស្រាយ* ដែលត្រូវបានចេញ ដោយអនុលោមតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ[103]។ នៅមុនពេលនោះ ស.ច.ស ទទួលពិនិត្យសំណុំរឿងនេះ[104] ហើយមានអំណាចក្នុងការស៊ើបសួរបន្ថែមទៀត ទៅតាមសំណើសុំរបស់ភាគីនានា ឬ *ដោយឥស្សរចិត្ត* និងអាចពិចារណាឡើងវិញទៅលើគ្រប់សេចក្តីសម្រេច និងដីកាសម្រេចពីមុនៗ រួមទាំងសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរណាក៏ដោយផង។

38. ដូចដែលដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងដូច្នោះដែរ[105] បន្ទាប់ពីការលាឈប់ពីតំណែងរបស់ ស.ច.ស.អ លោក Blunk ស.ច.ស.អ បម្រុង បានទទួលកាន់កិច្ចការនេះនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ និងបានវាយតម្លៃឡើងវិញទៅលើស្ថានភាពនៃសំណុំរឿង០០៣ បានប្រកាសថា សំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ ស.ព.អ[106] ត្រូវបានទទួលយក និងបញ្ជា

---

[103] ឯកសារ **D257/1/8** សេចក្តីសម្រេចលើពាក្យសុំរបស់ មាស មុត សុំឲ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ ("សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពីភស្តុតាងបានមកពីទារុណកម្ម") កថាខណ្ឌ ១១ ["អ.ប.ជ បកស្រាយវិធាន ៦៦(១) ៦៧(១) និងវិធាន ៧៦(២) នៃវិធាន ផ្ទៃក្នុង ដោយមានការពាក់ព័ន្ធទៅនឹងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងចាត់ទុកថា "កិច្ចស៊ើបសួរ" ត្រូវបានបញ្ចប់ជា ផ្លូវការដោយការចេញដីកាដំណោះស្រាយ និងមិនមែននៅពេលដែល ស.ច.ស ជូនដំណឹងភាគីនានាអំពីគោលបំណង របស់ខ្លួន ក្នុងការបញ្ចប់ដីកាដំណោះស្រាយនោះទេ"]។ *សូមអានផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧។ មាស មុត ក៏បាននិយាយគាំទ្រគោលជំហរនេះផងដែរ៖ ឯកសារ **D257/1/7** ការឆ្លើយតបរបស់ មាស មុត ចំពោះ ចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងពាក្យសុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលត្រូវបាន អះអាងថាបានមកពីភស្តុតាងបានពីទារុណកម្ម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៦។

[104] *សូមអាន* សំណុំរឿង ០០២/០៨-០៧-២០០៩-អ.វ.ត.ក-អ.ប.ជ (ឯកសារលេខ ២) សេចក្តីសម្រេចលើសំណើបន្ទាន់បង្ខំសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធីជាបន្ទាន់ និងជាស្ថាពរ ចំពោះការរំលោភលើនីតិវិធី ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ៦។ សំណុំរឿង ០០៤/២-ឯកសារ **D360/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោស លុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៦។

[105] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨។

[106] ដោយការពិចារណាទៅលើកិច្ចស៊ើបសួរ ដែលយ៉ាងជាក់ស្តែងមិនទាន់ចប់សព្វគ្រប់ ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស.ព.អ បានដាក់សំណើសុំកិច្ចស៊ើបសួរចំនួនបី នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១៖ ឯកសារ **D17** សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ ឯកសារ **D18** សំណើបំពេញកិច្ចស៊ើបសួរលើកទីពីររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ។ ឯកសារ **D19** សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សំណើទាំងនេះត្រូវបានច្រានចោលនៅលើកំហុសនីតិវិធី ដែលបានលើកឡើងចោទប្រកាន់នៅក្នុងឯកសារ **D20/3** ដីកា សម្រេចស្តីអំពី

ឱ្យបន្តបំពេញកិច្ចស៊ើបសួរនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១[107]។ ដោយហេតុថាគាត់បានធ្វើដូច្នោះនៅមុនពេលចេញដីកាដំណោះស្រាយ ហើយតាមពិតទៅ តាំងពីមុនពេលដែល ស.ច.ស.ជ បានចេញដីកាបញ្ជូនរឿងឱ្យទៅសហព្រះរាជអាជ្ញា តាមវិធាន ៦៦(៤) ទៅទៀត[108] ដូច្នោះដីកាជូនដំណឹងពីមុនតាមវិធាន ៦៦(១) ពិតជាហួសពេលហើយ[109]។ ការខកខានរបស់ អ.ប.ជ មិនអាចទទួលបានមតិភាគច្រើនលើសលប់ក្នុងការបដិសេធរបស់ ស.ច.ស លើសំណើរបស់ ស.ព.អ ដែលសុំឱ្យបំពេញកិច្ចស៊ើបសួរ[110] មិនបានផ្លាស់ប្តូរសិទ្ធិរបស់ ស.ច.ស.អ នាពេលខាងមុខ

---

សំណើសុំពន្យាពេលកំណត់ និង សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរ ជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១។ សំណើទាំងនេះត្រូវបានដាក់ឡើងវិញដោយ ស.ព.អ បន្ទាប់ពីការដោះស្រាយកំហុសដែលបានលើកឡើងចោទប្រកាន់កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១។ *សូមអាន* ឯកសារ **D22** សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់ ស.ព.អ។ ឯកសារ **D23** សំណើបំពេញកិច្ចស៊ើបសួរលើក ទីពីររបស់ ស.ព.អ។ ឯកសារ **D24** សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់ ស.ព.អ។ សំណើទាំងនេះក៏ត្រូវបាន ច្រានចោលផងដែរដោយ ស.ច.ស៖ *សូមអាន* ឯកសារ **D26** ដីកាសម្រេចស្តីពីការដាក់សារជាថ្មីនូវសំណើសុំបំពេញ កិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

[107] ឯកសារ **D28** ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ទំព័រ ៩៖ ផ្នែកសម្រេចសេចក្តី

[108] ឯកសារ **D52** ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣។ ស.ព.អ កត់សម្គាល់ថា គោលជំហររបស់ ស.ច.ស.ជ នៅក្នុងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យនេះទាក់ទងនឹងខ្លឹមសារនៃសំណុំរឿង គឺមិនទៀងទាត់ជាមួយនឹងការទុកចិត្តរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ គឺតែនៅលើភស្តុតាងនៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ប៉ុណ្ណោះ។ នៅក្នុងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ (ទំព័រ ៣) ស.ច.ស.ជ បានស្វែងរកបញ្ជូនសំណុំរឿង ០០៣ ទៅកាន់សហព្រះរាជអាជ្ញា ដែលមាន "តែឯកសារដែលត្រូវបានបញ្ចូលក្នុងសំណុំរឿងមុនការលាលែងរបស់លោក ចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ និងឯកសារពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីដាក់នៅអង្គភាពជនរងគ្រោះមុនកាលបរិច្ឆេទដែលត្រូវបានប្រកាសជាសាធារណៈ ក្នុងសេចក្តីថ្លែង ការណ៍របស់សហចៅក្រមស៊ើបអង្កេត ក្នុងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១"។

[109] Cass. Crim.ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៥ លេខ ៩៤-៨៥.៩៧៥ ["alors que l'acte d'information auquel il avait été procédé le 5 juillet 1994 rendait caduc l'avis de fin d'information qui avait été donné le 15 juin 1994, et que, faute d'un nouvel avis, le requérant restait recevable à contester la régularité de la procédure"]។ ការបកប្រែក្រៅផ្លូវការ៖ "រីឯ កិច្ចស៊ើបសួរ ដែលបានកើតឡើងកាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៤ បានផ្តល់មោឃភាព ដល់សេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ ដែលបានផ្តល់ជូននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ និងអវត្តមាននូវសេចក្តី ជូនដំណឹងថ្មី [ស្តីពីការបិទកិច្ចស៊ើបសួរ] គឺវានៅតែអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតវ៉ាពីសិទ្ធិតាមច្បាប់នៃកិច្ចដំណើរការនីតិ វិធី ជាដដែល"]។

[110] ឯកសារ **D20/4/4** សេចក្តីពិចារណារបស់ អ.ប.ជ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ នឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។ ឯកសារ **D26/1/3** សេចក្តីពិចារណារបស់ អ.ប.ជ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជំទាស់នឹង

ក្នុងការបន្តកិច្ចស៊ើបសួរមួយដែលនៅមិនទាន់បានបិទ តាមវិធាន ៦៧(១) ឬក្នុងការពិចារណាឡើងវិញលើសំណើសុំទាំងឡាយរបស់ ស.ព.អ នោះទេ[111]។

39. ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានជំទាស់ទៅនឹងសិទ្ធិរបស់ ស.ច.ស.អ បម្រុង ក្នុងការបើកការស៊ើបសួរឡើងវិញក្នុងឆ្នាំ២០១១ ឬបំពេញកិច្ចស៊ើបសួរណាមួយ ផ្អែកលើមូលដ្ឋានថា គាត់មិនត្រូវបានតែងតាំងជា ស.ច.ស.អ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ[112]។ យ៉ាងណាក៏ដោយ គោលជំហរនេះជាការយល់ច្រឡំទៅលើច្បាប់ អ.វ.ត.ក។ នៅពេលដែល ស.ច.ស.អ គឺលោក Blunk លាឈប់ពីតំណែងក្នុងខែតុលា ឆ្នាំ២០១១[113] លោក Laurent Kasper-Ansermet គឺជា ស.ច.ស.អ បម្រុងរួចជាស្រេចហើយ។ គាត់ត្រូវបានតែងតាំងតាមច្បាប់ដោយព្រះរាជក្រឹត្យចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយមានការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបានស្បថចូលកាន់មុខតំណែងនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១១[114]។ នៅក្នុងពេល "គ្មាន" ស.ច.ស.អ មាត្រា ២៦(២) នៃច្បាប់ អ.វ.ត.ក ចែងថា មុខងាររបស់ ស.ច.ស.អ ត្រូវអនុវត្តដោយ ស.ច.ស.អ បម្រុង[115]។ មាត្រា ២៧*ថ្មី* ក៏បានចែងផងដែរថា "ក្នុងករណីដែល [ស.ច.ស] បរទេសណាមួយអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយ [ស.ច.ស] បម្រុង"[116]។

---

សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ("សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរ")។

[111] *ផ្ទុយពីនេះ* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០-៤១, ៤៣។

[112] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨-២៩, ៤៤។

[113] ស.ច.ស.អ លោក Blunk បានលាឈប់កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ដោយមានអានុភាពចាប់តាំងពីថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១១។ *សូមអាន* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើប អង្កេតអន្តរជាតិ* ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សេចក្តីប្រកាសព័ត៌មានដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុង* ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

[114] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *បណ្ឌិត Siegfried Blunk ត្រូវបានចាត់តាំងជាសហចៅក្រមស៊ើបអង្កេត អន្តរជាតិថ្មី* ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សេចក្តីប្រកាសព័ត៌មានដោយសហ ចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុង* ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សេចក្តីប្រកាស ព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុង* ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២។ *សូមអានផងដែរ សុន្ទរកថា របស់ឯកឧត្តម គង់ ស្រីម ប្រធាននៃការប្រជុំពេញអង្គ* ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

[115] ច្បាប់ អ.វ.ត.ក មាត្រា ២៦ ["ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ"]។

[116] ច្បាប់ អ.វ.ត.ក មាត្រា ២៧*ថ្មី*(៣)។

លក្ខខណ្ឌចំនួនពីរសម្រាប់អនុវត្តបទប្បញ្ញត្តិទាំងនេះត្រូវបានបំពេញនៅពេលដែល ស.ច.ស.អ លោក Blunk បានលាឈប់ពីតំណែង។ មិនមានលក្ខខណ្ឌផ្លូវការផ្សេងៗទៀតនោះទេ។ ប្រសិនបើ ស.ច.ស.អ បម្រុង មិនអាចបំពេញកិច្ចនៅក្នុងកាលៈទេសៈទាំងនេះ មុខតំណែងចៅក្រមនេះគ្មានន័យអ្វីទេ។

40. ទោះយ៉ាងណាក៏ដោយ ដីកាសម្រេចលើកលែងចោទប្រកាន់មិនជំទាស់ទៅនឹងការតែងតាំង ស.ច.ស.អ លោក Mark Harmon និងលោក Michael Bohlander ទេ[117]។ តាមពិតទៅ លោកចៅក្រម Bohlander និងលោកចៅក្រម យូ ប៊ុនឡេង បានចេញដីកាសម្រេចលើកលែងចោទប្រកាន់រួមគ្នាមួយនៅក្នុងសំណុំរឿង០០៤/១[118]។ ការបំពេញកិច្ចស៊ើបសួរដែលបានបំពេញនៅក្នុងសំណុំរឿង០០៣ ដោយ ស.ច.ស.អ ទាំងពីររូបនេះ នៅមុនពេលដីកាដំណោះស្រាយណាត្រូវបានចេញ គ្រប់គ្រាន់ក្នុងការមោឃភាពសេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ ដែលបានចេញដោយ ស.ច.ស កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[119]។

41. មាស មុត តែងតែទទួលស្គាល់សុពលភាពនៃការបន្តការស៊ើបសួរ នៅក្រោយ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ជាផ្លូវការ គាត់បានចូលមើលសំណុំរឿង កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ បន្ទាប់ពីត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ លោក Harmon[120]។ ចាប់តាំងពីពេលនោះមក គាត់បានចូលរួមនៅក្នុងការស៊ើបអង្កេតរបស់ ស.ច.ស.អ បានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួន ២០[121] បានដាក់សំណើទៅកាន់ អ.ប.ជ ចំនួន ១៣ សុំមោឃភាពការស៊ើបសួរតាមផ្នែក[122] សំណើសុំចំនួន ៣ សុំទទួលយកលទ្ធផលការងារពីអ្នកស៊ើបអង្កេតនានារបស់ ក.ស.ច.ស[123] សំណើសុំចំនួន ៤ សុំឱ្យបញ្ជាក់ ឬផ្លាស់ប្តូរបច្ចេកទេសសួរចម្លើយ ដែលអ្នកស៊ើបអង្កេត

---

[117] *សូមអាន ឧទា.* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១។

[118] ឯកសារ **D261** ដីកាដំណោះស្រាយលើសំណុំរឿង ០០៤/១។

[119] *សូមអាន ខាងលើ* កំណត់សម្គាល់ជើងទំព័រលេខ ១០៩។

[120] ឯកសារ **D128** ដីកាសម្រេចដាក់ មាស មុត *ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D128.1** ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។

[121] **ឧបសម្ព័ន្ធ I**៖ ប្រវត្តិនីតិវិធី កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៤១។

[122] **ឧបសម្ព័ន្ធ I**៖ ប្រវត្តិនីតិវិធី កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៤៤។

[123] **ឧបសម្ព័ន្ធ I**៖ ប្រវត្តិនីតិវិធី កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៤២។

បានប្រើ[124] និងសំណើសុំជាច្រើនដើម្បីកែតម្រូវ ឬ បញ្ជាក់ទៅលើសម្ភារដែលបានដាក់ចូលទៅក្នុងសំណុំរឿងរួចហើយ[125]។ គាត់ក៏បានចូលរួមនៅក្នុងសវនាការស្តីពីការជូនដំណឹងអំពីការចោទប្រកាន់នៅចំពោះមុខ ស.ច.ស.អ លោក Bohlander[126] ហើយពេលដែលគាត់ជំទាស់លើបទចោទទាំងនេះ និងបទចោទពីមុន ដែលបានចេញដោយ ស.ច.ស.អ លោក Harmon គាត់បានធ្វើដូច្នេះដោយផ្អែកលើមូលដ្ឋាននីតិវិធី និងផ្នែកអង្គសេចក្តី[127]។ មិនមានពេលណាមួយក្នុងចំណោមពេលទាំងនោះដែល មាស មុត បានជំទាស់ថា ការស៊ើបអង្កេតបានបិទបញ្ចប់ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នោះឡើយ។

42. លើសពីនេះទៀត អ.ប.ជ បានទទួលយកជាឯកច្ឆ័ន្ទចំពោះសុពលភាពនៃការបន្តកិច្ចស៊ើបសួរ[128]។ អ.ប.ជ បានប្រកាសជាឯកច្ឆ័ន្ទអំពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១០ ដែល

---

[124] **ឧបសម្ព័ន្ធ I៖** ប្រវត្តិនីតិវិធី កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៤៣។

[125] **ឧបសម្ព័ន្ធ I៖** ប្រវត្តិនីតិវិធី កថាខណ្ឌ ១៥ កំណត់សម្គាល់ជើងទំព័រលេខ ៤៥។

[126] ឯកសារ **D174** កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

[127] ឯកសារ **D128/1/3** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត *ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥។ ឯកសារ **D128.1/1/3** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពី បទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។ ឯកសារ **D174/1/1** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦។

[128] *សូមអាន ឧទា.* ឯកសារ **D134/1/10** អ.ប.ជ សាលដីការបស់អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីការបស់ អ.ប.ជ លើសំណើសុំមោឃភាពចំនួនពីរ") កថាខណ្ឌ ៤៧ [បដិសេធជាឯកច្ឆ័ន្ទលើសំណើសុំមោឃភាពកិច្ចស៊ើបសួរនៅ ក្នុងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា, ចៅក្រម អ.ប.ជ បានកត់សម្គាល់ "ថា ស.ច.ស.អបានរំឭកថា ការ កំណត់បទចោទលើអង្គហេតុនានា នឹងត្រូវសម្រេចនៅពេលបិទបញ្ចប់កិច្ចស៊ើបសួរ។ ហេតុដូច្នេះ ភាគីទាំងអស់ត្រូវ អនុវត្តជាយថាហេតុនូវរាល់មធ្យោបាយតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស និងជាពិសេស ប្រឆាំងនឹង បទចោទប្រកាន់ផ្លូវច្បាប់នានាប្រសិនជាមានការសម្រេចរួច"]។ *សូមអានផងដែរ* ឯកសារ **D165/2/26** សាលដីការបស់ អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ("សាលដីការបស់ អ.ប.ជ ស្តីពីសំណើសុំមោឃភាពចំនួន

បានបង្កើតឡើងនៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយថា "ត្រូវបានអនុញ្ញាត"[129] រួមទាំងកំណត់ហេតុស្តាប់ចម្លើយមួយដែល ស.ច.ស.អ បម្រុងខ្លួនឯងបានប្រមូល នៅក្រោយពេលដែលគាត់បានបន្តការងារស៊ើបអង្កេត[130]។

## *ស.ច.ស មានកាតព្វកិច្ចធ្វើការស៊ើបអង្កេតពេញលេញ*

43. ទោះជាយ៉ាងណា នៅពេលដែល ស.ច.ស បានចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួររបស់ពួកគាត់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ពិតជាមិនទាន់បានពេញលេញនៅឡើយ និងខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការស៊ើបអង្កេតដោយស្មោះត្រង់ មិនលម្អៀង និងមានប្រសិទ្ធភាពលើអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ស.ព.អ នោះទេ។ អនុលោមតាមមាត្រា ១, ២*ថ្មី*, ៣*ថ្មី*, ៤, ៥ និង ៦

---

ប្រាំបួន") កថាខណ្ឌ ៣ ["ក្នុងអំឡុងពេលនៃការស៊ើបសួរ ស.ច.ស បានចេញដីកាបញ្ជូនរឿងទៅពិនិត្យចំនួនប្រាំ ដើម្បីស្នើសុំការបំភ្លឺទាក់ទងនឹងអង្គហេតុដែលបានប្តឹងមកខ្លួន" *ដោយបានលើកឡើង* (i) ឯកសារ **D1/2** សំណើសុំការបំភ្លឺនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ (Blunk)។ (ii) ឯកសារ **D47** ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ (Kasper-Ansermet)។ (iii) ឯកសារ **D50** ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ (Kasper-Ansermet)។ (iv) ឯកសារ **D102** ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ (Harmon)។ (v) ឯកសារ **D105** ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ (Harmon)], កថាខណ្ឌ ៥៤ [បានសម្រេចថា ស.ច.ស.អ មានហេតុផលស្របច្បាប់ ក្នុងការបដិសេធមិនបញ្ជូនសំណើសុំមោឃភាពរបស់ មាស មុត ទាក់ទងនឹងឯកសារ D54/81]។

[129] ឯកសារ **D257/1/8** សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី ភស្តុតាងបានមកពីទារុណកម្ម កថាខណ្ឌ ៣០-៣៥ [បានបញ្ជាក់អនុញ្ញាតឱ្យប្រើឯកសារ **D54/74.1.11** កំណត់ហេតុស្តាប់ចម្លើយ កោ ប៊ុនហេង (ដែលបានដាក់ក្នុងសំណុំរឿងនេះដោយចៅក្រម Harmon)។ ឯកសារ **D55/6** កំណត់ហេតុស្តាប់ចម្លើយ ជិន គីមធុង (Harmon) ឯកសារ **D98/3.1.283** កំណត់ហេតុស្តាប់ចម្លើយ សួង ស៊ីគឿន (Harmon) ឯកសារ **D114/20** កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន (Harmon) ឯកសារ **D114/85** កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុនណា (Harmon) ឯកសារ **D114/116** កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន (Bohlander) ឯកសារ **D114/233** កំណត់ហេតុស្តាប់ចម្លើយ សាំ គំនិត (Bohlander) ឯកសារ **D114/171** កំណត់ហេតុស្តាប់ចម្លើយ កែវ សារួន (Bohlander) ឯកសារ **D114/241** កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង (Bohlander) ឯកសារ **D114/36.1.62** កំណត់ហេតុស្តាប់ចម្លើយ ធុច ស៊ីថន (Bohlander) ឯកសារ **D234/2.1.73** កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម (Bohlander)។

[130] **D257/1/8** សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី ភស្តុតាងបានមកពីទារុណកម្ម កថាខណ្ឌ៣៤-៣៥ [បានបញ្ជាក់ថាអនុញ្ញាតឱ្យប្រើឯកសារ **D37** កំណត់ហេតុស្តាប់ចម្លើយ Robert Hamill ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២]។

នៃច្បាប់ អ.វ.ត.ក និងវិធាន ៥៥(១)[131] នៃវិធានផ្ទៃក្នុង អ.វ.ត.ក គឺ ក.ស.ច.ស[132] មានកាតព្វកិច្ចធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលស្ថិតក្រោមយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក។ ច្បាប់ និងយុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់ពីកាតព្វកិច្ចនេះ[133]។ ដូចដែល អ.ប.ជ បានរម្លឹកនៅក្នុងសំណុំរឿង០០២ ថា "[រាជរដ្ឋាភិបាលកម្ពុជា] មិនត្រឹមតែអាចធ្វើការជំនុំជម្រះលើបទល្មើសទាំងអស់នោះដែលបានកើតឡើងនៅក្នុងយុត្តាធិការដែនដីរបស់ខ្លួន[ប៉ុណ្ណោះទេ] [...] រាជរដ្ឋាភិបាលកម្ពុជាថែមទាំងមានកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ដើម្បីធ្វើការជំនុំជម្រះលើបទល្មើសបែបនេះទៀតផង"[134]។

---

[131] វិធាន៥៥(១) នៃវិធានផ្ទៃក្នុង ចែងថា៖ "ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

[132] ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, 2329 UNTS 117 ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា៥(១)។ វិធាន ៥៥-៧០ នៃវិធានផ្ទៃក្នុង។

[133] *សូមមើល* អនុសញ្ញាប្រល័យពូជសាសន៍ ទទួលស្គាល់ដោយប្រទេសកម្ពុជានៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ មាត្រា I និង V។ អនុសញ្ញាស្តីពីទារុណកម្ម ទទួលស្គាល់ដោយកម្ពុជានៅថ្ងៃទី១៥ ខែតុលា ឆ្នា១៩៩២ មាត្រា៤ និង ៥។ អនុសញ្ញាទីក្រុងហ្សឺណែវ III ទទួលដោយកម្ពុជានៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៥៨ មាត្រា១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវ IV ទទួលស្គាល់ដោយកម្ពុជានៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ១៩៥៨ មាត្រា១៤៦។ ICCPR៖ កម្ពុជា ដែលបានទទួលស្គាល់ ICCPR នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ក៏មាន និងនៅបន្តមានកាតព្វកិច្ចធានាថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យ បង្កឱ្យមានការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស បានទទួល និងត្រូវទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធិភាព។ ក្នុងន័យនេះ មាត្រា២(៣) នៃ ICCPR ចែងថា "រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា៖ (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។"។ កាតព្វកិច្ចនេះជាទូទៅតម្រូវឱ្យរដ្ឋកាត់ទោស និងដាក់ទណ្ឌកម្មអ្នកប្រព្រឹត្តការរំលោភបំពាន។ *សូមមើល Bautista ទល់នឹង Colombia* កថាខណ្ឌ៨.៦ ["រដ្ឋភាគីមានកាតព្វកិច្ចស៊ើបអង្កេតឱ្យបានហ្មត់ចត់លើការរំលោភសិទ្ធិមនុស្សដែលបានចោទប្រកាន់ [...] កាតព្វកិច្ចនេះអនុវត្ត*ហេតុផលគួរឱ្យជឿជាក់ជាង*ក្នុងរឿងក្តីដែលចារីនៃការរំលោភបំពានបែបនោះត្រូវបានកំណត់អត្តសញ្ញាណ។"]។ *សូមមើលផងដែរ Kononov ទល់នឹង Latvia* កថាខណ្ឌ២១៣ [ត្រឹមខែឧសភា ឆ្នាំ១៩៤៤ "រដ្ឋនានាត្រូវយ៉ាងហោចណាស់ទទួលបានការអនុញ្ញាត (ប្រសិនបើមិនតម្រូវ) ឱ្យចាប់ផ្តើមដាក់ទណ្ឌកម្មបុគ្គលទាំងឡាយចំពោះឧក្រិដ្ឋកម្ម [សង្គ្រាម] រួមទាំងដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់មេបញ្ជាការ"។

[134] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ២១៣។

44. ដូចដែលដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់[135] វិសាលភាពនៃការស៊ើបអង្កេតនោះត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា[136]។ ស.ច.ស ត្រូវតែស៊ើបអង្កេត*អង្គហេតុទាំងអស់* ដែលមាននៅក្នុងដីកាសន្និដ្ឋាន ទាក់ទងទាំងទៅនឹងបញ្ហាអ្វីដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង និងអ្នកដែលទទួលខុសត្រូវ។ ការមិនគោរពតាមនីតិវិធីដែលបានកំណត់ដោយវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុងពួកគេមិនអាចកែប្រែ កំណត់ឡើងវិញ ឬកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតបានទេ[137]។ អ.ប.ជ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា មុនពេលដែល ស.ច.ស ធ្វើការសម្រេច*ណាមួយ*ទាក់ទងនឹងការសម្រេចបញ្ចប់រឿងក្តី (ទោះបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់) "ជាដំបូងសហចៅក្រមស៊ើបអង្កេតត្រូវតែបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ដែលមានន័យថាសហចៅក្រមស៊ើបអង្កេតបានបញ្ចប់រាល់កិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនចាត់ទុកថាចាំបាច់ ដើម្បីបង្ហាញការពិតទាក់ទងទៅនឹងអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ"[138]។

45. ដើម្បី "បញ្ជាក់ការពិត" ការស៊ើបអង្កេតទាំងអស់ត្រូវតែទៀងត្រង់[139] មិនលម្អៀង[140] និងមានប្រសិទ្ធភាព[141]។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ឯករាជភាពរបស់តុលា

[135] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៧។

[136] វិធាន ៥៣, ៥៥(២), ៥៥(៣) និង ៥៥(៤) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា១២៥។

[137] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ៣៥។ សំណុំរឿង០០៤-ឯកសារ **D365/3/1/5** សាលដីកា អ.ប.ជ លើអំពើហិង្សាផ្លូវភេទ កថាខណ្ឌ៣៩។ សំណុំរឿង០០២-ឯកសារ **D198/1** ដីកាបញ្ជាក់របស់ ក.ស.ច.ស កថាខណ្ឌ៦។ *សូមមើលផងដែរ* Cass. Crim., ២០ មីនា ១៩៧២, No. 71-93.622 ["le juge d'instruction était saisi des faits dénoncés par le réquisitoire introductif"។ បកប្រែក្រៅផ្លូវការ៖ "ចៅក្រមស៊ើបសួរទទួលបានអង្គហេតុដែលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ"]។

[138] សំណុំរឿង០០២-ឯកសារ **D164/3/6** សាលដីកាលើ SMD កថាខណ្ឌ៣៥។ *សូមមើលបន្តទៀត* ឯកសារ **D26/1/3** សេចក្តីពិចារណារបស់ អ.ប.ជ លើសំណើសុំដាក់ឡើងវិញ កថាខណ្ឌ១០។

[139] *សូមមើល ឧទាហរណ៍ Urrutia ទល់នឹង Guatemala* កថាខណ្ឌ១១៩ ["រដ្ឋគួរតែបានធ្វើការស៊ើបអង្កេតមួយដែលទៀងត្រង់ មិនលំអៀង និងមានប្រសិទ្ធិភាព ដើម្បីបញ្ជាក់អង្គហេតុទាក់ទងនឹងការចាប់ពង្រត់ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម ដែល Maritza Urrutia បានទទួលរង និងជាពិសេស ដើម្បីកំណត់អត្តសញ្ញាណ និងដាក់ទណ្ឌកម្មអ្នកដែលទទួលខុសត្រូវ"]។ *សូមមើលផងដែរ Urrutia ទល់នឹង Guatemala* កថាខណ្ឌ១០៤(គ) [កិច្ចព្រមព្រៀងរបស់គណៈកម្មាធិការសិទ្ធិមនុស្សអន្តរអាមេរិក៖ "រដ្ឋត្រូវតែស្វែងរកការពិតយ៉ាងមានប្រសិទ្ធិភាព ហើយដើម្បីធ្វើបាន រដ្ឋត្រូវតែបង្ហាញឲ្យឃើញថាខ្លួនបានធ្វើការស៊ើបអង្កេតមួយភ្លាមៗ គ្រប់ជ្រុងជ្រោយ ទៀតត្រង់ និងមិនលំអៀង។ រដ្ឋក៏ត្រូវតែកំណត់អត្តសញ្ញាណ និងដាក់ទណ្ឌកម្មចារីដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះផងដែរ"]។ លក្ខន្តិកៈតុលាការ ICC មាត្រា១៧(១)(ក)។

ការក៏ដោយ ក៏បានធ្វើការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតថា ចំណុចនេះផ្តល់សិទ្ធិឲ្យ ស.ច.ស "ធ្វើការស៊ើបអង្កេតតាមវិធីណាមួយ"[142]។ ចៅក្រមពិតជាទទួលបានសេរីភាពជាច្រើនក្នុងការសម្រេចថាតើត្រូវធ្វើការស៊ើបអង្កេតទាំងនោះដោយវិធីណា[143] ប៉ុន្តែចំណុចនេះមិនអនុញ្ញាតឲ្យពួកគេងាកចេញពីកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តការយកចិត្តទុកដាក់ដ៏ហ្មត់ចត់ក្នុងការធ្វើការស៊ើបអង្កេតដ៏ទៀងត្រង់ និងប្រកបដោយប្រសិទ្ធភាពនោះឡើយ[144]។ ស.ច.ស មិនអាចបដិសេធមិនស៊ើបអង្កេតឡើយ[145]។

46. យោងតាមដីកាសម្រេចលើកលែងចោទប្រកាន់ "កិច្ចស៊ើបសួរ [...] បានផ្តោតជាបឋមថា តើជនត្រូវចោទ [...] ពិតជាស្ថិតចូលក្នុងយុត្តាធិការបុគ្គលរបស់ [អ.វ.ត.ក] ដែរឬទេ"[146]។ ដីកានេះបន្តទៀតថា "នាំឲ្យខាតបង់ពេលវេលាស៊ើបអង្កេត" និងថា "ដោយសារមានភាពសង្ស័យថាតើ មាស មុត ស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ [អ.វ.ត.ក] ទើប [ស.ច.ស] ទាំងពីររូបបានឯកភាពជាឯកច្ឆន្ទសម្រេចមិនដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការពិនិត្យនោះទេ"[147]។

---

[140] *សូមមើលឧទាហរណ៍* ច្បាប់ អ.វ.ត.ក មាត្រា ១០ថ្មី, ២៥។ *សូមមើលផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣)។ សំណុំរឿង០០២-ឯកសារ **C20/5/18** សេចក្តីសម្រេចឃុំខ្លួន អៀង ធីរិទ្ធិ បណ្តោះអាសន្ន កថាខណ្ឌ៦៣។

[141] *សូមមើលឧទាហរណ៍ Cantoral-Huamani និង García-Santa Cruz ទល់នឹង Peru* កថាខណ្ឌ ១៣១ ["កាតព្វកិច្ចស៊ើបអង្កេត គឺជាកាតព្វកិច្ចអំពីមធ្យោបាយ ជាជាងលទ្ធផល។ ទោះជាយ៉ាងណា ចំណុចនេះមិនមានន័យថា ការស៊ើបអង្កេតអាចត្រូវបានធ្វើឡើងជា 'ទម្រង់ការដែលកំណត់ជាមុនមិនឲ្យមានប្រសិទ្ធិភាព' នោះទេ។ ទង្វើនីមួយៗរបស់រដ្ឋ ដែលបង្កើតបានផ្នែកមួយនៃដំណើរការស៊ើបអង្កេត ក៏ដូចជាការស៊ើបអង្កេតទាំងមូល គួរមានគោលបំណងជាក់លាក់៖ ការសម្រេចអំពីការពិត និងការស៊ើបអង្កេត ការតាមចាប់ ការឃាត់ចាប់ ការកាត់ទោស និង ប្រសិនបើអាចអនុវត្តបាន ការផ្តន្ទាទោសអ្នកដែលទទួលខុសត្រូវចំពោះអង្គហេតុទាំងនោះ។"]។ *Finucane ទល់នឹង UK* កថាខណ្ឌ៦៨-៧១។

[142] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤២។ *សូមមើលបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៧។

[143] *សូមមើលឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **D164/3/6** សេចក្តីសម្រេច SMD កថាខណ្ឌ២១។ ឯកសារ **D134/1/6.1.4** សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ ប្តឹងជំទាស់ Drs. Stephen Heder និង David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ២០។

[144] *សូមមើល* Guéry ទំព័រ៨៥៣, ផ្នែក ២១២.១១ (ដកស្រង់ *យោងខាងលើ*ជើងទំព័រ២៧)។

[145] *សូមមើល* Guéry ទំព័រ១៥៨ ផ្នែក៥១.០២ *បានដកស្រង់* Cass. Crim., ៣១ មីនា ១៩៨៧, no. 86-90.769 (ដកស្រង់ *យោងខាងលើ* ជើងទំព័រ២៦)។

[146] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៨។

[147] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៥២-៣។

ទោះជាយ៉ាងណា ទស្សនៈបឋមអ្វីក៏ដោយដែល ស.ច.ស អាចមានអំពីបញ្ហាយុត្តាធិការបុគ្គល នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ក៏ការស៊ើបអង្កេតពេញលេញទៅលើការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅតែជាកាតព្វកិច្ច ហើយការបញ្ចប់មុនពេលកំណត់គឺជាការរំលោភអាណត្តិការងាររបស់ ស.ច.ស។

47. ការកំណត់អត្តសញ្ញាណមន្ត្រីខ្មែរក្រហម "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឱ្យមានការវាយតម្លៃទាំងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[148]។ ប្រសិនបើគ្មានការធ្វើការស៊ើបអង្កេតពេញលេញដើម្បីកំណត់ថាតើឧក្រិដ្ឋកម្មអ្វីត្រូវបានប្រព្រឹត្តឡើង និង ថាតើនរណាមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះ ស.ច.ស មិនអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវលើបញ្ហាដ៏សំខាន់នៃយុត្តាធិការនេះបានឡើយ[149]។

48. លើសពីនេះទៀត ការបញ្ចប់ការស៊ើបសួរមុនការអនុវត្តគម្រោងស៊ើបអង្កេតពេញលេញ តាមការកំណត់របស់វិធានផ្ទៃក្នុង ធ្វើឱ្យប៉ះពាល់ដល់សហព្រះរាជអាជ្ញា តាមរយៈការដកហូតឱកាសធ្វើការវាយតម្លៃភស្តុតាងក្នុងសំណុំរឿង ដើម្បីសម្រេចថាតើត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឬទេ និងបន្ទាប់មក ធ្វើសំណើទៅ ស.ច.ស អនុលោមតាមវិធាន ៦៦(៥) នៃវិធាន

---

[148] ក៏ដូចជាបុគ្គលណាផ្សេងទៀត ដែលមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌប្រឆាំងនឹងពួកគេ។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣, ៣៦៥-៧។ *សូមមើលបន្ថែមទៀត យោងខាងលើ* កថាខណ្ឌ៩-១២។

[149] *សូមមើល* សំណុំរឿង00៤/២-ឯកសារ **D185/1** ដីកាសម្រេចស្តីពីញត្តិរបស់ ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ("ដីកាសម្រេចលើញត្តិតាមវិធាន ៧៦នៃវិធានផ្ទៃក្នុង") កថាខណ្ឌ២៧។ *សូមមើលផងដែរ* Cass. Crim., ២៦ កុម្ភៈ ១៩៩៧, No. 95-86.088 ["la chambre d'accusation ne peut, sans méconnaître l'obligation d'informer imposée aux juridictions d'instruction par les articles 85 et 86 du Code de procédure pénale, déclarer territorialement incompétent un juge d'instruction saisi d'une plainte […], faisant état de ce que l'une des personnes soupçonnées d'avoir participé aux infractions dénoncées réside dans son ressort, tant que ce magistrat n'a pas effectué les investigations de nature à lui permettre de vérifier sa compétence." បកប្រែក្រៅផ្លូវការ៖ "ដោយមិនបដិសេធកាតព្វកិច្ចស៊ើបអង្កេតដែលកំណត់លើតុលាការជាន់ទាបដោយមាត្រា ៨៥ និង ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ផ្នែកដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចប្រកាសថា ចៅក្រមស៊ើបអង្កេតដែលទទួលយកបណ្តឹង មិនមានសមត្ថភាពក្នុងដែនដី […] និងដែលថ្លែងថា មនុស្សម្នាក់ក្នុងចំណោមជនទាំងឡាយដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ស្ថិតនៅក្នុងយុត្តាធិការរបស់គាត់ ដរាបណាចៅក្រមស៊ើបអង្កេតមិនបានធ្វើការស៊ើបអង្កេតលើលក្ខណៈបែបនេះ ដើម្បីជួយឱ្យគាត់ផ្ទៀងផ្ទាត់សមត្ថកិច្ចរបស់គាត់នោះទេ។"]។

ផ្ទៃក្នុង សុំឱ្យចោទប្រកាន់ជនត្រូវចោទ ឬលើកលែងចោទប្រកាន់[150]។ វិធានចែងយ៉ាងច្បាស់លាស់ថា មិនត្រឹមតែ ស.ច.ស ទេ ប៉ុន្តែថែមទាំងសហព្រះរាជអាជ្ញាផងដែរ ដែលត្រូវសម្រេចថាតើការស៊ើបអង្កេតមានភាពពេញលេញឬទេ[151]។

## *ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ពិតជាមិនពេញលេញទេនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១*

49. ដីកាសម្រេចលើកលែងចោទប្រកាន់អះអាងថា នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នៅពេលដែល ស.ច.ស យូ ប៊ុនឡេង និង Siegfried Blunk បិទបញ្ចប់ការស៊ើបអង្កេត[152] ការស៊ើបអង្កេតមានភាព "ពេញលេញ និងចប់សព្វគ្រប់"[153] ដោយសារតែ ស.ច.ស បាន "ពិនិត្យភ័ស្តុតាង ទាំងដាក់បន្ទុក និងដោះបន្ទុកទទួលបានពីសាក្សីសំខាន់ៗ"[154] និងបានបញ្ជូន "ភ័ស្តុតាងក្នុងសំណុំរឿង ០០២ ដែលមានជាង ២.០០០ (ពីរពាន់) ឯកសារ ឬ ៤៨.០០០ (បួនម៉ឺនប្រាំបីពាន់) ទំព័រ"[155]។ ប៉ុន្តែ ការពិនិត្យទៅលើភ័ស្តុតាងក្នុងសំណុំរឿងនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ បង្ហាញថា ស.ច.ស មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើការស៊ើបអង្កេតដ៏ទៀងត្រង់ និងប្រកបដោយប្រសិទ្ធភាពលើអង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅពេលនោះឡើយ[156]។ សម្រាប់ហេតុផលដូចគ្នានេះ មិនមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចេញដីកាសម្រេច

---

[150] សំណុំរឿង០០៤/២-ឯកសារ **D185/1** ដីកាសម្រេចលើញត្តិតាមវិធាន ៧៦នៃវិធានផ្ទៃក្នុង កថាខណ្ឌ២៨។

[151] វិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង [កំណត់កាតព្វកិច្ចឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពរតែ "នៅពេលដែលសហព្រះរាជអាជ្ញា យល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយ"។] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៦ ["ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបានបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ"]។

[152] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ២, ១៨។

[153] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៩។ *សូមមើលបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥៩។

[154] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤៨។ *សូមមើលបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤២។

[155] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥៩។ *សូមមើលបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤២។

[156] ស.ព.អ កត់សម្គាល់ថា នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ការស៊ើបអង្កេតរួមបញ្ចូលទីតាំងឧក្រិដ្ឋកម្ម ដែលជាប់ទាក់ទងខ្លាំងទៅនឹង ស៊ូ ម៉េត មួយចំនួននៃទីតាំងឧក្រិដ្ឋកម្មទាំងនេះតាំពីពេលនោះមកត្រូវបានដកចេញពីការស៊ើបអង្កេត តាមវិធាន ៦៦*ស្ទួន*។ *សូមមើល* ឯកសារ **D184/4** សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦*ស្ទួន*(២) ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

លើកលែងចោទប្រកាន់ ដែលបានសម្រេចថា មាស មុត មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

50. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សំណុំរឿងមានតែកំណត់ហេតុស្តាប់ចម្លើយចំនួន ២០ ប៉ុណ្ណោះ ("កំណត់ហេតុស្តាប់ចម្លើយ") ពីសាក្សីចំនួន ១៧នាក់[157]។ មានតែសាក្សីចំនួនប្រាំបីនាក់ ក្នុងចំណោមសាក្សីទាំងនេះ លើកឡើងអំពីទីតាំងឧក្រិដ្ឋកម្មកងពល ១៦៤ ឬតួនាទីរបស់ មាស មុត

---

[បានដកចេញពីការស៊ើបអង្កេតនូវការចោទប្រកាន់ *ជាអាទិ៍* មន្ទីរសន្តិសុខស-២១ និងទីតាំងសំណង់ព្រលានយន្តហោះកំពង់ឆ្នាំង]។ សម្រាប់គោលបំណងបច្ចុប្បន្ន ស.ព.អ ផ្តោតលើការស៊ើបអង្កេតលើឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មដែល ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចោទប្រកាន់ថា មាស មុត ទទួលខុសត្រូវ រួមជាមួយនឹងតួនាទី និងការទទួលខុសត្រូវរបស់គាត់។

[157] កំណត់ហេតុស្តាប់ចម្លើយ ១៧ ត្រូវបានធ្វើឡើងអនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួសតែមួយដែលចេញដោយចៅក្រម Lemonde (ឯកសារ **D2** ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០)៖ ឯកសារ **D2/2** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ លាង។ ឯកសារ **D2/3** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាត។ ឯកសារ **D2/4** កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ។ ឯកសារ **D2/5** កំណត់ហេតុស្តាប់ចម្លើយ ប៊ាន រុំ។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញ៉ូង ជ្រោង។ ឯកសារ **D2/7** កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន។ ឯកសារ **D2/8** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/9** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/10** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/11** កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ កែវ។ ឯកសារ **D2/12** កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ផាត។ ឯកសារ **D2/13** កំណត់ហេតុស្តាប់ចម្លើយ សាយ តាយ។ ឯកសារ **D2/14** កំណត់ហេតុស្តាប់ចម្លើយ មាំង បួលីន។ ឯកសារ **D2/15** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី។ ឯកសារ **D2/16** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន។ ឯកសារ **D2/18** កំណត់ហេតុស្តាប់ចម្លើយ ស្រេង ធី។ សរុបមានតែសាក្សីបីនាក់ប៉ុណ្ណោះ ត្រូវបានស្តាប់ចម្លើយយ៉ាងសង្ខេបដោយចៅក្រម Blunk និង/រ ចៅក្រម យូ ប៊ុនឡេង នៅខែមីនា-មេសា ឆ្នាំ២០១១៖ ឯកសារ **D6** កំណត់ហេតុស្តាប់ចម្លើយ ឈូក រិន ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ [ត្រូវបានស្តាប់ចម្លើយរយៈពេលពីរម៉ោងដោយចៅក្រម Blunk។ ក្នុងចំណោមសំណួរ២២ មាន១១សំណួរទាក់ទងនឹងអង្គហេតុជាក់លាក់ក្នុងសំណុំរឿង០០៣ (រួមទាំងតួនាទីរបស់ ស៊ូ ម៉េត) និង ១១ សំណួរទាក់ទងនឹងអង្គហេតុឧក្រិដ្ឋកម្មសំណុំរឿង០០៤។ ឯកសារ **D6** ក៏ត្រូវបានប្រើប្រាស់ពីរដងក្នុងឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រង់ជើងទំព័រ១៥១ និង ៩៤៣]។ ឯកសារ **D8** កំណត់ហេតុស្តាប់ចម្លើយ សំ ប៊ុនឡេង ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ [ត្រូវបានសួរក្នុងរយៈពេល ៣៤នាទី ដោយចៅក្រម Blunk។ មានសំណួរតែបួនប៉ុណ្ណោះត្រូវបានសួរ។ ដីកាសម្រេចលើកលែងចោទប្រកាន់បានចាត់ទុកកំណត់ហេតុស្តាប់ចម្លើយនេះ ថាមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០៣ ទេ៖ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ៥ (រៀបរាប់ឯកសារ **D8** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយមិនពាក់ព័ន្ធចំនួន ១៣០)]។ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ [ស.ច.ស ទាំងពីរនាក់បានស្តាប់ចម្លើយ ឌុច រយៈពេល១ម៉ោង ៤០ នាទី និងបានសួរ ៥សំណួរ (ជាឈុត) តែប៉ុណ្ណោះ]។

នៅក្នុងសេចក្ដីលម្អិតមួយ[158]។ តាមពិតនោះ ស.ច.ស ខ្លួនឯងផ្ទាល់ បានថ្លែងថា "សាក្សីមួយចំនួនដែលត្រូវបានអ្នកស៊ើបអង្កេតកំណត់អត្តសញ្ញាណក្នុងអំឡុងពេលស៊ើបសួរ មិនទាន់ត្រូវបានស្ដាប់ចម្លើយនៅឡើយទេ ដោយសារតែត្រូវផ្ដោតធនធានលើការងារពិនិត្យឯកសារ"[159]។

51. មុនពេលបិទការស៊ើបអង្កេត ស.ច.ស ក៏បានធ្វើការស៊ើបអង្កេតដល់មូលដ្ឋានតិចតួចបំផុត ដែលជាលទ្ធផលមានតែរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងតែប្រាំប៉ុណ្ណោះ[160]។ របាយការណ៍វត្តឥន្ទញ្ញាណ និងស្ទឹងហាវ មានលក្ខណៈជារបាយការណ៍ "បឋម" និងបានសង្កត់ធ្ងន់ថា ការស៊ើបអង្កេតមិនទាន់ចប់សព្វគ្រប់ ហើយការស៊ើបអង្កេតបន្ថែមទៀតចាំបាច់ត្រូវធ្វើ រួមទាំងការស្ដាប់ចម្លើយសាក្សីផង[161]។ ស.ច.ស ក៏បានរារាំងយ៉ាងសកម្មមិនឱ្យដាក់ភ័ស្តុតាងពាក់ព័ន្ធទៅក្នុងសំណុំរឿងនេះផងដែរ។ ឧទាហរណ៍ ទោះបីជារបាយការណ៍ស៊ើបអង្កេតចំនួនប្រាំបីត្រូវបានរៀបរាប់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ D2/1 ថាត្រូវបាន "ព្រាង [...] ទាក់ទងនឹងការស្រាវជ្រាវឯកសារនៅក្នុងការិយាល័យ ដែលត្រូវបានដាក់ក្នុងឧបសម្ព័ន្ធភ្ជាប់នឹងរបាយការណ៍នេះ"[162] ក៏របាយការណ៍ទាំងនេះមិនត្រូវបានរៀបរាប់នៅក្នុងបញ្ជីសរុបដែលត្រូវបានភ្ជាប់ជាមួយឡើយ[163] ហើយរបាយការណ៍ស៊ើបអង្កេតទាំងអស់នោះ ក៏ដូចជាឯកសារពាក់ព័ន្ធភាគច្រើនដែលត្រូវបានរៀបរាប់

[158] ឯកសារ **D2/4** កំណត់ហេតុស្ដាប់ចម្លើយ ប៉ូច កុយ។ ឯកសារ **D2/6** កំណត់ហេតុស្ដាប់ចម្លើយ ញូង ជ្រោង។ ឯកសារ **D2/7** កំណត់ហេតុស្ដាប់ចម្លើយ ប៉ែន សារិន។ ឯកសារ **D2/8** កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/9** កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/10** កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ិន។ ឯកសារ **D2/15** កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី។ ឯកសារ **D2/16** កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី។ ឯកសារ **D2/17** កំណត់ហេតុស្ដាប់ចម្លើយ អ៊ិន សារឿន [ចាត់ទុកថាមិនពាក់ព័ន្ធដោយឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រ៥]។ ឯកសារ **D6** កំណត់ហេតុស្ដាប់ចម្លើយ ឈួក រិន។ ឯកសារ **D12** កំណត់ហេតុស្ដាប់ចម្លើយ ឌុច។

[159] ឯកសារ **D2/1** របាយការបញ្ចប់កាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ KH 00657728។

[160] ឯកសារ **D2/19** មន្ទីរសន្តិសុខកងពល ៨០១ ក្នុងខេត្តរតនគិរី។ ឯកសារ **D2/20** មន្ទីរសន្តិសុខតំបន់ អូរចេង របស់កងពល ៨០១ ក្នុងខេត្តរតនគិរី។ ឯកសារ **D2/21** មន្ទីរសន្តិសុខស-២២។ ឯកសារ **D2/22** វត្តឥន្ទញ្ញាណ។ ឯកសារ **D2/23** កន្លែងវាយថ្មស្ទឹងហាវ និងទីតាំងដែលពាក់ព័ន្ធ។

[161] ឯកសារ **D2/22** របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងវត្តឥន្ទញ្ញាណ KH 00662102។ ឯកសារ **D2/23** របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងស្ទឹងហាវ KH 00662120, 39-30។

[162] ឯកសារ **D2/1** របាយការបញ្ចប់កាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ KH 00657728។

[163] ឯកសារ **D2/1.1** តារាងសង្ខេបឯកសារ (ភ្ជាប់ទៅនឹងរបាយការបញ្ចប់កាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស **D2/1**) ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១។

ខាងក្នុងនោះ[164] មិនដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នោះដែរ[165]។ គួរឲ្យកត់សម្គាល់បំផុតនោះ ទោះបីជាចម្លើយរបស់ US POW/MIA ធ្វើឡើងដោយថ្នាក់ក្រោមរបស់ មាស មុត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងដោយ ស.ច.ស នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១[166] ក៏ដោយ ក៏ចម្លើយចំនួនពីរដែលបានមកពី មាស មុត[167] ត្រូវបានលុប

[164] ឯកសារ **D64.1.1** & **D64.1.13** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០។ ឯកសារ **D2/24** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០ [រៀបរាប់ពីការរកឃើញចម្លើយរបស់ មាស មុត ដ៏សំខាន់ចំនួនពីរ ក្នុងចំណោមរបាយការណ៍ US POW/MIA និងបានណែនាំឲ្យដាក់ពួកវាទៅក្នុងសំណុំរឿង ដែលមិនបានដាក់នោះទេ]។ ឯកសារ **D64.1.14** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ [របាយការណ៍របស់អ្នកស៊ើបអង្កេត ដែលបានទំនាក់ទំនងទៅកាន់ R. Wetterhahn ដែលជាអ្នកនិពន្ធសៀវភៅ "សមរភូមិចុងក្រោយ" ដែលបានថ្លែងថា សាក្សី អែម សុន (អែម ស៊ុន) គឺជាប្រភពរបស់គាត់អំពីការសម្លាប់ជនជាតិអាមេរិកពីរនាក់ នៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ក្នុងខែឧសភា/មិថុនា ឆ្នាំ១៩៧៥។ អែម ស៊ុន មិនដែលត្រូវបានស្តាប់ចម្លើយដោយ ស.ច.ស.អ Blunk ទេ ទោះបីជា គាត់ជាសាក្សីដ៏មានតម្លៃទាក់ទងនឹងមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងតួនាទី និងមុខតំណែងរបស់ មាស មុត ក៏ដោយ។ *សូមមើល* កំណត់ហេតុស្តាប់ចម្លើយ អែម ស៊ុន ចំនួនបួន ដែលបានប្រមូលក្នុងខែវិច្ឆិកា ឆ្នាំ២០១៣៖ **D54/46**; **D54/47**, **D54/48**, **D54/49**]។ ឯកសារ **D64.1.16** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០។ ឯកសារ **D64.1.17** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១០។ ឯកសារ **D64.1.20** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ ឯកសារ **D64.1.21** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។ ឯកសារ **D64.1.49** របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០។

[165] របាយការណ៍ស៊ើបអង្កេតទាំងប្រាំបីចន្លោះខែមិថុនា និងខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានដាក់នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ (**D64.1.1** & **D64.1.13**; **D64.1.14**; **D64.1.16**; **D64.1.17**; **D64.1.20**; **D64.1.21**; **D64.1.49**) និងនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ (**D2/24**)។ ឯកសារចំនួន ៣៩ ដែលបានរៀបរាប់នៅក្នុងរបាយការណ៍ទាំងនោះត្រូវបានដាក់ក្នុងសំណុំរឿងពីរបីសប្តាហ៍ ឬប៉ុន្មានខែ ក្រោយថ្ងៃ១០ ខែកុម្ភៈ ឆ្នាំ២០១១ ប៉ុន្តែឯកសារ ៤៥ ផ្សេងទៀតមិនត្រូវបានដាក់ទៅក្នុងសំណុំរឿងទេ មុនពេលការលាឈប់របស់ចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk (តែត្រូវបានដាក់ដោយចៅក្រមស៊ើបអង្កេតអន្តរជាតិ Kasper-Ansermet នៅក្នុងឆ្នាំ២០១២ និងដោយចៅក្រម Harmon ក្នុងឆ្នាំ២០១៣៖ ឯកសារចំនួន ៣ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២ (**D22.2.181** & **D22.2.182**, **D22.1.10**) ឯកសារចំនួន ៤២ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (**D64.1.2**, **D64.1.3**, **D64.1.4**, **D64.1.5**, **D64.1.6**, **D64.1.7**, **D64.1.8**, **D64.1.9**, **D64.1.10**, **D64.1.11**, **D64.1.12**, **D64.1.15**, **D64.1.18**, **D64.1.19**, **D64.1.22**, **D64.1.23**, **D64.1.24**, **D64.1.25**, **D64.1.26**, **D64.1.27**, **D64.1.28**, **D64.1.29**, **D64.1.30**, **D64.1.31**, **D64.1.32**, **D64.1.33**, **D64.1.34**, **D64.1.35**, **D64.1.36**, **D64.1.37**, **D64.1.38**, **D64.1.39**, **D64.1.40**, **D64.1.41**, **D64.1.42**, **D64.1.43**, **D64.1.44**, **D64.1.45**, **D64.1.46**, **D64.1.47**, **D64.1.48**, **D64.1.50**)។ មិនមានមូលហេតុណាមួយត្រូវបានផ្តល់ដោយ ស.ច.ស នោះទេ ចំពោះការប្រព្រឹត្តខុសគ្នារវាងឯកសារទាំងនោះ។

[166] ឧទាហរណ៍ ឯកសារ **D4.1.745** ចម្លើយរបស់បុរសមិនស្គាល់ឈ្មោះនៅក្នុង US POW/MIA អំពីវរសេនាតូច៣៨៦ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៨។ ឯកសារ **D4.1.762** ចម្លើយរបស់ កាំ ម៉ែន នៅក្នុង US POW/MIA ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០០។ ឯកសារ **D4.1.746** ចម្លើយរបស់ សំ សុក នៅក្នុង US POW/MIA ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២។ ឯកសារ **D4.1.747** ចម្លើយរបស់ ឯក នី នៅក្នុង US POW/MIA ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២។ ឯកសារ **D4.1.749** សេង ស៊ិន (Seng Sin) និង

ចោល។ ស្រដៀងគ្នានេះដែរ ស.ច.ស មិនបានចាត់វិធានការស៊ើបអង្កេតជាក់ស្តែងដើម្បីស្វែងរកចម្លើយពាក់ព័ន្ធនឹងសំណុំរឿង០០៣ ពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ[168]។

52. សម្ភារផ្សេងៗទៀតនៅក្នុងសំណុំរឿងនេះ នៅពេលដែលការស៊ើបអង្កេតត្រូវបានបិទបញ្ចប់ក្នុងឆ្នាំ ២០១១ មានចំនួនតិចតួចណាស់។ មានឯកសារប្រមាណ ៥៩០ ដែលភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ស.ព.អ[169] ឯកសារដើមនៃសំណុំរឿង០០៣ មួយចំនួនតូចដែលបាន

---

ខៀវ នួក នៅក្នុង US POW/MIA ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣។ ឯកសារ **D4.1.760** ចម្លើយរបស់កម្មាភិបាលកម្ពុជាប្រជាធិតេយ្យ នៅក្នុង US POW/MIA អំពីការឃាត់ចាប់ទូកក្តោងមួយគ្រឿង ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦។

[167] ឯកសារ **D22.2.181** ចម្លើយរបស់ មាស មុត នៅក្នុង (US POW/MIA) ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១។ ឯកសារ **D22.2.182** ចម្លើយរបស់ មាស មុត នៅក្នុង (US POW/PIA) ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់ ប្រើខ្លឹមសារមួយផ្នែកនៃចម្លើយទាំងពីរនេះ ប៉ុន្តែយោងពួកវាទៅប្រភពផ្សេងវិញ។ *សូមមើល* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣១១ ដែលថ្លែងថា៖ "ឯកសារខ្លះបង្ហាញថា មាស មុត បានចូលសម្រាកពេទ្យនៅភ្នំពេញ ពីខែ ឧសភា ដល់ខែកក្កដា នៅក្នុងពេលឧប្បត្តិហេតុកប៉ាល់ម៉ៃយ៉ាហ្គេស។ គាត់បានត្រឡប់មកកំពង់សោមនៅខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៥។ គាត់បានបញ្ជាក់ថា គាត់ទទួលព័ត៌មានពីប្រពន្ធរបស់គាត់ និងពី ឆាន ទាក់ទងនឹងការចាប់កប៉ាល់ម៉ៃយ៉ាហ្គេ និងការវាយប្រហាររបស់អាមេរិក បន្ទាប់ពីឧប្បត្តិហេតុបានកើតឡើង និងមិនបានដឹងពីរឿងនេះពិស្តារទេ"។ ចំណុចនេះបានដកទាំងស្រុងមកពីឯកសារ **D22.2.181** ចម្លើយរបស់ មាស មុត នៅក្នុង (US POW/MIA) ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១ KH 00741997 ["៣. ឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ក. ពីខែឧសភា ដល់ខែកក្កដា ឆ្នាំ១៩៧៥ មាស មុត បានចូលសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យ នៅទីក្រុងភ្នំពេញ ដោយសារតែលោកមានជំងឺពោះវៀនធ្ងន់ធ្ងរ។ ប្រពន្ធរបស់លោកគឺជាប្រភពតែមួយគត់ដែលផ្តល់ព័ត៌មានដល់លោក ទាក់ទងនឹងឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេសនៅពេលនោះ។ ប្រពន្ធរបស់លោកបានថ្លែងប្រាប់លោកអំពីការចាប់នាវាម៉ាយ៉ាហ្គេស និងការវាយប្រហាររបស់អាមេរិកក្នុងអំឡុងពេលដែលអ្នកស្រីបានមកសួរសុខទុក្ខលោករយៈពេលខ្លី ប្រហែលពីរថ្ងៃបន្ទាប់ឧប្បត្តិហេតុនេះ ហើយបានទទួលព័ត៌មានអំពីការវាយប្រហាររបស់សហរដ្ឋអាមេរិក ប្រហែលពីរទៅបីថ្ងៃបន្ទាប់ពីឧប្បត្តិហេតុនេះបានបញ្ចប់។"] KH 00741998 ["គ. បន្ទាប់ពីវិលត្រឡប់មកកាន់ទីរបស់លោកវិញនៅខែកក្កដា ឬសីហា ឆ្នាំ១៩៧៥ លោក មាស មុត បានទទួលរបាយការណ៍មួយពី ឆាន ស្តីពីឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស និងការវាយប្រហាររបស់អាមេរិក។"]។ *សូមមើលផងដែរ* ឯកសារ **D22.2.182** ចម្លើយរបស់ មាស មុត នៅក្នុង (US POW/PIA) ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ KH 00741991 ["៥. ការសម្រាកនៅមន្ទីរពេទ្យ។ ប្រហែលជានៅថ្ងៃទី១០ ខែឧសភា ឆ្នា១៩៧៥ ឧត្តមសេនីយ៍ត្រី មុត បានចូលព្យាបាលជំងឺនៅមន្ទីរពេទ្យរុស្ស៊ី នៅទីក្រុងភ្នំពេញ"]។ ឯកសារដែលបានដកស្រង់ (ជើងទំព័រ ៩៤៦) ឯកសារ **D4.1.759** ការរៀបចំ និងប្រវត្តិកងពលធំលេខ៣ របស់កុម្មុយនីស្តខ្មែរការកប់អដ្ឋិធាតុនៅលើកោះតាង ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០០ ទំព័រ៥ មិនមានព័ត៌មានបែបនេះទេ។

[168] អ្នកស្នង ស.ច.ស.អ Blunk គឺ ស.ច.ស.អ Harmon និង Bohlander បានធ្វើដូច្នេះ។ *សូមមើល យោងខាងក្រោម* កថាខណ្ឌ៥៦ ជើងទំព័រ ១៩៤។

[169] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានភ្ជាប់ឯកសារ ៥៩០ ដែលការយោងចាប់ផ្តើមដោយឯកសារ "**D1.3**"។

ដាក់ក្នុងសំណុំរឿងនេះមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[170] និងបញ្ជីឈ្មោះអ្នកទោសយោធាចំនួនបី ដែលផ្ញើទៅកាន់ ស-២១ ដែលចងក្រងពីឯកសារនៃសំណុំរឿង០០២[171]។ ដីកាសម្រេចលើកលែងចោទប្រកាន់ដកស្រង់ការបញ្ជូន "ភ័ស្តុតាងក្នុងសំណុំរឿងលេខ ០០២ ដែលមានជាង ២.០០០ (ពីរពាន់) ឯកសារ" ដើម្បីធ្វើយុត្តិកម្មការលើកឡើងថា ការស៊ើបអង្កេត "ពេញលេញ"[172]។ ចំនួនឯកសារពិតប្រាកដដែលបានបញ្ជូនដោយ ស.ច.ស ពីសំណុំរឿង០០២ ទៅកាន់សំណុំរឿង០០៣ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ គឺ ១.២៨៧[173]។ ទោះបីជាភ័ស្តុតាងក្នុងសំណុំរឿង០០២ នេះមួយចំនួន បញ្ជាក់ពីព្រឹត្តិការណ៍ដែលដូចគ្នានឹងការចោទប្រកាន់ក្នុងសំណុំរឿង០០៣ ក៏ភស្តុតាងទាំងនោះមិនអាចជំនួសការស៊ើអង្កេតដ៏ហ្មត់ចត់នោះទេ ជាពិសេស ទាក់ទងទៅនឹងទីតាំងដែលមិនស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២។ ឯកសារទាំងនោះ មិនបានបញ្ជាក់អ្វីទាល់តែសោះអំពីការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះទេ។

53. លើសពីនេះទៀត យ៉ាងហោចណាស់ឯកសារចំនួន ១៣៥ ក្នុងចំណោមឯកសារសំណុំរឿង០០២ទាំងអស់នេះ គឺជាឯកសារស្ទួនដែលត្រូវបានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬរៀបរាប់នៅក្នុងកន្លែងផ្សេងៗទៀតក្នុងតារាងឯកសារ D4.1 ឬ D10.1[174]។ តិចជាង ៥០%

---

[170] មានឯកសារ ២៤ និងឧបសម្ព័ន្ធ ៤៨ រួមទាំងរូបថត និងផែនទី ដែលនៅក្នុងសំណុំរឿងនេះ ចាប់ផ្តើមដោយការយោងឯកសារ "**D2**" និងឯកសារ **D3.1.34, D3.1.36** (អត្ថបទសារព័ត៌មានទាំងពីរអំពីការស៊ើបអង្កេតកំពុងបន្ត មិនមែនជាភ័ស្តុតាងបែបដូច្នោះទេ)។

[171] ឯកសារ **D9** កំណត់សម្គាល់ស្តីពីការដាក់ឯកសារ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១។ បញ្ជីទាំងបីដែលភ្ជាប់ជាមួយ មិនមែនជាសម្ភារ ស-២១ ថ្មីឡើយ ប៉ុន្តែជាសម្ភារ ស-២១ នៃសំណុំរឿង០០៣ ដែលត្រូវបានវិភាគ និងចងក្រោយដោយ ស.ច.ស៖ ឯកសារ **D9.1** បញ្ជីឈ្មោះ ក.ស.ច.ស អំពីអ្នកចាប់ខ្លួនពីកងពល ៨០១។ ឯកសារ **D9.2** អ្នកទោស ស-២១ របស់ ក.ស.ច.ស មកពីកងពល ៥០២៖ ការពិនិត្យឡើងវិញ។ ឯកសារ **D9.3** អ្នកទោស ស-២១ របស់ ក.ស.ច.ស មកពីកងពល ១៦៤៖ ការពិនិត្យឡើងវិញ។

[172] **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣៥៩។ *សូមមើលបន្ថែមទៀត* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៤២។

[173] ឯកសារ **D4** កំណត់សម្គាល់ស្តីពីការដាក់ឯកសារ ពីសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ (ឯកសារ **D4.1**: ឯកសារ ១១៥៦ រួមបញ្ចូលទាំងស្ទួនជាច្រើន)។ ឯកសារ **D10** កំណត់សម្គាល់ស្តីពីការដាក់ឯកសារពីសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ (ឯសការ **D10.1**: ឯកសារ ១៣១ រួមទាំងស្ទួន)។

[174] *សូមមើល* **ឧបសម្ព័ន្ធ II** – បញ្ជីស្ទួន ១៣៥ ក្នុងចំណោមឯកសារសំណុំរឿង០០២ ដែលបានដាក់ក្នុងសំណុំរឿង០០៣ ដោយ ស.ច.ស នៅថ្ងៃទី៥ និងទី២៥ ខែមេសា ឆ្នាំ២០១១។

នៃឯកសារ ១.១៥២ ដែលនៅសល់ មានការពាក់ព័ន្ធផ្ទាល់ណាមួយទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នៃសំណុំរឿង០០៣ តួនាទី និងការទទួលខុសត្រូវរបស់ មាស មុត ឬពាក់ព័ន្ធខ្លាំងទៅនឹងគោលនយោបាយពាក់ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ឬ សេនាធិការ/បញ្ជាកងពលមជ្ឈិម[175]។ ដីកាសម្រេចលើកលែងចោទប្រកាន់ខ្លួនឯងផ្ទាល់សម្រេចថា កំណត់ហេតុស្តាប់ចម្លើយសំណុំរឿង០០២ មួយចំនួនធំ (១៣១) ដែលបានដាក់ក្នុងសំណុំរឿង០០៣ ក្នុងខែមេសា ឆ្នាំ២០១១ មិនមានការពាក់ព័ន្ធទេ[176]។ ទោះបីជា ស.ព.អ ជឿថា យ៉ាងហោចណាស់មានកំណត់ហេតុស្តាប់ចម្លើយមួយ ក្នុងចំណោមកំណត់ហេតុទាំងនេះ មានការពាក់ព័ន្ធក៏ដោយ (ចម្លើយរបស់ អ៊ិន សារឿន ដែលបានផ្តល់ព័ត៌មានលម្អិតពីការសម្លាប់ជនជាតិថៃដែលចាប់បាននៅសមុទ្រ)[177] ក៏ឯកសារមួយចំនួនធំតាមពិតទៅមិនពាក់ព័ន្ធ*ទាល់តែសោះ* ទៅនឹងសំណុំរឿង០០៣ទេ ហើយការដាក់បញ្ចូលឯកសារទាំងនេះទៅក្នុងសំណុំរឿង គ្រាន់តែបង្ហាញឲ្យឃើញពីស្ថិតិនៃការស៊ើបអង្កេតហួតចត់តែប៉ុណ្ណោះ។ ជាឧទាហរណ៍ពីរបី គឺឯកសារដែលទាក់ទងជាចម្បងទៅនឹង (i) ក្រសួងសង្គមកិច្ច[178] (ii) ក្រសួងការបរទេស[179] (iii) ការប្រព្រឹត្តិលើប្រជាជនចាម[180] (iv) មន្ទីរសន្តិសុខ

[175] ក្នុងចំណោមឯកសារ ១.១៥២ ស.ព.អ យល់ឃើញថា យ៉ាងហោចណាស់មាន ៥៩០ ឯកសារមិនពាក់ព័ន្ធផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្ម/ឧក្រិដ្ឋកម្មជាក់លាក់បច្ចុប្បន្ននៃសំណុំរឿង០០៣ (ក្នុងតំបន់កំពង់សោម/កងពល ១៦៤៖ មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទឹកសាប ការដ្ឋានរាម កងកេង និងបិតត្រាំង ទីតាំងសម្លាប់មនុស្សចំការចុរេន ការដ្ឋានស្ទឹងហាវ ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកនៅតាមសមុទ្រ និងអំពើប្រល័យពូជសាសន៍វៀតណាម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅភ្នំពេញ៖ មន្ទីរសន្តិសុខស-២១។ នៅក្រចេះ៖ ការបោសមជ្ឈិមសម្អាតកម្មាភិបាលកងពល១១៧/តំបន់៥០៥)។

[176] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន ជើងទំព័រ៥ [យោងទៅលើកំណត់ហេតុស្តាប់ចម្លើយ ១០៥ ដែលបានដាក់ដោយ ស.ច.ស នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ (កំណត់ហេតុស្តាប់ចម្លើយចាប់ផ្តើមដោយការយោងឯកសារ "**D4.1**") និងកំណត់ហេតុស្តាប់ចម្លើយ ២៥ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ (យោងឯកសារ "**D10.1**")។] ដីកាសម្រេចលើកលែងចោទប្រកាន់ក៏បានបញ្ជាក់ពីភាពមិនពាក់ព័ន្ធរបស់កំណត់ហេតុស្តាប់ចម្លើយ ៨ ផ្សេងទៀតផងដែរ៖ ឯកសារ **D1.3.32.43** កំណត់ហេតុស្តាប់ចម្លើយ សូ ខេ។ ឯកសារ **D2/2** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ លាង។ ឯកសារ **D2/3** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាត។ ឯកសារ **D2/5** កំណត់ហេតុស្តាប់ចម្លើយ ប៉ាន រុំ។ ឯកសារ **D2/12** កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ផាត។ ឯកសារ **D2/13** កំណត់ហេតុស្តាប់ចម្លើយ សយ តាយ។ ឯកសារ **D2/14** កំណត់ហេតុស្តាប់ចម្លើយ មាំង បួលីន។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន។ ឯកសារ **D8** កំណត់ហេតុស្តាប់ចម្លើយ សំ ប៊ុនឡេង។

[177] ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន។

[178] ឯកសារ **D4.1.768** កំណត់ហេតុស្តាប់ចម្លើយ សាយ វេត។ ឯកសារ **D4.1.770** កំណត់ហេតុស្តាប់ចម្លើយ ជុំ ណៃ។ ឯកសារ **D4.1.771** កំណត់ហេតុស្តាប់ចម្លើយ អ៊ែ ផល្លី។ ឯកសារ **D4.1.772** កំណត់ហេតុស្តាប់ចម្លើយ គ្រី ប៊ុនថេង។ ឯកសារ **D4.1.777** កំណត់ហេតុស្តាប់ចម្លើយ ស៊ិន អៀវ។ ឯកសារ **D4.1.779** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ស៊ាម។ ឯកសារ **D4.1.938** កំណត់ហេតុស្តាប់ចម្លើយ ប៊ុត ជួន។ ឯកសារ **D4.1.1046** កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ដាំ។

នៅសៀមរាប[181] (v) មន្ត្រីគណកម្មាធិការមជ្ឈិម[182] គ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំងអស់នេះពាក់ព័ន្ធទៅនឹងសំណុំរឿង០០៣ ឡើយ។

54. ការស៊ើបអង្កេតពិតជាមិនគ្រប់គ្រាន់ទេ តាមរយៈការពិនិត្យមើលឯកសារដែលបានបញ្ជូនពីសំណុំរឿង០០២ ដូចដែលបានបង្ហាញតាមរយៈការស្តាប់ចម្លើយតិចតួចក្នុងសំណុំរឿង០០៣ ដែលបានធ្វើនៅដើមឆ្នាំ២០១១។ ស.ច.ស មិនបានធ្វើការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង០០២ ឡើងវិញ (លើកលែងតែការស្តាប់ចម្លើយខ្លីៗជាមួយ ឌុច និង ឈូក រិន) អំពីចម្លើយពីមុនរបស់ពួកគេ និងដោយពិចារណាទៅលើការចោទប្រកាន់ជាក់លាក់ដែលបានធ្វើឡើងនៅក្នុងសំណុំរឿង០០៣។ ឯកសារដែលត្រូវបានបញ្ជូនពីសំណុំរឿង០០២ រួមទាំងសម្ភារ ស-២១ ផងនោះ គួរតែត្រូវបានបង្ហាញទៅកាន់សាក្សី ដើម្បីធ្វើការបញ្ជាក់ និងផ្តល់យោបល់[183]។

55. តាមការប្រៀបធៀប ស.ច.ស បានបន្ថែមឯកសារចំនួន ២.៤៦៧ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនទៅក្នុងសំណុំរឿង ចាប់តាំងពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ឯកសារ

---

[179] ឯកសារ **D4.1.834** កំណត់ហេតុស្តាប់ចម្លើយ គួច វណ្ណារិទ្ធិ។ ឯកសារ **D4.1.1125** កំណត់ហេតុស្តាប់ចម្លើយ សៅ រុន។ ឯកសារ **D4.1.1126** កំណត់ហេតុស្តាប់ចម្លើយ ឡុត និត្យា ហៅ សាឡុត បាន។ ឯកសារ **D4.1.1130** កំណត់ហេតុស្តាប់ចម្លើយ សួង ស៊ីគឿន។

[180] ឯកសារ **D4.1.418** កំណត់ហេតុស្តាប់ចម្លើយ សុខ ព្រឿង។ ឯកសារ **D4.1.419** កំណត់ហេតុស្តាប់ចម្លើយ សុខ ព្រឿង។ ឯកសារ **D4.1.468** កំណត់ហេតុស្តាប់ចម្លើយ អែល សំ។ ឯកសារ **D4.1.471** កំណត់ហេតុស្តាប់ចម្លើយ នោ សាតាស់។ ឯកសារ **D4.1.473** កំណត់ហេតុស្តាប់ចម្លើយ អ៊ឹត សេន។ ឯកសារ **D4.1.474** កំណត់ហេតុស្តាប់ចម្លើយ អះម៉ាត់ សហ្វីយ៉ាស់។ ឯកសារ **D4.1.475** កំណត់ហេតុស្តាប់ចម្លើយ សុះ រំលី។ ឯកសារ **D4.1.485** កំណត់ហេតុស្តាប់ចម្លើយ ស្មាន អាត។ ឯកសារ **D4.1.517** កំណត់ហេតុស្តាប់ចម្លើយ កើ ណោះ។ ឯកសារ **D4.1.529** កំណត់ហេតុស្តាប់ចម្លើយ សេង ស្រ៊ុន។ ឯកសារ **D4.1.530** កំណត់ហេតុស្តាប់ចម្លើយ សំរិត មុយ។ ឯកសារ **D4.1.531** កំណត់ហេតុស្តាប់ចម្លើយ ឡេង សុខជា។ ឯកសារ **D4.1.532** កំណត់ហេតុស្តាប់ចម្លើយ ឌីន ប៉ែត។ ឯកសារ **D4.1.533** កំណត់ហេតុស្តាប់ចម្លើយ ជី ផន។

[181] ឯកសារ **D4.1.457** កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ ផ្លាន។ ឯកសារ **D4.1.459** កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងួន។

[182] ឯកសារ **D4.1.566** កំណត់ហេតុស្តាប់ចម្លើយ សួង ស៊ីគឿន។ ឯកសារ **D4.1.930** កំណត់ហេតុស្តាប់ចម្លើយ សគឹម ល្មុត។

[183] ឧទាហរណ៍ គួរសួរសំណួរ ឌុច អំពីការចាប់កម្មាភិបាលកងពល ១៦៤ ដែលមានឈ្មោះនៅក្នុងបញ្ជីអ្នកទោស ស-២១ និងចំណារនៅលើចម្លើយសារភាពដែលយោងទៅកាន់ មាស មុត។

ទាំងនេះរួមមាន (i) ប្រតិចារឹកសវនាការសំណុំរឿង០០១ ចំនួន ៧៧[184] (ii) សេចក្តីរាយការណ៍ព័ត៌មានកម្ពុជាប្រជាធិបតេយ្យចំនួន ៤៣ រួមទាំងសេចក្តីរាយការណ៍ FBIS ចំនួន ៣៦ (iii) របាយការណ៍កម្ពុជាប្រជាធិបតេយ្យចំនួន ១៩ រួមទាំងរបាយការណ៍ចំនួនប្រាំមួយពី មាស មុត ឬ ថ្នាក់ដឹកនាំកងពល ១៦៤ អំពីស្ថិតិប្រចាំខែ និងរចនាសម្ព័ន្ធកងពល ១៦៤[185] និងរបាយការណ៍ពីអង្គភាពកំពង់សោមក្រោមការគ្រប់គ្រងរបស់កងពល ១៦៤[186] (iv) ឯកសារស-២១ រាប់រយឯកសារ រួមទាំងប្រវត្តិរូប[187] និង "ចម្លើយសារភាព" ដោយបង្ខំពីកម្មាភិបាល និងយុទ្ធជនកងពល ១៦៤[188] ពី

---

[184] ទោះបីជា ស.ច.ស អាចរកបាននៅក្នុងឆ្នាំ២០១០-១១ ក៏ដោយ ភាគច្រើននៃឯកសារទាំងនោះត្រូវបានយោងដោយ ស.ច.ស.អ Mark Harmon អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស **D54, D55** និង **D114** និងសេចក្តីសម្រេច ស.ច.ស.អ លេខឯកសារ **D98/1**។

[185] ឯកសារ **D22.2.1** ស្ថិតិមន្ទីរកងពល ១៦៤ គ្មានកាលបរិច្ឆេទ។ ឯកសារ **D22.2.2** បញ្ជីកម្លាំងប្រចាំថ្ងៃរបស់កងពល ១៦៤ ត្រឹមខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ **D22.2.4** បញ្ជីកម្លាំងប្រចាំថ្ងៃរបស់កងពល ១៦៤ ត្រឹមខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារ **D22.2.5** បញ្ជីកម្លាំងប្រចាំថ្ងៃរបស់កងពល ១៦៤ ត្រឹមខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D22.2.6** បញ្ជីកម្លាំងប្រចាំថ្ងៃរបស់កងពល ១៦៤ ដោយ មាស មុត ត្រឹមខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D22.1.12** របាយការណ៍ស្ថិតិពីកងពល ១៦៤ ខែធ្នូ ឆ្នាំ១៩៧៥។

[186] ឯកសារ **D126.1.1** របាយការណ៍ពីមូលដ្ឋានកំពង់សោម ទៅកាន់បង ៨៩ (សុន សេន) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

[187] *សូមមើលឧទាហរណ៍* ឯកសារ **D114/145.2.14** ប្រវត្តិរូប ស-២១ របស់ ផាម យ៉ាំង ថាន់ (ជនជាតិវៀតណាមដែលចាប់មកនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅសមុទ្រ ដំបូងគេបញ្ជូនទៅទឹកសាប ឱ្យធ្វើការនៅក្នុងចំការដើមធុរេន ក្រោយមកគេបញ្ជូនមក ស-២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦)។ ឯកសារ **D114/145.2.12** ប្រវត្តិរូបស-២១ របស់ ង្វៀង ធីធឿង ង្វៀង ហ៊ុវឡាង និង ចឹង ថាន់ហឿង (អ្នកនេសាទវៀតណាម ដែលចាប់បាននៅសមុទ្រក្នុងខែធ្នូ ឆ្នាំ១៩៧៥ និងបញ្ជូនទៅស-២១ នៅក្នុងខែឧសភា ឆ្នាំ១៩៧៦ ក្រោយពីឆ្លងកាត់ទឹកសាប)។ ឯកសារ **D251.1.1** ប្រវត្តិរូបស-២១ របស់ រ័ត្ន ណាង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨ (អនុលេខាកងពល ១១៧)។

[188] *សូមមើលឧទាហរណ៍* ឯកសារ **D22.2.144** ដល់ឯកសារ **D22.2.147** ចម្លើយសារភាពស-២១ របស់ វង់ ឡឹង ហៅ ចាន់ធន (បញ្ជាការវរសេនាតូច កងពល១៦៤) ខែកក្កដា ឆ្នាំ១៩៧៦-មេសា ១៩៧៧។ ឯកសារ **D114/145.1.10** ចម្លើយសារភាពស-២១ របស់ អ៊ូច ចាន់ធុល (កងពល ១៦៤) ខែមីនា ឆ្នាំ១៩៧៦។ ឯកសារ **D22.2.117** ចម្លើយសារភាពស-២១ របស់ សេក សេន ហៅ សុផល (យុទ្ធជនកងពល ១៦៤) ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ **D22.2.109** ចម្លើយសារភាពស-២១ របស់ ពៅ ឈាន ហៅ ប៊ុនឌី (លេខាវរសេនាតូច ១៦៥ កងពល ១៦៤) ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦ ឯកសារ **D22.2.23** ដល់ ឯកសារ **D22.2.47** ចម្លើយសារភាពស-២១ របស់ ដៃ ហាន ហៅ ឆាន់ ហៅ នង ឆាន់ (អនុបញ្ជាការទីពីររបស់កងពល ១៦៤) ខែតុលា ឆ្នាំ១៩៧៦-១៣ កុម្ភៈ ឆ្នាំ១៩៧៧។ ឯកសារ **D234/2.1.55** ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ឌឹម (អនុបញ្ជាការទីមួយរបស់កងពល ១៦៤) ថ្ងៃទី៤ ខែឧសភា-៣១ កក្កដា ឆ្នាំ១៩៧៧។ ឯកសារ **D126.1.60** ចម្លើយសារភាពស-២១ របស់ ម៉ែន ង៉ែត (សមាជិកគណៈកម្មាធិការកងពល ១៦៤) ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៥។ ឯកសារ **D114/145.1.6** ចម្លើយសារភាពស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត (លេខាវរសេនាតូច ៦៣១) ថ្ងៃទី២៤

កម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ នៅចុងឆ្នាំ១៩៧៨[189] ឬពីជនជាតិវៀតណាម និងជនជាតិផ្សេងទៀត ដែលចាប់បាននៅសមុទ្រដោយកងពល ១៦៤[190] និង (v) របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួន ១១ សម្រាប់ទីតាំងឧក្រិដ្ឋកម្មសំណុំរឿង០០៣[191]។

56. កំណត់ហេតុស្ដាប់ចម្លើយប្រហែលជា ៤៤៥ ត្រូវបានដាក់ទៅក្នុងសំណុំរឿងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ (ប្រហែល ៨៨ នៃការស្ដាប់ចម្លើយទាំងនេះបានធ្វើឡើងមុនថ្ងៃទី២៩ ខែមេសា

---

ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **D114/145.1.9** ចម្លើយសារភាពស-២១ របស់ ម៉ុម ជឹម ហៅ យ៉ាន (សមាជិកកងពល ១៦៤) ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧។ ឯកសារ **D22.2.137** ចម្លើយសារភាពស-២១ របស់ តាំង វ៉េងស៊ី ហៅ ឈិន (អ្នកបកប្រែភាសាកងពល ១៦៤) ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨។

[189] ឯកសារ **D114/145.1.12** ចម្លើយសារភាពស-២១ របស់ ស្វាយ ណូញ (ប្រធានមន្ទីរកងពល ១១៧) ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ឯកសារ **D114/145.1.8** ចម្លើយសារភាពស-២១ របស់ ឃុន សារ៉ុម (លេខាកងពល ១១៧) ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨។

[190] ឯកសារ **D126.1.40** ចម្លើយសារភាពស-២១ របស់ វិញ មិញចូវ (ទាហានជើងទឹកវៀតណាម ចាប់នៅសមុទ្រ) ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D114/145.2.192** ចម្លើយសារភាពស-២១ របស់ វិញ មិញជូ លេខ១៦២ ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D114/145.2.17** របាយការណ៍ស-២១ ផ្អែកតាមចម្លើយសារភាពរបស់ វិញ មិញ ចូវ វ៉ាំងឡឺ វិន ភីឡុង លេខ១៤០, ១៤១, ១៤២ ថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ **D114/145.2.18** ចម្លើយសារភាពស-២១ របស់ ង៉ៀង ថាញ់ក្វាង លេខ១៥៥ ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D54/4.1 & D54/4.2** ចម្លើយសារភាពស-២១ របស់ Ronald K. Dean ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៨-ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩។ ឯកសារ **D54/4.2** របាយការណ៍សង្ខេបដោយ ឆាន់ អំពីចម្លើយសារភាពស-២១ របស់ Ronald K. Dean, Michael S. Deeds និង Christopher E. Delance ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩។

[191] ឯកសារ **D114/30** (មន្ទីរសន្តិសុខវត្តឥន្ទញាណ)។ ឯកសារ **D114/46** (ទីតាំងកងពល ១៦៤ នៅកំពង់សោម)។ ឯកសារ **D114/54** (ទឹកសាប បិតត្រាំង វត្តឥន្ទញាណ កោះរ៉ុងសន្លឹម និងទីតាំងផ្សេងទៀតរបស់កងពល ១៦៤)។ ឯកសារ **D114/56** (មន្ទីរសន្តិសុខទឹកសាប)។ ឯកសារ **D114/60** (ស្ទឹងហាវ)។ ឯកសារ **D114/80** (ទីតាំងសម្លាប់មនុស្សធុរេន I និងបិតត្រាំង)។ ឯកសារ **D114/99** (ទីតាំងសម្លាប់មនុស្សធុរេន II ទឹកសាប និងបិតត្រាំង)។ ឯកសារ **D114/141** (ទឹកសាប)។ ឯកសារ **D114/227** (ទឹកសាប)។ ឯកសារ **D114/275** (មន្ទីរឃុំខ្លួនអូរកំបុត (គៀកទៅនឹង ទឹកសាប)។ ឯកសារ **D114/292** (បិតត្រាំង និងចំការធុរេន)។ ដូចដែលបន្សល់ខាងក្រោម ទីតាំងឧក្រិដ្ឋកម្មទាំងអស់ និងព្រឹត្តិការណ៍ឧក្រិដ្ឋបច្ចុប្បន្ននេះស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០៣ លើកលែងតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ *សូមមើល* **កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្ដីសម្រេចលើអង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។**

ឆ្នាំ២០១១ និងប្រហែល ៣៥៧[192] ទៀត ធ្វើក្រោយពេលនោះ)។ ឯកសារទាំងនេះរួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន ក្នុងចំណោមសាក្សីសំខាន់ៗបំផុតនៃសំណុំរឿង០០៣[193]។ ចម្លើយរបស់សាក្សីចំនួន ៣២០ ផ្សេងទៀត ភាគច្រើនបានមកពី DC-Cam[194] ហើយយ៉ាងហោច

---

[192] ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយទាំង ៣៥៧ ដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មាន ៣២៨ ជាកំណត់ហេតុដើមរបស់សំណុំរឿង០០៣ (ដោយមានឯកសារយោងចាប់ផ្តើមដោយ ឯកសារ **D114/** (កំណត់ហេតុស្តាប់ចម្លើយ ២០៥), **D54/** (កំណត់ហេតុស្តាប់ចម្លើយ ៩៩), **D32/** (កំណត់ហេតុស្តាប់ចម្លើយ ១២) ឬ **D55/** (កំណត់ហេតុស្តាប់ចម្លើយ៤) បន្ថែមលើកំណត់ហេតុស្តាប់ចម្លើយដែលបានយោងជាឯកសារ **D37**, **D39 ដល់ D43**, **D45** និង **D46**) ឯកសារមួយត្រូវបានផ្ទេរទៅកាន់សំណុំរឿង០០២ (ឯកសារ **D114/300.1.11** កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ប៊ុនសេង) និង ២៨ ត្រូវបានផ្ទេរពីសំណុំរឿង០០៤ (**D98/3.1.152; D98/3.1.295; D98/3.1.31; D98/3.1.162; D98/3.1.278; D98/3.1.252; D98/3.1.265; D98/1.1.1; D98/1.1.10; D98/3.1.206; D98/1.1.9; D98/1.1.6; D98/1.1.8; D98/1.1.3; D98/1.1.5; D98/1.1.2; D98/3.1.207; D98/1.1.7; D98/1.1.11; D98/1.1.4; D234/2.1.73; D234/2.1.129; D234/2.1.137; D234/2.1.74; D234/2.1.130; D114/297.1.1; D114/297.1.8; D228/1.1.1**)។

[193] ប៉ាក សុក (**D54/23; D54/24; D54/25; D54/26; D54/27**)។ ឯក នី (**D54/102; D54/103; D54/104; D54/105; D114/282; D114/283; D114/284**)។ ព្រុំ សារ៉ាត់ (**D54/87; D114/285**)។ ម៉ឺង វេត (**D54/59; D54/60; D54/61; D54/62; D54/63; D114/297.1.8**)។ ចេត ប៊ុនណា (**D114/65; D114/66; D114/85; D114/86**)។ ជុំ ជី (**D114/261; D114/262; D114/263; D114/264; D114/265; D114/281**)។ ឯម ស៊ុន (**D54/46; D54/47; D54/48; D54/49**)។ មាស អ៊ឹម (**D114/214; D114/215; D114/216**)។ មាស វឿន (**D54/50; D54/51; D54/52; D54/53; D54/54**)។ មូល ឈិន (**D114/31; D114/39; D114/40**)។ នាក់ យឿន (**D54/115; D54/116; D114/11; D114/12; D114/13**)។ ស៊ឹម នី (**D54/30; D54/31; D54/32; D54/37; D54/88**)។

[194] ចម្លើយប្រមាណជា ២៥០ ត្រូវបានប្រមូលមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ត្រូវបានដាក់ក្នុងសំណុំរឿង០០៣ ក្រោយកាលបរិច្ឆេទនោះ ដោយអ្នកស្នងរបស់ ស.ច.ស.អ Blunk ចំណែកចម្លើយ ៧០ ទៀត ឬច្រើនជាងនេះមានចុះកាលបរិច្ឆេទក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ក្នុងចំណោមបទសម្ភាសន៍ DC-CAM ផ្សេងៗគ្នាទាំង ៥០ ដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ (*សូមមើល* តារាង **D256/11.3** ដាក់ដោយ មាស មុត) មានឯកសារ ៤៣ ត្រូវបានដាក់ក្នុងសំណុំរឿងនេះ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ **D54/24.1 & D59/2/3.14a** ប៉ាក សុក។ **D54/28.1** លៀត ឡន។ **D54/30.1 & D59/2/2.16a** ស៊ឹម នី។ **D54/33.1** អ៊ី ផុន។ **D54/35.1** ប្រាក់ សុខា។ **D54/38.1** លន់ សេង។ **D54/42.1 & D59/1/4.27** ហេង វៀច។ **D54/60.2** ម៉ឹង វេត។ **D54/67.3** នង នេត។ **D54/70.2** មុត ម៉ៅ៖ **D54/78.1 & D59/1/1.12** ណុប ហាល។ **D54/81.2 & D59/1/1.14** ហ៊ីង អ៊ិច។ **D54/92.1 & D59/2/3.17a** យ៉ែម សំអុន។ **D54/99.1 & D59/1/1.9a** ឡាយ ប៊ុនហាក់។ **D54/106.2** សាន់ កាន ហៅ ប៊ុត។ **D54/112.1 & D59/1/1.10a** ផ្លុង ឈា។ **D54/115.1** នាក់ យឿន។ **D59/1/1.7a** ម៉ា ឈឿន។ **D59/1/1.8a** ព្រុំ សារ៉ាត់។ **D59/1/1.11a** ហៀង វ៉េត។ **D59/1/1.27** ម៉ុយ សុត។ **D59/1/1.29** ង៉ែត ចាន់ធូ។ **D59/1/1.46** ឡូត បណ្តែត។ **D59/1/1.52** ភាច រស់។ **D59/1/1.57** យ ម៉ុត។ **D59/1/4.21** អ៊ុក សុខ។ **D59/1/4.25** ឡុង លី។ **D59/2/2.14a** លាង បៀ។ **D59/2/2.118a** ទូច ឈុំ។ **D88.1.5 & D59/2/4.16a** សេង សឿន។ **D98/3.1.127** គឹម វ៉ា។ **D98/3.1.176** មាស វឿន។ **D114/17.1** ម៉ា ឈឿន។ **D114/36.149** ឡេង សាម៉េត។ **D114/79.1** កង សុំ។ **D114/157.1.2** សៅ ស្វ។ **D114/157.1.3** ចិន ផាត។ **D114/157.1.4** ហៅ ឱ។ **D114/215** មាស អ៊ឹម។ **D123/2/2.18a** ទូច

ណាស់មានចម្លើយប្រាំបួនដែលធ្វើឡើងដោយ មាស មុត ឆ្លើយតបទៅនឹងសារព័ត៌មាន ឬទៅកាន់អ្នកសម្ភាសពី US POW/MIA រួមទាំងចម្លើយចំនួនប្រាំ ដែលបានធ្វើឡើងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿងក្រោយពេលបើកការស៊ើបអង្កេតឡើងវិញតែប៉ុណ្ណោះ[195]។

57. លើសពីនេះទៀត ផ្ទុយទៅនឹងការអនុវត្តរបស់ ស.ច.ស ក្នុងសំណុំរឿង០០២[196] មុនពេលការស៊ើបអង្កេតត្រូវបានបិទបញ្ចប់មុនពេលកំណត់ក្នុងឆ្នាំ២០១១ ជនរងគ្រោះមិនទទួលបានព័ត៌មានណាមួយអំពីការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ ឬសិទ្ធិរបស់ពួកគេក្នុងការដាក់ពាក្យធ្វើជាដើម

ឃុំ។ **D220/1.2.1** អ៊ូ គឹម ហៅ រ៉េត។ **D234/2.1.94** ប្រាក់ យុត។ មានតែមួយប៉ុណ្ណោះត្រូវបានផ្ទេរពីសំណុំរឿង០០២ ទៅកាន់សំណុំរឿង០០៣ ដោយ ស.ច.ស ក្នុងខែមេសា ឆ្នាំ២០១១៖ ឯកសារ **D4.1.964** អៀង សារី។

[195] ឯកសារ **D22.2.181** ចម្លើយរបស់ មាស មុត (US POW/MIA) ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១។ ឯកសារ **D22.2.182** ចម្លើយរបស់ មាស មុត (US POW/PIA) ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២។ ឯកសារ **D22.2.184** ចម្លើយរបស់ មាស មុត ក្នុងអត្ថបទ *Ex-KR Division Chief Warns of Instability if Prosecuted* (កាសែត ឌឹខេមបូឌាដេលី) ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩។ ឯកសារ **D22.2.185** ចម្លើយរបស់ មាស មុត *Indict No More: Former Rebel Commander* (សំឡេងសហរដ្ឋអាមេរិក) ផ្សាយថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩។ ឯកសារ **D22.2.186** ចម្លើយរបស់ មាស មុត *Ex-KR leader responds to activist's allegations* (កាសែតភ្នំពេញប៉ុស្តិ៍) ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១។ ឯកសារ **D54/1.1** ចម្លើយរបស់ មាស មុត *A Last Stand* (សារព័ត៌មាន Southeast Asia Globe) ផ្សាយថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។ ឯកសារ **D114/307.5** ចម្លើយរបស់ មាស មុត នៅក្នុងប្រតិចារឹក *បងធំទីមួយ* (ភាពយន្ត Journeyman Pictures) ឆ្នាំ២០១៣ (ភាពយន្តឯកសារនៅក្នុងសំណុំរឿងក្នុងឯកសារ **D233/2.2R**)។ ឯកសារ **D114/307.6** ចម្លើយរបស់ មាស មុត (សំឡេងសហរដ្ឋអាមេរិក) ផ្សាយថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១។ ឯកសារ **D54/16/1R** ខ្សែអាត់សំឡេងបទសម្ភាសន៍ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ២០០៩។

[196] នៅក្នុងសំណុំរឿង០០២ ស.ច.ស បានចេញសេចក្តីប្រកាសព័ត៌មានមួយ នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយបានបង្ហាញពីវិសាលភាពនៃកិច្ចស៊ើបសួរ និងបានជូនដំណឹងជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេក្នុងការដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះ រយៈពេលជាងពីរខែមុនពេលបិទកិច្ចស៊ើបអង្កេត (នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០)។ *សូមមើល* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក *សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតស្តីពីកិច្ចស៊ើបសួរនៃសំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩។ ពួកគេបន្ទាប់មកបានបន្ថែមកាលបរិច្ឆេទកំណត់ពីរដងសម្រាប់ធ្វើដូច្នោះ (រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០)។ អ.ប.ជ នៅតែសម្រេចនៅក្នុងសំណុំរឿង០០២ថា ព័ត៌មានដែលបានផ្តល់ឲ្យជនរងគ្រោះមិនគ្រប់គ្រាន់ និងមិនបានផ្តល់ជូនក្នុងពេលវេលាសមស្រប ហេតុដូច្នេះបានរំលោភបំពានដល់សិទ្ធិរបស់ជនរងគ្រោះ៖ សំណុំរឿង០០២-ឯកសារ **D404/2/4** និង **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ៥១-៥។

បណ្តឹងរដ្ឋប្បវេណី ឬដើមបបណ្តឹងឡើយ[197]។ សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់ការស៊ើបអង្កេតតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង កំណត់រយៈពេល ១៥ថ្ងៃ ជាពេលដែលជនរងគ្រោះ អាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[198]។ អ្នកដែលនឹងអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចអនុវត្តសិទ្ធិនេះបានទេ នៅពេលដែលព័ត៌មានមិនត្រូវបានផ្តល់ជូនទាន់ពេលវេលាអំពីថាតើទីតាំងឧក្រិដ្ឋកម្មមួយណាស្ថិតក្រោមការស៊ើបអង្កេត[199]។ ការមិនដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទាំងមូល មុនពេលបិទបញ្ចប់ការស៊ើបអង្កេតមុនកាលកំណត់ក្នុងឆ្នាំ២០១១ នេះ នាំឲ្យមានការស៊ើបអង្កេតមិនពេញលេញ និងជាការបដិសេធសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង[200]។

---

[197] ស.ច.ស គ្រាន់តែបានប្រកាសទៅកាន់សាធារណជននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដោយខ្លួនឯងថា ពួកគេកំពុងចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ដោយមិនបានផ្តល់ព័ត៌មានណាមួយអំពីវិសាលភាពនៃការស៊ើបអង្កេតនោះ ឬព័ត៌មានអ្វីណាមួយនោះទេ។ សូមមើល សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក *សេចក្តីប្រកាសពីសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ["ថ្ងៃនេះ [ស.ច.ស] នៅក្នុងសេចក្តីសម្រេចជាសាធារណៈ បានបិទបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ (សំណុំរឿងនេះមានភ័ស្តុតាងជាង ២.០០០ ដែលមានជាង ៤៨.០០០ ទំព័រ) និងបានជូនដំណឹងភាគីនានាតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង"]។

[198] វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង។

[199] សំណុំរឿង០០២-ឯកសារ **D404/2/4** និង **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥១-៥៤។ *សូមមើលផងដែរ* វិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង តម្រូវថា អ.វ.ត.ក ធានាថាជនរងគ្រោះទទួលបានដំណឹង និងសិទ្ធិរបស់របស់ពួកគេត្រូវបានគោរព*នៅទូទាំង*កិច្ចដំណើរការនីតិវិធី (គូសបញ្ជាក់បន្ថែម)។

[200] *សូមមើល ជាអាទិ៍* សិទ្ធិដែលផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលកិច្ចស៊ើបសួរតាមវិធាន ៥៥(៨) នៃវិធានផ្ទៃក្នុង (ចុះទៅដល់កន្លែងកើតហេតុដែលធ្វើឡើងដោយ ស.ច.ស) ៥៥(១០) (ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ) ៥៨(៥) (ចូលរួមការតទល់គ្នា) ៥៩(៥) (ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឲ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀត) ៧៤(៤) (ធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត) និង ៧៦(២) (ដាក់ពាក្យសុំមោឃភាពផ្នែកណាមួយ នៃកិច្ចដំណើរការនីតិវិធី)។ ការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីអាចនាំឲ្យមានការស៊ើបអង្កេតមិនពេញលេញ ដោយសារតែភ័ស្តុតាងទាក់ទងនឹងការពិតនៃការចោទប្រកាន់មិនត្រូវបានរកឃើញ។ ឧទាហរណ៍ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ បានផ្តល់ព័ត៌មានសំខាន់អំពីរចនាសម្ព័ន្ធបញ្ជា និងការប្រាស្រ័យទាក់ទងរបស់កងពល ១៦៤ (ឯកសារ **D114/24** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.៤២, ៤៨, ៥៤, ៦១,៦៧-៧០, ៩១-៩២, ៩៧, ១៤០) រួមបញ្ចូលទាំងស្វ័យភាពនៃការសម្រេចរបស់ មាស មុត ផងដែរ (ឯកសារ **D114/24** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.៩០-៩១, ៩៦-៩៧, ១៤០-១៤១) និងបញ្ជារបស់គាត់ឲ្យចាប់ទូកបរទេសទាំងអស់ដែលបានចូលមកក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ (ឯកសារ **D114/24** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ៥៦, ៨៩-៩១,

## *ការខកខានមិនបានវាយតម្លៃភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងមានផលប៉ះពាល់ខ្លាំងបំផុតលើយុត្តាធិការបុគ្គល*

58. តាមរយៈការខកខានមិនបានពិចារណាលើភស្តុតាងណាមួយនៅក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ ដីកាសម្រេចលើកលែងចោទប្រកាន់នេះ បានបន្ថយលទ្ធភាពជាច្រើនរបស់ខ្លួនក្នុងការធ្វើសេចក្ដីសម្រេចមានសំអាងហេតុ ដើម្បីលើកលែងចោទប្រកាន់ មាស មុត ដោយមូលហេតុយុត្តាធិការបុគ្គល[201]។ កំហុសនេះដើរតួនាទីដ៏សំខាន់មួយក្នុងការខកខានមិនបានឈានទៅមានសំអាងហេតុត្រឹមត្រូវ ទាំងអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងអំពីកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត។

59. បន្ថែមលើការផ្ដល់ស្មើតែភស្តុតាងទាំងអស់ដែលមានពីទីតាំងឧក្រិដ្ឋកម្ម និងភស្តុតាងពីជនសង្ស័យសម្រាប់ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានលុបចោលទាំងស្រុងដោយដីកាសម្រេចលើកលែងចោទប្រកាន់ (កំហុសអង្គច្បាប់បន្ថែមទៀតមានរៀបរាប់ខាងក្រោម)[202] ភស្តុតាងដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលមិនត្រូវបានពិចារណានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ បានដើរតួនាទីដ៏សំខាន់បំផុតនៅក្នុងសំអាងហេតុមិនត្រឹមត្រូវទាំងនេះ។ ឧទាហរណ៍រួមមាន កំហុសក្នុង (i) ការកំណត់អត្តសញ្ញាណចំនួន និងប្រភេទជនរងគ្រោះ ដែល មាស មុត ទទួលខុសត្រូវនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ការដ្ឋានស្ទឹង

---

៩៦-៩៧)។ អ៊ូ ដាវ បានថ្លែងថា គាត់បានគោរពតាមបញ្ជាឲ្យបាញ់ជនបរទេស ដែលប្រឆាំងនឹងការឃាត់ចាប់របស់ពួកគេ គឺការនាំយកទូកថៃ និងវៀតណាមមកកាន់កំពង់សោម ដែលជាកន្លែងដែលពួកគេត្រូវបានប្រគល់ទៅឲ្យទាហានរបស់ មាស មុត និងក្រោយមកត្រូវបានដោះដូរជាមួយនឹងប្រេង (ឯកសារ **D114/24** កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.៥៦, ៨២-៨៤, ៨៦-៩១, ១០៣-១១៧, ១៣១, ១៣៣, ១៤៥-១៥៣, ១៥៧)។ ភស្តុតាងរបស់គាត់ក៏ពន្យល់អំពី ការចូលរួមរបស់ មាស មុត ក្នុងផែនការបោសសំអាតកងពល ១៦៤ និងការផ្ដោតគោលដៅលើពួកមូលធននិយម ប្រជាជនថ្មី និងអតីតទាហាន លន់ នល់ ផងដែរ (ឯកសារ **D114/25** កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.១៣-១៤)។ គាត់បានពិភាក្សាបន្ថែមទៀតអំពីប្រតិបត្តិការរបស់មន្ទីរសន្តិសុខទឹកសាប និងវត្តឥន្ទញ្ញាណ និងការដ្ឋានស្ទឹងហាវ (ឯកសារ **D114/25** កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.១៩-២០, ៣២-៣៣)។

[201] *សូមមើលឧទាហរណ៍ Perišić* សាលដីកា កថាខណ្ឌ ៩៥ [“ការវិភាគដែលកំណត់ត្រឹមផ្នែកជ្រើសរើសឯកសារភស្តុតាងពាក់ព័ន្ធ មិនគ្រប់គ្រាប់ដើម្បីបង្កើតបានជាយោបល់មានសំអាងហេតុនោះឡើយ”]។

[202] ដូចដែលបានរៀបរាប់លម្អិតបន្ថែមទៀតខាងក្រោម។ *សូមមើល* **កំហុសអង្គច្បាប់ នៃការខកខានមិនបានពិចារណា និងចេញសេចក្ដីសម្រេចលើវាល់អង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។**

ហារ និងចំពោះជនបរទេសដែលកងកម្លាំងកងពលលេខ១របស់ភូមិភាគបស្ចិមបានចាប់[203] (ii) ការវាយតម្លៃអំពីការចូលរួមរបស់ មាស មុត ក្នុងការអនុវត្តគោលនយោបាយខ្មាំង និងការធ្វើឱ្យទៅជាទាសកររបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការទៅពិនិត្យមើលមន្ទីរសន្តិសុខ និងការដ្ឋាននៅកំពង់សោម និងការកំណត់អត្តសញ្ញាណខ្មាំង[204] (iii) ការបន្តតួនាទីរបស់ មាស មុត ជាលេខាកងពល ១៦៤ ដោយគ្រប់គ្រងទាំងស្រុងលើយោធា និងជនស៊ីវិលក្នុងតំបន់កំពង់សោម រហូតដល់ខែមករា ឆ្នាំ១៩៧៩[205] និង (iv) មុខតំណែងរបស់ មាស មុត ជាសមាជិកសេនាធិការពីពាក់កណ្តាលឆ្នាំ១៩៧៥ និងជាអនុលេខាសេនាធិការពីចុងឆ្នាំ១៩៧៨[206]។

60. សំខាន់សម្រាប់ការវាយតម្លៃទៅលើយុត្តាធិការបុគ្គល[207] ភ័ស្តុតាងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១ ផ្តល់ភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ថា មាស មុត បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស.ច.ស ទទួលពិនិត្យអង្គហេតុនានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងជនជាតិវៀតណាម[208]។ ហេតុដូច្នេះ ពួកគាត់មានកាតព្វកិច្ចត្រូវស៊ើបអង្កេត "កាលៈទេសៈ ដែលគេចោទថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទ"[209]។

61. ស.ព.អ កត់សម្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ពិតជាមិនបានពិនិត្យទាល់តែសោះទៅលើភ័ស្តុតាងសំខាន់ៗមួយចំនួនក្នុងចំណោមភ័ស្តុតាងសំខាន់ៗនានាមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១ ស្តីអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិវៀតណាម និង

---

[203] *សូមមើ* **កំហុសអង្គហេតុអំពីការប្រព្រឹត្តិលជនរងគ្រោះរបស់ដីកាសម្រេចកលើកលែងចោទប្រកាន់។**

[204] *សូមមើល ឧទាហរណ៍ យោងខាងក្រោម* កថាខណ្ឌ១០៤, ២១-១៣៤។

[205] *សូមមើលយោងខាងក្រោម* កថាខណ្ឌ១៣៧-១៤១។

[206] *សូមមើលយោងខាងក្រោម* កថាខណ្ឌ១៤២-១៤៧។

[207] ដូចដែលបានពិភាក្សាខាងលើ ការបង្ហាញថា ជនសង្ស័យបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាការវាយតម្លៃសំខាន់មួយអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង។

[208] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៥៩-៦១។

[209] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។

ភ្នាក់ងាររបស់ពួកគេ[210] ការផ្សាយតាមវិទ្យុក្នុងឆ្នាំ១៩៧៨ អំពីចម្លើយសារភាពមន្ទីរស-២១ ដោយទាហាន ឬ "គិញ" វៀតណាម ដែលបានចាប់ខ្លួននៅសមុទ្រ[211] និងការប្រព្រឹត្តិលើជនជាតិវៀតណាមដោយកងទ័ពជើងទឹក និងនៅ ស-២១[212]។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ផ្អែកលើឯកសារភ័ស្តុតាងមួយចំនួនផ្សេងទៀតមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សម្រាប់គោលបំណងមួយចំនួនក៏ដោយ ក៏ដីកានេះមិនបានវិភាគអំពីរបៀបដែលពួកគេបញ្ជាក់អំពី (ក)

---

[210] ឯកសារទាំងអស់នេះមិនត្រូវបានដកស្រង់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ឡើយ៖ ឯកសារ **D4.1.862** *ទង់បដិវត្តន៍* ខែមេសា ឆ្នាំ១៩៧៧ KH 00062986 ["ចំពោះខ្មាំងជា [...] ភ្នាក់ងារ "យ [យួន]" ជាឆ្កែបំរើខ្មាំងយ៉ាងថោកទាប [...] កម្លាំងដែលនៅសេសសល់ក៏ត្រូវខ្ចាត់ខ្ចាយ រប៉ាត់រប៉ាយជាមូលដ្ឋានដែរ បៀបបីដូចកណ្តុរត្រូវវាយបែកសំបុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជនដេញសំពងឲ្យវិនាសអន្តរធាន"] KH 00062986 ["យើងត្រូវ [...] ឲ្យវាកាន់តែខ្ទេចខ្ទីទៅទៀត ងើបក្បាលមិនរួច"] KH 00062990-91, 93-94។ ឯកសារ **D4.1.617** FBIS, *របាយការណ៍ការពារជាតិកាលពីឆ្នាំមុនត្រូវបានពិនិត្យឡើងវិញ* ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ KH 00340543-44 [ពិភាក្សាអំពីការណែនាំរបស់បក្ស ឲ្យកំម្ទេចខ្មាំងឲ្យបានកាន់តែច្រើន [...] "យើងម្នាក់ត្រូវសម្លាប់វៀតណាម ៣០នាក់"] KH 00340547។ ឯកសារ **D1.3.25.33** FBIS, *សេចក្តីថ្លែងការរបស់ ខៀវ សំផន* ថ្ងៃទី៣១ ខែធ្នូ ឆ្នា១៩៧៧ KH 00229026-27។ ឯកសារ **D4.1.896** *យុវជនយុវនារីបដិវត្តន៍* ខែមេសា ឆ្នាំ១៩៧៧ KH 00376268-70។ ឯកសារ **D4.1.989** បទសម្ភាសន៍ ជា ស៊ីម ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩១ KH 00713926-30។ ឯកសារ **D1.3.19.4** សេចក្តីណែនាំរបស់ ប.ក.ក ពីមន្ទីរ ៨៧០ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ KH 00021108។ ឯកសារ **D4.1.866** *ទង់បដិវត្តន៍* ខែកុម្ភៈ ឆ្នាំ១៩៧៨ KH 00064441-2 ["វាយកំចាត់ខ្មាំង"]។ ឯកសារ **D4.1.893** *យុវជនយុវនារីបដិវត្តន៍* ខែតុលា ឆ្នាំ១៩៧៨ KH 00376497-98។ ឯកសារ **D1.3.29.5** សេចក្តីថ្លែងការណ៍របស់ ប៉ុល ពត ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ KH 00225371-73។ ឯកសារ **D10.1.59** *ទង់បដិវត្តន៍* ខែសីហា ឆ្នាំ១៩៧៧ KH 00062948, 64-65, 78។

[211] ឯកសារ **D1.3.26.7** BBC/SWB *ចម្លើយសារភាពគេញវៀតណាម* ថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៨ KH 00225133។ ឯកសារ **D1.3.26.5** BBC/SWB *ចម្លើយសារភាពទាហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាមដែលត្រូវបានចាប់ខ្លួន* ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ KH 00224832-36។ ឯកសារ **D1.3.25.40** FBIS *ប្រទេសកម្ពុជារាយការណ៍អំពីការបន្តទំលាក់គ្រាប់បែករបស់វៀតណាម* ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D10.1.68** FBIS *មន្ត្រីសាធារណរដ្ឋសង្គមនិយមវៀតណាមភ្ជាប់ទំនាក់ទំនងផែនការវាយប្រហារ* ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៨ EN 00169799-800។ *ចម្លើយសារភាពគេញពលបាលឯកដែលចាប់បាននៅថ្ងៃទី ២៩ ខែមីនា ត្រូវបានរាយការណ៍* ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៨ EN 00169865-66។

[212] ឯកសារ **D4.1.754** ចម្លើយរបស់ទាហានកងពល ១៦៤ មិនស្គាល់ឈ្មោះក្នុង US POW/ MIA ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ KH 00791383-84។ ឯកសារ **D1.3.17.5** Nayan Chanda *សត្រូវបងប្អូនឯង* KH 00191317-18 [រៀបរាប់អំពីរបៀបដែលទាហានខ្មែរបានជម្លៀសដោយភ្នុងនឹងកាំភ្លើងនូវប្រជាជនវៀតណាមចំនួនប្រាំរយនាក់ពីកោះ Poulo Panjang *(Tho Chu / កោះក្រចកសេះ)* ក្នុងឆ្នាំ១៩៧៥ និងរបៀបដែលពួកគេមិនដែលត្រូវបានគេឮម្តងទៀត]។ ឯកសារ **D4.1.5** របាយការណ៍វិភាគដោយ DC-Cam (*បញ្ជីជនបរទេសដែលកម្ទេចនៅស-២១*) [មានឈ្មោះជនជាតិវៀតណាមចំនួន ១១៣នាក់ ភាគច្រើនត្រូវបានរៀបរាប់ថាជា "គិញ" រួមមានយ៉ាងហោចណាស់ ៣៤នាក់ មកពីកំពង់សោម ត្រូវបានសម្លាប់នៅរវាងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨ នៅស-២១]។

អត្ថិភាពនៃគោលនយោបាយប្រល័យពូជសាសន៍របស់កម្ពុជាប្រជាធិបតេយ្យ ចំពោះជនជាតិវៀតណាម ដែលអាចយកចេញពីការឃោសនាឲ្យស្អប់វៀតណាមរបស់មជ្ឈិមបក្ស[213] ហើយដែល មាស មុត បានដឹង និងបានអនុវត្តតាម[214] និង (ខ) ការទទួលខុសត្រូវ និងចេតនាប្រល័យពូជសាសន៍ជាក់លាក់របស់ មាស មុត ក្នុងការឃាត់ឃាំង ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមជាប្រព័ន្ធ[215] ឬក្នុងការបញ្ជូនពួកគេទៅស-២១[216]។ ដីកាសម្រេចលើកលែងចោទ

---

[213] ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានយោងទៅលើការឃោសនារបស់មជ្ឈិមបក្សបែបនោះទាល់តែសោះ កាន់តែតិចជាងនេះទៀតនោះ ទៅកាន់គោលនយោបាយជាតិប្រល័យពូជសាសន៍ ផ្ទុយទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ៖ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៧៣៩-៦១ និងប្រភពនានាដែលបានដាក់ក្នុងសំណុំរឿងនេះ មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ បានយោង៖ ឯកសារ **D4.1.869** *ទង់បដិវត្តន៍* កក្កដា ១៩៧៨ KH 00064487 ["វាយកំចាត់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍របស់យើង"] KH 00064487, 501-503។ ឯកសារ **D1.3.24.5** *ទង់បដិវត្តន៍* ឧសភា-មិថុនា ១៩៧៨ KH 00064562, 66-67, 77។ ឯកសារ **D1.3.27.20** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH 00052407 [សុន សេន៖ "[វៀតណាម] ជាសត្រូវយើងពិតប្រាកដហើយ"]។ ឯកសារ **D4.1.374** FBIS កងទ័ពបដិវត្តន៍អនុម័តសេចក្តីសម្រេចស្តីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨ KH 00244273 ["[កំចាត់]ខ្មាំងយួនដែលជាអ្នកប៉ុនប៉ងយកកម្ពុជាជាឧបសម្ព័ន្ធ [...] ដើម្បីបោសសម្អាតពួកវាទាំងស្រុងចេញពីទឹកដីប្រទេសកម្ពុជា"]។ ឯកសារ **D4.1.868** *ទង់បដិវត្តន៍* មេសា ឆ្នាំ១៩៧៨ KH 00064708, 11-13, 24-25។ ឯកសារ **D1.3.17.1** Elizabeth Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* KH 00232320-21 ["នៅពាក់កណ្តាលឆ្នាំ ១៩៧៧ មតិណែនាំថ្មីមួយ បានបង្គាប់ឲ្យធ្វើការកម្ទេចប្រភេទសត្រូវថ្មីមួយទៀត គឺប្រជាជនកម្ពុជាដែលមានដើមកំណើតជាវៀតណាម"]។ ឯកសារ **D4.1.883** *ទង់បដិវត្តន៍* ខែមេសា ឆ្នាំ១៩៧៦ KH 00062749-50។ ឯកសារ **D1.3.17.3** នាយកដ្ឋានផ្សព្វផ្សាយ និងព័ត៌មាននៃក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សៀវភៅខ្មៅ ខែកញ្ញា ឆ្នាំ១៩៧៨ KH 00289657-59។ ឯកសារ **D4.1.45** *ទង់បដិវត្តន៍* ខែមករា-កុម្ភៈ ឆ្នាំ១៩៧៨ KH 00063495។ ឯកសារ **D4.1.193** សុន្ទរកថារបស់ នួន ជា ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៨ KH 00224454-55។ ឯកសារ **D4.1.583** សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិម ប.ក.ក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨។

[214] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៧៨១-៧៩ *ដកស្រង់* ឯកសារ **D1.3.2.2** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១០ ពី សុន សេន ទៅកាន់ មាស មុត ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ [ការណែនាំអំពីភាពចាំបាច់ដាច់ខាតក្នុងការកម្ទេចខ្មាំងដែលចូលក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ]។ ឯកសារ **D1.3.8.3** កំណត់ហេតុការប្រជុំកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦ KH 00021497 [បានបង្ហាញថាវៀតណាមគឺជាខ្មាំង]។ ឯកសារ **D1.3.27.20** កំណត់ហេតុការប្រជុំកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH 00940345 [សុន សេន៖ "ឥឡូវពួកវា ជាសត្រូវយើងពិតប្រាកដហើយ"]។ ឯកសារ **D1.3.34.60** ទូរលេខ ០០ ពី មាស មុត ទៅកាន់មន្ទីរ ៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH 00001325 ["យើងខ្ញុំទទួលមតិណែនាំ និងសេចក្តីថ្លែងការរបស់បក្ស ស្តីពីការឈ្លានពានរបស់យួន"]។

[215] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣១៣-១១៤, ៣១៥-៣២២ [ទោះបីជាវារៀបរាប់ពីការប្រាស្រ័យទំនាក់ទំនងរបស់ មាស មុត ក្នុងរបាយការណ៍ស្តីពីការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមទៅកាន់ សុន សេន ក៏ដោយ ក៏ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា មាស មុត មិនមានសិទ្ធិអំណាចចេញបញ្ជាតែងឲ្យចាប់ខ្លួន

ប្រកាន់យោងទៅរបាយការណ៍ពីររបស់ មាស មុត ទៅកាន់ សុន សេន អំពីការពន្លិច និងការចាប់ទូកវៀតណាម ក៏ដូចជា ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម ១២០នាក់ ដោយកងទ័ពជើងទឹក ក្នុងរយៈពេលតែបួនថ្ងៃ ខណៈដែលក្នុងពេលជាមួយគ្នានោះ អ្នកនេសាទថៃមួយចំនួនត្រូវបានដោះដូរយកស្បៀង[217] ប៉ុន្តែខកខានមិនបានទទួលស្គាល់ពីភាពខុសគ្នាយ៉ាងច្បាស់ក្រឡែតនៃការប្រព្រឹត្តិដែលរៀបចំឡើងសម្រាប់ជនជាតិវៀតណាម និងជនជាតិថៃដែលឃាត់ចាប់បាន[218]។

62. ទោះជាយ៉ាងណា សេចក្ដីសម្រេចដែលពិចារណាតែលើឯកសារនៅក្នុងសំណុំរឿងមុនថ្ងៃ២៩ ខែមេសា ឆ្នាំ២០១១ ធ្វើឱ្យ ស.ច.ស.ជ មិនពិនិត្យលំអ័ស្តុតាងលម្អិតបំផុតទាក់ទងទៅនឹងឧក្រិដ្ឋ

---

ឬសម្លាប់មនុស្សនោះទេ ដោយសារតែចាំបាច់ត្រូវបានបញ្ជារបស់ សុន សេន ឬ តាម៉ុក ឬពី ស៊ុម តាសៀង ឬតារ៉ន ចាំបាច់ត្រូវពិគ្រោះយោបល់។ ដីកាសម្រេចលើកលែងចោទប្រកាន់បង្ហាញ មាស មុត ថាជាខ្សែក្រវ៉ាត់ដឹកនាំរវាងមជ្ឈិម និងថ្នាក់ក្រោមរបស់គាត់។]។ ចេតនាពិសេសរបស់ មាស មុត ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍វៀតណាមអាចទាញចេញពីឯកសារមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D1.3.34.60** ទូរលេខ ០០ ពី មាស មុត ទៅកាន់មន្ទីរ ៨៧០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH 00001325 ["យើងខ្ញុំដែលមានភារកិច្ចការពារមុខសញ្ញាសមុទ្រ សូម៖ ១. ឯកភាពទាំងស្រុងជាមួយបក្ស។ ២. ប្ដេជ្ញា [...] ការពារមេតុភូមិកម្ពុជាសង្គមនិយមដាច់ខាត។ ដោយបោសសម្អាតគ្មានស្នាក់ស្នើរសមាសភាពបង្កប់របស់ខ្មាំងជាយួន និងខ្មាំងដទៃទៀត។"]។ ឯកសារ **D1.3.30.25, D4.1.635** ទូរស័ព្ទសំងាត់កម្ពុជាប្រជាធិបតេយ្យពី មាស មុត ទៅកាន់ សុន សេន ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH 00143506។ ឯកសារ **D1.3.34.64** ទូរស័ព្ទសំងាត់កម្ពុជាប្រជាធិបតេយ្យ ពី មាស មុត ទៅកាន់ សុន សេន ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D1.3.27.20** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH 00052411-12។ ឯកសារ **D2/16** កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.៣២-៣៣។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.៤២-៤៤។ ឯកសារ **D2/9** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.៥៨។

[216] *សូមមើល* ប្រភពឯកសារមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលបានដកស្រង់ក្នុងឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ១៦៨, ៥៤៤។

[217] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣១៣-៣១៤ *ដែលបានដកស្រង់* ឯកសារ **D1.3.34.64** សារទូរស័ព្ទ កម្ពុជាប្រជាធិបតេយ្យ ពី មាស មុត ទៅកាន់ សុន សេន KH 00020982។ ឯកសារ **D1.3.30.25** សារទូរស័ព្ទ កម្ពុជាប្រជាធិបតេយ្យ ពី មាស មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH 00611668។

[218] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣១៥-៣២២។ ទាក់ទងនឹងភាពខុសគ្នា នៃការប្រព្រឹត្តរវាងជនជាតិវៀតណាម និងថៃ ដែលឃាត់ចាប់បាននៅសមុទ្រ *សូមមើលផងដែរ* ឯកសារ **D1.3.30.25** សារទូរស័ព្ទ កម្ពុជាប្រជាធិបតេយ្យ ពី មាស មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH 00611668 [ការពិភាក្សាអំពីទម្រង់ដោះលែងជនជាតិថៃមួយចំនួនដើម្បីប្ដូរយកបារី និងប្រេងដូងប្រេង]។ ឯកសារ **D1.3.13.11** កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព EN 00217565 [រៀបរាប់អំពីការចរចារជាមួយអាជ្ញាធរថៃអំពីការដោះលែងអ្នកនេសាទ]។

កម្មប្រឆាំងនឹងជនជាតិវៀតណាម។ ជាពិសេស ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានពិចារណាលើកំណត់ហេតុស្តាប់ចម្លើយគួរឱ្យជឿជាក់ជាច្រើន[219] និងប្រតិចារឹកសវនាការដែលបានផ្តោតជាពិសេសលើអំពើប្រល័យពូជសាសន៍វៀតណាម[220] បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស និងសម្ភារ ស-២១ ផ្សេងៗទៀត[221] និងសេចក្តីរាយការណ៍ FBIS រួមទាំងរបាយ

---

[219] យ៉ាងហោចណាស់កំណត់ហេតុស្តាប់ចម្លើយដើមចំនួន ៦៨ នៃសំណុំរឿង០០៣ ត្រូវបានប្រមូលក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ពាក់ព័ន្ធផ្ទាល់ទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាមដែលចាប់បាននៅសមុទ្រ៖ ឯកសារ **D32/6** កែវ វិចិត្រ; **D32/10** ខៀវ សារ៉ន; **D54/7, D54/8** ឌុល សុង; **D54/23, D54/24, D54/25, D54/26** ប៉ាក សុក; **D54/31** ស៊ីម នី; **D54/33, D54/34** អ៊ឹង ឆុន ហៅ អ៊ី ឆុង; **D54/38, D54/43, D54/44, D54/45** លុន សេង; **D54/50, D54/51, D54/52, D54/53, D54/54** មាស រឿន; **D54/63** ម៉ឹង វេត; **D54/71, D54/72** មុត ម៉ៅ; **D54/78, D54/79** ណុប ហាល់; **D54/83** ហ៊ីង អ៊ិច; **D54/87** ព្រុំ សារ៉ាត់; **D54/93** យ៉ែម សំអុន; **D54/98, D114/287** ប៉ាង រ៉េត; **D54/100** ឡាយ ប៊ុនហាក់; **D54/102, D54/105, D114/282, D114/283, D114/284** ឯក នី; **D54/114** ហែម សម្បត្តិ; **D114/11, D114/12** នាក់ យឿន; **D114/16** សុក វណ្ណា; **D114/17, D114/18, D114/19** ម៉ាក ឈឿន; **D114/24, D114/25** អ៊ូ ដាវ; **D114/40** មូល ឈិន; **D114/52** ជាង ជួ; **D114/58** សំ សោម; **D114/65** ជេត ប៊ុណ្ណា; **D114/84** ឯក សុផល; **D114/103** លៀត ឡុន; **D114/104** អៀម ភុង; **D114/122** ណុប ផន; **D114/123** ជួន ធី; **D114/126** អ៊ូ គីម; **D114/130** អៀម ភុង; **D114/132** ម៉ៅ រ៉ាន់; **D114/42, D114/43** សួស ធី; **D114/186** សាត ចក់; **D114/211** នង សុផង់; **D114/247** ហុក យន់; **D114/259** កែវ លឿ; **D114/261, D114/263, D114/264** ជុំ ជី; **D114/301** ឈុន ផល; **D114/302** គង់ ផៃ។

[220] *សូមមើលឧទាហរណ៍* ឯកសារ **D98.3.1** ឧបសម្ព័ន្ធ ក- ឯកសារត្រូវដាក់ក្នុងសំណុំរឿង០០៣ លេខ ៤២ (R. Hamill, D98/3.1.42), ៥៣, ៥៤, ៥៥ (ហ៊ឹម ហ៊ុយ, **D98/3.1.53**, 54, 55), ១៧៨ (មាស មរឿន **D98/3.1.178**)។ **D98/1.2.22** ឌុច ប្រតិចារឹក ថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ ម៉ោង 14.17.05-14.25.09។ **D114/297.1.20** ប៉ាក សុក ប្រតិចារឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10.03.10-13.58.15។ **D114/297.1.21** ប៉ាក សុក ប្រតិចារឹក ថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.54.50-10.58.50, 13.35.04-14.31.22។ **D234/2.1.92** ព្រុំ សារ៉ាត់ ប្រតិចារឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.55.25-10.58.17, 15.49.55-15.53.04។ **D234/2.1.93** ព្រុំ សារ៉ាត់ ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.51.04-10.49.35, 13.55.27-13.56.33។ **D234/2.1.95** មាស រឿន ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.10.55-14.35.36, 15.54.15-16.00.12។ **D234/2.1.96** មាស រឿន ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.15.00-09.29.08។ **D54/6.1.12** Nayan Chanda ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 09.34.11-09.36.16, 13.44.10-14.00.18។ **D234/2.1.112** ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.57.03-15.59.05។

[221] **D114/230.1.1** បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស [ដែលបង្ហាញថា ជនជាតិវៀតណាមចំនួន ១៨៨ នាក់ត្រូវបានចាប់ខ្លួននៅកំពង់សោមដោយកងទ័ពជើងទឹក (ដោយកងពលលេខ១ ដែលក្រោយមកបានបញ្ជូនពួកគេទៅកងពល ១៦៤) ត្រូវបានផ្ទេ រួចក្រោយមកត្រូវបានសម្លាប់នៅ ស-២១ ក៏ដូចជាជនជាតិវៀតណាម ៦នាក់ បានផ្ទេរដោយ មាស មុត ពីខេត្តក្រចេះនៅចុងឆ្នាំ១៩៧៨]។ *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ១២៦, ១៧៣, ៥៤៨, ៥៥១, ១០៩១។ *សូមមើលផងដែរ* <u>ប្រវត្តិរូប ស-២១</u> មួយចំនួនរបស់អ្នកទោសជនជាតិវៀតណាម ដែលបានចាប់នៅសមុទ្រដោយកងពល ១៦៤៖ **D114/145.2.1** (៣ នាក់), **D114/145.2.12** (៣ នាក់), **D114/145.2.13** (២ នាក់), **D114/145.2.10** (២

ការណ៍ឆ្នាំ១៩៧៨ ដែលមានចម្លើយសារភាពសង្ខេបរបស់ជនជាតិវៀតណាមផ្សាយតាមវិទ្យុភ្នំពេញ[222]។ ភ័ស្តុតាងនេះបង្ហាញថា មាស មុត និងរបបកម្ពុជាប្រជាធិបតេយ្យចាត់ទុកជនជាតិវៀតណាម ថាជា "សត្រូវសួរពូជ និងសត្រូវលេខ១"[223] ត្រូវតែកម្ទេចជាប្រព័ន្ធ ដូច្នេះ មិនគិតអំពីឋានៈ ភេទ និងអាយុរបស់ពួកគេ ដែលជា ជនភៀសខ្លួន អ្នកនេសាទ "គិញ" និងឈ្លើយសឹក (POW) ទារក កូនក្មេង យុវជន ឬមនុស្សចាស់ ប្រុស ឬស្រី ត្រូវតែកម្ទេចចោលទាំងអស់[224]។ មាស មុត បានផ្សព្វផ្សាយគោលនយោបាយប្រល័យពូជសាសន៍នេះនៅក្នុងកងពល ១៦៤ របស់គាត់ តាមរយៈវគ្គសិក្សា និងបណ្តុះបណ្តាល[225]។ ដោយសារតែបទបញ្ជាដែលចេញដោយ មាស មុត និងសេចក្តីសម្រេចដែលគាត់បានធ្វើអំពីការសម្លាប់ជនជាតិវៀតណាមទាំងអស់ដែលឃាត់ចាប់បាននៅសមុទ្រនេះ រាប់ពាន់នាក់[226] ភាគច្រើនជាជនភៀសខ្លួន[227] ត្រូវបានចាប់ខ្លួន

---

នាក់), **D114/145.2.14** (១ នាក់)។ ចម្លើយសារភាពស-២១ របស់ជនជាតិវៀតណាម (មិនមែនចាប់មកពីសមុទ្រទាំងអស់ទេ) ៖ **D126.1.3-5**, **D126.1.16-9**, **D126.1.21-54**, **D126.1.62**, **D126.1.67**, **D114/145.2.4-9**, **D114/145.2.18-19**, **D114/145.2.21-24**។

[222] របាយការណ៍ FBIS ទាំងអស់ក្នុងឆ្នាំ ១៩៧៨៖ **D64.1.35** to **D64.1.46** (១២ របាយការណ៍), **D114/37.1.82**។

[223] **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ១៣១, ១៣៧, ៣៦៣, ៣៨៧, ៣៩០, ៤០៧-៤០៨, ៧៤៤, ៧៥១-៧៥៣, ៧៨៣ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។

[224] **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ១២៨-១២៩, ១៣១, ១៤៦, ៣៨៧, ៤០៧, ៧៣៩, ៧៤៤, ៧៤៧-៧៥០, ៧៥៩, ៧៦៩-៧៧០, ៧៧២, ៧៨៤, ១១២៣ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។

[225] **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ១៣១, ១៣៨, ២៩០, ៧៤៤, ៧៨៣, ១១២៣ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។

[226] **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ១៧៣, ៤០២, ៧៩៣, ៧៩៥ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ១៣២-១៤៥, ២៤៨-២៥៧។

[227] **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ១៣៣, ៣៨៦, ៣៩៩, ៤០៣ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលបានដកស្រង់) រួមបញ្ចូល៖ ឯកសារ **D54/24.1** បទសម្ភាសន៍ ប៉ាក សុក ដោយ DC-Cam KH 00955508 ["ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បាន បាញ់សម្លាប់ចោលទៅ"]។ ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.២៩។ ឯកសារ **D114/283** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.៤, ១៨។ ឯកសារ **D54/79** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.៨, ១១, ១៨, ២៣។ ឯកសារ **D54/23** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុក ឆ.៣៧-៣៨។ ឯកសារ **D54/25** កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុក ឆ.១១, ២០។ ឯកសារ **D114/127** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.៣។ ឯកសារ **D114/126** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.៣៦-៤១។ ឯកសារ **D114/57** កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.២០-២៣។ ឯកសារ **D98/3.1.178** មាស វឿន ប្រតិចារឹក ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.23.23-10.26.02។ ឯកសារ **D54/87** កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត់ ឆ.១២១-១២៥, ១៣២។

និងសម្លាប់នៅសមុទ្រ នៅតាមកោះ ឬនៅកំពង់សោម[228]។ មាស មុត បានចូលរួមចំណែកបន្ថែមទៀតក្នុងអំពើប្រល័យពូជសាសន៍នេះ តាមរយៈការជួយសម្រួល ឬការបញ្ជាឲ្យបញ្ជូនអ្នកទោសជនជាតិវៀតណាមយ៉ាងហោចណាស់ ១៨៨ នាក់ ទៅកាន់ ស-២១[229] រួមទាំងក្មេងជំទង់ប្រាំបីនាក់ផងដែរ[230]។

## គ. កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្ដីសម្រេចលើរាល់អង្គហេតុទាំងអស់ក្នុងវិសាលភាពនៃសំណុំរឿង ០០៣

63. ស.ច.ស មានកាតព្វកិច្ចចេញសេចក្ដីសម្រេចលើរាល់អង្គហេតុទាំងអស់ ដែលពួកគេទទួលពិនិត្យ[231]។ ដីកាសម្រេចលើកលែងចោទប្រកាន់មានវិការៈផ្នែកអង្គច្បាប់ ដោយសារតែដីកានេះខកខានមិនបានពិចារណាលើទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋជាច្រើន ដែល ស.ច.ស ទទួលពិនិត្យតាមច្បាប់។ ទីតាំង និងព្រឹត្តិការណ៍ដែលមិនត្រូវបានពិចារណានោះរួមមាន (i) មន្ទីរសន្តិសុខទឹកសាប (ii) ការដ្ឋាន និងសហករណ៍តំបន់រាម (រួមទាំង បិតត្រាង កងកេង និង

---

[228] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ ១៣១-២, ១៣៩, ១៤០-១, ៣១៣, ៣៧៩-៨០, ៣៨៥, ៣៨៧, ៣៩២-៣, ៣៩៩, ៤០១-៦, ៤១០-១, ៤១៣, ៤២១-២, ៤២៥, ៤៣២, ៥០០, ៥០២, ៧៧០, ៧៨៤-៥, ៧៩២, ៧៩៦-៧ (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។

[229] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ 137, 141-2, 174, 387, 417-9, 425, 428, 500, 544-6, 548, 550-1, 583, 585, 588, 797 (*សូមមើល* ឯកសារយោងមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)។ ឯកសារ **D114/230.1.1** បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខ 592-4, 596-7, 602, 606-7, 612, 625, 651-3, 663, 676, 678, 8164-7, 8250-63, 8271-2, 8400-3, 8405-10, 8689, 8982-4, 8987-90, 8992-4, 9647, 9650-53, 9857-9, 9888, 9899-9900, 9917-9928, 10257-10262, 10264, 10265, 10267, 11872-5, 11877, 12490-8, 12653-6, 13007-20, 13431-4, 13436-7, 13446, 13453, 13458, 13463, 13469, 13474, 13483, 13486, 13488, 13498-13499, 13501, 13529, 13532, 13535, 13541, 13543, 13642-3, 13895-6, 13912-31, 14728, 14758, 14785, 14795-9, 14816, 14820។ ឯកសារ **D54/87** កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.១៣៥, ១៣៧, ១៤៤។

[230] ឯកសារ **D114/230.1.1** បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខ 13434, 8405, 8255, 8258, 8408, 10262, 12496។

[231] សំណុំរឿង០០១-ឯកសារ **D99/3/42** សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ៣៣, ៣៧-៨។ សំណុំរឿង០០២-ឯកសារ **D198/1** ដីកបញ្ជាក់របស់ ក.ស.ច.ស កថាខណ្ឌ១០។ Cass. Crim., ថ្ងៃទី២៤ មីនា ឆ្នាំ១៩៧៧ លេខ 76-91.442។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៦, ១២៩ (ចៅក្រម Beauvallet និង Baik)។

ទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ) (iii) ការបោសសម្អាតកម្មាភិបាលកងពល ១១៧ និង កម្មាភិបាលតំបន់ ៥០៥ នៅខេត្តក្រចេះ (iv) ការបោសសម្អាតកងពលយោធាផ្សេងៗទៀត រួមទាំងអ្នកទាំងឡាយដែលត្រូវបានបញ្ជូនទៅកាន់ ស-២១ និង (v) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ)។ វិការៈនេះប៉ះពាល់ធ្ងន់ធ្ងរដល់ការសម្រេចលើយុត្តាធិការបុគ្គលរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលតម្រូវឱ្យមានការវាយតម្លៃពេញលេញ ទាំងទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត[232]។ កំហុសអង្គច្បាប់នេះគឺជាលទ្ធផលនៃការដែលដីកាសម្រេចលើកលែងចោទប្រកាន់មិនបានបកស្រាយឱ្យបានត្រឹមត្រូវអំពីវិសាលភាពនៃសំណុំរឿង០០៣ ដូចដែលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងទទួលស្គាល់កិច្ចផ្នែកនីតិវិធី ដែលធ្វើឡើងនៅក្នុងការស៊ើបអង្កេតក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលរួមទាំង ជាពិសេស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ ដែលបានដាក់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤[233]។

## *ទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*

64. ជាការពិតណាស់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ចាត់ទុកតែទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ទាំងឡាយណាដែលត្រូវបានរៀបរាប់*យ៉ាងច្បាស់* នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថាស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០៣ (ដូចជា មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ កន្លែងវាយច្រាំងស្ទឹងហាវ មន្ទីរ ស-២១ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ)។ ទោះជាយ៉ាងណា ចំណុចនេះយល់ច្រឡំទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មដែល ស.ច.ស បានទទួលពិនិត្យ។ មុនពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម វិសាលភាពនៃការស៊ើបអង្កេតសំណុំរឿង០០៣ ត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

232 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣, ៣៦៥-៧។ *សូមមើលផងដែរ យោងខាងលើ* កថាខណ្ឌ៩-១២។

233 ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ [ស.ព.អ] ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងសំណុំរឿង០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។

ស៊ើបសួរ[234] ដោយរួមទាំងខ្លឹមសារនៃឧបសម្ព័ន្ធរាប់រយ[235]។ តាមច្បាប់ ស.ច.ស ត្រូវបានប្តឹងអំពី *អង្គហេតុ* ទាំងអស់ "ចែង" នៅក្នុងនោះ[236]។ "អង្គហេតុ" មិនដូចគ្នាទៅនឹង "ទីតាំងឧក្រិដ្ឋកម្ម" ដែលមិនចាំបាច់ត្រូវរៀបរាប់ដោយផ្ទាល់នៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលត្រូវ "កំណត់" នៅក្នុងនោះទេ ប្រសិនបើការស៊ើបអង្កេតលើទីតាំងនោះតម្រូវឱ្យបំពេញកាតព្វកិច្ចស៊ើបអង្កេតពេញលេញលើអង្គហេតុជាក់លាក់នោះ។ អ.ប.ជ បានសន្និដ្ឋានជាឯកច្ឆ័ន្ទថា ស.ច.ស ទទួលពិនិត្យលើ "កាលៈទេសៈជុំវិញអំពើទាំងឡាយដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ"[237] ដែលរួមទាំង ទីកន្លែងដែលអង្គហេតុដែលត្រូវបានចោទប្រកាន់បានកើតឡើង ឬដែលជាប់ទាក់ទងទៅនឹងអង្គហេតុទាំងនោះ[238]។ លើកលែងតែការចោទប្រកាន់អំពីការរៀប

---

[234] វិធាន ៥៣, ៥៥(២) នៃវិធានផ្ទៃក្នុង។ ក្រមនិតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥។ សំណុំរឿង00១-ឯកសារ **D99/3/42** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤-៣៥។ សំណុំរឿង00៤-ឯកសារ **D365/3/1/5** សាលដីកា អ.ប.ជ លើអំពើហិង្សាផ្លូវភេទ កថាខណ្ឌ ៣៩។ សំណុំរឿង00២-ឯកសារ-**D198/1** ដីកាបញ្ជាក់របស់ ក.ស.ច.ស កថាខណ្ឌ៦។

[235] Cass. Crim., ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩១, No. 91-82.706 ["La saisine du magistrat instructeur, quant aux faits, est déterminée par les pièces annexées à ce réquisitoire"។ បកប្រែក្រៅផ្លូវការ៖ "បញ្ហានៅចំពោះមុខចៅក្រមស៊ើបអង្កេតទាក់ទងនឹងអង្គហេតុត្រូវកំណត់ដោយឯកសារឧបសម្ពន្ធភ្ជាប់ទៅនឹងដីកាសន្និដ្ឋាន"]។ Cass. Crim., ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧២, No. 72-90.719។ *សូមមើលផងដែរ* ឯកសារ **D134/1/10** សាលដីកា អ.ប.ជ លើពាក្យសុំមោឃភាពចំនួនពីរ កថាខណ្ឌ ៤ (ចៅក្រម Beauvallet និង Bwana)។ ឯកសារ **D165/2/26** សាលដីកា អ.ប.ជ លើពាក្យសុំមោឃភាពចំនួនប្រាំបួន កថាខណ្ឌ១៥0 (ចៅក្រម Beauvallet និង Baik)។ វិធាន ៥៣(២) នៃវិធានផ្ទៃក្នុង។

[236] វិធាន ៥៣, ៥៥(២), ៥៥(៣) និង ៥៥(៤) នៃវិធានផ្ទៃក្នុង។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥។

[237] សំណុំរឿង00១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥។

[238] Cass. Crim., ថ្ងៃទី១0 ខែមីនា ឆ្នាំ១៩៧៧, No. 75-91.224 ["S'il est interdit aux juges de statuer sur des faits autres que ceux qui leur sont déférés, il leur appartient de retenir tous ceux qui, bien que non expressément visés dans le titre de la poursuite, ne constituent que des circonstances du fait principal, se rattachant à lui et propre à le caractériser." បកប្រែក្រៅផ្លូវការ៖ "ចំណែកឯចៅក្រមត្រូវបានហាមឃាត់មិនឱ្យវិនិច្ឆ័យអង្គហេតុណាក្រៅពីអង្គហេតុដែលមាននៅចំពោះមុខពួកគេ វាស្ថិតនៅលើពួកគេក្នុងការសន្និដ្ឋានលើរាល់អង្គហេតុទាំងអស់នោះ ដែល ទោះបីជាមិនត្រូវបានលើកឡើងច្បាស់លាស់នៅក្នុងកិច្ចដំណើរការនិតិវិធីក្តី ក៏អង្គហេតុទាំងនោះបង្កើតបានជាកាលៈទេសៈអង្គហេតុចំបង ដែលពួកវាមានទំនាក់ទំនងគ្នា និងដែលពួកវាមានលក្ខណៈពិសេស។"]។ Cass. Crim., ថ្ងៃទី២៤ ខែមេសា ឆ្នាំ២0១៣, No. 12-80.750, inédit ["lorsqu'une activité délictueuse consiste en une situation d'agissements identiques étroitement liés les uns aux autres qui se développent dans le temps, ces agissements forment une opération unique de sorte que le juge d'instruction est autorisé à informer sur l'ensemble de ces agissements alors même que l'acte de poursuite ne viserait que certains d'entre eux; en l'espèce, le juge d'instruction est saisi de l'ensemble des fausses écritures comptables qui sont le corollaire des faits d'abus de confiance aggravés et leur sont rattachés de manière indivisible" បកប្រែក្រៅផ្លូវការ៖ "ត្រង់ចំណុចដែលសកម្មភាពឧក្រិដ្ឋមានការប្រព្រឹត្តដូចគ្នាដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធ

អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ដែលមានជាលើកដំបូងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស.ច.ស ទទួលពិនិត្យទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតទាំងអស់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

65. ស.ព.អ បានប្ដឹងទៅ ស.ច.ស ចំពោះអង្គហេតុដែលពាក់ព័ន្ធនឹង (i) យោធាក្នុងកងពល ១៦៤ ដែលត្រូវ "បានគេចាប់ខ្លួនជាញឹកញាប់ និងតាមទំនើងចិត្ត និងពលកម្មដោយបង្ខំ" (ii) ការបោសសម្អាតនៅក្នុងកងពល១៦៤ (ជាអាទ៍ យោធា និងកម្មាភិបាលពីភូមិភាគបូព៌ា ក្រោមអនុលេខាឌឹម) រួមទាំង ការចាប់ខ្លួន និងការសម្លាប់ ហើយនឹង (iii) ការចាប់ខ្លួន និងការសម្លាប់ជនដែលគេបានកំណត់អត្តសញ្ញាណថាមានការជាប់ពាក់ព័ន្ធនឹងរបបចាស់[239]។ ស.ព.អ បានបញ្ជាក់ថា វត្តឥន្ទញ្ញាណ គឺជាទិសដៅតែមួយគត់នៅក្នុងតំបន់កំពង់សោមដែលអាចជាកន្លែងដែលគេបានយកពួកយោធាដែលត្រូវបានគេបោសសម្អាតក្នុងកងពល១៦៤ ទៅកាន់ទីនោះ[240]។ លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានប្ដឹងឱ្យ ស.ច.ស បើកកិច្ចស៊ើបសួរទៅលើតួនាទីរបស់កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យក្នុងការចាប់ខ្លួនអ្នកនេសាទវៀតណាម និងថៃ ឬជនបរទេស

ដែលបានធ្វើឡើងកន្លងមក ការប្រព្រឹត្តបែបនោះបង្កើតជាដំណើរការមួយ ហើយដូច្នេះវាអនុញ្ញាតឱ្យចៅក្រមស៊ើបសួរ ស៊ើបអង្កេតការប្រព្រឹត្តនោះទាំងមូល ទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពាក់ព័ន្ធតែមួយផ្នែកក្ដី ក្នុងន័យនេះ ចៅក្រមស៊ើបអង្កេតទទួលបានគ្រប់ឯកសាររឿងរ៉ាវក្លែងបន្លំទាំងអស់ ដែលទាក់ទងទៅនឹងការរំលោភបំពានធ្ងន់ធ្ងរនៃសេចក្ដីទុកចិត្ត និងមានទំនាក់ទំនងមិនអាចផ្ដាច់បានទៅនឹងវា"]។ *សូមមើលបន្ថែមទៀត* ឯកសារ **D134/1/10** សាលដីកា អ.ប.ជ លើពាក្យសុំមោឃភាពចំនួនពីរ កថាខណ្ឌ១៤, ១៩ (ចៅក្រម Beauvallet និង Bwana) ["ការស៊ើបអង្កេត [របស់ ស.ច.ស] ត្រូវកំណត់ព្រំដែនត្រឹមអង្គហេតុឧក្រិដ្ឋកម្មជាសក្ដានុពល ដែលកំណត់ដោយសហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែ ទន្ទឹមនឹងនោះ ចៅក្រមទទួលបន្ទុកក្នុងការបង្ហាញកាលៈទេសៈនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ជាពិសេសគឺបង្ហាញទីតាំងដែលឧក្រិដ្ឋកម្មនោះបានកើតឡើង។ [...] អវត្តមាននៃការបញ្ជាក់ច្បាស់លាស់អំពីអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [...] មិនគ្រប់គ្រាន់ដើម្បីកំណត់ថាតើ អង្គហេតុចោទប្រកាន់ថាត្រូវបានប្រព្រឹត្តនៅទីតាំងនោះ ឬជួនកាលអង្គហេតុដែលមិនដឹងត្រូវបានប្រព្រឹត្តនៅកន្លែងណាច្បាស់លាស់ នៅក្នុងកក្របខណ្ឌនៃដីកាសុំឱ្យស៊ើបអង្កេតហ្នឹង នោះទេ។ ដោយសង្ខេប ទីតាំងប្រព្រឹត្តជាកម្មទេសកាលកន្លែងរបស់អង្គហេតុ គឺមិនមែនអង្គហេតុផ្ទាល់នោះទេ។"]។ ឯកសារ **D165/2/26** សាលដីកា អ.ប.ជ លើពាក្យសុំមោឃភាពចំនួនប្រាំបួន កថាខណ្ឌ ១៥២ (ចៅក្រម Beauvallet និង Baik)។

[239] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥២-៥៤។

[240] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥៣។

ដទៃទៀតនៅលើសមុទ្រ និងជោគវាសនារបស់ពួកគេនាពេលក្រោយមក (ជាឧទាហរណ៍ ពលកម្មដោយបង្ខំ ការសម្លាប់ ឬការបញ្ជូនទៅ ស-២១)[241]។

66. ដូច្នេះ មានទំនាក់ទំនងច្បាស់លាស់មួយរវាងការបោសសម្អាតកងពល ១៦៤ និង *មន្ទីរសន្តិសុខទឹកសាប*។ មន្ទីរសន្តិសុខនេះ និងទីតាំងសម្លាប់មនុស្សដែលនៅជាប់គ្នានោះ ត្រូវបានប្រើប្រាស់ដោយកងពល ១៦៤ សម្រាប់ឃុំឃាំង "កសាង" និងសម្លាប់ទាហានខ្លួនឯង[242] ដូច្នេះវាស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរយ៉ាងច្បាស់ក្រឡែត ជាទីតាំងមួយនៃទីតាំង "បោសសម្អាតធំៗ"[243] នៃកងពល១៦៤[244]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានភ្ជាប់ឧបសម្ព័ន្ធបទសម្ភាសន៍មួយរបស់ ក.ស.ព ដែលបានបញ្ជាក់ថា ទឹកសាប គឺជាទីតាំងសម្លាប់មនុស្សមួយ[245]។ លើសពីនេះទៀត ជនបរទេសដែលត្រូវបានចាប់ខ្លួននៅលើសមុទ្រ ត្រូវបានគេយកទៅទឹកសាប ជាទីកន្លែងដែលពួកគេត្រូវបានឃុំខ្លួន បង្ខំឱ្យធ្វើការ សម្លាប់ចោល និង/ឬ បញ្ជូនទៅ ស-២១[246]។ អាស្រ័យហេតុនេះ ទឹកសាប គឺជាផ្នែកដ៏សំខាន់នៃអង្គហេតុពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ ចំការធ្លូរេន I ក៏ស្ថិតក្នុងអង្គហេតុដូចគ្នាទាំងនេះដែរ ដោយសារវាជាទីតាំងសម្លាប់មនុស្សមួយដែលត្រូវបានប្រើប្រាស់ដោយកងពល ១៦៤ ក្នុងគោលបំណងមួយចំនួន រួមទាំងសម្រាប់ជនបរទេសដែលគេបានចាប់ខ្លួនពីសមុទ្រ [247]។

---

[241] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥៩-៦១។

[242] *សូមមើល យោងខាងក្រោម,* កថាខណ្ឌ ៧៣-៧៥។

[243] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥៣។

[244] *សូមមើលផងដែរ* ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ១៨៩-២០០ (ចៅក្រម Beauvallet និង Baik)។ *សូមមើលបន្ថែម* ឯកសារ **D102/1** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យទាក់ទងនឹងមន្ទីរសន្តិសុខទឹកសាប, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤, កថាខណ្ឌ៣។ ឯកសារ **D165/2/15** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងអង្គសេចក្តីនៃពាក្យសុំរបស់ មាស មុត ឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលទាក់ទងនឹងទឹកសាប, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦។

[245] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កំណត់សំគាល់ជើងទំព័រ ២២៦ *យោង* ឯកសារ **D1.3.13.8** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព លើឈ្មោះ ប៉ែន សារិន, KH 00217562។

[246] *សូមមើល* យោងខាងក្រោម, កថាខណ្ឌ ៧៣-៧៥។

[247] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥៩-៦១។ *សូមមើលបន្ថែម* ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី២, កថាខណ្ឌ ៣៤-៣៤ (ចៅក្រម Beauvallet និង Bwana)។ ឯកសារ **D134/1/6** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេច[របស់ ស.ច.ស.អ]

67. ការឃុំឃាំង ការងារដោយបង្ខំ និងការសម្លាប់អ្នកនេសាទថៃ និងវៀតណាមនៅ*ភាម* ការដ្ឋាន និងទីតាំងសម្លាប់មនុស្សនានា[248] ក៏មានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅលើសមុទ្រដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យផងដែរ[249]។ លើសពីនេះទៀត *ការដ្ឋានតំបន់ភាម* រួមទាំង *កងកេង*[250] និង *បិតត្រាំង*[251] ក៏ស្ថិតក្នុងវិសាលភាពនៃការចោទប្រកាន់ក្នុងសំណុំរឿង00៣ ដែរ ពាក់ព័ន្ធនឹង “ការចាប់ខ្លួនជាញឹកញាប់ និងតាមទំនើងចិត្ត និងការងារដោយបង្ខំ” ចំពោះបុគ្គលិកយោធាក្នុងកងពល១៦៤[252] ដោយសារទាំងនេះគឺជាការដ្ឋានការងារដោយបង្ខំក្រោមសិទ្ធិអំណាចរបស់កងពល១៦៤[253] និងត្រូវបានប្រើប្រាស់ជាកន្លែងអប់រំ/កសាង

---

លើពាក្យសុំរបស់ មាស មុត ស្នើឱ្យ[អ.ប.ជ]ទទួលពិនិត្យនិងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ(“ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងពាក្យសុំសំណើសុំមោឃភាពចំនួនពីរ”), ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥, កថាខណ្ឌ២៣-២៧។ ឯកសារ **D47** ដីកាបញ្ជូនរឿងទៅពិនិត្យ, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ២, ៥-៦។ ឯកសារ **D47/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ ៦។ ឯកសារ **D54** ដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ឧបសម្ព័ន្ធ I, KH 00893723។

[248] *សូមមើល យោងខាងក្រោម,* កថាខណ្ឌ ៧៦-៧៨។

[249] ឯកសារ **D1** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ៥៩-៦១។ *សូមមើលបន្ថែម* ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ២០៧-២១១, ២១៤។

[250] *សូមមើលបន្ថែម* ឯកសារ **D165/2/16** ចម្លើយតប[របស់ ស.ព.អ] លើអង្គសេចក្តីនៃពាក្យសុំរបស់ មាស មុត ឱ្យប្តឹងទៅ[អ.ប.ជ]អំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលទាក់ទងនឹងការដ្ឋានពលកម្មដោយបង្ខំ និងមន្ទីរអប់រំកែប្រែ កងកេង, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦។ ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ១៧៥-១៨៤ (ចៅក្រម Beauvallet និង Baik)។ ឯកសារ **D47/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ ៨។

[251] *សូមមើលបន្ថែម* ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី២, កថាខណ្ឌ ៣៥-៤៦ (ចៅក្រម Beauvallet និង Bwana)។ ឯកសារ **D134/1/6** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងពាក្យសុំមោឃភាពចំនួនពីរ”), ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥, កថាខណ្ឌ២៣, ២៨-៣៣។ ឯកសារ **D47** ដីកាបញ្ជូនរឿងទៅពិនិត្យ, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ២, ៥, ៧។ ឯកសារ **D47/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ ៧-៨។ ឯកសារ **D54** ដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ឧបសម្ព័ន្ធ I, KH 00893723 *យោង* ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥២, ៨៦(ក)។

[252] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥២។ *សូមមើលបន្ថែម* ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ២១២-២១៤។

[253] *សូមមើល យោងខាងក្រោម* កថាខណ្ឌ ៧៦។

បុគ្គលផ្សេងៗ រួមទាំង "សមាសធាតុមិនល្អ" របស់កងពល ១៦៤ ផង[254]។ កំណត់ហេតុនៃកិច្ចប្រជុំខ្លះរបស់កងពលយោធា ១៦៤ ដែលគាំទ្រការលើកឡើងដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថា មាស មុត បានរាយការណ៍អំពីការចាប់ខ្លួនខ្មាំងផ្ទៃក្នុង បានហៅកងកេងថាជាតំបន់ចាប់ខ្លួនកងទ័ពដោយកងពល១៦៤[255]។ ដោយហេតុថា ចំការធូរនេ I, ចំការធូរនេ II (ដែលគេស្គាល់ដែរថាជា ចំការធូរនេអូរត្រាវ) និងបន្ទាយសេអ៊ី (Centre d'Instruction ("C.I.")) ត្រូវបានគេប្រើជាទីតាំងសម្លាប់ពួកកម្មករធ្វើការដោយបង្ខំនៅរាម[256] ដូច្នេះ ទីតាំងទាំងនេះមានទំនាក់ទំនងទៅនឹងប្រតិបត្តិការទីតាំងទាំងនេះ។

68. *ការបោសសម្អាតតាមបណ្តាកងពលដទៃទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា ៖* ស.ព.អ បានប្តឹងទៅ ស.ច.ស អំពីការបោសសម្អាតកងពលមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា កងវរៈសេនាធំឯករាជ្យ និងសមាជិកនៃអគ្គសេនាធិការទាំងអស់ រួមទាំងបុគ្គលិកយោធាដែលត្រូវបានបញ្ជូនទៅ ស-២១ ពីកងពល១៦៤ កងពល៥០២ និងកងពល ៣១០[257]។ ដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងអ្នកទោសរបស់កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់នោះ តាមរយៈការរួមចំណែករបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មក្នុងការបោសសម្អាតខ្មាំង និងជនក្បត់ពីបណ្តាកងពលរបស់កងទ័ពបដិវត្តន៍កម្ពុជាដែលបានរាយការណ៍ទៅអគ្គសេនាធិការ[258]។ ការបោសសម្អាតកងពល៣១០ និងជាទូទៅ ៥០២ ត្រូវបានបញ្ជាក់បន្ថែមទៀតនៅក្នុងកថាខណ្ឌ ៤៤-៥១ និង៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[259]។ ស.ច.ស ក៏ទទួលពិនិត្យ[260] ទៅលើការបោសសម្អាតកងពល១១៧ នៅចុងឆ្នាំ១៩៧៨ ផង

[254] *សូមមើល យោងខាងក្រោម* កថាខណ្ឌ ៧៦-៧៧។

[255] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៥២, កំណត់សំគាល់ជើងទំព័រ ២១៦ *លើកយោង* ឯកសារ **D1.3.8.4** កំណត់ហេតុនៃកិច្ចប្រជុំរបស់យោធា, ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦។

[256] *សូមមើល យោងខាងក្រោម* កថាខណ្ឌ ៧៧-៧៨។

[257] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៤៣, ៦៥-៦៦។

[258] ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៤៣, *ដោយបង្រួបបង្រួមតាមរយៈសេចក្តីយោង* កថាខណ្ឌ ៣៣-៤១។

[259] *សូមមើលជាពិសេស* ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៤៥ ["បុគ្គលិកកងពលលេខ ៥០២ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការភ័យខ្លាចជានិច្ចអំពីការចាប់ខ្លួន ឬយកទៅសម្លាប់។ [...] អ្នកដែលបានប្រព្រឹត្តកំហុស នឹងត្រូវបានចាប់ខ្លួន។ [...] អ្នកដែលត្រូវបានគេចាប់ខ្លួនមិនបានត្រឡប់មកវិញឡើយ។ បុគ្គលិកដែលត្រូវបានចោទប្រកាន់ថាជាប់ខ្សែក្បត់ត្រូវបានបញ្ជូនចេញ។ [ពួកគេ]ជាច្រើននាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដើម្បីសម្លាប់។ [...] ការបោសសម្អាតនៅក្នុងកងពលបាន

ដែរ ដោយសារវាជាកងពលមជ្ឈិមដែលរាយការណ៍ផ្ទាល់ទៅអគ្គសេនាធិការ[261]។ តាមពិត បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បានរាយឈ្មោះអ្នកជាប់ឃុំឃាំងពីកងពល ១១៧[262]។ បញ្ជីនេះក៏កត់ត្រាឈ្មោះកម្មាភិបាលដែលត្រូវបានបោសសម្អាតពីតំបន់ ៥០៥ នៅចុងឆ្នាំ ១៩៧៨ ដែរ[263]។ ការបោសសម្អាតកម្មាភិបាលតំបន់៥០៥ គឺជាផ្នែកមួយនៃប្រតិបត្តិការដូចគ្នានឹងការបោសសម្អាតដែលបានធ្វើឡើងចំពោះកងពល ១១៧ ផងដែរ ហើយការបោសសម្អាតទាំងពីរជាប់ពាក់ព័ន្ធគ្នាជៀសមិនផុត[264]។

---

បន្ត"], កថាខណ្ឌ ៤៩ [និយាយអំពីការរីកចម្រើននៃ "ការបោសសម្អាតកងពលធំលេខ ៣១០"], កថាខណ្ឌ ៦៦ ["ការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជាក៏ត្រូវបានធ្វើឡើងនៅទីតាំងខុក្រិដ្ឋកម្មផ្សេងទៀតផងដែរ"]។

260 គេច្បាស់ណាស់តាមរយៈពាក្យថា "រួមទាំង" នៅក្នុង ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កថាខណ្ឌ ៤៣ ថា បណ្ដាកងពលធំដែលបានរាយឈ្មោះទាំងនោះមិនទាន់អស់នៅឡើយទេ ដូច្នេះវាស្ថិតលើ ស.ច.ស ដែលត្រូវកំណត់អត្តសញ្ញាណកងពល"ស្រួច"របស់កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់។ *សូមមើលបន្ថែម* ឯកសារ **D165/2/17** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងអង្គសេចក្ដីនៃពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងទៅអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរ និងការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការបោសសម្អាតនៅក្នុងខេត្តក្រចេះ (តំបន់ ៥០៥) នៅចុងឆ្នាំ១៩៧៨, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦។ *សូមមើលផងដែរ* ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ១៥៦-១៦៥ (ចៅក្រម Beauvallet និង Baik)។

261 បន្ទាប់ពីការបង្កើតសាខាមួយរបស់កងពលធំលេខ១ នៅលង្វែក កងពលធំ ១១៧ ត្រូវបានបញ្ជូនទៅក្រចេះ ដោយបានដាក់ឲ្យនៅក្រោមការត្រួតត្រារបស់សេនាធិការ។ *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨៥៦។

262 *សូមមើលជាឧទាហរណ៍* ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កំណត់សំគាល់ជើងទំព័រ ១៤១ *លើកយោង* ឯកសារ **D1.3.33.1** បញ្ជីរួមអ្នកទោស ស-២១, KH 00171540 [ឃុន សារ៉ុម (ឃុន រ៉ុម), កងពលធំ ១១៧, លេខា, ថ្ងៃចូល ០៨-១២-៧៨]; KH 00171675 [វ៉ត លាង (វ័ត្ត លាង), អនុលេខាកងពល ១១៧, ថ្ងៃចូល ០១-១២-៧៨]; KH 00171737 [ស្វាយ ណូញ, ប្រធានមន្ទីរកងពល ១១៧, ថ្ងៃចូល ២៩-១១-៧៨]។

263 ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កំណត់សំគាល់ជើងទំព័រ ១៤១ *លើកយោង* ឯកសារ **D1.3.33.1** បញ្ជីរួមអ្នកទោស ស-២១, KH 00171461 (ឈឹម ខុន, អនុលេខាតំបន់ក្រចេះ។ តាមរយៈ ឯកសារ **D1.3.28.137** បញ្ជីអ្នកទោស ស-២១, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, KH 00086822 (លេខរៀងទី៤), ឈឹម ខុន ចូលស-២១ នៅថ្ងៃទី ២-១២-៧៨); ឯកសារ **D1.3.33.1** បញ្ជីរួមអ្នកទោស ស-២១, KH 00171595 (មាស មឿន, ថ្ងៃចូល ស-២១ ៨-១២-៧៨។ តាមរយៈ ឯកសារ **D1.3.28.137** បញ្ជីអ្នកទោស ស-២១, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, KH 00758337 (លេខរៀងទី១៥), មាស មឿន គឺជាលេខាតំបន់ ៥០៥)។

264 ទោះបីកាន់មុខតំណែងដូចជាស៊ីវិលនៅពេលនោះ កម្មាភិបាលជាន់ខ្ពស់នៃតំបន់ ៥០៥ ដែលត្រូវបានបោសសម្អាតនៅចុងឆ្នាំ ១៩៧៨ រួមមាន លេខាតំបន់ មាស មឿន, លេខាស្រុកក្រចេះ ហ៊ួន យ៉េង និងលេខាស្រុកស្នួល ឈុំ ជីន *ហៅ* ភ័ណ្ឌ គឺសុទ្ធតែជាកម្មាភិបាលយោធានៃកងទ័ពបដិវត្តន៍កម្ពុជា អ្នកខ្លះមកពីកងពល ១១៧ ផ្ទាល់តែម្ដង ហើយបុគ្គលម្នាក់ៗទាំងនេះ សុទ្ធតែមានការពាក់ព័ន្ធក្នុងការប្រយុទ្ធនៅតាមព្រំដែនជាមួយវៀតណាម ជាមួយនឹងកម្មាភិបាលយោធានៃកងពល១១៧។ *សូមមើល* ឯកសារ

69. មន្ទិលណាមួយទៅលើថាតើទីតាំង និងហេតុការណ៍ឧក្រិដ្ឋកម្មទាំងនេះ ស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែរឬទេនោះ ត្រូវបានដោះស្រាយ នៅពេលដែល ស.ច.ស.អ បានបំភ្លឺពីវិសាលភាពនៃសំណុំរឿង ០០៣ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[265]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក៏បានដាក់អង្គហេតុមួយចំនួនទៅ ស.ច.ស ឱ្យពិនិត្យពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ដោយសារតែការបង្ខំឱ្យការរួមសង្វាស[266]។

## *ឧក្រិដ្ឋកម្មទាំងនេះបង្កើនភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែល មាស មុត ទទួលខុសត្រូវ*

70. ទំហំ វិសាលភាព និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែល មាស មុត ទទួលខុសត្រូវ មានច្រើនជាងអ្វីដែលដីកាសម្រេចលើកលែងចោទប្រកាន់បានកំណត់។ គេមិនអាចវាយតម្លៃទៅលើការទទួលខុសត្រូវរបស់គាត់ ដោយមិនបានពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើតួនាទីរបស់ មាស មុត

**D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨៥៥, ៨៥៨។ លើសពីនេះ ការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់កងពល ១១៧ និងជនស៊ីវិលតំបន់៥០៥ គឺកើតឡើងក្នុងពេលដំណាលគ្នា ត្រូវបានជុំរុញទឹកចិត្តដោយគោលគំនិតដូចគ្នាគឺអំពើក្បត់ ក្រោយកងទ័ពបរាជ័យក្នុងការប្រយុទ្ធជាមួយវៀតណាម។ អ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានបញ្ជូនទៅស-២១ ជាមួយគ្នា ហើយការប្រជុំដែលបានកោះហៅដោយ មាស មុត នៅពេលការបោសសម្អាតកំពុងតែដំណើរការ ត្រូវបានធ្វើឡើងទាំងផ្នែកយោធា និងទាំងស៊ីវិល។ *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨៥៩-៨៨៣។ *សូមមើលបន្ថែម* ឯកសារ **D165/2/17** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងអង្គសេចក្ដីនៃពាក្យសុំរបស់ មាស មុត ឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរ និងការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការបោសសម្អាតនៅក្នុងខេត្តក្រចេះ (តំបន់ ៥០៥) នៅចុងឆ្នាំ១៩៧៨, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦។ *សូមមើលផងដែរ* ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើពាក្យសុំមោឃភាពលើកទី៩, កថាខណ្ឌ ១៦៦-១៧០ (ចៅក្រម Beauvallet និង Baik)។

[265] វិធាន៥៣, វិធាន៥៥(៣) នៃវិធានផ្ទៃក្នុង។ ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម, កថាខណ្ឌ៦ (ចំការធូរេន I និងបិតត្រាំង), កថាខណ្ឌ ៧-៩ (កងកេង និង ចំការទុរេន II), កថាខណ្ឌ ១០-១១ (ទឹកសាប), កថាខណ្ឌ ១២-១៤ (ការបោសសម្អាតកម្មាភិបាលកងពល ១១៧ និង តំបន់ ៥០៥ នៅក្រចេះ នៅចុងឆ្នាំ១៩៧៨), កថាខណ្ឌ ១៥-១៩ (ការដ្ឋានសហករណ៍ និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធតំបន់ រាម)។ ស.ព.អ កត់សំគាល់ឃើញថា ខណៈដែល មាស មុត ស្វែងរកការធ្វើមោឃភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនេះ ចៅក្រម អ.ប.ជ ខកខានមិនអាចឈានដល់មតិភាគច្រើនទេ ដូច្នេះហើយសុពលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមក៏ត្រូវបានតម្កល់។ *សូមមើល* ឯកសារ **D120/3/1/8** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

[266] ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម, កថាខណ្ឌ ២០-២៤។

នៅក្នុងឧក្រិដ្ឋកម្មនានាប្រឆាំងនឹងជនដែលគេបានចាប់ខ្លួនពីសមុទ្រ បុគ្គលិកយោធានៃកងទ័ពបដិវត្តន៍កម្ពុជា និងជនស៊ីវិលក្រោមការត្រួតត្រារបស់គាត់នៅក្នុងតំបន់កំពង់សោមនោះឡើយ។ ភាពអាក្រក់នៃអំពើប្រព្រឹត្តរបស់ មាស មុត និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់គាត់ អាចនឹងបង្ហាញនៅពេលពិចារណាថា គាត់ [មាស មុត] បានចូលរួមចំណែកយ៉ាងច្រើនទៅឧក្រិដ្ឋកម្មដ៏ធំនៅក្នុងរយៈពេលយ៉ាងយូរ និងនៅទីកន្លែងជាច្រើន[267]។

71. *<u>អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ</u>* ៖ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានក្នុងការពិចារណាអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (ការរួមសង្វាសដោយបង្ខំ) ដែលជាផ្នែកមួយនៃទង្វើល្មើសរបស់ មាស មុត។ ក្នុងការអនុវត្តគោលនយោបាយរបស់ បកក ដើម្បីបង្កើនចំនួនប្រជាជននៅតំបន់កំពង់សោម ការរៀបការត្រូវបានរៀបចំឡើងយ៉ាងទៀងទាត់សម្រាប់ទាំងបុគ្គលិកយោធា និងជនស៊ីវិល ចាប់តាំងពីចុងឆ្នាំ១៩៧៥ រហូតដល់ចប់បញ្ចប់នៃរបបនេះ[268]។ ស្ត្រី រួមទាំងស្ត្រីជាច្រើននាក់ទៀតមកពីកងវរៈសេនាតូចនារីនៃកងពល ១៦៤[269] និងជនស៊ីវិល[270] ត្រូវបានបង្ខំឲ្យរៀបការជាមួយយុទ្ធជន/យុទ្ធនារីកងពល១៦៤[271]។ អាពាហ៍ពិពាហ៍បានធ្វើឡើងក្នុងកាលៈទេសៈបង្ខិតបង្ខំ ដែលការព្រមព្រៀងពិតប្រាកដរបស់បុគ្គលម្នាក់ៗមិនអាចមានបានទេ[272]។ ជនដែលត្រូវបានជ្រើសរើសសម្រាប់ការរៀបការទាំងនេះ ជាញឹកញាប់ តែងមានការភ័យខ្លាចពីផលវិបាកផ្សេងៗដែលអាចកើតពីការបដិសេធ[273]។ អ្នកខ្លះដែលមិនព្រមរៀបការត្រូវបានគំរាមកំហែង និងធ្វើទណ្ឌកម្ម[274]។ ការរៀបការមួយលើកអាចមានរហូត

---

[267] ការចូលរួមប្រព្រឹត្តនៅក្នុងឧក្រិដ្ឋកម្មទាំងនេះរបស់ មាស មុត ក៏បានលើកយកមកពិភាក្សានៅកន្លែងផ្សេងទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍នេះផងដែរ។ *សូមមើល យោងខាងក្រោម* កថាខណ្ឌ ២៨-៣២, ៩៦, ៩៨-១០៧, ១២១-១៣៤។

[268] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៩៨-២០១, ២០៥, ៧៩៩, ៨០០-៨២០, ៨២២-៨២៦ និងកំណត់សំគាល់ជើងទំព័រ ៣៣២៩-៣៣៣១។

[269] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨២៧។

[270] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨២១, ៨២៧។

[271] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨២៧-៨២៩។

[272] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨១៤-៨១៧, ២០៤-២០៥, ៨២៣, ៨២៧, ៨២៩-៨៣០, ៨៣៥, ៨៣៧។

[273] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨២៧, ៨៣៥-៨៣៧។

[274] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ២០៣, ៨៣៦, ៨៣៨[*សូមមើលផងដែរ*កថាខណ្ឌ ៨១៧]។

ដល់ទៅ ៧១ គូ[275]។ ការរៀបការធ្វើឡើងដោយមិនបានធ្វើតាមប្រពៃណីរបស់ប្រជាជនកម្ពុជាទេ។ ជាញឹកញាប់ គ្មានវត្តមានរបស់ក្រុមគ្រួសារទេ ហើយគូស្រករភាគច្រើនត្រូវបានគេរៀបការដោយគ្មានការជូនដំណឹងជាមុន ឬមានការជូនដំណឹងតិចតួចប៉ុណ្ណោះ[276]។ អាចថា មានមនុស្សរាប់រយនាក់ត្រូវបានគេបង្ខំឲ្យរៀបការនៅតំបន់កំពង់សោម ក្រោមការត្រួតត្រារបស់ មាស មុត[277]។

72. អ្នកដែលត្រូវបានគេបង្ខំឲ្យរៀបការ បន្ទាប់ពីបានរៀបការហើយ ត្រូវបានគេរំពឹងថា ឬត្រូវបានគេបង្ខំឲ្យរួមសង្វាសជាមួយគ្នា[278]។ ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ទទួលរងការប៉ះទង្គិចធ្ងន់ធ្ងរជាច្រើនទម្រង់[279]។ ទង្វើនេះគួរត្រូវបានកំណត់បទចោទថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ)[280]។

73. *<u>មន្ទីរសន្តិសុខទឹកសាប:</u>* ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានក្នុងការពិចារណាទៅលើការទទួលខុសត្រូវរបស់មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅមន្ទីរសន្តិសុខទឹកសាប[281]។ ភ័ស្តុតាងដែលថា មានអ្នកទោសជាង ១,000 នាក់ ត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្ត និង/ឬត្រូវបានសម្លាប់ចោលភ្លាមៗនៅទីតាំងនេះ[282] រួមទាំង (i) យុទ្ធជន/យុទ្ធនារីដែលត្រូវបានដកចេញពីកងពល១៦៤[283] (ii) អតីតយុទ្ធនារី/យុទ្ធនារីរបស់ លន់ នល់ ដែលបានចុះចូលក្នុងខែមេសា

---

[275] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ២០៥, ៨២៦។

[276] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨២៦, ៨៣២-៨៣៣, ៨២៨[*សូមមើលផងដែរ* កថាខណ្ឌ ៨00, ៨១៨]។

[277] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ២០៥, ១០៩១។

[278] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨៣៩-៨៤២ [*សូមមើលផងដែរ* កថាខណ្ឌ ៨១៨]។

[279] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៨៤៣។

[280] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ១១៣៦។

[281] ទឹកសាប គឺជាមន្ទីរសន្តិសុខមួយរបស់កងពល ១៦៤ និងជាទីតាំងសម្លាប់មនុស្សនៅក្នុងតំបន់កំពង់សោម ដែលបានគ្រប់គ្រងដោយកងវរៈសេនាធំ ៦៣ យ៉ាងហោចណាស់ក៏ចាប់តាំងពីពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ១៩៧៥ រហូតដល់ចុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៦៥, ១៥៨, ២៣៧, ៤៨១-៤៨៨។

[282] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ១៥៩, ៤៣៨-៤៤០, ៤៩២, ៥០៣-៥០៥, ៥១៩។

[283] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤២, ៣៤៦, ៣៥៤, ៣៦៤, ៣៦៦, ៤៩៥-៤៩៦។

ឆ្នាំ១៩៧៥[284] (iii) ជនស៊ីវិលពីតំបន់កំពង់សោមដែលគេបានចាត់ទុកថា "ខ្មាំង" របស់បដិវត្តន៍[285] រួមទាំងប្រជាជន ១៧ មេសា និងជនស៊ីវិលខ្មែរក្រោម[286] និង (iv) ជនជាតិវៀតណាម ថៃ និងជនបរទេសដទៃទៀតដែលត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[287]។ ជនរងគ្រោះខ្លះគឺជាកុមារ[288]។ គុកធំដាក់អ្នកទោសបានរហូតដល់ ១០០ នាក់ ក្នុងមួយពេល ហើយមានអ្នកទោស ៦០ នាក់ បន្ថែមទៀតត្រូវបានគេឃុំនៅរោងអារឈើ[289]។

74. អ្នកទោសទទួលរងការឈឺចាប់ពីលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ។ អ្នកទោសភាគច្រើនត្រូវបានគេដាក់ខ្នោះដៃ និងខ្នោះជើង[290]។ អ្នកទោសជាច្រើនត្រូវបានបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌលំបាក ទាំងជាប់ច្រវាក់ ឬត្រូវបានចងខ្សែដោយចោះត្រចៀក[291]។ អ្នកជាប់ឃុំឃាំងមិនមានអាហារគ្រប់គ្រាន់ត្រូវគេធ្វើទារុណកម្ម និងទទួលរងការប៉ះទង្គិចធ្ងន់ធ្ងរផ្នែករាងកាយ និងផ្លូវចិត្ត[292]។ មានភស្តុតាងច្រើនលើសលប់ថា អ្នកទោសភាគច្រើនត្រូវបានគេសម្លាប់។ អ្នកទោសរាប់រយនាក់ត្រូវបានគេយកទៅទឹកសាប ហើយក៏បាត់ខ្លួនតែម្តង[293] ហើយមានសាកសពយ៉ាងហោចណាស់មួយពាន់ត្រូវបានគេរកឃើញនៅចំការក្បែរនោះ ដោយសាកសពខ្លះត្រូវបានគេកប់ធ្វើជាជីសម្រាប់ដើមធូរេន[294]។

75. សកម្មភាពទាំងនេះគួរត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗ

[284] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៩៩។

[285] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៩៧, ៧១៤។

[286] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៩៨, ៧១១-៧១៣។

[287] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៤៦, ៣៤៧, ៣៦៤, ៤១០, ៤១២, ៤២៥, ៤២៧-៤៣០, ៤៨៥, ៤៩១, ៥០០-៥០១, ៥២៣។

[288] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥០២, ៥២២។

[289] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥០៣។

[290] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥០៦។

[291] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥០៦, ៥០៩-៥១១។

[292] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៦៤, ៥០៧-៥០៨, ៥១១-៥១៥។

[293] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥១៦, ៥១៨-៥២០។

[294] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥០៥, ៥២០-៥២២។

ទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ (ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា និងការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព)[295]។

76. *ការដ្ឋាន និងទីតាំងសម្លាប់មនុស្សតំបន់រាម ៖* ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានលើកឡើងពីអង្គហេតុនានានៅការដ្ឋាន និងសហករណ៍ផ្សេងៗរបស់កងពល ១៦៤[296] នៅក្នុងតំបន់រាមជាទីកន្លែងដែលទាហាន និងជនស៊ីវិលរាប់ពាន់នាក់ត្រូវបានគេធ្វើឲ្យទៅជាទាសករ[297]។ កម្មករមកពីខាងកងទ័ព ភាគច្រើនជាកម្មាភិបាលដែលត្រូវដកចេញពីកងពល ១៦៤[298] ហើយជនស៊ីវិលរួមទាំងកុមារ និងមនុស្សចាស់[299] គឺជាអ្នកនេសាទថៃដែលត្រូវបានចាប់ខ្លួននៅលើសមុទ្រ គ្រួសារទាហាន ប្រជាជន ១៧ មេសា អ្នកស្រុកមូលដ្ឋាន ខ្មែរក្រោម និងប្រជាជនភូមិភាគបូព៌ា[300]។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៦ មាស មុត បានរាយការណ៍ថា មនុស្ស ១៧,០០០ នាក់ បានចូលរួមក្នុងការងារបង្កបង្កើនផលនៅតំបន់កំពង់សោម[301]។

---

[295] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ១១៣៦។

[296] ការដ្ឋាន និងទីតាំងសម្លាប់មនុស្សតំបន់រាម ត្រូវបានគ្រប់គ្រងដោយកងវរៈសេនាធំ ៦៣ នៅទូទាំងរបបនេះ ដោយមានកងវរៈសេនាតូច ៦២ នៅឈរជើងក្បែរឆ្នេរសមុទ្ររាម ដែលមានមុខងារទទួលអ្នកទោសដែលចាប់បានពីបណ្ដាកោះនានា និងនៅលើសមុទ្រ។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ២៣៧-២៤១, ៣៣៧-៣៣៨, ៦៦២-៦៦៦, ៦៦៨, ៦៧២-៦៧៣, ៧១៨។ សម្រាប់សេចក្ដីលម្អិតអំពីទីតាំងទាំងនេះ *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ៦៤៩-៦៦១, ៦៧៦-៦៧៧។

[297] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ១៨៧, ៦៤៩។

[298] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤២, ៣៤៥, ៣៥៣, ៣៦០, ៣៦៦, ៦៧០, ៦៧៤, ៦៨០-៦៨៨ [ជាឧទាហរណ៍ អតីតកងវរៈសេនាតូច ៣៨៦ នៅក្រោម ឆាន់, អ្នកដែល"ជាប់ពាក់ព័ន្ធ" ជាមួយរបប លន់ នល់, ទាហានដែលចាប់ខ្លួនបាននិងដោះលែងដោយវៀតណាម, ខ្សែ"បូព៌ា"នៅក្រោម ឌឹម, ឬអ្នកផ្សេងទៀតដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើស]។

[299] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ៦៧៤, ៦៨២, ៧១១, ៧៣០។

[300] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ៣៩៧, ៦៧១, ៦៧៤, ៦៨៨-៦៨៩, ៦៩៩-៧០១។

[301] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ពាពររបស់ ស.ព.អ, កថាខណ្ឌ ៦៥៦, ៦៧៤-៦៧៥។ ខណៈដែល ស.ព.អ មិនបានសន្និដ្ឋានថា ពួកគេទាំងអស់នេះសុទ្ធតែមានមូលដ្ឋាននៅតំបន់រាមក៏ពិតមែន គាត់កត់សំគាល់ថា កន្លែងនេះតំបន់ផលិតស្រូវជាចំបងនៅក្នុង

77. កម្មករត្រូវបានបង្ខំឱ្យធ្វើការឱ្យគ្រប់តាមផែនការកំណត់ហួសហេតុ និងគ្មានសិទ្ធិសេរីភាពក្នុងការដើរហើរ[302]។ លក្ខខណ្ឌការងារ និងការរស់នៅ មានលក្ខណៈអមនុស្សធម៌[303]។ អ្នកខ្លះដែលធ្លាក់ខ្លួនឈឺ ឬអ្នកដែលចាត់ទុកថា ខ្ជិល ឬមិនអាចបំពេញតាមផែនការកំណត់របស់ខ្លួន ឬអ្នកដែលបានប្រព្រឹត្ត"កំហុស"ផ្សេងទៀត ត្រូវបានគេវាយដំ ឬបង្ខំឱ្យធ្វើការកាន់តែខ្លាំងឡើងថែមទៀត[304]។ ការធ្វើការងារហួសកម្លាំង រាងកាយចុះស្គមរីងរៃ មានជំងឺជាប្រចាំ ដំណេកមិនគ្រប់គ្រាន់ បានធ្វើឱ្យមនុស្សជាច្រើនមិនហ៊ានតវ៉ាទេដោយសារតែខ្លាចការដាក់ទណ្ឌកម្ម[305]។ កម្មករបានស្លាប់ដោយសារតែការងារលើសកម្លាំង ការបង្អត់អាហារ និងជំងឺ[306]។ អ្នកដែលត្រូវបានគេចោទថាបានប្រព្រឹត្ត 'បទល្មើស' ត្រូវបានបញ្ជូនទៅស្នឹងហាវ ទឹកសាប ចំការធូរេន I ឬចំការធូរេន II បន្ទាយសេអ៊ី ឬ ស-២១[307]។ ប្រជាជន ១៧ មេសាជាច្រើន[308] អ្នកដែលគេចាត់ទុកថាជា "ភ្នាក់ងារ លន់ នល់"[309] យោធាដែលគេបានដកចេញពីកងពល ១៦៤[310] និងខ្មែរក្រោម[311] បានបាត់ខ្លួន ហើយមិនដែលបានជួបទៀតឡើយ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីជាច្រើនបានឃើញរណ្តៅសាកសព និងរណ្តៅសាកសពរួម ដែលមានសាកសព ឆ្អឹង លលាដ៏ក្បាល និងសម្លៀកបំពាក់នៅរាយប៉ាយនៅលើទីតាំងសម្លាប់មនុស្សនានា[312]។ អំពើទាំងនេះគួរត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ

---

តំបន់កំពង់សោម និងថា ចំនួននេះគឺជាការបង្ហាញអំពីទំហំនៃចំនួនមនុស្សដែលបានត្រូវគេធ្វើឱ្យទៅជាទាសករនៅក្នុងតំបន់នេះ។ [*សូមមើលផងដែរ* កថាខណ្ឌ ១៨០, ៣៤១, ៤៦៨]។

[302] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៧៦-៦៨០។

[303] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៨៧, ៦៧៩-៦៨៥, ៧២៧-៧៣៥។ [long hours of work without breaks, insufficient food, and punished with even smaller rations if they could not work].

[304] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៨២, ៦៨៤, ៧៣១-៧៣២។

[305] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៨៤-៦៨៥, ៧៣០។

[306] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧២៧-៧២៨។

[307] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៥៤, ៦៧៩, ៦៨២-៦៨៥, ៧០២-៧០៤, ៧១៤-៧១៦, ៧១៩-៧២៥, ៧៣៣។ សូមមើលសេចក្តីពិស្តារបន្ថែមទាក់ទងនឹងទីតាំងសម្លាប់មនុស្សចំការធូរេន II និង បន្ទាយ សេងអ៊ី *សូមមើល* កថាខណ្ឌ ៦៦០ (ចំការធូរេន II), ៦៦១ (បន្ទាយ សេអ៊ី)។

[308] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧០៥, ៧១៦, ៧២២, ៧២៤។

[309] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧០៦។

[310] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧២៤។

[311] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧០៧-៧១៦។

[312] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧១៧-៧១៨, ៧២៣, ៧២៦។

អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[313]។

78. *ចំការធ្លូរេន I:* ដីកាសម្រេចលើកលែងចោទប្រកាន់ ខកខានមិនបានសន្និដ្ឋានអំពីទីតាំងសម្លាប់មនុស្ស"ចំការធ្លូរេន I"[314] ដែលត្រូវបានប្រើជាទីតាំងសម្លាប់មនុស្សដែលគេយកពីការដ្ឋានតំបន់រាម និងជនបរទេសដែលរួមមានថៃ និងវៀតណាម ដែលត្រូវបានចាប់ខ្លួននៅលើសមុទ្រដោយកងទ័ពបដិវត្តន៍កម្ពុជា[315]។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ មានសាក្សីជាច្រើនបានឃើញរណ្ដៅសាកសព និងផ្នូរខ្មោច និងសាកសពដែលគេកប់នៅក្រោមដើមធ្លូរេនដើម្បីធ្វើជី[316]។ ចំនួនអ្នកស្លាប់អាចដល់រាប់រយនាក់[317]។ អង្គហេតុទាំងអស់នេះគួរត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ហើយនឹងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ (ការធ្វើមនុស្សឃាតដោយចេតនា)[318]។

79. *ការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា ៖ ក្រចេះ (កងពល១១៧ និងតំបន់ ៥០៥):* មាស មុត ត្រូវបានចាត់តាំងឲ្យដឹកនាំការបោសសម្អាតនៅក្រចេះចំពោះពួកមន្ត្រីថ្នាក់ខ្ពស់នៅក្នុងកងពល១១៧ និងតំបន់ ៥០៥ នៅក្រចេះ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៨ និងកម្មាភិបាលយោធាថ្នាក់ទាប និងជនស៊ីវិលដែលត្រូវបានចោទថាក្បត់[319]។ ក្នុងអំឡុងពេលបោសសម្អាតនេះ យ៉ាងហោចណាស់ក៏មានមនុស្ស ៣២ នាក់ដែរ ដែលត្រូវបានបញ្ជូនមកភ្នំពេញ និងសម្លាប់ចោលនាពេលក្រោយមក[320]។ អ្នកផ្សេងៗទៀតត្រូវបានគេឃុំនៅផ្សារពោធិ៍ចិនតុងនៅភ្នំពេញ ឬតាមបណ្ដាមន្ទីរសន្តិសុខក្នុងខេត្ត

---

313 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១១៣៦។

314 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៥៨-៦៥៩, ៧១៨។

315 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៥៩, ៧១៦។

316 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧១៧-៧១៨។

317 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៧១៦-៧១៨។ *សូមមើលផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ២៦៧។

318 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១១៣៦។

319 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១២០-១២៤, ៨៦០-៨៦៨, ៨៧៦។

320 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៥០-៥៥១, ៨៦១, ៨៦៨-៨៦៩។

ក្រចេះ ឬ"បានបាត់ខ្លួនរហូតមក"[321]។ លើសពីនេះទៀត មាស មុត បានបញ្ជាឲ្យសម្លាប់ដោយចេតនាចំពោះកម្មាភិបាលយោធាតំបន់ឈ្មោះ ម៉ៅ អឿន ដោយផ្ទាល់[322]។ យោធាមួយក្រុមមានគ្នា ១១នាក់ មកពី កងពល១១៧ បានចាប់ខ្លួន និងត្រូវសម្លាប់ចោលនៅចុងរបបនេះ ដោយចោទថាក្បត់[323] ហើយកម្មាភិបាលជាន់ខ្ពស់ជាច្រើននាក់ផ្សេងទៀត រួមទាំងយោធាពី ១០-២០ នាក់ នៅក្នុងកងវរៈសេនាធំ១៧ នៃកងពល១១៧ ត្រូវបានគេហៅឲ្យទៅរៀនសូត្រ ហើយក៏បាត់ខ្លួនរហូត[324]។

80. *<u>កងពល៥០២ និង៣១០៖</u>*[325] ដីកាសម្រេចលើកលែងចោទប្រកាន់ ខកខានក្នុងការពិចារណាទៅលើតួនាទីរបស់ មាស មុត ក្នុងការបោសសម្អាតកងពល៥០២ និង ៣១០ នៅក្នុងសេចក្តីសម្រេចស្តីពីយុត្តាធិការបុគ្គលរបស់ខ្លួន។ បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស បានកំណត់អត្តសញ្ញាណយោធា ៣៥៧ នាក់ ពីកងពល ៥០២ និង ១,១១៧ នាក់ ពីកងពល ៣១០ ដែលត្រូវបានបញ្ជូនទៅ ស-២១[326]។ លើសពីនេះទៀត មានយោធាភូមិភាគបូព៌ាចំនួន ១៥០ នាក់ មកពីកងពល ៥០២ ត្រូវ

---

[321] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨៦៧, ៨៧០-៨៧២។

[322] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨៦៧, ៨៧៤។

[323] ឯកសារ **D114/203** កំណត់ហេតុស្តាប់ចម្លើយ ម៉ិញ នឿម, ឆ: ២៥-៣៩។

[324] ឯកសារ **D114/203** កំណត់ហេតុស្តាប់ចម្លើយ ម៉ិញ នឿម, ឆ: ៣៨។

[325] ស.ព.អ កត់សំគាល់ថា ក្រៅពីអ្នកដែលត្រូវបានគេបញ្ជូនទៅ ស-២១ គាត់មិនបានស្វែងរកការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មផ្សេងទៀតដែលបានប្រព្រឹត្តឡើងស្របតាមការបោសសម្អាតកងពល៥០២ និង៣១០ នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ទេ ដោយសារថាគាត់យល់ថា ការចោទប្រកាន់ដូច្នេះក៏នឹងត្រូវបានច្រានចោលពីកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៦៦ស្ទួនដែរ (ឯកសារ **D184/2** ចម្លើយតប[របស់ ស.ព.អ] ទៅនឹងសំណើរសុំយោបល់[របស់ ស.ច.ស.អ], ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៦, កថាខណ្ឌ ២២)។ យ៉ាងណាមិញ ស.ច.ស.អ បានច្រានចោលសេចក្តីសន្និដ្ឋាននេះ និងបានរក្សាទុកអង្គហេតុទាំងនេះ នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣ (ឯកសារ **D184/3** សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ, ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦, កថាខណ្ឌ ២១)។ សម្រាប់សេចក្តីលម្អិតបន្ថែមស្តីពីការបញ្ចូលគ្នានៃកងពល ៥០២ និង ៣១០ ព្រមទាំងការដឹកនាំការបោសសម្អាត, *សូមមើល* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ២៩២-២៩៤, ៣០០-៣០២ (កងពល៥០២), ២៩៥-២៩៧, ៣០៤-៣៣៤ (កងពល៣១០)។

[326] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧២, ៥៥២ *យោង* ឯកសារ **D114/230.1.1** បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណ <u>កងពលធំ ៣១០</u> - អ្នកទោស ១,១១៧ នាក់; <u>កងពលធំ ៥០២</u> - អ្នកទោស ៣៥៧ នាក់]។

គេបញ្ជូនទៅកាន់ភូមិមួយនៅជិតតាខ្មៅដើម្បីអប់រំ។ ពួកគេទាំងនោះបានបាត់ខ្លួន នៅសល់តែ ១៥ នាក់ប៉ុណ្ណោះ បន្ទាប់ពីពួកគេត្រូវបានគេយកចេញទៅដោយចោទថាក្បត់[327]។

81. *__កងពលផ្សេងៗទៀត:__* បន្ថែមទៅនឹងកងពល១៦៤ កងពល១១៧ កងពល៥០២ និងកងពល ៣១០ មានសមាជិកកងពលមជ្ឈិម និងកងវរៈសេនាធំឯករាជ្យ និងសេនាធិការ ចំនួនប្រមាណ៣,៣៣០ នាក់ផ្សេងទៀត ត្រូវបានបញ្ជូនទៅ ស-២១ ជាទីដែលពួកគេត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និង សម្លាប់ចោល[328]។

82. អំពើដែលបានកើតឡើងនៅតាមបណ្ដាទីតាំងជាច្រើនក្រៅពី ស-២១ គួរត្រូវបានកំណត់បទចោទ ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត(ការបាត់ខ្លួនដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ នៅស-២១ អំពើទាំងអស់នេះគួរត្រូវបានកំណត់បទចោទថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)[329]។

---

[327] ឯកសារ **D45** កំណត់ហេតុស្ដាប់ចម្លើយ ថោង ចាន់ណា, KH 00802852-7។

[328] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧២, ៥៥២ *យោង* ឯកសារ **D114/230.1.1** បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណចំនួនអ្នកទោសខាងក្រោមថា "បានចាប់មកពី" កងពលធំ កងវរៈសេនាធំ និងមន្ទីរផ្សេងៗទៀតដែលរួមមានទាំងកងទ័ពបដិវត្តន៍កម្ពុជា និងអ្នកដែលមេដឹកនាំរបស់ពួកគេបានចូលរួមជាមួយ មាស មុត នៅក្នុងកិច្ចប្រជុំនានារបស់លេខាកងពលធំ: __កងពលធំ ១៧០__ - អ្នកទោស ៤០៣ នាក់; __កងពលធំ ២៩០__ - អ្នកទោស ៤៤១ នាក់; __កងពលធំ ៤៥០__ - អ្នកទោស ៥០៩ នាក់; __កងពលធំ ៧០៣__ - អ្នកទោស ៦៧៦ នាក់; __កងពលធំ ៨០១__ - អ្នកទោស ៣៥ នាក់; __កងពលធំ ៩២០__ - អ្នកទោស ៣៩៥ នាក់; __កងវរៈសេនាធំ ១៥២__ - អ្នកទោស ២៩១ នាក់; __កងវរៈសេនាធំ ៣៧៧__ - អ្នកទោស ៥៣ នាក់; __កងវរៈសេនាធំ ៤៨៨__ - អ្នកទោស ៧៧ នាក់; __សេនាធិការ__ - អ្នកទោស ៤៥៣ នាក់]។ សម្រាប់សេចក្ដីលម្អិតអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់នៅ ស-២១ *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៥៣-៥៩៣។

[329] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១១៣៦។

# ឃ. កំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការប្រព្រឹត្តិនៃការបង្ខិតបង្ខំ ការគាបសង្កត់ និង បញ្ជាថ្នាក់លើ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ នៅពេលធ្វើការកំណត់អំពីកម្រិត នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

## ១. ដីកាសម្រេចលើកលែងចោទប្រកាន់ផ្តល់ទម្ងន់ហួសហេតុទៅលើបញ្ជាថ្នាក់លើ និងការគាបសង្កត់នៅក្នុងការវិភាគអំពីយុត្តាធិការបុគ្គល

83. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា មាស មុត មិនស្ថិតនៅក្នុងប្រភេទនៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យនោះ បានយកចិត្តទុកដាក់ទៅលើការពិតដែលថា មាស មុត (i) ទទួលបញ្ជាពីថ្នាក់លើ គឺ សុន សេន និងគណៈអចិន្ត្រៃយ៍[330] (ii) ធ្វើតែការងារអនុវត្ត និងផ្សព្វផ្សាយគោលនយោបាយរបស់មជ្ឈិមបក្ស[331] និង (iii) ធ្វើឡើងដោយមានការគាបសង្កត់នៅក្នុងប្រព័ន្ធបង្ខិតបង្ខំដែលបានបង្កើតឡើងដោយបកក តែប៉ុណ្ណោះ[332]។ ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា មាស មុត មិនមានតួនាទី ឬសិទ្ធិអំណាចខ្លាំងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេដោយសារតែសេចក្តីណែនាំរបស់គណៈមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មិនបានផ្តល់សិទ្ធិឱ្យគាត់កម្ទេចក្នុងជួរ និងក្រៅជួរបក្សទេ[333] ហើយគាត់មិនគួរជាសមាជិកគណៈអចិន្ត្រៃយ៍នោះទេ[334]។ នៅពេលជាច្រើន ដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងថា មាស មុត ជាកម្មាភិបាលថ្នាក់ទាប[335] គ្មាន

---

[330] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១២១, ១៦៦, ២១២, ២១៦, ២២៦, ២៥២, ២៥៧, ៣១៦, ៣២២, ៤១៥, ៤២៤។

[331] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩៧-៩៨, ១៦៧, ២២៦, ២៣២, ២៤៨, ២៧៧, ៣០៥, ៣២២, ៣៨៧, ៤១៦, ៤១៨, ៤២០។

[332] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩៨, ១០០, ២៥៦, ២៨៤, ៣៨៦, ៤១២, ៤១៥, ៤២០។

[333] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៣០, ១៦៩, ២៣២, ២៤៦, ២៥៤, ២៧១, ៤២៥។

[334] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១១១-១១២, ១១៥, ១១៧, ១៥៨-១១៩, ១២១-១២២។

[335] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៥៦ ["ការអះអាងរបស់ មាស មុត បញ្ជាក់ថាថ្នាក់ក្រោមត្រូវតែគោរពតាមបញ្ជា" គឺ មាស មុត ចង់បានន័យថា គាត់ខ្លួនឯងគឺជាកម្មាភិបាលថ្នាក់ក្រោមម្នាក់ដែរ], កថាខណ្ឌ ៤១៩ ["មាស មុត ស្ថិតនៅក្រោមកម្មាភិបាលប្រហែល ៥០ (ហាសិប) រូប និងមានឋានៈស្មើកម្មាភិបាលជាច្រើនទៀត"], កថាខណ្ឌ ៤២៣ ["[ឯកសារ] មិនបានបង្ហាញពីការផ្តួចផ្តើម ការបញ្ជាឱ្យចាប់ខ្លួន ឬសម្លាប់ដោយ [ជនណាម្នាក់] ដោយ មាស មុត ទេ ក្រៅតែពីការរាយការណ៍"], កថាខណ្ឌ ៤២៨ ["មាស មុត មានតួនាទី និងមិនមានអំណាចច្រើនទេ"], កថាខណ្ឌ ៣៨៧

អំណាចក្នុងការធ្វើសេចក្តីសម្រេចសំខាន់ណាមួយឡើយ សូម្បីតែលើការចាប់ខ្លួនបុគ្គលណាម្នាក់ក្រោមការត្រួតត្រារបស់គាត់ក៏ដោយ[336]។

84. បុគ្គលបីនាក់ដែលត្រូវបានកាត់ទោស និងផ្តន្ទាទោសរួចហើយឱ្យជាប់ពន្ធនាគារមួយជីវិតនៅ អ.វ.ត.ក កន្លងមកធ្លាប់អះអាងថា ពួកគេធ្វើតែតាមបញ្ជាប៉ុណ្ណោះ និងមានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់ខ្លួន បើសិនមិនធ្វើតាមបញ្ជា។ ខៀវ សំផន ធ្លាប់អះអាងថា គាត់គ្មានអំណាចក្នុងការធ្វើសេចក្តីសម្រេចទេ[337] មិនយល់ស្របនឹងផ្នែកមួយចំនួននៃគោលនយោបាយរបស់ បកក ប៉ុន្តែបាននិយាយថា "ខ្ញុំមិនរស់ទេ បើសិនជាខ្ញុំហ៊ានលាតត្រដាងអំពីការមិនយល់ស្រប ឬការជំទាស់ចំពោះអ្វីមួយ"[338]។ ឌុច បាននិយាយថា គាត់ភ័យរន្ធត់ និងខ្លាចបាត់បង់ជីវិតរបស់ខ្លួន[339]។ សូម្បីតែ នួន ជា ក៏ធ្លាប់បានប្រាប់អ្នកសរសេរប្រវត្តិរូបរបស់គាត់ថា គាត់ខ្លាចគេហៅគាត់ថា ខ្មាំង បន្ទាប់ពីមានកម្មាភិបាលថ្នាក់ដឹកនាំជាច្រើននាក់ត្រូវបានគេចាប់ដាក់គុក និងធ្វើទារុណកម្ម[340]។ តាមពិតបុគ្គលជាច្រើនដែលដីកាសម្រេចលើកលែងចោទប្រកាន់កំណត់ជា បេក្ខជនទ្រឹស្តីសម្រាប់ការជំនុំជម្រះនៅ អ.វ.ត.ក តាមរយៈសមាជិកភាពរបស់គណៈអចិន្ត្រៃយ៍ និង/ឬ គណៈមជ្ឈិម[341]នោះ

["កម្មាភិបាលថ្នាក់ក្រោមៗមានតួនាទីញៀវផ្សាយគោលនយោបាយ និង/ឬ អនុវត្តបញ្ជាតែមួយមុខគត់"], កថាខណ្ឌ ៤០១ ["ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ នឹងមិនរាលដាលដល់កម្មាភិបាលនៅថ្នាក់ក្រោមឡើយក្រៅពី ឌុច"], កថាខណ្ឌ ៣៨៦។ *សូមមើលផងដែរ* ឯកសារ **D54/1.1** សេចក្តីថ្លែងការណ៍របស់ មាស មុត, *ជំហរចុងក្រោយ* (Southeast Asia Globe), ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១, EN 00915788 ["ខ្ញុំជាមន្ត្រីថ្នាក់ទាប [...] ខ្ញុំមិនមែនជាមេដឹកនាំខ្មែរក្រហមទេ"]។

[336] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៥៤, ២៨៣, ៤១៨, ៤២៨។

[337] ឯកសារ **D4.1.192** កំណត់ហេតុ ខៀវ សំផន (SOAS/HRW), ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥, EN 00078213-14។ ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, KH 00156619។ ឯកសារ **D4.1.1074** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, KH 00156677-78។

[338] ឯកសារ **D4.1.1074** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, KH 00156677-78។ *សូមមើលផងដែរ* ឯកសារ **D4.1.1075** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, KH 00156690-91។

[339] *សូមមើល យោងខាងក្រោម,* កថាខណ្ឌ ១១០, កំណត់សំគាល់ជើងទំព័រ ៤៥៤-៤៥៥។

[340] ឯកសារ **D234/2.1.14** G. Chon & ធ. សម្បត្តិ, *នៅពីក្រោយវាលពិឃាត,* KH 00858389 (ទំព័រ ១៧៦, ខាងក្រោម)។

[341] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៩៥ ["[មេដឹកនាំជាន់ខ្ពស់] សំដៅទៅលើតែសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។ ទោះបីមិនមានតារាងបញ្ជីឈ្មោះជនទាំងនោះ ក៏ប៉ុន្តែក្រុមការងារទំនងជាសំដៅជាសំខាន់លើមេដឹកនាំកំពូល[...] ដែលបុគ្គលទាំងនោះជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬ ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស"], កថាខណ្ឌ ៣៦៥, ៤០៦។

តាមពិតត្រូវបានគេបោសសម្អាត[342]។ បើសិនជាការអនុវត្តតាមបញ្ជាពីអាជ្ញាធរថ្នាក់លើ អាចឲ្យបុគ្គលរូបនោះមិនស្ថិតក្នុងចំណោមជនទាំងឡាយនៃមេដឹកនាំជាន់ខ្ពស់ ឬជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ម្ល៉េះគ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសឡើយ ដោយសារម្នាក់ៗអាចអះអាងថា ប៉ុល ពត គឺជាថ្នាក់លើរបស់ខ្លួន ហើយគាត់មិនត្រាប្រណីចំពោះអ្នកប្រឆាំងឡើយ។

85. អ.ជ.ត.ក ធ្លាប់សម្រេចថា អត្ថិភាពនៃបញ្ជាថ្នាក់លើ មិនបានរារាំងការសន្និដ្ឋានថា ជនសង្ស័យគឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ៖

> ចាប់ផ្តើមធ្វើការវាយតម្លៃ ដោយប្រៀបធៀបពីការទទួលខុសត្រូវព្រហ្មទណ្ឌ [...] នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[...]គឺមានន័យស្មើនឹងការបង្កើតឲ្យមានមធ្យោបាយការពារដោយប្រយោលដោយមូលហេតុបញ្ជារបស់ថ្នាក់លើ ហើយផ្ទុយនឹងបទប្បញ្ញត្តិនានាដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ[343]។
>
> យ៉ាងហោចណាស់ចាប់តាំងពីមានធម្មនុញ្ញទីក្រុងឡុង ដែលបានបង្កើតតុលាការយោធាអន្តរជាតិ ("IMT") នៅនូរាំប៊ឺក[344] មានការកំណត់ច្បាស់ថា នៅក្រោមច្បាប់ទម្លាប់អន្តរជាតិ អ្នកដែលធ្វើតាមបញ្ជាថ្នាក់លើ នៅតែមានការទទួលខុសត្រូវព្រហ្មទណ្ឌដដែលចំពោះឧក្រិដ្ឋកម្មអន្តរជាតិណា

---

[342] ជាឧទាហរណ៍ វន វេត, សោ ភីម, កុយ ធួន និង រស់ ញឹម គឺជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬ ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម (ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១០៨, ១១៧, ១២៦-១២៧, ១៣៩, ២៧៣), ប៉ុន្តែពួកគេ"ត្រូវបានកម្ទេច"អស់ហើយ ឬ ក្នុងករណី សោ ភីម វិញ គាត់បានធ្វើអត្តឃាតដោយសារមិនអាចគេចផុតពីការបោសសម្អាតមុនការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១០០, ១០៨, ១២៦)។

[343] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៦២។

[344] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ - ឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមធំៗរបស់អាកហ្សឺសអ៊ឺរ៉ុប, ទីក្រុងឡុង, ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ("ធម្មនុញ្ញទីក្រុងឡុង"), 82 UNTS 279, មាត្រា ៨ ["ប្រការដែលចុងចោទបានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលរបស់គាត់ ឬរបស់ថ្នាក់លើ មិនត្រូវឲ្យគាត់រួចខ្លួនពីការទទួលខុសត្រូវឡើយ ប៉ុន្តែគាត់អាចត្រូវបានពិចារណាក្នុងការសម្រាលពីការផ្តន្ទាទោស បើសិនជាតុលាការសម្រេចថា យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ""]។

មួយដែលខ្លួនបានប្រព្រឹត្ត[345]។ ស្រដៀងគ្នានេះដែរ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[346] និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[347] សុទ្ធតែកំណត់ថា បញ្ជាខុសច្បាប់ពីថ្នាក់លើ មិនបានជួយសម្រាលដល់ជន

---

[345] *សូមមើលជាឧទាហរណ៍* ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ.១០, ការផ្តន្ទាទោសជនដែលមានពិរុទ្ធចំពោះឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ ("ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ.១០), មាត្រា II(៤)(ខ) ["ប្រការដែលជនណាម្នាក់បានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលរបស់គាត់ ឬរបស់ថ្នាក់លើណាម្នាក់ មិនអាចឱ្យគាត់គេចផុតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយបានឡើយ ប៉ុន្តែអាចត្រូវបានពិចារណាក្នុងការសម្រាល"]។ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់សម្រាប់ចុងបូព៌ា, ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦, មាត្រា ៦។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ដែលបានធ្វើបច្ចុប្បន្នភាពនៅខែកញ្ញា ឆ្នាំ២០០៩, មាត្រា ៧(៤) ["ប្រការដែលជនជាប់ចោទណាម្នាក់បានធ្វើតាមបញ្ជារបស់រដ្ឋាភិបាលណាមួយ ឬរបស់ថ្នាក់លើណាម្នាក់ មិនត្រូវឱ្យគាត់គេចផុតការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មណាមួយឡើយ ប៉ុន្តែអាចត្រូវបានពិចារណាក្នុងការសម្រាលក្នុងការផ្តន្ទាទោសប្រសិនបើតុលាការអន្តរជាតិនោះកំណត់ថា យុត្តិធម៌តម្រូវដូច្នេះ"]។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា, ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤, មាត្រា៦(៤)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាឡេអូន ស្តីពីការបង្កើតឱ្យមានតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, ហ្វ្រីថោន, ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ ("ច្បាប់លក្ខន្តិកៈ SCSL"), មាត្រា ៦(៤)។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ១៧៥៧, វិសោធនកម្ម, ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់លីបង់, ឯកសារ អ.ស.ប S/RES/1757, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧, មាត្រា៣(៣)។ *សហរដ្ឋទល់នឹង* *List et al.*, មតិយោបល់ និង សាលក្រម, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៤៨, សវនាការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធានូរ៉ាំប៊ឺកក្រោមច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ.១០ ("TWC"), ភាគ XI, ទំព័រ ១២៣៦-១២៣៧។ សាលដីកាក្នុងរឿងក្តី *Šainović*, កថាខណ្ឌ ១៦៦១។ *សូមមើលបន្ថែម* សាលក្រមក្នុងរឿងក្តី *Taylor*, កថាខណ្ឌ ៤៧៦ ["ថ្នាក់ក្រោមជាអន្តរការីដែលស្ថិតក្នុងខ្សែសង្វាក់នៃការបញ្ជាដែលជាអ្នកបញ្ជូនបញ្ជាបន្តទៅចារី ក៏អាចនឹងត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការបញ្ជាដែលនាំឱ្យមានការប្រព្រឹត្តបទល្មើសនោះដែរ ឱ្យតែជននោះស្ថិតស្ថានភាពនៃចិត្តគំនិតដូចលក្ខខណ្ឌតម្រូវ"] *ដោយបានតម្កល់* សាលដីកាក្នុងរឿងក្តី *Taylor*, ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣, កថាខណ្ឌ ៥៨៩។ សាលក្រមក្នុងរឿងក្តី *Kupreškić*, កថាខណ្ឌ ៨៦២។ សាលក្រមក្នុងរឿងក្តី *Milutinović*, ភាគ ១ ក្នុងចំណោមបួនភាគ, កថាខណ្ឌ ៨៧។

[346] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២៩(៤) ["ប្រការដែលជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតខ្លួនពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ"]។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៥៥២ ["ការប្រព្រឹត្តទៅតាមបញ្ជារបស់ថ្នាក់លើមិនបង្កើតបានជាការការពារខ្លួនស្របច្បាប់ ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ"]។ *សូមមើលបន្ថែម* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៥២៧។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១"), កថាខណ្ឌ ៧០២ ["ការទទួលខុសត្រូវអាចកើតមាននៅពេលជនជាប់ចោទចេញបញ្ជា ឬ ផ្ទេរការបញ្ជាដែលរួមទាំងតាមរយៈអន្តរការីផងដែរ"]។

សង្ស័យណាម្នាក់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ។ បើសិនជាបញ្ជានោះជាបញ្ជាខុសច្បាប់ជាក់ស្តែង ដូចជា បញ្ជាឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[348] មិនអាចឲ្យជនត្រូវចោទទាមទារការបន្ធូរបន្ថយការកាត់ទោសនោះទេ[349]។ នៅចំពោះ

---

[347] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦, មាត្រា ១០០ ["ក្នុងករណី ដែលសេចក្តីបង្គាប់ ជាអនិត្យានុកូល, ហើយអ្នកបញ្ជា ជាអាជ្ញាធរធម្មានុរូប នោះ, ចៅក្រម ត្រូវថ្លឹងមើល តាមការណ៍គួរ នូវភាព នៃការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌ របស់ភ្នាក់ងារអ្នកសម្រេចការណ៍នោះ" (បកប្រែក្រៅផ្លូវការ)]។

[348] *សូមមើលជាឧទាហរណ៍* ច្បាប់លក្ខន្តិកៈតុលាការ ICC, មាត្រា ៣៣(២)។

[349] *សហរដ្ឋ ទល់នឹង Ohlendorf នឹងគូកន.,* មតិយោប់ និងសាលក្រម, ចុះថ្ងៃទី៨-៩ ខែមេសា ឆ្នាំ១៩៤៨ ("សាលក្រម *Einsatzgruppen*"), សវនាការលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធានូរ៉ាំប៊ឺក នៅក្រោមច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០, ភាគ IV, ទំព័រ ៤៧០-៤៧១ ["ការគោរពរបស់ទាហាន មិនមែនជាការគោរពគ្រឿងយន្តស្វ័យប្រវត្តិកម្មទេ។ ទាហានគឺជាភ្នាក់ងារដែលមានហេតុផល។ គាត់មិនឆ្លើយតបទេ ហើយក៏មិនសង្ឃឹមថានឹងឆ្លើយតប ដូចផ្នែកណាមួយនៃគ្រឿងម៉ាស៊ីននោះដែរ។ មានជំនឿខុសមួយដែលគេតែងតែប្រើយ៉ាងទូលំទូលាយនោះគឺថា ទាហានតែងតែគោរពតាមអ្វីៗគ្រប់យ៉ាងដែលមន្ត្រីថ្នាក់លើរបស់ខ្លួនបញ្ជាគាត់ឲ្យធ្វើអ្វីមួយ។ [...] អ្នកក្រោមបង្គាប់មានកាតព្វកិច្ចគោរពតែបញ្ជាធម្មានុរូបរបស់ថ្នាក់លើរបស់ខ្លួនប៉ុណ្ណោះ ហើយបើសិនជាគាត់ទទួលយកបញ្ជាឧក្រិដ្ឋ និងអនុវត្តវាជាមួយនឹងគំនិតព្យាបាទរបស់ខ្លួនឯងផ្ទាល់ គាត់មិនអាចយកបញ្ជារបស់ថ្នាក់លើធ្វើជាលេសដើម្បីសម្រាលដល់បទល្មើសរបស់ខ្លួនឡើយ។ បើសិនជាប្រភេទនៃសកម្មភាពដែលបានបញ្ជាជាក់ស្តែងវាហួសពីវិសាលភាពនៃសិទ្ធិអំណាចរបស់ថ្នាក់លើ នោះអ្នកក្រោមបង្គាប់មិនអាចយកភាពមិនដឹងមិនឮធ្វើជាលេសចំពោះឧក្រិដ្ឋភាពនៃបញ្ជានោះឡើយ"]។ *សូមមើលផងដែរ សហរដ្ឋ ទល់នឹង Milch*, សាលក្រម, ចុះថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ១៩៤៧ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ច្បាប់នៃស្តីពីសវនាការឧក្រិដ្ឋជនសង្គ្រាម, ភាគ VII, ទំព័រ ៤០-៤២, ៦៥ [តុលាការយោធាសហរដ្ឋ បានទាត់ចោលសំណើរសុំអភ័យទោសដែលយកមូលហេតុបញ្ជាថ្នាក់លើធ្វើជាលេសដើម្បីសម្រាលទោស ដោយបានផ្តល់ទឡ្ហីករណ៍ថាបញ្ជាទាក់ទងនឹងការធ្វើសង្គ្រាមឈ្លានពាន មានការពាក់ព័ន្ធនឹងការប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ និងភេរវកម្មដែលចុងចោទ*ត្រូវតែបានដឹងថា* វាជាអំពើអនុត្យានុកូល]។ *សូមមើលបន្ថែម Buck និងគូកន.*, តុលាការយោធាអង់គ្លេស, Wuppertal (ចុះថ្ងៃទី៦-១០ ខែឧសភា ឆ្នាំ១៩៤៦) ដែលបានរាយការណ៍នៅក្នុង LRTWC, ភាគ V, ទំព័រ ៤២-៤៣: ["ចៅក្រមការពារបានថ្លែងថា តាមគោលការណ៍ បញ្ជាថ្នាក់លើមិនអាចការពារខ្លួនចំពោះបទចោទព្រហ្មទណ្ឌណាមួយឡើយ [...] ចៅក្រមការពារបញ្ចេញទស្សនៈឲ្យឃើញថា ជនជាប់ចោទនឹងមានពិរុទ្ធ បើសិនជាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមតាមបញ្ជារបស់ថ្នាក់លើ ទីមួយ បើសិនជាបញ្ជានោះ*អនីត្យានុកូលជាក់ស្តែង,* ទីពីរ បើសិនជាជនជាប់ចោទ*បានដឹងថាបញ្ជានោះអនីត្យានុកូល* ឬទីបីបើសិនជា*គាត់តោងតែដឹងថា បញ្ជានោះគឺអនីត្យានុកូល បើសិនជាគាត់បានពិចារណាលើកាលៈទេសៈផ្សេងៗពេលបញ្ជានោះត្រូវបានផ្តល់"*]។ *Golkel និងគូកន.*, តុលាការយោធាអង់គ្លេស, Wuppertal, អាល្លឺម៉ង់, ចុះថ្ងៃទី១៥-២១ ខែឧសភា ឆ្នាំ១៩៤៦ ("រឿងក្តី *Golkel*") ដែលបានរាយការណ៍នៅក្នុង LRTWC, ភាគ V, ទំព័រ ៥១: ["មិនអាចទាមទារយកបញ្ជាថ្នាក់លើធ្វើជាការការពារខ្លួនបានឡើយ ប្រសិនបើវា*អនីត្យានុកូលយ៉ាងជាក់ស្តែង* ដូចនៅក្នុង *រឿងក្តី "Llandovery Castle"*។ និងប្រសិនជាមានក៏ការការពារខ្លួននោះមិនល្អដែរ ប្រសិនជាជនជាប់ចោទ*បានដឹងថាបញ្ជានោះគឺអនីត្យានុកូល ឬ ត្រូវបានគេយល់តាមរយៈកាលៈទេសៈជុំវិញដែលឲ្យដឹងថា បញ្ជាទាំងនោះគឺ អនីត្យានុកូល"*]។

មុខបញ្ហាខុសច្បាប់ កាតព្វកិច្ចគឺត្រូវមិនគោរពតាម មិនមែនអនុវត្តតាមទេ[350]។ ដូច្នេះ បើសិនជាជនជាប់ចោទធ្វើសកម្មភាពដោយផ្អែកលើបញ្ជាខុសច្បាប់ជាក់ស្តែង ចំណុចនេះមិនប៉ះពាល់ដល់ការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវ ឬយុត្តាធិការបុគ្គលរបស់គាត់នោះទេ[351]។

86. ចៅក្រមនៃតុលាការ IMT បានយល់ស្រប៖

មេធាវីការពារក្តីរបស់ Wilhelm Keitel ពឹងផ្អែកលើអង្គហេតុដែលថា គាត់ជាទាហានម្នាក់ និងផ្អែកតាមទ្រឹស្តីនៃ "បញ្ជាថ្នាក់លើ" ដែលត្រូវបានហាមឃាត់តាមមាត្រា ៨ នៃធម្មនុញ្ញ ជាមេធាវីការពារក្តី។

គ្មានអ្វីជួយបន្ធូរបន្ថយបានឡើយ។ បញ្ជាថ្នាក់លើ សូម្បីតែបញ្ជាទៅទាហានណាម្នាក់ក៏ដោយ មិនអាចត្រូវបានពិចារណាសម្រាប់ជាការបន្ធូរបន្ថយឡើយ បើសិនជាឧក្រិដ្ឋកម្មដ៏គួរឱ្យរន្ធត់ និងយ៉ាងធំ ត្រូវបានប្រព្រឹត្តដោយសម្បជញ្ញៈ គ្មានត្រាប្រណី និងគ្មានលេស ឬយុត្តិកម្មខាងផ្នែកយោធា[352]។

---

[350] មតិយោបល់របស់ Cassese ក្នុងសាលដីកានៃរឿងក្តី *Erdemović*, កថាខណ្ឌ ១៥។ សាលដីកាតុលាការកំពូលឆ្នាំ ១៩៨៦ ក្នុងរឿងក្តី *Erdemović*, កថាខណ្ឌ ១៨។ សាលដីកាក្នុងរឿងក្តី *Mrkšić & Šljivančanin*, កំណត់សំគាល់ជើងទំព័រ ៣៣១។ ICRC (គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ), ទិន្នន័យច្បាប់ទម្លាប់មនុស្សធម៌អន្តរជាតិ, វិធាន ១៥៤, អាចរកបាននៅក្នុង https://ihl-databases.icrc.org/customary-ihl/eng/docs/v1_rul_rule154។

[351] ដូចបានលើកឡើងដោយ ស.ច.ស.ជ នៅក្នុង ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៦៨ "ការពិចារណាអំពីយុត្តាធិការបុគ្គល ក៏មិនខុសគ្នានឹងការពិចារណាដែលត្រូវធ្វើនៅពេលកំណត់ទោសដែរ"។

[352] *សហរដ្ឋ និងគូកន ទល់នឹង Göring និងគូកន.*, សាលក្រម, ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ ("សាលក្រមតុលាការយោធា IMT"), *សវនាការកាត់សេចក្តីលើឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ*, ភាគ I, ទំព័រ ២៩០-២៩១។ *សូមមើលផងដែរ* សាលក្រមតុលាការយោធា IMT, ទំព័រ ៣២៥ ["និយាយឱ្យខ្លី ការការពារខ្លួន [របស់ Alfred Jodl's] គឺជាទ្រឹស្តីនៃ "បញ្ជាថ្នាក់លើ" ដែលត្រូវបានហាមឃាត់ដោយមាត្រា ៨ នៃធម្មនុញ្ញនេះ ថាជាការការពារខ្លួន។ គ្មានអ្វីដែលអាចជួយសម្រាលបានទេ។ ដោយសារវាមិនមែនជាលក្ខខណ្ឌតម្រូវចំពោះទាហានណាម្នាក់ ការចូលរួមក្នុងឧក្រិដ្ឋកម្មដូច្នេះមិនអាចឱ្យគាត់យកធ្វើជាខែលសម្រាប់ជាលក្ខខណ្ឌតម្រូវបែបទេវកថាក្នុងការការពារខ្លួន ថាជាអ្វីមួយដែលទាហានត្រូវតែគោរពទោះបីក្នុងតម្លៃណាក៏ដោយដើម្បីធ្វើជាលេសនៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះបានឡើយ"]។

87. នៅក្នុងសំណុំរឿង០០១ ក្នុងការច្រានចោលសំណើអំពីបញ្ជាថ្នាក់លើ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា “[ឌុច] ក៏បានដឹងផងដែរថា បទបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឱ្យប្រព្រឹត្តនូវបទល្មើសទាំងនេះ គឺខុសច្បាប់”[353]។

88. ដីកាសម្រេចលើកលែងការចោទប្រកាន់បន្តជំទាស់ថា បញ្ជាថ្នាក់លើពីថ្នាក់លើរបស់កម្ពុជាប្រជាធិបតេយ្យ មានការគាបសង្កត់ ឬការបង្ខិតបង្ខំ ដោយ មាស មុត ក៏ដូចកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដទៃៗទៀតដែរ ត្រូវតែគោរពតាមបញ្ជាថ្នាក់លើដោយសារតែខ្លាចគេចាប់ខ្លួនយកទៅសម្លាប់ចោល[354]។ អំណះអំណាងនេះមិនអាចទទួលយកបានទេ អាស្រ័យដោយមូលហេតុជាច្រើន។ ទីមួយ ដីកាសម្រេចលើកលែងចោទប្រកាន់យោងទៅតែកំណត់ហេតុមួយគត់របស់ មាស មុត ដែលគាំទ្រដល់អំណះអំណាងមួយដែលថា មាស មុត ខ្លួនឯងផ្ទាល់ក៏មានអារម្មណ៍ថាមានការគាបសង្កត់ ឬបង្ខិតបង្ខំក្នុងការអនុវត្តបទបញ្ជាដែរ[355]។ លើសពីនេះ ដីកាសម្រេចលើកលែងចោទប្រកាន់បានលុបចោលទាំងស្រុងដោយមិនបានយោងទៅកំណត់ហេតុទាំងមូលរបស់ មាស មុត ដែលនាំឱ្យគាត់ធ្វើការប្រៀបធៀបយ៉ាងសម្ញែងដោយយករូបគាត់ និង ឌុច ប្រៀបជាមួយនឹង Reichsmarschall Hermann Göring នៃប្រទេសអាល្លឺម៉ង់ថា “ចំពោះខ្ញុំជាមួយនឹងតុលាការគ្មានបញ្ហាអ្វីទេ។ ខ្ញុំនឹងនិយាយរឿងរ៉ាវគ្រប់យ៉ាង: ដែលខ្ញុំបានដឹង និងដែលខ្ញុំបានធ្វើ។ អ្នកមានឋានៈតូចតាចត្រូវតែគោរពបទបញ្ជា។ វាដូចជានៅក្រោមការគ្រប់គ្រងរបស់ហ៊ីត្លែអីចឹង។ ហ៊ីត្លែបានស្នើឱ្យ Goering សម្លាប់ជនជាតិជ្វីព។ បើ Goering មិនធ្វើតាមទេ គាត់នឹងត្រូវគេសម្លាប់។ ដូច [អតីតមេគុក ស-២១] លោក ឌុច អីចឹង គាត់ត្រូវគេបញ្ជាឱ្យសម្លាប់មនុស្ស ហើយបើគាត់មិនសម្លាប់ទេ គាត់នឹងត្រូវគេសម្លាប់”[356]។ ខណៈ មាស មុត អាចនិយាយត្រូវយ៉ាងប្រាកដត្រង់ចំណុចនេះដែលថាមេដឹកនាំណាស៊ីដែលប្រឆាំងនឹងគោលនយោបាយព្រហ្មទណ្ឌរបស់ហ៊ីត្លែរ ត្រូវប្រឈមមុខនឹង

[353] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៥៥២។

[354] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩៨, ១០០, ២៥៦, ២៨៤, ៤១២, ៤១៥, ៤២០។

[355] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៥៦ [“ការអះអាងរបស់ មាស មុត បញ្ជាក់ថា ថ្នាក់ក្រោមត្រូវតែគោរពតាមបញ្ជា”], *លើកយោង* ឯកសារ **D1.3.33.16** កិច្ចសម្ភាសន៍ មាស មុត ដោយ C. Chaumeau និង B. Saroeun (Phnom Penh Post), KH 00283079-80។

[356] ឯកសារ **D1.3.33.16** កិច្ចសម្ភាសន៍ មាស មុត ដោយ C. Chaumeau និង B. Saroeun (Phnom Penh Post), KH 00283079-80 [សូមមើលផងដែរច្បាប់ចុងក្រោយនៅក្រោមសេចក្តីយោង ឯកសារ **D22.2.180**, EN 00161881 (សម្រង់គ្មានការផ្លាស់ប្តូរ)]។

គ្រោះដល់អាយុជីវិតក៏ដោយ តែគ្មានតុលាការណាមួយបានទទួលស្គាល់ថា នោះគឺជាមូលហេតុមួយក្នុងការលើកលែងការផ្តន្ទាទោសអ្នកដែលបានអនុវត្តគោលនយោបាយព្រហ្មទណ្ឌទាំងនោះទេ។ Hermann Göring ត្រូវបានកាត់ទោសប្រហារជីវិតនៅនូរ៉ាំប៊ឺក[357] ដូចគ្នានឹង ឌុច ដែលត្រូវបានកាត់ឲ្យជាប់ពន្ធនាគារអស់មួយជីវិតនៅ អ.វ.ត.ក[358]។ ជាការពិត នៅត្រង់កំណត់សំគាល់ចុងក្រោយរបស់ខ្លួនស្តីពីចុងចោទ Göring តុលាការយោធា IMT បានសម្រេចថា "ពិរុទ្ធភាពរបស់គាត់ធំសម្បើមមានលក្ខណៈពិសេសខុសប្លែកពីគេ។ កំណត់ហេតុមិនបានបង្ហាញលេសសម្រាប់បុរសនេះទេ"[359]។ Göring និង ឌុច គឺជាឧទាហរណ៍ឥតខ្ចោះសម្រាប់បង្ហាញឲ្យឃើញថា វាមិនបំរើឲ្យផលប្រយោជន៍យុត្តិធម៌ឡើយ ប្រសិនបើមានខែលការពារចារីសំខាន់ៗ ដែលពួកគេបានអនុវត្តគោលនយោបាយឧក្រិដ្ឋកម្មសាហាវនានាយ៉ាងរំភើបចិត្ត ដោយគ្រាន់តែអះអាងថា ពួកគេបានអនុវត្តបញ្ជាទាំងនោះដោយសារតែមានការគាបសង្កត់នោះ។

89. ជាការពិត យើងច្បាស់ណាស់ថា "[...] គេមិនអាចអះអាងថា មានការបង្ខិតបង្ខំនោះទេ នៅពេលដែលការគំរាមកំហែងនោះ កើតចេញពីការអនុវត្តគោលនយោបាយដែលធ្វើឲ្យមានភាពភ័យរន្ធត់ដែល [ជនជាប់ចោទ] ខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត"[360]។ លើសពីនេះទៀត ដោយបានចូលរួមក្នុងការបង្កើត និងថែទាំប្រព័ន្ធបង្ខិតបង្ខំរបស់កម្ពុជាប្រជាធិបតេយ្យ មាស មុត ក៏យល់ថាខ្លួនឯងក៏ជាកម្មវត្ថុនៅក្នុងប្រព័ន្ធនោះដែរ ហើយក្នុងមធ្យោបាយណាក៏ដោយ មិនអាចយកជាលេសដើម្បីបន្ធូរបន្ថយការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនោះទេ។

---

[357] សាលក្រមតុលាការយោធា IMT, ទំព័រ ៣៦៥។

[358] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៣៨៣, ផ្នែកសម្រេចសេចក្តី។

[359] សាលក្រមតុលាការយោធា IMT, ទំព័រ ២៨២។

[360] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៥៥៧។ *សូមមើលបន្ថែម* មតិរបស់ Cassese ក្នុងសាលក្រម *Erdemović*, កថាខណ្ឌ១៦, ១៧ ["យោងតាមច្បាប់យុត្តិសាស្ត្រស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ ការបង្ខិតបង្ខំ ឬភាពចាំបាច់ មិនអាចជាលេសដើម្បីគេចពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌ សម្រាប់ជនដែលមានបំណងចង់បាននូវការការពារខ្លួនដូច្នេះឡើយ ប្រសិនបើបុគ្គលរូបនោះបានជ្រើសរើសដោយសេរី និងដោយស្ម័គ្រចិត្តដើម្បីចូលជាសមាជិកនៃអង្គភាព អង្គការ ឬក្រុមណាមួយដែលស្ថាប័ននោះមានចេតនាធ្វើសកម្មភាពផ្សេងៗដែលផ្ទុយពីច្បាប់មនុស្សធម៌អន្តរជាតិ"], កថាខណ្ឌ ៤១, ៥០ (ដូចបានបញ្ជាក់អះអាងដោយចៅក្រម Stephen នៅត្រង់កថាខណ្ឌ ៦៨ នៃមតិយោបល់ដាច់ដោយឡែក និងជំទាស់របស់គាត់)។ សាលដីកាឆ្នាំ ១៩៩៦ ក្នុងរឿងក្តី *Erdemović*, កថាខណ្ឌ ១៨។ សាលក្រម ក្នុងរឿងក្តី *Einsatzgruppen*, ទំព័រ ៤៨០-៤៨១។ *សហរដ្ឋ ទល់នឹង Milch*, សាលក្រម, ចុះថ្ងៃទី១៦-១៧ ខែមេសា ឆ្នាំ១៩៤៧, TWC, ភាគ II, ទំព័រ ៧៩១។

90. ដីកាសម្រេចលើកលែងចោទប្រកាន់ ខកខានក្នុងការបង្ហាញឲ្យឃើញថា មាស មុត មិនគ្រាន់តែជាកម្មាភិបាលយោធាធម្មតាម្នាក់ ដែលត្រូវបានបង្ខំឲ្យអនុវត្តបញ្ជារបស់ថ្នាក់លើប្រឆាំងនឹងឆន្ទៈរបស់គាត់នៅក្នុងបរិយាកាសបង្ខិតបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ ដូចបានបញ្ជាក់នៅក្នុងដីកាលើកលែងចោទប្រកាន់ដែរ មាស មុត មិនធ្លាប់ខកខានម្តងណាឡើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងការបង្ហាញការប្តេជ្ញាចិត្តដាច់ខាត និងភាពស្មោះត្រង់របស់គាត់ចំពោះបក្ស[361]។ ក្នុងនាមជាកូនប្រសាររបស់តាម៉ុក ជាមេបញ្ជាការកងពលជាទីទុកចិត្ត ជាកម្មាភិបាលសេនាធិការជាន់ខ្ពស់ និងជាសមាជិកគណៈកម្មាធិការមជ្ឈិម មាស មុត ទទួលបានសន្តិសុខដោយសារសាច់ញាតិយ៉ាងល្អនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៀត ក្នុងនាមជាមេបញ្ជាការកងពល ១៦៤ ជាលេខាតំបន់ស្វយ័តកំពង់សោម និងសំខាន់បំផុតនោះ ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ចាប់ពីយ៉ាងហោចណាស់ខែមករា ឆ្នាំ១៩៧៦ ហើយក្រោយមកជាអនុលេខាសេនាធិការ មាស មុត គឺជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ក្នុងចំណោមកម្មាភិបាលជាន់ខ្ពស់ម្នាក់របស់កម្ពុជាប្រជាធិបតេយ្យដែលបានជួយដោយស្ម័គ្រចិត្ត និងយ៉ាងសកម្ម ក្នុងការបង្កើត និងថែរក្សាឧបករណ៍ដ៏គួរឲ្យភ័យរន្ធត់នេះ។ ក្នុងនាមជាមេបញ្ជាការយោធាកំពូលម្នាក់ដែលបានដឹកនាំកម្លាំងទៅកាន់សមរភូមិ មាស មុត មានស្វ័យភាពច្រើនក្នុងការអនុវត្តគោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ។ គាត់ខ្លួនឯង ក៏ទទួលបានផលប្រយោជន៍ពីអំពើឧក្រិដ្ឋរបស់ខ្លួនគាត់ផ្ទាល់ផងដែរ ព្រោះគាត់ត្រូវបានតម្លើងឋានៈជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានទទួលសិទ្ធិសំខាន់[362]។ ជាការពិត មនុស្សតែម្នាក់គត់ដែលបានធ្វើឲ្យគេភ័យរន្ធត់

---

[361] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៥៦, កំណត់សំគាល់ជើងទំព័រ ៨១៣-៨១៤ លើកយោងឯកសារ **D1.3.34.60** ទូរលេខ 00 របស់កម្ពុជាប្រជាធិបតេយ្យ ពី មាស មុត គោរពជូនគណៈម.៨៧0, ចុះថ្ងៃទី ៣១.១២.៧៧, KH 00001325។ *សូមមើលផងដែរ* ឯកសារ **D1.3.27.20** កំណត់ហេតុនៃការប្រជុំរបស់កងទ័ព, ចុះថ្ងៃទី ៩.១០.៧៦, KH 00052411-12 [អំពីវិធានការណ៍ដែលត្រូវចាត់ប្រឆាំងនឹងពួកក្បត់ មាស មុត និយាយថា "ខ្ញុំយល់ស្រប ឯកភាពជាមួយបក្សទាំងស្រុង។ ធ្វើម៉េច កុំឲ្យស្ថានការណ៍ជ្រុលហួស"]។ សូម្បីតែក្នុងពេលថ្មីៗនេះ មាស មុត នៅបន្តបង្ហាញភាពស្មោះត្រង់របស់គាត់ចំពោះរបបកម្ពុជាប្រជាធិបតេយ្យពីអតីតកាលដដែលៈ ឯកសារ **D1.3.7.8** កិច្ចសម្ភាសន៍ មាស មុត, *អ្វីដែលកន្លងផុតទៅឲ្យវាផុតទៅចុះ* (Cambodia Daily), ចុះថ្ងៃទី១-២ ខែមីនា ឆ្នាំ២00៨, EN 00165821 [[មាស មុត] "និយាយថា គាត់គ្មានវិប្បដិសារីទេ ការពិតខ្មែរក្រហមគ្មានពេលគ្រប់គ្រាន់ដើម្បីសម្រេចបានតាមការសន្យានូវរបបនិយមស្រែចំការរបស់ខ្លួន"]។

[362] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៨-៧៨ [មាស មុត បានចូលរួមជាមួយខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧0 បានក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សកុម្មុយនិស្តកម្ពុជា យ៉ាងហោចណាស់ក្នុងឆ្នាំ១៩៧៣ បានក្លាយជាសមាជិកគណៈតំបន់១៣ ទទួលបន្ទុកខាងកងទ័ព (១៩៧១-១៩៧៣), មេបញ្ជាការកងពលធំលេខ ៣ នៅភូមិភាគនិរតី (ក្នុងឆ្នាំ១៩៧៣/ដើមឆ្នាំ១៩៧៤), មេបញ្ជាការកងពលមជ្ឈិមធំជាងគេនៃកងទ័ពបដិវត្តន៍កម្ពុជា(កងពលធំលេខ៣/១៦៤ចាប់ពីឆ្នាំ១៩៧៥) លេខា

ទាំងជនស៊ីវិល និងយោធានៅកំពង់សោម (និងក្រោយមកនៅតំបន់ ៥០៥) គឺ មាស មុត នេះឯង ដែលជាមេដឹកនាំនៅមិនឆ្ងាយប៉ុន្មានពីភ្នំពេញ[363]។ នៅពេលការស្លាប់ចូលមកដល់ វាតែងតែកើតឡើងនៅក្រោមជនដែលធ្វើការនៅក្រោមបញ្ជាផ្ទាល់របស់ មាស មុត រួមទាំង កងវរៈសេនាតូច ១៦៥/៤៥០ ដ៏អសោច[364]ផងដែរ។

91. ការលើកឡើងថា មាស មុត គ្មានជម្រើសក្រៅពីការចូលរួមក្នុងឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យដោយសារការភ័យខ្លាចគេចាប់ខ្លួន និងសម្លាប់ចោលនោះ[365] ដីកាសម្រេចលើកលែងចោទប្រកាន់ក៏មិនគិតពីការពិតដែលថា កម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដទៃៗទៀត រួមទាំងកម្មាភិបាលមកពីកងពលមជ្ឈិមផង បានឈប់រួមចំណែកដល់សកម្មភាពឧក្រិដ្ឋរបស់ បកក ហើយបានរត់គេចខ្លួនឆ្លងដែន ឬក៏បានតស៊ូជាមួយនឹងរបបនេះនៅក្នុងប្រទេសកម្ពុជា។ ដីកាសម្រេចលើកលែងចោទប្រកាន់មិនពិចារណាលើអង្គហេតុដែលថា មាស មុត មានប្រយោជន៍ពីការឈរជើងនៅមូលដ្ឋានក្នុងចម្ងាយ ២៣០ គ.ម ពីទីបញ្ជាការ ក-១ និង ក-៣ របស់ បកក នៅភ្នំពេញ និងនៅកៀកនឹងព្រំដែនសមុទ្រជាមួយវៀតណាម និងថៃ ព្រមទាំងព្រំដែនទឹកអន្តរជាតិនោះទេ[366] (ខុសពីអ្នកផ្សេង ដូចជា ឌុច ជាដើម ដែលត្រូវបានយល់ឃើញថាជាជនម្នាក់នៃជនទាំងឡាយដែលទទួល

---

តំបន់ស្វយ័តកំពង់សោម (១៧ មេសា ១៩៧៥), សមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា (ត្រឹមខែមករា ឆ្នាំ ១៩៧៦) និងអនុលេខាសេនាធិការ (ក្នុងឆ្នាំ១៩៧៨)]។

[363] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨០ (កំណត់សំគាល់ជើងទំព័រ ២៣៧-២៣៨), ៨៥ (កំណត់សំគាល់ជើងទំព័រ ២៥៧-២៥៩), ៣៦៧ (កំណត់សំគាល់ជើងទំព័រ ១២៦០-១២៦១)។

[364] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨០, ១៥៣, ១៥៥, ២១៣, ២៤៩, ២៥២-២៥៥, ៣៦៦, ៤៣២, ៤៣៤, ៤៤៥, ៤៧៧។

[365] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩៨, ១០០, ២៨៤, ៤១២, ៤១៥, ៤២០។

[366] កោះរបស់កម្ពុជាប្រជាធិបតេយ្យដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ មាស មុត ដែលនៅកៀកនឹងវៀតណាម និងកោះត្រល់ (ភូកុក) ដែលជាកោះដ៏ធំរបស់ប្រទេសនេះ គឺកោះសេះ និងកោះថ្មី។ មាស មុត បានចុះទៅដល់កោះរុង។ កោះរុង (នៅជិតព្រំដែនថៃ), កោះតាង និងកោះពូលូវៃ (នៅជិតថៃ និងព្រំដែនទឹកអន្តរជាតិ): ឯកសារ **D1.3.34.10** ទូរលេខ ៤៤ របស់កម្ពុជាប្រជាធិបតេយ្យ ពីលេខាកងពល១៦៤ មាស មុត ជំរាបបង សុន សេន, KH 00000860។ ឯកសារ **D114/89** កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន, ឆ.១៧១, ១៧៣, ១៧៧។ ឯកសារ **D114/127** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ហៅ រ៉េត, ឆ.៤៩-៥៤។ *សូមមើលផងដែរ* ឯកសារ **D1.3.30.2** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពី មាស មុត ជំរាបបង ៨៩, ចុះថ្ងៃទី ៥.០១.៧៦, KH 00021446។ ឯកសារ **D54/92** កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន, ឆ.៤៩។ ឯកសារ **D22.1.10** FBIS, *គណៈប្រតិភូចិនធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម,* ចុះថ្ងៃទី ១៣.១២.៧៧, KH 01194843។ ឯកសារ **D114/19** កំណត់ហេតុស្តាប់ចម្លើយ ម៉ាក(ម៉ា) ឈឿន, ឆ.៣៣-៣៤។

ខុសត្រូវខ្ពស់បំផុត)។ មាស មុត អាចរត់គេចចេញពីរបបកម្ពុជាប្រជាធិបតេយ្យបានយ៉ាងងាយ តាមនាវាណាមួយរបស់កងទ័ពជើងទឹក បើសិនជាគាត់ចង់។ ការដែលថា មាស មុត គ្មានជម្រើស ក្រៅពីធ្វើឲ្យប្រជាជន និងជនបរទេសរាប់ពាន់នាក់ក្លាយជាទាសករ និងសម្លាប់ពួកគេនៅក្រោម សិទ្ធិអំណាចរបស់ខ្លួនដើម្បីតែសង្គ្រោះជីវិតរបស់ខ្លួនឯងនោះ គឺជាការយកចិត្តទុកដាក់ដំណើរ សកម្មភាពផ្សេងៗដែលអាចមាន។

## ២. មាស មុត ប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានឆន្ទៈ និងចំណាប់អារម្មណ៍ ដោយគ្មានការបង្ខំ និងគាបសង្កត់

92. ការពិនិត្យទៅលើការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ ក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ផ្អែកទៅលើមូលដ្ឋានថា ការភ័យខ្លាចចំពោះជីវិតខ្លួនឯងគឺត្រូវតែជាមូលហេតុចាំបាច់ ដែលធ្វើឲ្យ មាស មុត បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ដោយសារ បុគ្គលដែលមិនគោរពតាមរបបកម្ពុជាប្រជាធិបតេយ្យនឹងត្រូវទទួលរងទណ្ឌកម្មនោះ[367]។ ប៉ុន្តែ ដូចអង្គជំនុំជម្រះសាលាដំបូងបានកំណត់នៅក្នុងសំណុំរឿង០០១ ដែរថា "អ្នកនៅក្រោមបង្គាប់ដែល បង្ហាញឲ្យឃើញនូវអត្ថិភាពនៃបញ្ជាថ្នាក់លើ អាចនឹងទទួលការផ្តន្ទាទោសក្នុងកម្រិតស្រាលជាង *វៀរលែងតែ* ក្នុងករណីដែលបង្ហាញច្បាស់ថា បញ្ជាថ្នាក់លើពិតជាអាចកាត់បន្ថយកម្រិតនៃពិរុទ្ធ ភាពរបស់អ្នកនៅក្រោមបង្គាប់។ ប្រសិនបើ បញ្ជានោះមិនមានឥទ្ធិពលទៅលើអាកប្បកិរិយានៃការ ប្រព្រឹត្តខុសច្បាប់របស់ជនជាប់ចោទនោះទេ ដោយសារតែជនជាប់ចោទបានត្រៀមខ្លួនរួចជាស្រេច ដើម្បីអនុវត្តបញ្ជានោះ នោះគេមិនអាចនិយាយថា កាលៈទេសៈសម្រាលបែបនោះបានកើតមាន នោះឡើយ"[368]។

93. ជាការពិត យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II មានឧទាហរណ៍យ៉ាងច្រើនសម្រាប់ ការប៉ុនប៉ងគេចចេញពីការទទួលខុសត្រូវ ឬសម្រាលទោស ដោយការសំអាងលើបញ្ជាថ្នាក់លើ និង/ឬការបង្ខិតបង្ខំ ឬការគាបសង្កត់ ត្រូវបានច្រានចោលតាមរយៈសេចក្តីសម្រេចថា ជនជាប់

---

[367] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៩៨, ១០០, ២៨៤, ៣៨៨, ៤២០, ៣៨៦-៣៨៧, ២៥៦, ២៧៩។

[368] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៦០៧ *លើកយោង* សាលដីកាសាលាកំពូលឆ្នាំ១៩៩៦ ក្នុងរឿងក្តី *Erdemović,* កថាខណ្ឌ ៥៣។

ចោទបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មអស់ពីចិត្ត។ ក្នុងរឿងក្តី *Einsatzgruppen* តុលាការយោធាសហរដ្ឋអាមេរិកបានសម្រេចថា៖

> លក្ខខណ្ឌដែលត្រូវអនុវត្តគឺថាតើ អ្នកនៅក្រោមបង្គាប់បានធ្វើអំពើអ្វីមួយក្រោមការបង្ខិតបង្ខំ ឬមួយថាតើគាត់ខ្លួនឯងបានយល់ព្រមតាមគោលការណ៍ដែលពាក់ព័ន្ធក្នុងបញ្ជានោះដែរឬទេ។ ប្រសិនបើឃ្លាទីពីរខាងលើជាការពិត នោះសំណូមពរយកមូលហេតុបញ្ជាថ្នាក់លើ គឺជារឿងបរាជ័យ។ អ្នកធ្វើមិនអាចស្នើសុំការគ្មានទោសនៃអំពើឧក្រិដ្ឋណាមួយដែលត្រូវបានបញ្ជាដោយថ្នាក់លើរបស់ខ្លួនឡើយ ប្រសិនបើអ្នកធ្វើនោះបានយល់ស្របតាមគោលការណ៍ និងចេតនារបស់ថ្នាក់លើរូបនោះ[369]។

[369] សាលក្រមក្នុងរឿងក្តី *Einsatzgruppen*, ទំព័រ ៤៨០។ *អគ្គរដ្ឋអាជ្ញានៃរដ្ឋាភិបាលអ៊ីស្រាអែល ទល់នឹង* Eichmann, តុលាការកំពូលអ៊ីស្រាអែល, លេខ. 336/61, ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៦២, កថាខណ្ឌ ១៥ [ដោយប្រើតេស្តសាកល្បងនៅក្នុងរឿងក្តី *Einsatzgruppen* តុលាការបានសន្និដ្ឋានថា Eichmann មិនអាចស្នើសុំដោយយកការបង្ខិតបង្ខំជាមូលហេតុឡើយដោយសារតែ "[គាត់] បានបំពេញតាមបញ្ជាឲ្យសម្លាប់រង្គាលគ្រប់ពេលទាំងអស់*យ៉ាងទន់ភ្លន់* គឺមានន័យថា ប្រកបដោយសេចក្តីក្លៀវក្លា និងការលះបង់ខ្ពស់ចំពោះការងារនោះ"]។ *សូមមើលផងដែរ សហរដ្ឋ ទល់នឹង Krupp នឹងគូកន.*, មតិយោបល់ និងសាលក្រម, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៤៨, TWC, ភាគ IX, ទំព័រ ១៤៣៩ ["ក្រោមវិធានស្តីពីភាពចាំបាច់ ការបង្ខំដែលបានគិតទុកនោះ គឺជាក់ស្តែងត្រូវតែធ្វើតាមឆន្ទៈរបស់ជនជាប់ចោទ បើសិនជាជននោះពិតជាត្រូវបានគេបង្ខំឲ្យធ្វើអ្វីមួយដែលគាត់មិនគួរនឹងធ្វើទេនោះ...។ ក្នុងការប្រតិបត្តិតាមអំពើអនីត្យានុកូល បើសិនជាឆន្ទៈរបស់ជនជាប់ចោទមិនត្រូវបានផ្តល់អំណាចឲ្យទេនោះ ប៉ុន្តែផ្ទុយទៅវិញ គាត់បានធ្វើស្របតាមឆន្ទៈរបស់ជនដែលជាអ្នកបង្កើតការបង្ខំ នោះមានន័យថា គ្មានភាពចាំបាច់ដើម្បីធ្វើជាយុត្តិកម្មនូវអំពើអនីត្យានុកូលឡើយ"]។ *Bralo*, IT-95-17-A, សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងនឹងការកាត់ទោស, ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៧, កថាខណ្ឌ២៤ ["អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនត្រឹមតែបានពិចារណាថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានតតាំងជាមួយនឹងបញ្ជាខុសច្បាប់ទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានសង្កត់ធ្ងន់លើការរំភើបចិត្តនិងឆន្ទៈរបស់គាត់ក្នុងការអនុវត្តបញ្ជាទាំងនោះផងដែរ ដូចមានភ័ស្តុតាងបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីចំណង់របស់ម្ចាស់បណ្តឹងសាទុក្ខដើម្បីបំបាក់មុខជនរងគ្រោះរបស់ខ្លួន"]។ *សាលដីកាតុលាការកំពូលក្នុងរឿងក្តី Mrđa*, កថាខណ្ឌ ៦៦ ["អវត្តមាននៃភ័ស្តុតាងដែលគួរឲ្យជឿជាក់បានណាមួយអំពីសញ្ញាណដ៏មានអត្ថន័យដែលថា Darko Mrđa លែងសេពគប់ដោយបានដកខ្លួនចេញពីការសម្លាប់រង្គាលក្នុងពេលដែលឧក្រិដ្ឋកម្មនេះកំពុងត្រូវបានប្រព្រឹត្តឡើង គឺជាកត្តាដែលរារាំងអង្គជំនុំជម្រះសាលាដំបូងពីការទទួលយកការបង្ខិតបង្ខំ ធ្វើជាកាលៈទេសៈសម្រាល"]។

94. ថ្វីបើមានការបដិសេធរបស់គាត់[370] ក៏ភស្តុតាងក្នុងសំណុំរឿង០០៣ បង្ហាញយ៉ាងច្បាស់ថា មាស មុត ប្រកាន់យ៉ាងខ្ជាប់ខ្ជួនចំពោះគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ហើយបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រព្រឹត្តបទឧក្រិដ្ឋដោយស្ម័គ្រចិត្ត។ ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានសន្និដ្ឋាន និងគ្មានភស្តុតាងបង្ហាញថា មាស មុត ធ្លាប់មិនគោរពបញ្ជាថ្នាក់លើដែរ[371]។ ផ្ទុយទៅវិញ គាត់បានអនុវត្តភារកិច្ចជាច្រើនរបស់គាត់ ដើម្បីបំរើកម្ពុជាប្រជាធិបតេយ្យដោយទឹកចិត្តពុះកញ្ជ្រោល និងយ៉ាងស្មោះត្រង់។ សមាជិកភាពក្នុងគណៈកម្មាធិការមជ្ឈិមរបស់គាត់[372] និងទំនាក់ទំនងជិតស្និទ្ធជាមួយមេដឹកនាំគណៈកម្មាធិការអចិន្ត្រៃយ៍ បកក រួមទាំងជាមួយ សុន សេន[373] បានធានាដល់ការបង្កើនអំណាចខ្លួនគាត់ផ្ទាល់ផង និងអនុញ្ញាតឲ្យគាត់បានប្រើប្រាស់ស្វ័យភាពក្នុងកម្រិតច្រើន តាមរបៀបដែលអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្តចំពោះយោធាកម្ពុជា និងប្រជាជនស៊ីវិលក្រោមការត្រួតត្រារបស់គាត់ និងចំពោះជនបរទេសដែលចាប់ខ្លួនពីសមុទ្រ[374]។

95. ជាឧទាហរណ៍ នៅក្នុងកិច្ចប្រជុំបុគ្គលិកផ្ទៃក្នុង មាស មុត បានបញ្ជាក់ពីការគាំទ្រគ្មានលក្ខខណ្ឌរបស់គាត់ចំពោះផែនការរបស់ សុន សេន ក្នុងការកំណត់អត្តសញ្ញាណ បោសសម្អាត និងកម្ទេច

---

[370] ឯកសារ **D22.2.186** កិច្ចសម្ភាសន៍ មាស មុត, *អតីតមេដឹកនាំខ្មែរក្រហម ឆ្លើយតបទៅនឹងការចោទប្រកាន់របស់សកម្មជន* (Phnom Penh Post), ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១, EN 00687297 ["មាស មុត បាននិយាយ [...] គាត់ "គ្មានកំហុស"ទេ។ ខ្ញុំមិនធ្លាប់ពាក់ព័ន្ធនឹងការចាប់ខ្លួន ឬសម្លាប់មនុស្សទេ"]។ ឯកសារ **D22.2.185** កិច្ចសម្ភាសន៍ មាស មុត, *គ្មានការចោទប្រកាន់ទៀតទេ: អតីតមេបញ្ជាការពូកខ្មាម,* ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ [បដិសេធថា មិនបានប្រព្រឹត្តកំហុសណាមួយក្នុងនាមជាមេបញ្ជាការកម្ពុជាប្រជាធិបតេយ្យមួយរូប]។ ឯកសារ **D22.2.181** កិច្ចសម្ភាសន៍ មាស មុត (US POW/MIA), ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១, KH 00742002 [បដិសេធថា មិនបានដឹងអំពីការចាប់ជនបរទេសនៅលើទូកក្តោង ក្នុងឆ្នាំ១៩៧៥-១៩៧៨"]។ ឯកសារ **D54/1.1** កិច្ចសម្ភាសន៍ មាស មុត, *ជំហរចុងក្រោយ* (Southeast Asia Globe), ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១, EN 00915788 [មាស មុត "បានបដិសេធទាំងស្រុងអំពីការលើកឡើងថា គាត់មានការពាក់ព័ន្ធនៅក្នុងអំពើឃុងឃ្លងយ៉ាងរង្គាល"]។

[371] អង្គជំនុំជម្រះសាលាដំបូងបានរកឃើញដូចគ្នានឹង ឌុច ដែរថា: "[ទោះបីជនជាប់ចោទបានរៀបរាប់អំពីស្ថានភាពជាច្រើនដែលខ្លួនគាត់ផ្ទាល់មានអារម្មណ៍ភ័យខ្លាចក៏ដោយ គាត់មិនបានលើកអំពីការមិនគោរពតាមបញ្ជាណាមួយទេ"។ សូមមើលសំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ឌុច, កថាខណ្ឌ ៥៥៥។

[372] *សូមមើលយោងខាងក្រោម,* កថាខណ្ឌ១៤៨-១៥៤។*សូមមើលផងដែរ* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៩-៥១។

[373] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៩១, ៩៥-១០០។

[374] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨១, ៣៣២។ *សូមមើលផងដែរ* ឯកសារ **D1.3.34.11** ទូរលេខ ១១ របស់កម្ពុជាប្រជាធិបតេយ្យ ពី ឌឹម ជូនបង មុត, ២៤ កញ្ញា ១៩៧៦, KH 00000863។

ជនណាដែលគេយល់ថាខ្មាំងលាក់ខ្លួននៅក្នុងជួរកងពលមជ្ឈិមនៃកងទ័ពបដិវត្តន៍កម្ពុជាទាំងអស់[375] រួមទាំងកងពល ១៦៤ផងដែរ និងបានអនុវត្តផែនការបោសសម្អាតនោះយ៉ាងក្តៀវក្លា[376]។ គាត់បានប្រកាសនៅក្នុងកិច្ចប្រជុំរបស់សេនាធិការមួយថា "សមាសធាតុមិនល្អ ឬខ្មាំង នៅតែពួនបង្កប់ ក្នុងជួរ[...]សុំយល់ព្រមឯកភាពជាមួយបក្សទាំងស្រុង។ ធ្វើម៉េចកុំឱ្យស្ថានការណ៍ វាពង្រីងពង្រីកខ្លួនបានឱ្យសោះ"[377]។ មាស មុត បានធ្វើការប្តេជ្ញាចិត្តបោសសម្អាតផ្ទៃក្នុងឱ្យអស់ជាដាច់ខាត ដូចបានពោលថា "ដោយបោសសម្អាតគ្មានស្នាក់ស្នើរសមាសភាគបង្កប់របស់ខ្មាំងជាយួន និងខ្មាំងដទៃទៀត"[378]។

96. មាស មុត បានរក្សាការសន្យារបស់ខ្លួន គឺ ការស្រាវជ្រាវយ៉ាងសកម្មដើម្បីស្វែងរកសមាសភាគមិនល្អ និងជនក្បត់ និងខ្សែបណ្តាញខ្មាំងនៅក្នុងកងពល១៦៤ បានធ្វើឱ្យមានការដកហូតអាវុធ ការចាប់ខ្លួន ការធ្វើឱ្យទៅជាទាសករ និងជាញឹកញាប់ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ទាហាន និងកម្មាភិបាលរាប់ពាន់នាក់នៅតំបន់កំពង់សោម[379] ខណៈដែលពួកគេតែមួយចំនួនតូចប៉ុណ្ណោះ ជាពិសេសកម្មាភិបាលថ្នាក់ខ្ពស់ ត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅ ស-២១[380]។ ការដែលយោធា និងកម្មាភិបាលចំនួន ៦៧ នាក់ មកពីកងពល១៦៤ ត្រូវបានចាប់ដាក់គុក ធ្វើទារុណកម្ម និងសម្លាប់នៅ ស-២១[381] ដែលនេះគ្រាន់តែជាចំនួនតិចមួយ

---

[375] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣៣២។

[376] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣២៨-៣៣៨, ជាពិសេស កថាខណ្ឌ ៣២៩, ៣៣៤ (កំណត់សំគាល់ជើងទំព័រ ១១៥៥-១១៥៦)។

[377] ឯកសារ **D256/7** ICP ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣២៩ (កំណត់សំគាល់ជើងទំព័រ ១១៣៣)។

[378] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣៣៤ (កំណត់សំគាល់ជើងទំព័រ ១១៥៦)។ ចំពោះអំពើប្រល័យពូជសាសន៍វៀតណាម *សូមមើលយោងខាងលើ* កថាខណ្ឌ ៦០-៦២។

[379] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣៣៥-៣៣៧, ៣៤០-៣៦៧ [ក្នុងចំណោមអ្នកដែលត្រូវបោសសម្អាត: (ក) កងទ័ពចំនួន ៣០០-៧២០ នាក់ ពីកងពលលេខ៣ ដែលបានចាប់ខ្លួនដោយជនជាតិវៀតណាមក្នុងខែឧសភា-មិថុនា ឆ្នាំ១៩៧៥ ដែលត្រូវបានបោសសម្អាតក្រោយពួកគេត្រូវបានដោះលែង; (ខ) អ្នកដែលត្រូវបានគេចាត់ទុកថាជាជនក្បត់ និងខ្សែរបស់ពួកគេ រួមទាំងមនុស្សរាប់រយនាក់មកពីកងវរៈសេនាតូច៣៨៦/តំបន់៣៧ ដែលគេចោទថា មកពីខ្សែរបស់ឆាន់ និងកងទ័ពបូព៌ាចំនួនពី ៧០០-១០០០នាក់ មកពីខ្សែរបស់ ឌីម; (គ) កងទ័ពនៃកងពល១៦៤ ដែលគេចោទថាបានជាន់ពាក់ព័ន្ធជាមួយនឹងរបប លន់ នល់ ឬវៀតណាម, សហភាពសូវៀត ថៃឡុងដ៍ សហរដ្ឋ; (ឃ) អ្នកដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ និងស្រាល; និង (ង) អ្នកចុះចូលមួយចំនួន]។

[380] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤៦-៣៤៧។

[381] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤៧, ៥៤២-៥៤៣។

បើប្រៀបធៀបទៅនឹងកងពលមជ្ឈិមដទៃទៀត[382] និងចំនួនដ៏ច្រើននៃកងកម្លាំងដែលកងពល ១៦៤ មាន[383] បញ្ជាក់ថា មេដឹកនាំបក្សមានការពេញចិត្តនឹង មាស មុត ក្នុងការដឹកនាំបោសសម្អាតខ្លាំងផ្ទៃក្នុងតាមមន្ទីរសន្តិសុខ និងការដ្ឋានជាច្រើនខុសៗគ្នាដែលស្ថិតនៅក្នុងវិសាលភាពនៃកងពលរបស់គាត់ផ្ទាល់នៅក្នុងតំបន់កំពង់សោម[384]។ នៅកងពល១៦៤ និងតំបន់ស្វយ័តកំពង់សោម មានតែ មាស មុត ទេដែលមានអំណាចសម្រេចកម្មេចខ្លាំង ហើយគាត់មិនបានធ្វើប្រតិភូកម្មអំណាចនេះទៅអ្នកនៅក្រោមបង្គាប់របស់គាត់ណាម្នាក់ឡើយ[385]។ មាស មុត បានបង្រួមអំណាចរបស់ខ្លួនយ៉ាងរឹងមាំតាមរយៈការបោសសម្អាតអនុបញ្ជាការរបស់គាត់ឈ្មោះ ឆាន់ និង ឌឹម ព្រមទាំងអ្នកនៅក្រោមបង្គាប់របស់ពួកគាត់រាប់រយនាក់ទៀត ដែលពីមុនពួកគេនៅខាងតំបន់ ៣៧ និងភូមិភាគបូព៌ា[386]។ មាស មុត បានប្រើអំណាចរបស់ខ្លួនដោយគ្មានត្រាប្រណី វាយដំលើរូបរាងកាយអ្នកនៅក្រោមបង្គាប់ ចំពោះអ្នកដែលគាត់យល់ថាបានប្រព្រឹត្តកំហុស[387]។

97. ការដែល មាស មុត បានទទួលការតម្លើងឋានៈជាញឹកញាប់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបង្ហាញថា មេដឹកនាំកំពូលរបស់ បកក បានទទួលស្គាល់ការរួមចំណែករបស់គាត់ទៅក្នុង

---

[382] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧២ [លម្អិតអំពីចំនួនកងទ័ពកងពលមជ្ឈិមដែលបានជាប់មន្ទីរឃុំឃាំងនៅ ស-២១]។

[383] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៤, ១០៨២ [កងពលលេខ៣/១៦៤ មានកងទ័ពយ៉ាងតិច ៨,៦០០នាក់ និងឡើងដល់ ១២,០០០នាក់ ខណៈដែលកងពលធំលំដាប់ទីពីរ គឺកងពល៣១០ មានកងទ័ព ៦,០០០នាក់ នៅដើមឆ្នាំ ១៩៧៧ មុនពេលការបោសសម្អាតកងពលនេះ]។

[384] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១០២-១១៩, ៣២៨-៣៦៧ [ការបោសសម្អាតកងពល ១៦៤], កថាខណ្ឌ ១៥០-១៥៧, ៤៥០-៤៥៥ [មន្ទីរសន្តិសុខវត្តឥន្ទញាណ], កថាខណ្ឌ ១៥០-១៥២, ១៥៨-១៦៣, ៤៩០, ៤៩៥-៤៩៧ [មន្ទីរសន្តិសុខទឹកសាប], កថាខណ្ឌ ១៨៦-១៩២, ៦៧៥-៦៩៨ [ការដ្ឋានតំបន់រាម], កថាខណ្ឌ ១៩៣-១៩៧, ៦១៣-៦៤៨ [ការដ្ឋានស្ទឹងហាវ]។

[385] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៣២ (កំណត់សំគាល់ជើងទំព័រ ១១៤៣-១១៤៤) [សាក្សី ប៉ាង រ៉េត បានពន្យល់ថា មាស មុត បានសម្រេចសម្លាប់ទាហានធម្មតា ខណៈដែលការអនុញ្ញាតរបស់សេនាធិការតម្រូវឲ្យសម្លាប់តែកម្មាភិបាលដែលមានឋានៈខ្ពស់], កថាខណ្ឌ ៨១ 81 (កំណត់សំគាល់ជើងទំព័រ ២៤៥-២៤៧)។ *សូមមើលបន្ថែម* ឯកសារ **D114/24** កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដារ, ឆ.១៤០។

[386] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤៨-៣៥៤(ឆាន់), ៣៥៥-៣៦០ (ឌឹម)។

[387] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៦៧ [សាក្សីពិពណ៌នាអំពីគាត់ថា គាត់ជាមនុស្ស "កាច", "អាក្រក់", ឬ "សាហាវ"]។

របបឧក្រិដ្ឋកម្មនេះ ជាពិសេសក្នុងការអនុវត្តការបោសសម្អាតផ្ទៃក្នុងដោយការបង្ហូរឈាម[388]។ សូម្បីតែនៅក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ មាស មុត រស់នៅតែជាមួយមេដឹកនាំផ្សេងទៀតរបស់ខ្មែរក្រហមនៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៩ និងនៅតែការពារមរតករបស់កម្ពុជាប្រជាធិបតេយ្យ[389]។ សាមសិបឆ្នាំក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ មាស មុត បានសារភាពថា មនុស្សត្រូវបានសម្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែបាននិយាយថា "គាត់គ្មានវិប្បដិសារីទេ ដោយសារខ្មែរក្រហមគ្មានពេលគ្រប់គ្រាន់ដើម្បីសម្រេចបានរបបនិយមស្រែចំការរបស់ខ្លួន"[390]។ នៅក្នុងឆ្នាំ២០១៣ គាត់បានឱ្យដឹងទៀតថា បើសិនជាកម្ពុជាប្រជាធិបតេយ្យនៅតែកាន់អំណាច ម្ល៉េះកម្ពុជានឹង "រីកចម្រើនជាងនេះ២០ដង" និងថា មានអ្នកជ្រៀតចូល ដែលព្យាយាមផ្តួលរំលំ ប៉ុល ពត និងបង្ខូចតម្លៃ "គោលនយោបាយដ៏ល្អ"របស់គាត់ គឺជាអ្នកដែលបានសម្លាប់មនុស្ស[391]។

## ៣. សុន សេន បានប្រគល់ឱ្យ មាស មុត នូវអំណាចចាប់ខ្លួន និងកម្មេសជនបរទេសដែលចាប់បាននៅសមុទ្រ

98. ដើម្បីផ្តល់ទឡ្ហីករណ៍ថា មាស មុត មិនមានអំណាចបញ្ជាឱ្យសម្លាប់មនុស្ស ដីកាលើកលែងចោទប្រកាន់ ដកស្រង់ដដែលៗនូវសេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលបានផ្តល់ឱ្យ"គណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ" "គណៈកម្មាធិការមជ្ឈិម" "សេនាធិការ" និង "គណៈកម្មាធិការអចិន្ត្រៃយ៍" នូវ "សិទ្ធិកម្មេសខាងក្នុង និងខាងក្រៅជួរ"[392]។ ដីកាលើកលែងចោទប្រកាន់ បញ្ជាក់ថា មាស មុត មិនត្រឹមតែត្រូវរាយការណ៍ទៅ សុន សេន ឬមជ្ឈិមបក្ស អំពីហេតុការណ៍សន្តិសុខណាមួយទេ ប៉ុន្តែថែមទាំង ត្រូវរង់ចាំសេចក្តីណែនាំជាក់លាក់

---

[388] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៨-៧៨, ៨៤៥។

[389] ឯកសារ **D1.3.7.8** កិច្ចសម្ភាសន៍ មាស មុត, *អ្វីដែលកន្លងផុតទៅ ឱ្យវាផុតទៅចុះ* (Cambodia Daily), ចុះថ្ងៃទី១-២ ខែមីនា ឆ្នាំ២០០៨, EN 00165821។ ឯកសារ **D54/1.1** សេចក្តីថ្លែងការណ៍របស់ មាស មុត, *ជំហរចុងក្រោយ* (Southeast Asia Globe), ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១, EN 00915789។

[390] ឯកសារ **D1.3.7.8** កិច្ចសម្ភាសន៍ មាស មុត, *អ្វីដែលកន្លងផុតទៅ ឱ្យវាផុតទៅចុះ* (Cambodia Daily), ចុះថ្ងៃទី១-២ ខែមីនា ឆ្នាំ២០០៨, EN 00165821។

[391] ឯកសារ **D114/307.5** កិច្ចសម្ភាសន៍ មាស មុត, ប្រតិចារឹកនៃ "បងធំទីមួយ" (Journeyman.tv), ឆ្នាំ២០១៣, KH 01505962 [មាស មុត ប៉ាន់ស្មានថា ចំនួនមនុស្សស្លាប់តិចជាងមួយលាននាក់នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ]។

[392] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៣០, ១៦៩, ២៣២, ២៤៦, ២៥៤, ២៧១, ៤២៥។

ពី សុន សេន ឬមជ្ឈិមបក្ស មុននឹងធ្វើសកម្មភាព[393]។ គាត់ត្រូវបានចាត់ទុកថាគ្មានអំណាចច្រើនទេ ដោយគ្រាន់តែបញ្ជូនបន្តបទបញ្ជារវាង សុន សេន ជាមួយនឹងអ្នកក្រោមបង្គាប់ប៉ុណ្ណោះ[394]។ អន្តរការីបែបនេះមិនអាចត្រូវចាត់ទុកថាជាជនម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត"ទេ។ ប៉ុន្តែ មានកំហុសអង្គហេតុយ៉ាងច្បាស់មួយចំនួននៅក្នុងការសន្និដ្ឋានទាំងនេះ។

99. ដីកាលើកលែងចោទប្រកាន់ បញ្ជាក់ថា "មាស មុត បានរាយការណ៍ទៅ សុនសេន ទាក់ទងនឹងការវាយប្រហារទូកនេសាទ និងការចាប់ខ្លួនទូកវៀតណាម *ព្រមទាំងស្នើសុំយោបល់អំពីវិធានការដែលខ្លួនត្រូវធ្វើ*"។ ភស្តុតាងដែលបានដកស្រង់ដើម្បីគាំទ្រសេចក្តីសន្និដ្ឋាននេះគឺរបាយការណ៍តាមទូរសព្ទដែល មាស មុត បានផ្ញើទៅ សុន សេន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨[395]ប៉ុន្តែ នៅក្នុងរបាយការណ៍នេះ គ្មានត្រង់ណាដែល មាស មុត ស្នើសុំយោបល់អំពីអ្វីដែលត្រូវធ្វើទេ ប៉ុន្តែ គាត់គ្រាន់តែជូនដំណឹងទៅ សុន សេន អំពីហេតុការណ៍កន្លងមក និងសេចក្តីសម្រេចដែលគាត់បានធ្វើ[396]។

100. តាមពិត ដូចដែលមាស មុត មានសេរីភាពក្នុងការសម្រេចលើជោគវាសនារបស់យោធាថ្នាក់ក្រោមដែលត្រូវបានបោសសម្អាតនៅកងពល ១៦៤ ក្រោយមក កងពល ១១៧/កម្មាភិបាលតំបន់ ៥០៥ នៅក្រចេះ[397] គាត់ក៏មានស្វ័យភាពច្រើនក្នុងការសម្រេចថាតើជនជាតិវៀតណាម ថៃ និងជនបរទេសផ្សេងៗទៀតដែលចាប់បាននៅសមុទ្រ ត្រូវចាត់ការយ៉ាងណា។ ក្នុងនាមជាសមាជិកសេនាធិការ យ៉ាងហោចណាស់ចាប់តាំងពីខែកក្កដា ខែសីហា ឆ្នាំ១៩៧៥ និងជាអនុលេខារបស់ សុន សេន នៅឆ្នាំ១៩៧៨[398] មាស មុត អាចធ្វើសេចក្តីសម្រេចក្នុងការចាប់ខ្លួន និងកម្ទេចមនុស្ស

---

[393] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១២១, ១៦៦, ២១២, ២១៦, ២២៦, ២៥២, ២៥៧, ៣១៦, ៣២២។

[394] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥, ៩៧-៩៨, ១៦៧, ២២៦, ២៣២, ២៤៨, ២៥៤, ២៧៧, ៣០៥, ៣២២, ៣៨៧, ៤១៦, ៤១៨-២០។

[395] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២១៦(គូសបញ្ជាក់បន្ថែម)។

[396] ឯកសារ **D1.3.34.64** (**D54/25.1**) ការទាក់ទងតាមទូរសព្ទកម្ពុជាប្រជាធិបតេយ្យពី មាស មុត ទៅ សុន សេន ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00020982។

[397] *សូមមើលខាងលើ* កថាខណ្ឌ ៦៥-៦, ៧៩, ៩៥-៩៦។ *សូមមើលខាងក្រោម* កថាខណ្ឌ ១២៣, ១២៧-៨, ១៣២-៣, ១៤៦។

[398] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥៣។ ឌុច បានបញ្ជាកប្រាប់ចៅក្រម Blunk និងចៅក្រម យូ ប៊ុនឡេង ថា មាស មុត និង ស៊ូ ម៉េត ក្នុងនាមជាប្រធានកងទ័ពជើងទឹក និងកងទ័ពជើងអាកាស គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍អគ្គសេនាធិការ ចាប់តាំងពីបង្កើតដំបូង ហើយ *មិនមែន*ជាជំនួយការទេ៖ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00680803។

ដែលចាប់បាននៅដែនសមុទ្រ តាមសេចក្ដីណែនាំចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[399]។ លើសពីនេះទៀត ដោយសារឧស្សាហ៍ចាប់បានទូកបរទេស[400] និងការងាររមមាញឹករបស់ សុន សេន (ដោយសារសង្គ្រាមជាមួយនឹងវៀតណាមបានកើនឡើងនៅឆ្នាំ ១៩៧៧-ឆ្នាំ១៩៧៨) ព្រមទាំងតម្រូវការក្នុងការធ្វើសេចក្ដីសម្រេចភ្លាមៗនៅក្នុងស្ថានការណ៍មួយចំនួននោះ[401] ទើបមិនអាចពិគ្រោះយោបល់ជាមួយ សុន សេន ចំពោះហេតុការណ៍នីមួយៗ ហើយរង់ចាំបញ្ហាមុនពេលចាត់វិធានការឡើយ។

101. ទោះបីជាមានប៉ុន្មានករណីដែល មាស មុត ពិតជាបានរាយការណ៍ទៅសុន សេន ដើម្បីស្នើសុំមតិណែនាំក៏ដោយ[402] ក៏ភស្តុតាង សូម្បីតែភស្តុតាងដែលប្រមូលបានមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ក៏ដោយ ក៏បង្ហាញថា ចំពោះជនបរទេសដែលចាប់បាននៅដែនសមុទ្រ សុន សេន ជាទូទៅបានផ្ទេរសិទ្ធិអំណាចរបស់គាត់ ហើយសេចក្ដីសម្រេចឲ្យបាញ់ពន្លិចឲ្យស្លាប់ ចាប់ខ្លួន សួរចម្លើយ និង/ឬសម្លាប់អ្នកទោស គឺជាការសម្រេច មាស មុត[403]។ ដីកាលើកលែងចោទប្រកាន់ ទទួលស្គាល់

---

[399] សេចក្ដីណែនាំចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិមបានផ្ដល់ឲ្យ“អគ្គសេនាធិការ”នូវអំណាចកម្ទេសក្នុងជួរ និងក្រៅជួរ។ ការបងស្រាយផ្ទាល់ខ្លួនរបស់ ឌុច គឺថា នេះមានន័យថាសំដៅលើតែ “សុន សែន”តែប៉ុណ្ណោះ។ ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៧០, ២៧១ *ដកស្រង់* កំណត់ហេតុស្ដាប់ចម្លើយ ឌុច KH 00680805; ឯកសារ **D98/1.2.1** & **D54/6.1.10** ប្រតិចារឹក ឌុច ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ 12.10.00-12.15.13។ ឯកសារ **D10.1.64** ចម្លើយជាលាយលក្ខណ៍អក្សរចុងក្រោយរបស់ ឌុច KH 00404806។

[400] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤២១-៤។ ប៉ុន្តែ នៅក្នុងកិច្ចសម្ភាសន៍មួយ មាស មុត បានបញ្ជាក់ថា ការចាប់ទូកធ្វើឡើងបីខែម្ដង៖ ឯកសារ **D54/16/1R** កិច្ចសម្ភាសន៍ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ២០០៩ [ភាសាអង់គ្លេស] 35:30-39។

[401] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៥ (ជើងទំព័រ ១៣១៤-៨), ៣៧៦ (ជើងទំព័រ១៣២១-៣)។

[402] *សូមមើលឧទាហរណ៍* ឯកសារ **D1.3.14.1** កម្ពុជាប្រជាធិបតេយ្យ ទូរលេខពី មាស មុត ផ្ញើជូន សុន សេន ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ KH 00003702 [មាស មុត ស្នើយោបល់អង្គការសុំសេចក្ដីសម្រេចលើបញ្ហាសន្តិសុខមួយពាក់ព័ន្ធនឹងអនុគាត់ ឈ្មោះ ឌឹម និងសមមិត្តឈ្មោះ សម្អាត ហៅ ស៊ុន នៅកងវរសេនាតូច ១៦៥]។ ឯកសារ **D1.3.34.10** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ៤៤ ពី មាស មុត លេខាកងពល ១៦៤ ផ្ញើជូន សុន សេន KH 00000860 [ស្នើសុំយោបល់បន្ថែមអំពីការចាប់កាំភ្លើង ៧៥]។

[403] ឯកសារ **D1.3.2.2** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ១០ ពី សុន សេន ផ្ញើជូន មាស មុត ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00162492[“ជំហររបស់យើង ត្រូវកំទេសវាឲ្យបានក្នុងពេលវេលាចូលដែនទឹក ឬដែនគោករបស់យើង”]។ ឯកសារ **D1.3.27.20** កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ EN 00052407 [សុន សេន

ចំណុចនេះ ដោយបញ្ជាក់ថា "*សេនាធិការជាអ្នកចេញបញ្ជា និងមតិណែនាំត្រឡប់មក កងពលនីមួយៗ រួមមានទាំង កងពលលេខ ១៦៤ ផងដែរ ដូចជា ការកម្ទេសត្រូវជាដាច់ខាត ទាំងនៅដែនគោក និងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ*"[404]។ ការផ្ទេរសិទ្ធិអំណាចរបស់ សុន សេន ក៏បានអនុវត្តផងដែរចំពោះស្ថានភាពផ្សេងៗ៖

ក. <u>ជនជាតិវៀតណាម</u>ទាំងអស់ដែលចាប់បាននៅសមុទ្រ (រួមទាំង កុមារ ផងដែរ) ត្រូវតែសម្លាប់ជាប្រព័ន្ធនៅពេញសម័យកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ មាស មុត ជាអ្នកសម្រេចអំពីរបៀបនៃការស្លាប់របស់ពួកគេ។ លើកលែងអ្នកដែល សុន សេន ឬមជ្ឈិមបក្ស តម្រូវឱ្យបញ្ជូនទៅ ស-២១[405] ក្រៅពីនោះ មាស មុត បាន បញ្ជាយោធារបស់គាត់ឱ្យបាញ់ជនជាតិវៀតណាមទាំងអស់ដែលនៅលើទូក ចង បោះចូលក្នុងសមុទ្រ ឬសម្លាប់ពួកគេនៅលើកោះ ឬនៅកំពង់សោម រួមទាំងអ្នក ខ្លះនៅទីបញ្ជាការធំផ្ទាល់ខ្លួនរបស់គាត់ផងដែរ[406]។ ចំណុចនេះមានភស្តុតាង បញ្ជាក់តាមរយៈសេចក្តីរាយការណ៍ និងសារទូរលេខដែល មាស មុត បានផ្ញើជូន សុន សេន និងតាមរយៈសក្ខីកម្មសាក្សីដែលបានដាក់ចូលក្នុងសំណុំរឿងក្រោយថ្ងៃ ទី២៩ ខែមេសា ឆ្នាំ២០១១ រួមមានសក្ខីកម្មរបស់សាក្សី ប៉ាក សុខ, ឯក នី, មូល សម្បត្តិ និង មុត ម៉ៅ[407] ។ ឧទាហរណ៍ សាក្សី ឯក នី នៅចាំថា ដំបូង សេចក្តីណែនាំគឺថា ជនជាតិវៀតណាមទាំងអស់ដែលកងកម្លាំងកងពល ១៦៤ ចាប់បាន ត្រូវបញ្ជូនទៅ មាស មុត នៅកំពង់សោម ដើម្បីយកទៅសម្លាប់។ ប៉ុន្តែ

---

ពន្យល់ថា ឥឡូវនេះ វៀតណាម គឺជាខ្មាំងពិតប្រាកដ]។ ឯកសារ **D1.3.34.60** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ 00 ពី មាស មុត ផ្ញើជូន ម.៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH 00001325 [មាស មុត ពន្យល់ថា គាត់នឹង "បោសសម្អាត" សមាស ភាព ខ្មាំង បង្កប់ "ជាយួន នឹងខ្មាំងដទៃទៀត" ដែលបង្ហាញថា គាត់មានអំណាចកម្ទេសអ្នក ទាំងនោះ។ អំពីអំណាចចាប់ខ្លួន និង សួរចម្លើយ *សូមមើល៖* ឯកសារ **D1.3.12.20** កម្ពុជាប្រជាធិបតេយ្យ របាយការណ៍ពី មាស មុត ផ្ញើជូន សុន សេន ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ KH 00020912។ ឯកសារ **D4.1.1020** កម្ពុជាប្រជាធិបតេយ្យ របាយការណ៍ពី មាស មុត ផ្ញើជូន សុន សេន ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00021459។

404 ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២១២(គូសបញ្ជាក់បន្ថែម)។

405 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៨៦-៧, ៤១៧, ៥៤៤។

406 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៦, ៣៨០, ៣៨៧, ៤១៣, ៤២១-៤។

407 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៣២-៤, ១៣៨-៤១, ៣៧៦, ៣៨០, ៣៨៥-៧, ៣៩២-៣, ៣៩៩-៤០៧, ៤១០-១។

ក្រោយមក មាស មុត បានបញ្ជាថា ជនជាតិវៀតណាមទាំងអស់ដែលចាប់បាននៅសមុទ្រ ត្រូវសម្លាប់ ហើយសាកសពត្រូវយកធ្វើជីសម្រាប់ដាំដូងនៅកោះតាង[408]។

ខ. តាមបញ្ជាដោយផ្ទាល់របស់ មាស មុត ជនជាតិថៃដែលចាប់បាន នឹងត្រូវបោះចោលនៅសមុទ្រ សម្លាប់នៅលើទូក នៅលើកោះ ឬនៅកំពង់សោម[409] ហើយជួនកាលបញ្ជូនទៅស-២១[410]។ ជនជាតិថៃមួយចំនួនត្រូវបានដោះលែងវិញ ដោយសារមូលហេតុការទូត ឬដោះដូរជាមួយនឹងទំនិញ ជួនកាលក្រោលពេលធ្វើពលកម្មដោយបង្ខំមួយរយៈ[411]។

គ. ជនបរទេសផ្សេងទៀត (លោកខាងលិច និងជនជាតិអាស៊ីផ្សេងៗទៀត) ដែលយោធារបស់ មាស មុត ចាប់ខ្លួនបាន ជាធម្មតា ត្រូវបញ្ជូនទៅវត្តឥន្ទញាណ ឬ ស-២១ ក្រោយពេលជាប់ឃុំខ្លួនមួយរយៈនៅកោះឫស្សី ឬនៅមន្ទីរសន្តិសុខនានានៅកំពង់សោម[412]។

102. ពាក្យពេចន៍នៅក្នុងសេចក្តីរាយការណ៍ និងទូរលេខជាច្រើនក្នុងចំណោមសេចក្តីរាយការណ៍ និងទូរលេខរបស់ មាស មុត បង្ហាញឲ្យឃើញច្បាស់ថា គាត់ធ្វើការសម្រេចតែម្នាក់ឯងក្នុងការវាយប្រហារ ចាប់ខ្លួន ឬសម្លាប់ អ្នកដែលចាប់បាននៅសមុទ្រ ដោយគ្មានសេចក្តីណែនាំជាក់លាក់ពី សុន សេន ទេ ហើយ ក្រោយតែពេលមានការសម្លាប់រួចហើយទេ ទើបគាត់រាយការណ៍អំពីហេតុការណ៍នេះ។ ឧទាហរណ៍ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ មាស មុត បានរាយការណ៍ថា ជនជាតិ

---

[408] ឯកសារ **D114/282** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.៦៣, ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.៤១, ៤៣-៤៤ *ដកស្រង់នៅក្នុង* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៣២។

[409] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៤-៧, ៣៧៩(ក-គ), ៣៨៩, ៣៩២, ៣៩៤-៥, ៤០០-២, ៤០៦, ៤១០-២, ៤១៤-៧, ៤១៩, ៤២១-៤។ *សូមមើលផងដែរ* ឯកសារ **D1.3.34.10** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ៤៤ ពី មាស មុត ផ្ញើជូន សុន សេន[បង ៨៩] ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ KH 00000860។ ឯកសារ **D118/207.2** កម្ពុជាប្រជាធិបតេយ្យ របាយការណ៍ពី ឌឹម ផ្ញើ សុន សេន និង មាស មុត ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧។

[410] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៧, ៣៧៩(គ), ៥៤៤-៦។

[411] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៥, ៣៧៩(ឃ), ៣៩៦-៧, ៤០៧, ៤១០។

[412] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៨-៩, ១៧៣, ៣៩០-១, ៣៩៨, ៤០៨, ៤២០, ៥៤៩។

វៀតណាម ១២០ នាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់នៅចុងខែមីនា ឆ្នាំ១៩៧៨ ហើយចាប់បានទូកប្រាំគ្រឿង[413]។ ចុងក្រោយ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សាក្សីនានាបានផ្តល់សក្ខីកម្មថា មាស មុត បានឱ្យសេចក្តីណែនាំភ្លាមៗតាមវិទ្យុទាក់ទង ហើយក្នុងករណីបន្ទាន់ សេចក្តីណែនាំបានឱ្យផ្ទាល់ទៅនាវាដែលទទួលខុសត្រូវចាប់ទូក ដែលបង្ហាញថា មិនតម្រូវឱ្យមានការពិគ្រោះយោបល់ថែមទៀតជាមួយថ្នាក់លើឡើយ[414]។ នៅក្នុងអំឡុងពេលវគ្គរៀនសូត្រ មាស មុត ក៏បានចេញសេចក្តីណែនាំនៅកងនាវា ថា ក្នុងករណីបន្ទាន់ កងនាវា ត្រូវវាយប្រហារទូកបរទេសភ្លាមៗ ហើយចាប់ ឬពន្លិចទូកទាំងនោះ មិនរង់ចាំបញ្ជាថែមទៀតទេ[415]។

## ៤.មាស មុត បានបង្កើត និងចូលរួមក្នុងយន្តការកំណត់អត្តសញ្ញាណអ្នកដែលត្រូវចាត់ទុកថាជាខ្មាំង បញ្ជាឱ្យចាប់ខ្លួនទាំងនោះ និងបញ្ជូនអ្នកខ្លះទៅ ស-២១

103. ដីកាលើកលែងចោទប្រកាន់ ពឹងផ្អែកលើចម្លើយរបស់ មាស មុត ដើម្បីសម្រេចថា មិនមានការបញ្ជាក់ថា គាត់បានចាប់ខ្លួន ឬបញ្ជូននរណាម្នាក់ទៅ ស-២១ ទេ[416] ។ ប៉ុន្តែ ដីកាលើកលែងចោទប្រកាន់ យល់ឃើញថា ការចាប់ខ្លួនដែលធ្វើឡើងដោយកងពលរបស់ មាស មុត និងការចាប់ខ្លួនយោធាពីកងពលរបស់គាត់ ធ្វើឡើងតាមសេចក្តីណែនាំរបស់ ប៉ុល ពត, នួន ជា ឬ សុន សេន ឬ ដោយសារថា អ្នកក្រោមបង្គាប់របស់ ឌុច បានចាប់ខ្លួនអ្នកទាំងនោះ[417]។ ដីកាលើកលែងចោទ

[413] ឯកសារ **D54/73.1** (**D4.1.635** & **D1.3.30.25**) របាយការណ៍ទូរសព្ទសម្ងាត់ពី មាស មុត ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH 00979298។ *សូមមើលផងដែរ* ឧទាហរណ៍៖ ឯកសារ **D1.3.34.64** ការទាក់ទងតាមទូរសព្ទកម្ពុជាប្រជាធិបតេយ្យពី មាស មុត ទៅ សុន សេន ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH 00020982 [មាស រាយការណ៍អំពីការបាញ់ពន្លិចទូកវៀតណាមមួយគ្រឿង ចាប់បានទូកថែមមួយគ្រឿងជាមួយនឹងមនុស្ស ២១ នាក់ និងចាប់បានទូកវៀតណាមពីរគ្រឿងដោយជនជាតិវៀតណាម ៧៦ នាក់នៅលើទូកនោះ]។ ឯកសារ **D1.3.34.10** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ៩៤ ពី មាស មុត ផ្ញើជូន សុន សេន[បង ៨៩] ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ KH 00000860។ ឯកសារ **D1.3.12.18** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ 0៩ ពី មាស មុត ផ្ញើជូន សុន សេន ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.12.20** របាយការណ៍ពី មាស មុត ផ្ញើជូន សុន សេន ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ KH 00020912។ ឯកសារ **D1.3.12.7** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៦ KH 00233963។

[414] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៦(ជើងទំព័រ ១៣២៣), ៣៨១(ជើងទំព័រ ១៣៤០), ៣៨២(ជើងទំព័រ ១៣៤៣)។

[415] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៦ (ជើងទំព័រ ១៣២៤)។

[416] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩-៨០, ២៨៩។

[417] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩-៨០, ២៨៣, ២៨៦, ៤២៥។ *សូមមើល* ឯកសារ **D256/7**

ប្រកាន់ លើកឡើងដដែលៗថា មាស មុត មិនមានអំណាចចាប់ខ្លួន បញ្ជូន ឬសម្លាប់នរណាម្នាក់ឡើយ[418] ប៉ុន្តែ គាត់ត្រូវតែតាមដាន និងរាយការណ៍ជនសង្ស័យទៅឱ្យ សុន សេន ដែលជាអ្នកធ្វើសេចក្តីសម្រេចនាពេលបន្ទាប់[419]។ ការសន្និដ្ឋានផ្ទុយទៅនឹង ស្លូម្បីតែឯកសារមួយក្នុងចំណោមឯកសារដែលដីកាលើកលែងចោទប្រកាន់បានដកស្រង់ក៏ដោយ គឺ ទូរលេខមួយពី ឌឹម អនុរបស់គាត់ ដែលរាយការណ៍ថា ការចាប់ខ្លួនខ្មាំងត្រូវបានធ្វើឡើងបន្ទាប់ពីមានសេចក្តីសម្រេចពី មាស មុត[420]។ ចុងក្រោយ ទោះបីជាដីកាលើកលែងចោទប្រកាន់សន្និដ្ឋានថា "មាស មុត បានចូលរួមគាំទ្រគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងការបង្ក្រាបខ្មាំងស៊ីរូងផ្ទៃក្នុង" យ៉ាងណាក៏ដោយ[421] ក៏ដីកាលើកលែងចោទប្រកាន់ សន្និដ្ឋានថា "ទាំងការសម្របសម្រួល ការចាប់បញ្ជូនខ្លួន [យោធាកងពល ១៦៤]"ទៅមន្ទីរសន្តិសុខ ស-២១ ក៏ដូចជា ការបង្ក្រាបក្នុងដែនទឹក ទំនងថា មាស មុត គ្មានសិទ្ធិអំណាចច្រើនទេ"។ ដីកាលើកលែងចោទប្រកាន់ បញ្ជាក់ថា មានតែកងទ័ព ៤២ នាក់ទៅ ៦៧ នាក់នៅកងពល ១៦៤ "និង*មួយចំនួនទៀត* ដែលត្រូវបានចាប់មកពីសមុទ្រ" ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១[422]។ ដីកាលើកលែងចោទប្រកាន់សន្និដ្ឋានថា សមាសភាពទាំងនោះមិនផ្តល់យុត្តាធិការបុគ្គលលើ មាស មុត មក អ.វ.ត.ក ទេ។

104. ការវិភាគនេះផ្អែកលើកំហុសឆ្គងមួយចំនួន។ ដីកាលើកលែងចោទប្រកាន់ធ្វើការប៉ាន់ស្មានទាបយ៉ាងខ្លាំងអំពីជនរងគ្រោះនៅ ស-២១ ដែល មាស មុត ទទួលខុសត្រូវ[423] ហើយដីកាលើកលែងចោទប្រកាន់ មិនបានឱ្យតម្លៃលើកម្រិតដែល មាស មុត បានទទួលខុសត្រូវចំពោះជោគវាសនារបស់ជនរងគ្រោះទាំងនោះទេ។ លើសពីនេះទៀត តាមពិត មាស មុត បានដើរតួនាទីមួយយ៉ាងសំខាន់ក្នុងការសម្រេចថាតើអ្នកទោសណាដែលនឹងត្រូវបញ្ជូនទៅ ស-២១ ឬត្រូវដាក់ទោសនៅកំពង់សោម តាមរយៈ (i) ការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួននៅកំពង់សោម និងក្រចេះ

---

ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥៤០ (ជើងទំព័រ ២០៣៩)។

[418] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩-៨០, ២៨៣, ២៨៦, ៤២៣, ៤២៥។

[419] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៣, ២៨៦, ៣១៩។

[420] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៥ *ដកស្រង់* ឯកសារ **D1.3.34.11** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ១១ ពី ឌឹម ផ្ញើជូន មាស មុត ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦។

[421] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២២។

[422] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥-៦ (គូសបញ្ជាក់បន្ថែម)។

[423] *សូមមើលខាងក្រោម* កថាខណ្ឌ ១៦៩-៧០ [សូមមើលផងដែរ កថាខណ្ឌ ១៥៦, ១៥៨, ១៦០-៤, ១៦៦]។

ចំពោះខ្មាំងផ្ទៃក្នុង និងខ្សែរយៈរបស់ខ្មាំងផ្ទៃក្នុងតាមរយៈប្រព័ន្ធពិនិត្យប្រវត្តិរូប ស្វ័យតិះទៀន ការសួរចម្លើយអ្នកទោស និងការវិភាគលើសកម្មភាពគួរឲ្យសង្ស័យមុនពេលបញ្ជូនអ្នកទោសខ្លះ ទៅ ស-២១[424] (ii) ការផ្តល់អំណាច និងជំនួយឲ្យចាប់ខ្លួន និង/ឬបញ្ជូនខ្មាំងផ្ទៃក្នុងដែលឌុច បានកំណត់អត្តសញ្ញាណតាមរយៈការសួរចម្លើយធ្វើទារុណកម្មនៅ ស-២១[425] (iii) ការកំណត់អត្តសញ្ញាណជនក្បត់ថែមទៀតតាមរយៈខ្លឹមសារចម្លើយសារភាពនៅ ស-២១ និងការសម្រេចចាប់ខ្លួនជនជាប់ពាក់ព័ន្ធ និង/ឬបញ្ជូនពួកគេទៅភ្នំពេញ/ស-២១[426]។ ហេតុនេះ ការចូលរួមរបស់ មាស មុត នៅក្នុងសហឧក្រិដ្ឋកម្មរួម មិនត្រឹមតែមានលក្ខណៈសំខាន់ទេ ប៉ុន្តែក៏មិនអាចខ្វះបានផងដែរ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មឲ្យបានជោគជ័យ។

105. សុន សេន បានស្នើឲ្យ មាស មុត ត្រួតពិនិត្យចម្លើយសារភាពនៅ ស-២១ ហើយកំណត់ ថាតើកងទ័ពដែលជាប់ឈ្មោះនៅក្នុងចម្លើយសារភាពគឺជាជនក្បត់ដែរឬទេ។ ចម្លើយសារភាពចំនួនពីររបស់អ្នកទោស ស-២១ មានចំណារពី សុន សេន ដែលបង្ហាញថា នៅឆ្នាំ១៩៧៧ គាត់បានធ្វើសំណើជាក់លាក់ទៅ មាស មុត សុំឲ្យស៊ើបអង្កេតបន្ថែមទៀត[427]។ ឌុច បានបញ្ជាក់ថា កងពលមជ្ឈិមរបស់ ក.ប.ក បានទទួលចម្លើយសារភាព ស-២១ ដោយសារមូលហេតុចំនួនពីរ៖ "ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និង [...]អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់[428]។ គាត់បានបន្ថែមថា "មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ"[429] ហើយ "មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"[430]។

---

[424] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៨, ៨៤, ១០៣-៦, ១១៥-៦, ១១៨-២៣, ១៥១, ១៥៦-៧, ១៥៩-៦១, ១៧២-៣, ៣៣៧-៣៤០, ៣៤៦-៥០, ៣៥៦-៨, ៥៣៩, ៥៤៣, ៥៥០-១។

[425] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១១៣, ១១៩, ១៦៣-៤, ១៦៨, ១៧២, ៣៤៦, ៣៥៧, ៥៣៩, ៥៤២-៣, ៥៥០។

[426] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១០៦, ១០៨-១០, ១១៧, ១៦៨-៧០, ៣៤៦-៧, ៣៥០, ៣៥៦, ៣៥៨-៩, ៥៣៩-៤០។

[427] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១១៧, ៥៣៩(ជើងទំព័រ ២០៣២), ៥៤០។

[428] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥៣៩(ជើងទំព័រ ២០៣០)។

[429] ឯកសារ **D4.1.400** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00239838។

[430] ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00680805។ ដីកាលើកលែងចោទប្រកាន់ សង្កត់ធ្ងន់ថា ឌុច បានបញ្ជាក់

106. មាស មុត បានជួបប្រជុំជាទៀងទាត់ជាមួយតំណាង ស-២១ នៅក្នុងអង្គប្រជុំសេនាធិការ (ឬវគ្គរៀនសូត្រ) ដែលនៅពេលនោះ លេខាកងពល រាយការណ៍អំពីអ្នកទោសដែលបានបញ្ជូនទៅ ស-២១[431]។ នៅក្នុងកិច្ចសម្ភាសន៍មួយជាមួយនឹងវីអូអេ មាស មុត បានសារភាពខ្លួនឯងថា គាត់ដឹងថា អ្នកខ្លះក្នុងចំណោមអ្នកក្រោមបង្គាប់គាត់ត្រូវបានយកទៅ ស-២១ ក្រោយពីចូលរួមរៀនសូត្រនៅភ្នំពេញ[432] ។ ភស្តុតាងដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ បង្ហាញយ៉ាងច្បាស់ថា នៅក្នុងអង្គប្រជុំធំមួយចំនួនរបស់កងពល ១៦៤ ដែល មាស មុត ធ្វើជាគណៈអធិបតី គាត់ បានប្រកាសអំពីការចាប់ខ្លួន"ជនក្បត់" និងពិភាក្សា ឬអានសេចក្ដីដកស្រង់ពីចម្លើយសារភាព ស-២១ ជាពិសេសចម្លើយសារភាពរបស់អនុគាត់[433]។ លើសពីនេះទៀត មុនពេលបញ្ជូនទៅ ស-២១ អ្នកទោសបានជាប់ឃុំខ្លួនបណ្ដោះអាសន្ននៅតំបន់កំពង់សោម រួចហើយដោយមានការឯកភាពពី មាស មុត[434]។

107. ដីកាលើកលែងចោទប្រកាន់ បញ្ជាក់ថា បុគ្គលិក ស-២១ រួមមានសាក្សី ហ៊ឹម ហ៊ុយ[435]បាន បញ្ជូនអ្នកទោសពីកំពង់សោម ទៅ ស-២១ នៅឆ្នាំ១៩៧៧-១៩៧៨ ។ ប៉ុន្តែ នៅក្នុងការស្ដាប់ចម្លើយមួយនៅឆ្នាំ២០១៥ ដែលដីកាលើកលែងចោទប្រកាន់ មិនបានយកចិត្តទុកដាក់ ហ៊ឹម ហ៊ុយ បានបញ្ជាក់ថា គាត់មិនដែលបានទៅយកអ្នកទោសនៅកំពង់សោម ទេ[436]។ លើសពីនេះទៀត ឌុច បានបញ្ជាក់

---

ថា "ចំពោះ ស៊ូ ម៉េត និង មាស មុត មិនមានឯកសារបញ្ជាក់ពីការសុំពិនិត្យនេះទេ"។ (**D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៤)។ ការបញ្ជាក់នេះផ្ទុយពីចំណាររបស់ សុន សេន នៅក្នុងចម្លើយសារភាពចំនួនពីរ។ ដោយគិតថា រកឃើញតែចម្លើយសារភាព ស-២១ មួយចំនួនតូចប៉ុណ្ណោះដែលមានចំណាររបស់ សុន សេន ទើប គោលការណ៍ជាទូទៅដែល ឌុច រៀបរាប់ នៅតែមានសុពលភាព។

[431] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ ៥៣៦, ៥៤០(ជើងទំព័រ២០៣៦-៧)។

[432] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ ៣៤៧(ជើងទំព័រ ១១៩៩) [អនុមានឈ្មោះ ជ័យ ហាន ហៅ ឆាន មកពីតំបន់ ៣៧ និង ហ៊ឹង ឌឿន ហៅ ឌឹម មកពីភូមិភាគបូព៌ា និងអ្នកផ្សេងប៉ុន្មាននាក់ទៀត]។

[433] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ ១០៧-១០, ៥៤៣ (ជើងទំព័រ ២០៦៤)។

[434] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ កថាខណ្ឌ ៣៤៧, ៣៥៨, ៤៨៥ (ជើងទំព័រ ១៨១៩), ៥០០, ៥៤៦, ៧៩៧។ *សូមមើលខាងលើផងដែរ* កថាខណ្ឌ ៦៦, ១០១(គ), ៥៥ (ជើងទំព័រ ១៨៧)។ *សូមមើលខាងក្រោម* កថាខណ្ឌ ១២៣, ១២៧, ១៦៧។

[435] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៩-៨០ [ដកស្រង់ ហ៊ឹម ហ៊ុយ], កថាខណ្ឌ ៣១៩។ *សូមមើលផងដែរ* ចំពោះជនលោកខាងលិច ឯកសារ **D54/16/1R** ខ្សែអាត់សំឡេងនៃបទសម្ភាន់ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ២០០៩ 49:18-50:33[ភាសាអង់គ្លេស]។

[436] ឯកសារ **D114/92** កំណត់ហេតុស្ដាប់ចម្លើយ ហ៊ឹម ហ៊ុយ ឆ.២១-៨ [ពន្យល់ថា គេប្រាប់ថានឹងទៅកំពង់សោម ប៉ុន្តែ បែរជា

ថា មុនឆ្នាំ១៩៧៧ បុគ្គលិក ស-២១ ជាធម្មតា រៀបចំការដឹកអ្នកទោសពីកងពល ទៅ ស-២១ ប៉ុន្តែពេលខ្លះ កងពលបញ្ជូនអ្នកទោសមកដោយខ្លួនឯង។ ចាប់ពីឆ្នាំ១៩៧៧ ទៅ ដូចបានទទួលស្គាល់នៅក្នុងដីកាលើកលែងចោទប្រកាន់[437] ឌុច បានពន្យល់ថា កងពលទទួលខុសត្រូវនាំអ្នកទោសមកភ្នំពេញ[438] លើកលែងតែកម្មាភិបាលថ្នាក់ខ្ពស់ដែលត្រូវមជ្ឈិមបក្ស អញ្ជើញឱ្យចូលរួមអង្គប្រជុំនៅភ្នំពេញ សិនមុនពេលយកទៅ ស-២១។ ករណីនេះក៏ធ្វើដូចគ្នាផងដែរចំពោះកងពល ១៦៤ និងតំបន់ស្វយតកំពង់សោម ដោយ មុនឆ្នាំ១៩៧៧ មាស មុត ម្តងម្កាលដឹកអ្នកទោស ទៅ ស-២១ ហើយក្រោយឆ្នាំ១៩៧៧ គាត់ធ្វើដូច្នេះជាលក្ខណៈប្រព័ន្ធ លើកលែងតែកម្មាភិបាលថ្នាក់ខ្ពស់ដែលត្រូវមជ្ឈិមបក្សអញ្ជើញឱ្យមកភ្នំពេញ[439]។

## ៥. ការអនុវត្តខុសគ្នាតាមអំពើចិត្តចំពោះការបញ្ជាថ្នាក់លើ ការបង្ខំ និងការគំរាមកំហែង នៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០៣

108. ការសន្និដ្ឋានផ្ទាល់របស់ ស.ច.ស.ជ នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០១ ផ្តល់ការបដិសេធទាំងស្រុងចំពោះការអះអាងដែលថា ទង្វើដែលបានធ្វើឡើងតាមបញ្ជាថ្នាក់លើ ធ្វើឱ្យជនណាម្នាក់រួចផុតពីប្រភេទជនដែល "ទទួលខុសត្រូវខ្ពស់បំផុត"។ នៅក្នុងសំណុំរឿង ០០១ ស.ច.ស បានសន្និដ្ឋានថា ឌុច បានទទួលបញ្ជាជាក់លាក់ពីថ្នាក់លើរបស់គាត់ចំពោះបញ្ហាជាច្រើន រួមទាំង (i)

---

ទៅយកអ្នកទោសនៅស្រែអំបិល នៅភូមិភាគនិរតី] ឆ.៣០-១, ៣៧ (និយាយថាបានឃើញ ជនស៊ីវិលថៃ ២០ នាក់ទៅ ៣០ នាក់ដែលត្រូវនាំមក ស-២១នៅឆ្នាំ១៩៧៦ ឬ១៩៧៧ មិនបានមកដល់ ស-២១ តាមឡាន ស-២១ទេ)]។

[437] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៧៥(ជើងទំព័រ ៨៥៨)។

[438] ឯកសារ **D4.1.1118** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00195597-8 ["ចាប់តាំងពីឆ្នាំ១៩៧៧មក [...] អង្គភាពដទៃទៀតដែលជាអ្នកទទួលបន្ទុកដឹកជញ្ជូន(កងពល១៧០ កងពល ២៩០ កងពល៣១០ [...] ។ល។)"]។ ឯកសារ **D4.1.1109** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00177581 [ពន្យល់ថា ចំពោះវៀតណាម ដំបូង បុគ្គលិក ស-២១ ជួនកាលដឹកអ្នកទោសទាំងនេះ ដោយមានកាន់លិខិតដើរផ្លូវពិសេស ប៉ុន្តែ ក្រោយមក ការរៀបនេះត្រូវបានលុបចោលវិញ។ ស-២១ ឈប់ដឹក ហើយមានភារកិច្ចតែទទួលអ្នកទោសទេ]។ ឯកសារ **D1.3.33.9** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00178048 ["ចំពោះជនជាតិវៀតណាម[ឈ្លើយសឹក]ស២១ មិនដែលទទួលខុសត្រូវដឹកជញ្ជូននោះទេ គឺអង្គភាពដែលចាប់ទេ ដែលជាអ្នកដឹកជញ្ជូនអ្នកទោសង្គ្រាមទាំងនោះមក ស ២១ ដោយខ្លួនឯង"]។ ឯកសារ **D4.1.404** កំណត់ហេតុស្តាប់ចម្លើយ ឌុច KH 00242921។

[439] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤១៧។

សេចក្តីដកស្រង់ និងខ្លឹមសារចម្លើយសារភាព[440] (ii) របបអាហារដែលត្រូវឱ្យអ្នកទោស[441] (iii) ការពិសោធន៍វេជ្ជសាស្ត្រលើអ្នកទោសមួយចំនួន[442] (iv) ការប្រើប្រាស់ការធ្វើទារុណកម្មលើអ្នកទោសមួយចំនួន[443] (v) នីតិវិធីរដ្ឋបាលដែលត្រូវអនុវត្តនៅពេលដែលប្រហារជីវិតអ្នកទោស[444] និង (vi) របៀបសម្លាប់ និងបោះចោលសាកសពអ្នកទោសសំខាន់ៗមួយចំនួន[445]។ ស.ច.ស ក៏បានសន្និដ្ឋានថា ឌុច មានឥទ្ធិពលមានកម្រិតលើអ្នកដែលគេចាប់ខ្លួនបាន[446]។ គាត់មិនអាចបដិសេធមិនទទួលយកអ្នកទោសដែលបានបញ្ជូនមកគាត់ទេ។ ក្រោយពីការស៊ើបអង្កេត គាត់មិនមានសេរីភាពធ្វើសេចក្តីសន្និដ្ឋានថា នរណាម្នាក់គ្មានទោសទេ[447]។ គាត់មិនអាចដោះលែងអ្នកទោសបានទេ[448] ហើយគាត់គ្មានឆន្ទានុសិទ្ធិក្នុងការមិនសម្លាប់អ្នកទោសដែលបានបញ្ជូនមកគាត់ទេ។ សេរីភាពធំបំផុតដែលធ្លាក់លើគាត់បានឱ្យគាត់គឺសិទ្ធិទុកអ្នកទោសមួយចំនួនដែលមានជំនាញ ឱ្យនៅរស់សម្រាប់ធ្វើការមួយរយៈពេល[449]។ ស.ច.ស បានសម្រេចយ៉ាងច្បាស់ថា "តួនាទីចម្បងរបស់មន្ទីរ ស-២១ '*គឺការអនុវត្តមាគ៌ានយោបាយបក្ស*ចំពោះខ្មាំង'"[450]។

109. ការត្រួតពិនិត្យដោយត្រឹមត្រូវលើដីកាដំណោះស្រាយសំណុំរឿង ០០១ និងភស្តុតាងនៅក្នុងសំណុំរឿង ០០៣ បង្ហាញថា មាស មុត មានឆន្ទានុសិទ្ធិជាង ឌុច ទៅលើរបៀបដែលគាត់អនុវត្តសេចក្តីណែនាំរបស់គាត់ ហើយមួយផ្នែកដោយសារថា មាស មុត មានតំណែងខ្ពស់ជាងខ្លាំងនៅក្នុងឋានានុក្រម ប.ក.ក និង ក.ប.ក។ ខណៈដែល មាស មុត មានភារកិច្ចអនុវត្តគោលនយោបាយប្រឆាំងខ្មាំងផ្ទៃក្នុង និងខាងក្រៅរបស់ ប.ក.ក ក៏មានភស្តុតាងតិចតួចបញ្ជាក់ថា គាត់ទទួលបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់ជនមួយចំនួន។ ឌុច គ្រាន់តែទទួលអ្នកទោសដែលបានបញ្ជូនមកគាត់ ហើយ

[440] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៩៩។
[441] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៦៨។
[442] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៧០។
[443] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៨៥, ៩៩។
[444] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១០៧។
[445] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ១២២។.
[446] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣៣, ៥១-២។
[447] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៤៤, ៥៣។
[448] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣១។
[449] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣១, ១១១។
[450] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាខណ្ឌ ៣១ (គូសបញ្ជាក់បន្ថែម)។

គ្មានសិទ្ធិអំណាច ឬមានសិទ្ធិអំណាចមានក្រមិត ក្នុងការដោះលែងអ្នកដែលគាត់ត្រូវបានបញ្ជាឲ្យសួរចម្លើយ និងសម្លាប់។ ផ្ទុយទៅវិញ មាស មុត មានអំណាចធ្វើសេចក្តីសម្រេចលើជោគវាសនារបស់ជនដែលស្ថិតនៅក្រោមអំណាចរបស់គាត់ ជាពិសេស កងទ័ពថ្នាក់ក្រោមដែលត្រូវបានបោសសម្អាត ឬគ្មានវិន័យ និងជនស៊ីវិល[451]។ មានភស្តុតាងតិចតួចរហូតដល់គ្មានភស្តុតាងបញ្ជាក់ថា មិនដូច ឌុច ទេ មាស មុត "ឋិតនៅក្រោមការឃ្លាំងមើលជាប្រចាំ"ពីសំណាក់សុន សេន ឬសមាជិកគណៈអចិន្ត្រៃយ៍[452]។

110. ដីកាលើកលែងចោទប្រកាន់ សន្និដ្ឋានថា ក្នុងនាមជាកម្មាភិបាលថ្នាក់ក្រោមនៅកម្ពុជាប្រជាធិបតេយ្យ មាស មុត ត្រូវតែគោរពតាមបញ្ជាទាំងអស់ ហើយខ្លាចបាត់បង់ជីវិតគាត់ ប្រសិនបើគាត់មិនធ្វើតាម ដែលចង់បង្ហាញថាជាសំអាងហេតុមួយសម្រាប់សេចក្តីសម្រេចថា គាត់មិនបាន"ទទួលខុសត្រូវខ្ពស់បំផុត"ទេ[453]។ ប៉ុន្តែ នៅក្នុងសំណុំរឿង ០០១ ស.ច.ស បានទទួលស្គាល់ភស្តុតាងរបស់ ឌុច ដែលថា ការបោសសម្អាតរបស់ ប.ក.ក ធ្វើឲ្យគាត់ "មានអារម្មណ៍ព្រួយបារម្ភ និងភ័យខ្លាចចំពោះអាយុជីវិតរបស់គាត់" "ខ្លាចរហូតដល់គិតតែពីដេកទាំងយប់ទាំងថ្ងៃ"[454] ហើយភ័យខ្លាចបាត់បង់ជីវិតសមាជិកគ្រួសារគាត់[455]។ អារម្មណ៍ភ័យខ្លាចរបស់គាត់កាន់តែកើនឡើងតាមរយៈការជួបប្រទះ ពីព្រោះថា គាត់បានដឹងថា សមាជិកជាន់ខ្ពស់ជាច្រើននាក់នៅក្នុង ប.ក.ក ដែលមានតួនាទីខ្ពស់ជាងគាត់ខ្លាំងនៅក្នុងឋានានុក្រមបក្ស ត្រូវបានដាក់គុក ទទួលរងអំពើអមនុស្សធម៌ ត្រូវបានធ្វើទារុណកម្ម និងសម្លាប់នៅ ស-២១។

111. ដោយឃើញថា បញ្ជាថ្នាក់លើ ការបង្ខំ និងការគំរាមកំហែង មិនបានឲ្យ ឌុច ផុតពីប្រភេទជនដែល"ទទួលខុសត្រូវខ្ពស់បំផុត"ទេ ទើបមិនអាចធ្វើដូច្នេះបានចំពោះករណី មាស មុត ដែរ។ ប្រសិនបើសម្រេចថា មាស មុត ស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដោយសារថា គាត់ធ្វើតាមបញ្ជាថ្នាក់លើ ហើយមានការភ័យខ្លាចអំពីផលលំបាក ប្រសិនបើប្រឆាំង ចំណែកឯ ឌុច, នួន

[451] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៧៩-៨៧។

[452] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាណ្ឌ ១៧០។

[453] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៩៨, ១០០, ២៥៦, ២៨៤, ៤១២, ៤១៥, ៤២០។

[454] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាណ្ឌ ១៦៩។

[455] សំណុំរឿង ០០១ -ឯកសារ **D99** ដីកាដំណោះស្រាយ *ឌុច* កថាណ្ឌ ១៧០។

ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ វិញ ស្ថិតនៅក្នុងយុត្តាធិការ នោះមានន័យថា ជនស្ថិតក្នុងស្ថានភាពស្រដៀងគ្នា ទទួលបានការអនុវត្តច្បាប់ផ្សេងគ្នាតាមអំពើចិត្ត។

## ខ. កំហុសអង្គច្បាប់ និងអង្គហេតុនៅក្នុងដីកាលើកលែងចោទប្រកាន់ពាក់ព័ន្ធនឹងការពិនិត្យនៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅពេលកំណត់កម្រិតនៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

### ១. ដីកាលើកលែងចោទប្រកាន់ ឱ្យតម្លៃហួសហេតុទៅលើការចូលរួមដោយផ្ទាល់ និងការនៅជិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងការវិភាគអំពីយុត្តាធិការបុគ្គល

112. ដីកាលើកលែងចោទប្រកាន់ បញ្ជាក់ថា ដោយសារអ្នករៀបចំកិច្ចព្រមព្រៀង អ.វ.ត.ក បានដាក់បញ្ចូលប្រភេទជនដែល"ទទួលខុសត្រូវខ្ពស់បំផុត"សម្រាប់ករណី ឌុច អតីតប្រធាន ស-២១ ទើបមានន័យថា "ជនដែលទទួលខុសត្រូវខ្ពស់បំផុតនេះជាបុគ្គលដែលដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ កៀកកិតនឹងការប្រព្រឹត្តិ មានស្វ័យភាពក្នុងការងារ និងអំណាចតាមការអនុវត្តជាក់ស្តែង"[456] ហើយជនដែលស្ថិតនៅថ្នាក់ក្រោម អាចត្រូវកំណត់ថា "ទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកតែលើ "ការចូលរួមចំណែកដោយឡែកៗរបស់បុគ្គលនោះចំពោះអំពើឃោរឃៅ"[457]។ ដីកាលើកលែងចោទប្រកាន់បន្តទៀតថា "វិសាលភាពនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និងអានុភាពនៃអំពើទាំងនោះ គឺជាចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវមួយ"[458]។

---

[456] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៦-៧ ["ជារួម គេអាចនិយាយបានថា ពាក្យ 'ជនដែលទទួលខុសត្រូវខ្ពស់បំផុត' ត្រូវបានដាក់បញ្ចូលសម្រាប់តែករណីពិសេសលើអតីតប្រធានមន្ទីរសុខ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច [...]។ ការដាក់បញ្ចូល ឌុច ក្នុងន័យថា ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនេះ ជាបុគ្គលដែលដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ កៀកកិតនឹងការប្រព្រឹត្ត មានស្វ័យភាពក្នុងការងារ និងអំណាចតាមការអនុវត្តជាក់ស្តែង"]។ *សូមមើលថែមទៀត* ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧៣ ["ឌុច ជាជនទទួលខុសត្រូវខ្ពស់បំផុត ជាសំខាន់ផ្តោតលើការចូលរួមផ្ទាល់ អំណាច និងឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេច និងចាត់ចែង"], កថាខណ្ឌ ៤០៥ ["បុគ្គលដែលនឹងស្ថិតចូលក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺពិតជាមានចំនួនតិចតួចបំផុត ដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលមានអំណាច និងជនដែលទទួលខុសត្រូវខ្ពស់បំផុតដែលបានចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ និងកៀកជិតនឹងទង្វើប្រព្រឹត្តិតាមរយៈអំណាច និងឥទ្ធិពលជាក់ស្តែងហួសពីអំណាចផ្លូវការដែលមាន"]។

[457] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨។

[458] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨។

113. នៅពេលដែលវាយតម្លៃការចូលរួម និងសិទ្ធិអំណាចរបស់ មាស មុត នៅទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដីកាលើកលែងចោទប្រកាន់សង្កត់ធ្ងន់ដដែលៗថា មាស មុត មិនមានវត្តមានដោយផ្ទាល់ទេ[459] ហើយធ្វើសេចក្តីសន្និដ្ឋានថា គាត់មិនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យទេ ដោយសារថា គាត់ "មិនសកម្ម មិនជុំកំភួន និងមិនបានកៀកកិតនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ" និងដោយសារថា ចំនួនជនរងគ្រោះដោយសារអំពើ *ផ្ទាល់* របស់ មាស មុត ទាបជាងករណី ឌុច[460]។

114. ទទ្បីករណ៍ទាំងនេះមានកំហុសឆ្គងខាងហេតុផល អង្គច្បាប់ និងអង្គហេតុ។ ទីមួយ ដូចបានបង្ហាញលម្អិតថែមទៀតនៅខាងក្រោម ប្រភេទជនដែល"ទទួលខុសត្រូវខ្ពស់បំផុត" ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ទាំងតាមខ្លឹមសារ ទាំងតាមចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺថា ជាប្រភេទជនទូទៅដែលអាចកំណត់បានតែដោយសហព្រះរាជអាជ្ញា និងចៅក្រម អ.វ.ត.ក ផ្អែកលើភស្តុតាងរួម។ តាមពិត ដីកាលើកលែងចោទប្រកាន់សន្និដ្ឋានយ៉ាងត្រឹមត្រូវថា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ត្រូវតែកំណត់តាមភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ដោយពិចារណាលើកត្តាផ្សេងៗរាប់មិនអស់[461] ។ កត្តាទាំងនោះមិនតម្រូវថាត្រូវតែនៅកៀកកិតផ្ទាល់នឹងបទឧក្រិដ្ឋ ឬការប្រព្រឹត្តិដោយផ្ទាល់នោះទេ[462] ។

115. ចំណុចនេះត្រឹមត្រូវយ៉ាងខ្លាំង។ អំពើដែលចូលរួមចំណែកក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិ អាចមិនមែនជាអំពើប្រព្រឹត្តដោយផ្ទាល់តាមភូមិសាស្ត្រ និងពេលវេលាទេ ហើយជារឿយៗ ចំពោះជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត មិនមែនជាអំពើប្រព្រឹត្តដោយផ្ទាល់តាមភូមិសាស្ត្រ និង

---

[459] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧, ៣០៥, ៣១១។

[460] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨ (គូសបញ្ជាក់បន្ថែម)។

[461] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៥-៧។ ខាងលើ កថាខណ្ឌ ៩-១២។

[462] កត្តាមួយក្នុងចំណោមកត្តាដែលត្រូវពិចារណានៅក្នុងការវិភាគលើកម្រិតនៃការទទួលខុសត្រូវ និងកម្រិតនៃការចូលរួមរបស់ជនត្រូវចោទនៅក្នុងឧក្រិដ្ឋកម្ម។ ខណៈដែលពាក្យ "ការចូលរួម"មិនមែនជាពាក្យមួយដែលមានន័យជាក់លាក់ទេ ប៉ុន្តែច្បាស់ណាស់ ពាក្យនេះមិនកម្រិតនៅត្រឹមថា ការចូលរួម*ដោយផ្ទាល់* ទេ ហើយឧស្សាហ៍ត្រូវបានប្រើប្រាស់ដើម្បីសំដៅលើទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ដែលមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក។ *សូមមើល* ឧទាហរណ៍ *សាលដីកា Kayishema & Ruzindana* កថាខណ្ឌ ១៨៥, *សាលក្រម Musema* កថាខណ្ឌ ១១៤, *សាលក្រម Kamuhanda* កថាខណ្ឌ ៥៨៨, *សាលដីកា* Delalić កថាខណ្ឌ ៣៥១។

ពេលវេលាទេ។ ចាប់តាំងពីការជំនុំជម្រះក្ដីក្រោយសង្គ្រាមលោកលើកទីពីរ មានការកំណត់ថា ដើម្បីសន្និដ្ឋានពីការទទួលខុសត្រូវតាមរយៈទម្រង់ណាមួយនៃការទទួលខុសត្រូវដែលមានចែងនៅក្នុងមាត្រា ២៩ នៃ ច្បាប់ អ.វ.ត.ក មិនតម្រូវថា ត្រូវមានវត្តមានដោយផ្ទាល់នៅទីតាំងឧក្រិដ្ឋកម្មទេ លើកលែងតែការប្រព្រឹត្តិដោយផ្ទាល់[463]។ ចំណុចនេះត្រូវបានទទួលស្គាល់ចំពោះការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម[464]។ តាមពិត ការចូលរួមនៅក្នុងគោលបំណងរួម មិនចាំបាច់ទាល់តែ

---

[463] *សូមមើល ឧទាហរណ៍ សាលក្រម* Tadić កថាខណ្ឌ ៦៧៩ [“ការចូលរួមនោះនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម មិនតម្រូវឱ្យមានវត្តមានផ្ទាល់ជាក់ស្ដែងទេ ឬក៏ការជួយដោយមានវត្តមានផ្ទាល់ បង្ហាញឱ្យឃើញត្រូវបានទទួលយកយ៉ាងខ្លាំងនៅការជំនុំជម្រះក្ដីឧក្រិដ្ឋកម្មសង្គ្រាម Nürnberg”] និងកថាខណ្ឌ ៦៨១ [“មិនចាំបាច់ត្រូវមានវត្តមានដោយផ្ទាល់ជាក់ស្ដែងទេនៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត”] *ដោយដកស្រង់*រឿងក្ដី *Golkel* Case ទំព័រ ៥៣ [ភាសាអង់គ្លេស] [“ច្បាស់ណាស់គឺថាពាក្យពេចន៍ទាំងនោះ [‘ពាក់ព័ន្ធនឹងការសម្លាប់’] មិនមានន័យថា ជាក់ស្ដែង គេត្រូវតែមានវត្តមាននៅកន្លែងបាញ់ប្រហារទេ” និង*ការជំនុំជម្រះក្ដី និងមនុស្ស ១៧ នាក់ទៀត* តុលាការយោធាចក្រភពអង់គ្លេស ទីក្រុង Hamburg ប្រទេសអាល្លឺម៉ង់ ថ្ងៃទី ១ ខែកក្កដា ដល់ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៤៧ ត្រូវបានរាយការណ៍នៅក្នុង LRTWC វ៉ុល XI ទំព័រ ៤៣-៤៤[ភាសាអង់គ្លេស] [“ដោយរកឃើញថា ជនចាប់ចោទ Schimmel និង Gmeiner មានពិរុទ្ធភាព តុលាការ បានបង្ហាញថា ការ‘ពាក់ព័ន្ធនឹងការសម្លាប់’មិនចាំបាច់ទាល់តែថា ជនជាប់ចោទត្រូវមានវត្តមាននៅកន្លែងឧក្រិដ្ឋកម្មទេ ពីព្រោះថា ទាំង Schimmel ទាំង Gmeiner បានឱ្យសេចក្ដីណែនាំទៅឱ្យអ្នកក្រោមបង្គាប់របស់ខ្លួន ប៉ុន្តែមិនបានមានវត្តមាននៅកន្លែងបាញ់ប្រហារទេ”(ដោយដកស្រង់ពីទំព័រ ៤៦ [ភាសាអង់គ្លេស])។ រឿងក្ដី *Gustav Becker, Wilhelm Weber និងមនុស្ស ១៨ នាក់ផ្សេងទៀត* សាលាក្ដីយោធាអចិន្ត្រៃយ៍ នៅលីយ៉ុង ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៤៧ LRTWC វ៉ុល VII ទំព័រ ៦៧, ៧០ [ភាសាអង់គ្លេស]។ [ជនជាប់ចោទទាំអស់ ក្រៅពីជនជាប់ចោទម្នាក់ បានចាប់ជនស៊ីវិលប៉ុន្មាននាក់នៅក្នុងប្រទេសបារាំងដែលស្ថិតក្រោមការកាន់កាប់ បន្ទាប់មក ជនស៊ីវិលទាំងនោះត្រូវបាននិរទេសទៅជំរុំការងារនៅប្រទេសអាល្លឺម៉ង់ ហើយមនុស្សបីនាក់ក្នុងចំណោមជនស៊ីវិលទាំងនោះបានស្លាប់នៅទីនោះដោយសារការធ្វើបាប]។ ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ ដោយសារធ្វើឱ្យជនស៊ីវិលបារាំងទាំងនោះស្លាប់នៅអាល្លឺម៉ង់ តាមរយៈការចូលរួមចំណែក និងការសម្របសម្រួលនិរទេសជនស៊ីវិលទាំងនោះ]។ *សាលក្រម Kayishema & Ruzindana* TJ កថាខណ្ឌ ២០០ [“មិនមានការសន្មតថា ជនជាប់ចោទត្រូវតែមានវត្តមាននៅកន្លែងឧក្រិដ្ឋកម្មទេ ហើយការចូលរួមចំណែករបស់គាត់ មិនចាំបាច់ត្រូវទាល់តែជាការចូលរួមចំណែកដោយផ្ទាល់ដែរ”]។

[464] *សូមមើលឧទាហរណ៍* សាលដីកា *Krnojelac* កថាខណ្ឌ ៨១ [“អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា មិនតម្រូវឱ្យមានវត្តមានរបស់អ្នកចូលរួមសហឧក្រិដ្ឋកម្មរួមឡើយនៅពេលដែលឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយជនល្មើសផ្ទាល់”។ សាលដីកា *Kvočka* កថាខណ្ឌ ១១២។ សាលដីកា *Simba* កថាខណ្ឌ ២៩៦។ សាលដីកា *Karemera & Ngirumpatse* កថាខណ្ឌ ១៥៣ [“មិនសំខាន់ថាតើ Ngirumpatse នៅក្រៅប្រទេសដែរឬអត់នោះទេនៅពេលដែលអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តនោះ។ អ្នកចូលរួមសហឧក្រិដ្ឋកម្ម មិនតម្រូវឱ្យមានវត្តមានដោយផ្ទាល់នៅពេល និងនៅទីកន្លែងដែលឧក្រិដ្ឋបានប្រព្រឹត្តទេ”]។ សាលក្រម *Bagilishema* កថាខណ្ឌ ៣៣។

ចូលរួមប្រព្រឹត្តបទឧក្រិដ្ឋណាមួយឡើយ[465] ហើយអ្នកចូលរួមអាចមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិកនៅក្នុងសហឧក្រិដ្ឋកម្មរួម[466]។ ស្រដៀងគ្នានេះដែរ ការប្រព្រឹត្តិដោយផ្ទាល់ ឬវត្តមានដោយផ្ទាល់ មិនតម្រូវឱ្យមានទេចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈការរៀបចំផែនការ ការញុះញង់ និងការបញ្ជា[467] ឬតាមរយៈការជួយ និងការជំរុញ[468] ឬការទទួលខុសត្រូវថ្នាក់លើ[469]។

116. ប្រសិនបើអំពើតាមរយៈទម្រង់ណាមួយនៃការទទួលខុសត្រូវ ក្រៅពីការចូលរួមដោយផ្ទាល់ មិនអាចឱ្យសម្រេចថា ជនសង្ស័យឈានដល់កម្រិត "ទទួលខុសត្រូវខ្ពស់បំផុត" ទេនោះ សូម្បីតែមនុស្សម្នាក់ក៏ស្ទើរតែមិនអាចត្រូវបានកាត់ទោសផង ក្រៅពីអ្នកដែលមានតួនាទីទាបបំផុតនៅក្នុងរបបឧក្រិដ្ឋមួយណាមួយ ដូចជា កម្ពុជាប្រជាធិបតេយ្យ ជាដើម។ ដោយពិនិត្យមើលលក្ខណៈជារួមនៃឧក្រិដ្ឋកម្មអន្តរជាតិ កម្រិតនៃការទទួលខុសត្រូវ ជាទូទៅកើនឡើង ចំណែកឯ ការកៀកកិតនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ និងការប្រព្រឹត្តិដោយផ្ទាល់ ថយចុះ។ ឧត្តមសេនីយ៍ដែលរៀបចំផែនការសម្លាប់រង្គាល ត្រូវចាត់ទុកថាជាអ្នកទទួលខុសត្រូវច្រើនជាងទាហានថ្មើជើងដែលបានអនុវត្ត

---

[465] សំណុំរឿង ០០២ -E313 សាលក្រមសំណុំរឿង ០០២/១ កថាខណ្ឌ ៦៩៣។ សំណុំរឿង ០០១-E188 សាលក្រម *ឌុច* កថាខណ្ឌ ៥០៨។ *សាលដីកា Tadić* កថាខណ្ឌ ២២៧, ២២៩។ សាលដីកា *Šainović* កថាខណ្ឌ ៩៨៥។ សាលដីកា *Prlić* កថាខណ្ឌ ១៤១០, ១៨៨០។ សាលដីកា *Sesay* កថាខណ្ឌ ៦១១។

[466] សំណុំរឿង ០០២-F36 សំណុំរឿង ០០២/០១ សាលដីកា កថាខណ្ឌ ១០៤០។ សំណុំរឿង ០០២ -E313 សាលក្រមសំណុំរឿង ០០២/១ កថាខណ្ឌ ៦២៥។ សាលដីកា *Prlić* កថាខណ្ឌ ១៩៩៨។ សាលដីកា *Brđanin* កថាខណ្ឌ ៤១០-៤១៤។ សាលដីកា *Đorđević* កថាខណ្ឌ ១៦៥។ សាលដីកា *Sesay* កថាខណ្ឌ ៣៩៨-៤០០។

[467] សាលដីកា *Boškoski & Tarčuloski* កថាខណ្ឌ ១៣២ ["អង្គជំនុំជម្រះតុលាការកំពូល រំឭកថា វត្តមានរបស់ជនជាប់ចោទនៅកន្លែងឧក្រិដ្ឋ មិនមែនជាធាតុផ្សំតម្រូវនៃការរៀបចំផែនការ ការញុះញង់ និងការបញ្ជាឡើយ"]។ *សូមផងដែរ* <u>ការញុះញង់</u>៖ សាលដីកា *Nahimana* កថាខណ្ឌ ៦៦០, សាលដីកា *Nyiramasuhuko* កថាខណ្ឌ ៣៣២៧។ <u>ការបញ្ជា</u>៖ សាលដីកា *D. Milošević* កថាខណ្ឌ ២៩០។

[468] ករណីលើកលែងមួយគឺករណីអ្នកឈរមើល។ *សូមមើលឧទាហរណ៍* សាលដីកា *Lukić & Lukić* កថាខណ្ឌ ៤២៥ ["អង្គជំនុំជម្រះតុលាការកំពូល ឃើញថា វត្តមានដោយផ្ទាល់របស់អ្នកជួយ និងអ្នកជំរុញ នៅកន្លែងឧក្រិដ្ឋកម្ម ឬនៅជិតកន្លែងឧក្រិដ្ឋ អាចជាកត្តាមួយពាក់ព័ន្ធ ក្នុងករណីជួយ និងការជំរុញ តាមរយៈការឯកភាពតាមដោយបានដឹង"]។ ជាងនេះទៀត ធាតុផ្សំសត្យានុម័តនៃការជួយ និងការជំរុញ អាចមានពីចម្ងាយ"]។ សាលដីកា *Ntagerura* កថាខណ្ឌ ៣៧២ សាលក្រម *Akayesu* កថាខណ្ឌ ៤៨៤។ សាលក្រម *Rutaganda* កថាខណ្ឌ ៤៣។ សាលក្រម *Brima* កថាខណ្ឌ ៧៧៥។

[469] សាលដីកា *Karemera & Ngirumpatse* កថាខណ្ឌ ២៥៩["ចាំថា មិនតម្រូវឱ្យមានវត្តមានទេសម្រាប់ការទទួលខុសត្រូវថ្នាក់លើ យោងតាមមាត្រា ៦(៣)នៃលក្ខន្តិក"]។

ផែនការនេះ[470]។ ហេតុនេះ ការឲ្យតម្លៃហួសហេតុទៅលើការប្រព្រឹត្តិដោយផ្ទាល់ និងការកៀកកិតដោយផ្ទាល់នឹងការប្រព្រឹត្តិក្នុងការកំណត់ថាតើជនណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅយ៉ាងរង្គាលដែលមានការចាត់តាំង មិនបានផ្តោតលើលក្ខណៈ និងយន្តការនៅពីក្រោយឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុតទេ។

117. តាមពិត ដីកាលើកលែងចោទប្រកាន់បានបង្កើតភាពដាច់ដោយឡែកពីគ្នាមិនសមហេតុផលរវាង "មេដឹកនាំជាន់ខ្ពស់" ជាមួយនឹង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។ ការធ្វើរបៀបនេះផ្ទុយពីការសម្រេចរបស់ អ.ជ.ត.ក (ដែលដីកាលើកលែងចោទប្រកាន់ បានពឹងផ្អែកជាមូលដ្ឋាន [471]) ដែលសម្រេចថា ប្រភេទជនទាំងពីរដែលស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺមានការ "ទាក់ទងគ្នា" ហើយមេដឹកនាំជាន់ខ្ពស់ ក៏ត្រូវតែទទួលខុសត្រូវខ្ពស់បំផុតផងដែរចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[472]។ លើសពីនេះទៀត ការធ្វើរបៀបនេះក៏មិនយកចិត្តទុកដាក់លើគោលការណ៍ដែលត្រូវបានទទួលស្គាល់ថា ក្នុងការវាយតម្លៃកម្រិតនៃការទទួលខុសត្រូវ "ឋានានុក្រម ឬមុខតំណែងរបស់ជនត្រូវចោទ" ត្រូវតែយកមកពិចារណា[473]។ ចុងក្រោយ ចំណុចនេះក៏ផ្ទុយនឹងការសន្និដ្ឋានរបស់ដីកាលើកលែងចោទប្រកាន់ ដែលថា "ដើម្បីសម្រេចថាតើបុគ្គលណាស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត គឺ

---

[470] *សូមមើល* ឧទាហរណ៍ *សាលដីកា* *Tadić* កថាខណ្ឌ ១៩១ [ពេលវេលាភាគច្រើន ឧក្រិដ្ឋកម្មទាំងនេះមិនមែនកើតឡើងដោយចេតនាឧក្រិដ្ឋរបស់បុគ្គលម្នាក់ៗទេ ប៉ុន្តែ ជាការបង្ហាញពីចេតនាឧក្រិដ្ឋសមូហភាព៖ ឧក្រិដ្ឋកម្ម ឧស្សាហ៍ប្រព្រឹត្តឡើងដោយជនជាក្រុមដើម្បីសម្រេចផែនការឧក្រិដ្ឋរួម។ ទោះបីជាថា មានតែសមាជិកខ្លះនៅក្នុងក្រុម អាចប្រព្រឹត្តអំពើឧក្រិដ្ឋនេះដោយមានវត្តមានផ្ទាល់[...] ក៏ដោយ ក៏ជារឿយៗ ការចូលរួម និងការចូលរួមចំណែករបស់សមាជិកផ្សេងទៀតនៅក្នុងក្រុមគឺមានសារៈសំខាន់ណាស់ក្នុងការសម្របសម្រួលឲ្យប្រព្រឹត្តបទល្មើសនេះ។ ហេតុនេះ ជារឿយៗ ស្ថានទម្ងន់នៃការចូលរួមបែបនេះខាងផ្លូវចិត្ត គឺមិនស្រាលជាងស្ថានទម្ងន់នៃការចូលរួមរបស់អ្នកដែលប្រព្រឹត្តអំពើនេះជាក់ស្តែងទេ ឬក៏តាមពិតគ្មានអ្វីខុសគ្នាទេ"]។

[471] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៥។

[472] សំណុំរឿង ០០១ -**F28** សាលដីកា *ឌុច* កថាខណ្ឌ ៥៧ ["ពាក្យថា 'មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត' សំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា ប៉ុន្តែ ប្រភេទទាំងពីរនោះទាក់ទងគ្នា។ ប្រភេទីមួយ គឺជាមេដឹកនាំជាន់ [...] ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត"]។

[473] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៧, ៣៦៩។

[...] ផ្តោតលើ [...] កម្រិតដែលបុគ្គលនោះបានចូលរួមចំណែកការសម្រេចលើគោលនយោបាយ និង/ឬការអនុវត្តគោលនយោបាយ"[474]។

118. លើសពីនេះទៀត គោលជំហរនេះក៏ខុសគ្នាផងដែរពីការយល់ឃើញពីមុនៗរបស់ ស.ច.ស.ជ អំពីយុត្តាធិការបុគ្គលនៅក្នុងសំណុំរឿង ០០២[475]។ នៅក្នុងសំណុំរឿង ០០២ ស.ច.ស រួមទាំង ស.ច.ស.ជ បានសន្និដ្ឋានថា ជនត្រូវចោទចំនួនបួននាក់ គឺ នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ មិនត្រឹមតែជាមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរ "ដោយការចូលរួមជាបុគ្គលរបស់អ្នកទាំងនេះនៅក្នុងការអនុវត្តផែនការរួមរបស់ ប.ក.ក តាមមធ្យោបាយឧក្រិដ្ឋ"[476]។ ស.ច.ស មិនបានសន្និដ្ឋានថា នរណាម្នាក់ក្នុងចំណោមជនត្រូវចោទទាំងនេះបានចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មណាមួយឡើយ ហើយការទទួលខុសត្រូវរបស់ជនត្រូវចោទទាំងនេះ មិនមែនពឹងផ្អែកតែលើវត្តមានរបស់ពួកគេនៅទីតាំងឧក្រិដ្ឋកម្មណាមួយដែលបានស៊ើបអង្កេតនោះទេ[477]។

119. ចុងក្រោយ ដីកាលើកលែងចោទប្រកាន់មើលរំលងទាំងស្រុងលើយុត្តិសាស្ត្រផ្ទុយគ្នារបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត។ ទោះបីជា ដីកាលើកលែងចោទប្រកាន់ពឹងផ្អែកយ៉ាងច្បាស់លើលក្ខណវិនិច្ឆ័យនៃវិធាន ១១*ស្ទួន* ដែលបង្ហាញដោយតុលាការ ICTY យ៉ាងណាក៏ដោយ[478] ក៏ដីកាលើកលែងចោទប្រកាន់ មិនបានគិតថា សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY ដែលជនត្រូវចោទត្រូវបានបញ្ជាក់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត មិនបានឱ្យតម្លៃខ្លាំងទៅលើការកៀកកិតនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬការចូលរួមដោយផ្ទាល់នោះទេ[479]។ លើសពីនេះទៀត តុលាការ ICTY បានផ្តន្ទាទោស Zdravko Tolimir ឱ្យជាប់ពន្ធនាគារ

[474] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦១-៧៤។

[475] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦១-៧៤។

[476] ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១៣១៧-៨។

[477] ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១៥២១-៦៣។ *សូមមើលថែមទៀត* ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ៨៦២-៩៩៣(នួន ជា), ៩៩៤-១១២៥(អៀង សារី), ១១២៦-១២០០(ខៀវ សំផន), ១២០១-៩៥(អៀង ធីរិទ្ធ)។

[478] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៦-៧។

[479] សេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី *D. Milošević* ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី កថាខណ្ឌ ២១-២៣។ [ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី បានសម្រេចថា Milošević ស្ថិតនៅក្នុងចំណោមជន"ជាន់ខ្ពស់បំផុត" ពីព្រោះថា គាត់

អស់មួយជីវិតពីបទប្រល័យពូជសាសន៍[480] ដោយសារការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមដែលសម្លាប់មនុស្សប្រុស និងក្មេងប្រុសជនជាតិស្រេប្រេននីកា (Srebrenica) ទោះបីជាស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ Ratko Mladic ហើយមិនដែលមានវត្តមាននៅស្រេប្រេននីកានៅក្នុងអំឡុងពេលប្រល័យពូជសាសន៍នេះក៏ដោយ[481]។

120. រឿងក្តី *Taylor* នៅតុលាការពិសេសសម្រាប់ស៊ីរ៉ាឡេអូន ("SCSL") ប្រហែលជាឧទាហរណ៍ល្អបំផុតអំពីកំហុសឆ្គងនេះនៅក្នុងវិធីសាស្ត្ររបស់ដីកាលើកលែងចោទប្រកាន់។ មាត្រា ១(១) នៃលក្ខន្តិកៈតុលាការនេះកំណត់យុត្តាធិការបុគ្គលរបស់តុលាការនេះនៅត្រឹមជន *"ដែលមានការទទួលខុសត្រូវធំបំផុត"* ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសង្គ្រាមស៊ីវិលស៊ីរ៉ាឡេអូនទេ[482]។ នៅក្នុងសេចក្តីសម្រេចមួយដែលត្រូវបានតម្កល់នៅពេលប្តឹងសារទុក្ខ អង្គជំនុំជម្រះសាលាដំបូងនៃ

---

បានកាន់តំណែងអចិន្ត្រៃយ៍ជាមេបញ្ជាការ SRK រយៈពេលដ៏យូរអង្វែង ដែលជាកងកម្លាំងមានទាហាន ១៨ ០០០ នាក់ មានតែមេបញ្ជាការយោធាថ្នាក់លើតែមួយគត់ដែលនៅពីលើគាត់ ហើយគាត់បានដើរតួនាទីដឹកនាំយ៉ាងច្បាស់ ឧទាហរណ៍ការចូលរួមកិច្ចចរចា]។ សាលដីកា *Lukić* កថាខណ្ឌ ២១-២៣។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី *Lukić & Lukić* ដែលបានសម្រេចបញ្ជូនរឿងក្តីនេះទៅអាជ្ញាធរប៊ូស្នៀ ដោយយល់ឃើញថា ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី បានសង្កត់ធ្ងន់ហួសហេតុលើវិសាលភាពភូមិសាស្ត្រមានកំណត់នៃអំពើរបស់ជនជាប់ចោទ ហើយមិនបានវាយតម្លៃកម្រិតនៃការចូលរួមរបស់គាត់ក្នុងនាមជា"មេដឹកនាំ និងជាអ្នករៀបចំម្នាក់នៃឧក្រិដ្ឋកម្មទាំងនេះ"។ សេចក្តីសម្រេចកំណត់សមត្ថកិច្ចរឿងក្តី*Delić* កថាខណ្ឌ២០-២៥[ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី បានរកឃើញថា ជនជាប់ចោទស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត" ដោយសារតំណែងយោធាជាន់ខ្ពស់របស់គាត់ និងតួនាទីរបស់គាត់នៅក្នុងការរៀបចំផែនការ ណែនាំ និងតាមដានប្រតិបត្តិការយោធា]។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តី បានកត់សម្គាល់ថា ជនជាប់ចោទ មិនត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយសារការប្រព្រឹត្តិដោយផ្ទាល់ទេ ហើយបានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមប្រឹក្សា"មិនជឿតាមអយ្យការដែលថា 'ភាពនៅឆ្ងាយ'របស់ជនជាប់ចោទពីបទល្មើសទាំងនោះ កាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់គាត់ដែលត្រូវបានចោទប្រកាន់ រហូតដល់កម្រិតមួយដែលធ្វើឲ្យរឿងក្តីនេះសមបញ្ជូនទៅទេ"]។

[480] សាលដីកា *Tolimir* កថាខណ្ឌ ៦៤៨ [អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថា ដោយពិចារណាលើការផ្តន្ទាទោស Tolimir ចំពោះអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តតាមរយៈការសម្លាប់មនុស្សប្រុសមកពីស្រេប្រេននីកា និងតាមរយៈការបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្តមកលើប្រជាជនឥស្លាមប៊ូស្នៀនៅស្រេប្រេននីកា កម្រិតនៃការទទួលខុសត្រូវរបស់ Tolimir ត្រូវទទួលការដាក់ទោសអស់មួយជីវិតដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង]។

[481] សាលក្រម *Tolimir* កថាខណ្ឌ ៩១៥-៦, ១០៩៦, ១០៩៩, ១១០១, ១១០៣-០៤, ១១០៩-១០, ១១២៩, ១២៤២។

[482] លក្ខន្តិកៈតុលាការ SCSL មាត្រា ១(១) (គូសបញ្ជាក់បន្ថែម)។

តុលាការបានផ្តន្ទាទោសអតីតប្រមុខរដ្ឋលីប៊ីរី ដែលមិនដែលបានជាន់ដីសេរ៉ាឡេអូន[483] ចំពោះការជួយ និងការជំរុញឧក្រិដ្ឋកម្មនៅទីនោះ ហើយបានកាត់ទោសគាត់ឲ្យជាប់ពន្ធនាគារចំនួន ៥០ ឆ្នាំ[484] ។

## ២. មាស មុត បានដើរតួនាទីដោយផ្ទាល់ និងយ៉ាងសកម្មនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ

121. ក្នុងករណីណាក៏ដោយ ការសន្និដ្ឋានរបស់ដីកាលើកលែងចោទប្រកាន់ ដែលថា ការចូលរួមរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្ម មិនជាដុំកំភួន មិនសកម្ម និងមិនបានកៀកកិតនោះ គឺជាការសន្និដ្ឋានមិនសមហេតុផលយ៉ាងខ្លាំង[485]។ ដូចបានបញ្ជាក់ខាងលើ មាស មុត បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមដើម្បីបោសសម្អាត ឃុំខ្លួន និងសម្លាប់ខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ និងដំណើរការសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ ដែលយោធា និងជនស៊ីវិល ត្រូវបានធ្វើឲ្យទៅជាទាសករ[486]។ គាត់មានអំណាចពេញលេញដើម្បីចាប់ខ្លួន និងកម្ទេច ក) ជនបរទេសដែលចាប់បាននៅសមុទ្រ ខ) យោធានៅក្នុងកងពល ១៦៤ និង គ) អ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំងនៅតំបន់ស្វ័យតកំពង់សោម បញ្ជាឲ្យចាប់ខ្លួនអ្នកទាំងនោះ និងបញ្ជូនអ្នកខ្លះទៅ ស-២១[487]។ លើសពីនេះទៀត ដូចបង្ហាញខាងក្រោមនេះ សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចទាញបានក្រោយពីធ្វើការពិនិត្យគ្រប់ជ្រុងជ្រោយលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង គឺថា នៅក្នុងការអនុវត្តយ៉ាងខ្លាំងក្លានូវគោលនយោបាយរបស់ ប.ក.ក ប្រឆាំងនឹងខ្មាំង ការធ្វើឲ្យទៅជាទាសករ និងការរៀបការដោយបង្ខំ មាស មុត បានបង្កើត បានចុះទៅ និងបានដើរតួនាទីមួយដោយផ្ទាល់ និង

---

[483] សាលដីកា *Taylor* កថាខណ្ឌ ៩៨ [“ខណៈដែលលោក Taylor មិនដែលជាន់ជើងនៅសេរ៉ាឡេអូន ទេ ប៉ុន្តែ ស្នាមជើងដ៏ធ្ងន់ធ្ងររបស់គាត់គឺនៅទីនោះ ហើយអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ដែនសមត្ថកិច្ចនៅក្រៅប្រទេសនៃអំពើឧក្រិដ្ឋរបស់គាត់គឺជាកត្តាស្ថានទម្ងន់មួយ”]។

[484] សាលក្រម *Taylor* កថាខណ្ឌ ៦៩៩៤។ សាលដីកា *Taylor* ផ្នែកសេចក្តីសម្រេច ទំព័រ ៩០[ភាសាអង់គ្លេស]។

[485] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[486] *សូមមើលខាងកើ* កថាខណ្ឌ ២៨-៣២, ៩៦, ៩៨-១០៧។ មនុស្សដែលគាត់មិនអាចកម្ទេសនៅកំពង់សោម គឺអ្នកដែលមជ្ឈិមបក្សស្នើឲ្យបញ្ជូនមក ស-២១ (ជាពិសេស ជនជាតិថៃ និងវៀតណាមដែលចាប់បាននៅសមុទ្រ ហើយ ចូល ស-២១ នៅខែឧសភា ឆ្នាំ១៩៧៦ ជនជាតិវៀតណាមមួយចំនួនដែលចាប់បាននៅសមុទ្រ ហើយចម្លើយសារភាពរបស់ពួកគេនៅ ស-២១ ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងឃោសនានៅឆ្នាំ១៩៧៨ កម្មាភិបាលជាន់ខ្ពស់មកពីកងពល ១៦៤ ឬតំបន់ស្វ័យតកំពង់សោម ប្រជាជនសាមញ្ញមួយចំនួនតូច និងយោធាសាមញ្ញមួយចំនួនតូច)។

[487] *សូមមើលខាងលើ* កថាខណ្ឌ ៩៦, ៩៨-១០៧។

យ៉ាងសកម្មនៅក្នុងដំណើរការមន្ទីរសន្តិសុខ និងការដ្ឋាននានានៅកំពង់សោម រៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានចូលរួមដោយផ្ទាល់នៅក្នុងការបោសសម្អាតនៅក្រចេះ។

122. *__មន្ទីរសន្តិសុខវត្តឥន្ទញាណ៖__* ដីកាលើកលែងចោទប្រកាន់ សន្និដ្ឋានថា "មិនមានឯកសារបង្ហាញពីវត្តមានរបស់ មាស មុត នៅពេលចាប់ខ្លួន ឬការត្រួតពិនិត្យជាទៀតទាត់នៅវត្តឥន្ទញាណឡើយ" ប៉ុន្តែ "កងវរៈសេនាតូច ៤៥០ នេះប្រហែលជាបានមកកាន់វត្តឥន្ទញាណ"ពីចុងខែមេសា ឬដើមខែឧសភា ឆ្នាំ១៩៧៥[488] ។ ការអះអាងបែបនេះមើលរំលងទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់ មាស មុត ជាមួយនឹងមន្ទីរសន្តិសុខនេះ។ ដំបូង មាស មុត បានបង្កើតមន្ទីរសន្តិសុខនេះនៅវត្តឥន្ទញាណ ដែលមានទីតាំងនៅជិតនឹងទីបញ្ជាការកងពល ១៦៤ ជាកន្លែងដែលគាត់ស្នាក់នៅ[489]។ កងទ័ពរបស់គាត់ដណ្តើមបានវត្តនេះភ្លាមៗក្រោយថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលកងពល ៣ ចូលកំពង់សោម ដោយបណ្តេញព្រះសង្ឃចេញពីវត្ត។ បន្ទាប់មក មាស មុត បានបញ្ជាកងវរសេនាតូចឯករាជ្យ ៤៥០/១៦៥ ឲ្យរៀបចំទីតាំងនេះ[490]។

123. ក្រៅពីការសន្និដ្ឋានថា កងវរសេនាតូច៤៥០ "មានមុខងារខាងសន្តិសុខទូទៅផងដែរសម្រាប់កងពលលេខ១៦៤" ហើយ "តា នន ជាអ្នកទទួលខុសត្រូវក្នុងអង្គភាពសន្តិសុខ ៤៥០"[491] ដីកាលើកលែងចោទប្រកាន់ មើលរំលងទាំងស្រុងលើសារៈសំខាន់នៅក្នុងបរិបទនៃទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់កងវរសេនាតូច៤៥០/១៦៥ ជាមួយនឹង មាស មុត។ កងវរសេនាតូចនេះគឺជាកងកម្លាំងពិសេសជាន់ខ្ពស់ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់[492] ដែលជាអង្គភាពដែលផ្តល់និរសារ និងអង្គរក្សផ្ទាល់ខ្លួនរបស់ មាស មុត[493] ធានាសន្តិសុខនៅទីបញ្ជាការកងពល[494] ហើយមានភារកិច្ច

---

[488] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩១, ២៩៧។

[489] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៤១, ៤៤៣, ៤៤៥ [*សូមមើលផងដែរ*] កថាខណ្ឌ ២១១, ២១៦។

[490] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៤២-៣។

[491] ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩១, ២៩៧។

[492] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៥៣, ១៥៥, ២៥២-៥, ៣៦៦, ៤៣២។ *សូមមើលផងដែរ* ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២០១-០៣។

[493] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២៥៣-៤, ៣៦៦, ៤៣២។ *សូមមើលផងដែរ* ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២០៣។

[494] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២៥៣, ៤៣២។

ស៊ើបអង្កេត ចាប់ខ្លួន និងសម្លាប់មនុស្សនៅក្នុងកងពលទាំងមូលតាងនាមឲ្យគាត់[495]។ មេបញ្ជាដំបូងនៅកងវរសេនាតូចនេះ ឈ្មោះ សា/ស មឿន រាយការណ៍ដោយផ្ទាល់ទៅ មាស មុត[496] ហើយអ្នកជំនួសមឿន ឈ្មោះ នន ឈរជើងនៅច្រកចូលផ្ទះផ្ទាល់ខ្លួនរបស់ មាស មុត និងទីបញ្ជាការកងពល[497]។ វត្តឥន្ទញាណ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបោសសម្អាតផ្ទៃក្នុងរបស់ មាស មុត[498] បើមិនមែនជាកន្លែងចុងក្រោយសម្រាប់កងទ័ពជាច្រើននាក់ដែលត្រូវបានរំសាយទេ ក៏ជាកន្លែងឃុំខ្លួនមុនពេលបញ្ជូនទៅ ស-២១ ដែរ[499]។ ពេលខ្លះ វត្តនេះក៏ដាក់អ្នកដែល មាស មុត បានបញ្ជាឲ្យចាប់ខ្លួននៅសមុទ្រផងដែរ[500]។

124. មាស មុត ត្រូវបានគេឃើញជាប្រចាំនៅវត្តឥន្ទញាណ ជាញឹកញាប់ភ្ជាប់ទស្សនកិច្ចរបស់គាត់ជាមួយនឹងការប្រជុំនៅតាមទីតាំងផ្សេងៗទៀត ដូចជា ស្ទឹងហាវ រាម ឬ កងកេង[501]។ នៅទីនោះ មាស មុត បានសួរចម្លើយអ្នកទោស បានកត់ត្រាចម្លើយសារភាពរបស់ពួកគេ និង "បានបញ្ជូនពួកគេចេញ"[502]។ គាត់បានទទួលដំណឹងអំពីការសម្លាប់នៅវត្តឥន្ទញាណ និងបានប្រកាសអំពីការសម្លាប់ទាំងនោះប្រាប់ថ្នាក់ក្រោមរបស់គាត់។ ក្នុងពេលបោសសម្អាតអតីតវរសេនាតូច ៣៨៦ ស្នងការនយោបាយរបស់ខ្លួនក្នុងកងពល ១៦៤ ឈ្មោះ រ៉ែម ត្រូវបានសម្លាប់ដោយសមាជិកកងវរសេនាតូចលេខ ៤៥០/១៦៥ នៅខាងមុខវត្តឥន្ទញាណ ខណៈដែលប៉ុនប៉ងជំទាស់ទៅនឹងការចាប់ខ្លួន។ មាស មុត បានបង្រៀនរឿងរបស់ រ៉ែម នៅពេលដែលគាត់អានចម្លើយសារភាពនៃការបោសសម្អាតកម្មាភិបាលទៅកាន់កងទ័ពកងពល ១៦៤ ស្តាប់នៅក្នុងការប្រជុំមួយ[503]។

---

[495] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២៥៣, ៤៣២, ៤៣៤,៤៧៦-៧, ១៤១ [ការសម្លាប់ស្ត្រីវៀតណាមម្នាក់ និងមនុស្សពេញវ័យពីរនាក់នៅក្នុងទីបញ្ជាការកងពល ១៦៤] យាមកាមដោយកងវរសេនាតូច ១៦៥/៤៥០]។

[496] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៥៥, ២៥២, ២៥៥, ៤៣៣។

[497] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ២៥៥, ៤៣៣-៤។

[498] *សូមមើលខាងលើ* កថាខណ្ឌ ២៨-៣២, ៩៦, ៩៨-១០៧។

[499] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៤៥-៧, ៣៥១, ៣៦៤, ៣៦៦, ៤២៥, ៤២៧, ៤៥០-៤។

[500] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៩០, ៤៥៧-៦០។

[501] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៥៦, ៤៤៤-៥។

[502] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៥៦, ៤៤៤-៦។

[503] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៧៧ *បានដកស្រង់* ឯកសារ **D54/101** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១១ ["តាមុត បានលើកយករឿងនេះមកបង្រៀនពួកយើងនៅពេលនោះ ដោយមានទាំងចម្លើយសារភាពរបស់ពួក [កម្មាភិបាល] នោះមកអានប្រាប់យើងស្តាប់ផង ហើយគាត់បានប្រកាសថា ពួកនេះជាខ្សែរយៈពួកក្បត់។"]។

125. *ការដ្ឋាន និងគុកស្ទឹងហាវ៖* ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានស្រដៀងគ្នាថា "មិនមានសក្ខីកម្ម ឬភ័ស្តុតាងជាក់លាក់ណាមួយបញ្ជាក់អំពីការត្រួតពិនិត្យការដ្ឋានដោយ មាស មុត" នៅស្ទឹងហាវឡើយ[504]។ ទោះជាយ៉ាងណា ចំណុចនោះពិតជាបដិសេធចោលភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលផ្ទុយពីនេះ រួមទាំងចម្លើយរបស់ ប៉ែន សារិន មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលថា "មាស មុត បានមកមើល [ស្ទឹងហាវ] ជាច្រើនដង"[505]។ ក្នុងការដកស្រង់កំណត់ហេតុប្រជុំថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦[506] ដីកាសម្រេចលើកលែងចោទប្រកាន់មើលរំលងចំណុចដែលថា កំណត់ហេតុដដែលនេះបង្ហាញថា មាស មុត ជាប់ពាក់ព័ន្ធផ្ទាល់ក្នុងការបែងចែកមនុស្ស "ល្អ" និងមនុស្ស "អាក្រក់" នៅក្នុងស្ទឹងហាវ[507]។ ដីកាសម្រេចលើកលែងចោទប្រកាន់បន្តខកខានក្នុងការពិចារណាលើភ័ស្តុតាងដែលបានបង្ហាញថា មាស មុត (i) បានចេញបញ្ជាពីទីកន្លែងស្ទឹងហាវទៅកាន់ប្អូនប្រុសរបស់គាត់ មាស អ៊ឹម ដែលជាសមាជិកគណៈស្ទឹងហាវ ដែលទទួលខុសត្រូវផ្នែកភស្តុភារសម្រាប់កងពល ១៦៤ ទាំងមូល[508]។ (ii) បានប្រជុំនៅទីនោះ ដែលជាទីដែលគាត់បានប្រកាសឈ្មោះ "ជនក្បត់" និងបានបង្រៀនកម្មាភិបាលអំពីគោលនយោបាយខ្លាំងរបស់ ប.ក.ក[509]។ (iii) បានទទួលព័ត៌មានបច្ចុប្បន្នភាពជាប្រចាំដោយផ្ទាល់អំពីជីវភាពប្រចាំថ្ងៃនៅស្ទឹងហាវ[510] រួមទាំងលក្ខខណ្ឌអាហារមិនល្អនៅទីនោះផង[511]។

---

*សូមមើលផងដែរ* ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.៥ ["រឿងរបស់ រ៉េម គឺយោធាស្ទើតែទាំងអស់បានដឹង"]។

[504] ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣០៥។

[505] ឯកសារ **D1.3.13.8** កំណត់ហេតុនៃកិច្ចសម្ភាសន៍ ប៉ែន សារិន ដោយ ក.ស.ព EN 00217560 ["មាស មុត បានមកមើល [ស្ទឹងហាវ] ជាច្រើនដង ហើយនៅពេលដែលគាត់ស្នាក់នៅស្ទឹងហាវមួយយប់ គាត់ស្នាក់នៅកន្លែងជាមួយអ្នកបច្ចេកទេសចិន"]។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១១០, ១៩៧, ៣៥២, ៤៥៥, ៦០៥-៧។

[506] ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៥ *បានដកស្រង់* ឯសការ **D1.3.8.4** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ (សមមិត្ត ១៦៤) ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦។

[507] ឯកសារ **D1.3.8.4** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ (សមមិត្ត ១៦៤) ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00162489 ["កន្លងមកគណៈកងពលបានបំបែកពួកមិនល្អ ឲ្យនៅដោយឡែក ដើម្បីកុំឲ្យច្របូកច្របល់នឹងពួកល្អ"]។ *សូមមើលផងដែរ* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦២៣។

[508] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៦០៨។

[509] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១១០, ៣៥២, ៦០៦។

[510] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦០៧-៨។

[511] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៤៥។

126. លើសពីនេះទៀត ដីកាសម្រេចលើកលែងចោទប្រកាន់ ជាថ្មីម្តងទៀត មើលរំលងសារសំខាន់នៃការបង្កើតរបស់កងពល ១៦៤ នៃទីតាំងនោះភ្លាមៗបន្ទាប់ពីកងទ័ពរបស់ មាស មុត បានមកដល់ក្នុងឆ្នាំ១៩៧៥[512] និងការគ្រប់គ្រប់ដោយវរសេនាតូចលេខ ៤៥០/១៦៥[513]។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់លើកឡើងដោយប្រយោលដល់អង្គហេតុដែលថា កម្មករភាគច្រើនគឺជាទាហានកងពល ១៦៤ ក៏ដោយ ក៏វាមិនបានលើកឡើងទាល់តែសោះអំពីតួនាទីដ៏សំខាន់ដែលទីតាំងនេះមាននៅក្នុងការបោសសំអាតផ្ទៃក្នុងរបស់ មាស មុត។ កម្មាភិបាលថ្នាក់ទាប ឬ យុទ្ធជនដែលគាត់បានរំសាយ ត្រូវបានធ្វើឲ្យទៅជាទាសករនៅស្ទឹងហាវ ដើម្បីលត់ដំ ឬកសាង។ អ្នកផ្សេងទៀតត្រូវបានឃុំខ្លួននៅទីនោះ[514]។ មាស មុត ក៏បានបញ្ជូនអ្នកទោសពីស្ទឹងហាវ ទៅកាន់ ស-២១ផងដែរ[515]។

127. *<u>មន្ទីរសន្តិសុខទឹកសាប៖</u>* ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានដោះស្រាយអំពីមន្ទីរសន្តិសុខទឹកសាបក៏ដោយ[516] ប្រសិនបើបានធ្វើនោះ នោះបានរកឃើញភ័ស្តុតាងស៊ីសង្វាក់គ្នាបង្ហាញថា កងទ័ពរបស់ មាស មុត បានកាន់កាប់ទីតាំងទឹកសាបស្ទើតែភ្លាមៗ បន្ទាប់ពីបានចូលទៅដល់កំពង់សោម ក្នុងខែមេសា ឆ្នាំ១៩៧៥[517] បានបង្កើតមណ្ឌលភស្តុភារកងពល ១៦៤ និងមន្ទីរសន្តិសុខផ្សេងទៀតរបស់ មាស មុត[518]។ ដូចគ្នាទៅនឹងវត្តឥន្ទ្រញាណដែរ ទឹកសាបបានដើរតួនាទីសំខាន់មួយនៅក្នុងការបោសសម្អាតរបស់ មាស មុត[519] ទាំងក្នុងនាមជាគោលដៅចុងក្រោយសម្រាប់កងទ័ពរំសាយជាច្រើនរបស់កងពល ១៦៤ ឬជាទីកន្លែងឃុំខ្លួនមុនពេលបញ្ជូនខ្លួន

---

[512] ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៣០២។ *សូមមើលបន្ថែមទៀត* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥៩០។

[513] ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០០, ៣០៥។ *សូមមើលយោងខាងលើ* កថាខណ្ឌ១២៣។

[514] ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០២។ *សូមមើលបន្ថែមទៀត* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៣៥៣, ៣៦០, ៣៦៤, ៣៦៦, ៤២៥, ៦០៣, ៦១៣, ៦២១-៣០។

[515] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៤២។

[516] *សូមមើល* **កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើរាល់អង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។**

[517] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៨៥។

[518] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៨២, ៤៨៥។

[519] *សូមមើលយោងខាងលើ* កថាខណ្ឌ ២៨-៣២, ៩៦, ៩៨-១០៧។

ពួកគេទៅកាន់ ស-២១[520]។ វាក៏ជាទីកន្លែងឃុំខ្លួន និងសម្លាប់ដ៏សំខាន់មួយផងដែរសម្រាប់អ្នកទាំងឡាយណាដែល មាស មុត បានបញ្ជាឲ្យចាប់ខ្លួននៅតាមសមុទ្រ[521]។

128. មាស មុត បានទៅមើលទីកសាបជាប្រចាំ[522]។ លើសពីនេះទៀត ទីតាំងទីកសាបស្ថិតក្រោមការគ្រប់គ្រងរបស់កងវរសេនាធំលេខ ៦៣[523] ដែលដូចគ្នាទៅនឹងវរសេនាតូច ៤៥០/១៦៥ មានទំនាក់ទំនងជិតស្និទ្ធទៅនឹង មាស មុត ដោយផ្ទាល់។ ស៊ិន ជន ដែលជាមេបញ្ជាការវរសេនាធំ ៦៣ ចាប់ពីចុងឆ្នាំ១៩៧៦ ឡើងទៅ បានរាយការណ៍ផ្ទាល់ទៅកាន់ មាស មុត[524] និងអ្នកស្នងរបស់គាត់ឈ្មោះ ញ៉ាណ ដែលជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលដែល មាស មុត ទុកចិត្តបំផុតដែលដើរតួជាបណ្ដាញទំនាក់ទំនងផ្ទាល់ទៅកាន់ មាស មុត។ ក្នុងអំឡុងពេលបោសសម្អាត អ្នកទាំងពីរបានដឹកនាំវគ្គបណ្ដុះបណ្ដាលជាមួយគ្នា ដើម្បីរម្លើងឫស "ពួកក្បត់" ហើយ មាស មុត បានតែងតាំង ញ៉ាន់ ជាគណៈកងពល ១៦៤។ ញ៉ាន់ ទៅរស់នៅក្នុងបរិវេណរបស់ មាស មុត នៅកំពង់សោម និងនៅចុងឆ្នាំ១៩៧៨ មាស មុត បានចាត់តាំងគាត់ឲ្យទៅខេត្តក្រចេះធ្វើជាលេខាកងពល ១១៧ ក្រោយពេលដែលគាត់បោសបានសម្អាតថ្នាក់ដឹកនាំកងពលមុន[525]។

129. _*ការដ្ឋាន និងទីតាំងសម្លាប់មនុស្សតំបន់រាម៖*_ ជាថ្មីម្តងទៀត ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានលើកឡើងអំពីការដ្ឋានតំបន់រាម និងទីតាំងសម្លាប់មនុស្ស ទោះបីជាត្រូវបានប្ដឹងយ៉ាងត្រឹមត្រូវដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ[526]។ ទោះជាយ៉ាងណា ភស្តុតាងនៅក្នុងសំណុំរឿង រួមទាំងភស្តុតាងដាក់នៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ផង បង្ហាញថា មាស មុត ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងក្នុងដំណើរការនានា។ ឧទាហរណ៍ ទូរលេខមួយផ្ញើទៅកាន់ មាស មុត

---

[520] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ៣៤២, ៣៤៦-៧, ៣៥៤, ៣៦៤, ៣៦៦, ៤២៧, ៤២៩, ៤៩៤-៤៩៦។

[521] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤១០, ៤១២, ៤២៨, ៥០០-១។

[522] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ១៦២, ៤៨៧។

[523] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៨៨។ *សូមមើល* ឯកសារ **D266** ដីសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៩៥។

[524] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៨៩។

[525] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៤៩០។

[526] *សូមមើល* **កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើរាល់អង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។**

ដោយអនុរបស់គាត់ ឈ្មោះ ខឹម បង្ហាញថា មាស មុត បានចេញបញ្ជាឱ្យអនុវត្តគោលនយោបាយខ្លាំងរបស់ ប.ក.ក នៅទីនោះ[527]។ ទូរលេខដដែលនេះក៏បានបង្ហាញផងដែរថា មាស មុត ទទួលដំណឹងជាប្រចាំ សូម្បីតែអំពីការស្លាប់ណាមួយក្នុងចំណោមកម្មករ និងព័ត៌មានលម្អិតតិចតួចអំពីការកើនឡើងនៃការធ្វើកសិកម្មស្រូវ[528]។ កំណត់ហេតុប្រជុំក៏បង្ហាញផងដែរថា មាស មុត បានរាយការណ៍អំពី "សកម្មភាពលួច" នៅកងកេង[529] និងការដាក់កាំភ្លើងធំនៅរាម និងកងកេង[530]។

130. លើសពីនេះទៀត សំណុំរឿងមានភស្តុតាងស៊ីសង្វាក់គ្នាថា មាស មុត (i) បានបញ្ជាដោយផ្ទាល់ក្នុងការសម្លាប់ និងការកប់សាកសពជនជាតិថៃ និងវៀតណាមនៅធូរេន I[531] (ii) បានទៅមើលជាប្រចាំ ដោយបានប្រជុំជាមួយមេភូមិ និងបានកោះហៅប្រធានសហករណ៍ឱ្យមកពិភាក្សាអំពីផែនការបង្កើនផលជាមួយពួកគេ[532] និង (iii) បានដឹកនាំការប្រជុំដ៏ធំមួយនៅព្រលានយន្តហោះកងកេង ជាទីដែលគាត់បានកំណត់អត្តសញ្ញាណ "ជនក្បត់" និង "ទាហានសមាសភាពមិនល្អ" និងបានអានចម្លើយសារភាពរបស់ពួកគេ[533]។ ចំណែកឯនៅស្ទឹងហាវវិញ មាស មុត បានដាក់ទាហានរំសាយ

---

[527] ឯកសារ **D4.1.699** ទូរលេខ ១១ ពី ខឹម ទៅកាន់ បង មុត (មាស មុត) ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00092628 (គូសបញ្ជាក់បន្ថែម) ["នៅឃុំរាម និងបបុសពី យើងមានវិធានការចំពោះខ្មាំងមួយដែល<u>បងសំរេច</u> វាមានរត់ចូលព្រៃ ៥នាក់ ឥឡូវយើងតាមចាប់បានទាំងអស់"]។ *សូមមើលផងដែរ* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៨៨។

[528] ឯកសារ **D4.1.699** ទូរលេខ ១១ ពី ខឹម ទៅកាន់ បង មុត (មាស មុត) ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00092628 ["សភាពការណ៍យើង យុទ្ធជននៅកង ៦២ ធ្វើស្រែទៅធ្វើស្រែម្តុំចំការដូង ពលីម្នាក់ដោយលង់ទឹក ប៉ុន្តែមូលហេតុពិនិត្យមិនទាន់ច្បាស់ [...] សភាពស្រូវនៅគ្រប់កន្លែង មានការរីកចំរើន តែនៅកងកេងមានទឹកជ្រូវ ១២ ហិកតា ប៉ុន្តែបងប្អូន [យុទ្ធជន] កំពុងប្រយុទ្ធសង្គ្រោះ [ពីទឹកជំនន់]។"]។

[529] ឯកសារ **D1.3.27.18** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ *កំណត់ហេតុការប្រជុំលេខា និងភស្តុតាង (ប្រធាន)* ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00052391 ["នៅកងកេង មានលេចសកម្មភាពលួច ច្រើនលេចចេញពីសមាសភាពទាហាន"]។

[530] ឯកសារ **D1.3.8.3** កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ *កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម* ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦ KH 00021496 ["I. សេចក្តីរាយការណ៍អំពីសភាពការយោធា៖ សមមិត្ត មុត៖ ១. ការរៀបចំកម្លាំងការពារ៖ ក. កម្លាំងអាវុធនៅជុំវិញកំពង់សោម លើដីគោក៖ នៅក្នុងក្រុងកំពង់សោម មានកាំភ្លើងធំ ១០៥ ម.ម ៤ដើម - កាំភ្លើង ៤០ ម.ម ១ដើម - កាំភ្លើង ៣៧ ម.ម ៦ដើម - ១២.៧ ម.ម ២ដើម។ នៅរាម និងកងកេង មានកាំភ្លើងធំ ១០៥ម.ម - ៣៧ម.ម និង ១២.៨ម.ម ទាំងអស់ ៦ដើម។"]។

[531] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៦, ៤១៤។

[532] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៩១-២, ៤៤៥, ៦៦៤-៦។

[533] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៦៤-៥, ៣៥២, ៦៩៣។

របស់កងពល ១៦៤ នៅតាមការដ្ឋានរាម (រួមបញ្ចូលទាំងនៅ កងកេង និង បិតត្រាង) និងនៅតាមវាលស្រែ[534]។ មេបញ្ជាការវរសេនាធំ ៦៣ ឈ្មោះ គឹម ញ៉ុន ដែលជាមនុស្សជំនិតដែល មាស មុត ទុកចិត្ត បានជួបជាមួយប្រធានសហករណ៍ជាប្រចាំ និងបានធ្វើជាបណ្តាញទំនាក់ទំនងទៅកាន់ មាស មុត[535]។

131. *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ៖* ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានដោះស្រាយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅកំពង់សោម[536]។ នៅកំពង់សោម មាស មុត បានអនុវត្តគោលនយោបាយ ប.ក.ក បង្ខំមនុស្សឲ្យរៀបការជាមួយដៃគូដែលជ្រើសរើសដោយរបបនោះ ហើយបន្ទាប់មកឲ្យរួមសង្វាស់ក្នុងអាពាហ៍ពិពាហ៍នោះ ដើម្បីបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ[537]។ គាត់បានផ្សព្វផ្សាយគោលនយោបាយនេះនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់ទាំងមូល និងបានណែនាំកម្មាភិបាលរបស់គាត់ឲ្យរៀបចំអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំសម្រាប់យោធាកងពល ១៦៤ និងជនស៊ីវិល[538]។ ជាលទ្ធផល គូស្រករភាគច្រើនមិនបានស្គាល់គ្នា ប៉ុន្តែមានអារម្មណ៍ថាត្រូវបានបង្ខំឲ្យរៀបការ និងរួមសង្វាស់ក្នុងអាពាហ៍ពិពាហ៍នោះ[539]។ នៅក្នុងវគ្គសិក្សាមួយក្នុងឆ្នាំ ១៩៧៨ ដែលបានធ្វើឡើងនៅឆ្នេរអូរឈើទាល មាស មុត បានបង្ហាញអំពី "ផែនការប្រចាំឆ្នាំអំពីចំនួនគូដែលគួររៀបការ"។ នៅក្នុងការប្រជុំនោះ មាស មុត និង គឹម ញ៉ុន "បានពិនិត្យមើលសំណើសុំរៀបការកន្លងមកទាំងអស់ ហើយកំណត់គូដែលត្រូវរៀបការ"។ បន្ទាប់មក មាស មុត បានណែនាំកម្មាភិបាលឲ្យ "ពិនិត្យមើលសំណើទាំងអស់ដែលគេស្នើសុំរៀបការ ហើយរៀបការឲ្យអ្នកទាំងនោះឲ្យអស់" និងបានពន្យល់ជាសាធារណៈថា នេះចាំបាច់ត្រូវសម្រេចគោលដៅរបស់បក្សដើម្បីបង្កើនចំនួនប្រជាជនឲ្យបានដល់ ២០លាននាក់[540]។ ក្នុងនាមជាមេបញ្ជាការកងពល មាស

---

534 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៤២, ៣៤៥, ៣៦០, ៣៦៦។

535 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៦៦, ៦៧២។

536 *សូមមើល* **កំហុសអង្គច្បាប់នៃការខកខានមិនបានពិចារណា និងចេញសេចក្តីសម្រេចលើរាល់អង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង០០៣។**

537 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៧៩៩, ៨២១។

538 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៨២២, ៨២៥, ៨២៧។

539 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៨២៧-៨, ៨៣៥-៤២។

540 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៨២២។

មុត មានអំណាចមិនត្រឹមតែអនុញ្ញាឲ្យរៀបការនោះទេ ប៉ុន្តែថែមទាំងក្នុងការសម្រេចថាតើអ្នកដែលបានបដិសេធមិនព្រមរៀបការត្រូវដាក់ទណ្ឌកម្ម ឬទេ[541]។ ការរៀបការបានកើតឡើងនៅផ្ទះរបស់គាត់ ម.១៦៤ និងនៅតាមទីកន្លែងសំខាន់ៗផ្សេងទៀតរបស់កងពល ១៦៤ រួមបញ្ចូលទាំងកន្លែងបណ្តុះបណ្តាល ឬមន្ទីរភស្តុភារ[542] និងត្រូវបានដឹកនាំដោយមេដឹកនាំថ្នាក់ក្រោមនៃកងពល ១៦៤ របស់ មាស មុត[543]។ មាស មុត ខ្លួនឯងផ្ទាល់ក៏បានធ្វើជាអធិបតីក្នុងពិធីរៀបការនៅថ្នាក់កងពលផងដែរ[544]។

132. <u>*ការបោសសម្អាតកងពលធំ ១១៧/តំបន់ ៥០៥៖*</u> ជាថ្មីម្តងទៀតដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានលើកឡើងអំពីការបោសសម្អាតនៅក្រចេះឡើយ[545]។ មាស មុត បានចូលរួមដោយផ្ទាល់និងយ៉ាងសកម្ម នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោសសម្អាតកម្មាភិបាល កងពលធំ ១១៧ និងតំបន់ ៥០៥ នៅចុងឆ្នាំ ១៩៧៨។ គាត់បានធ្វើដំណើរទៅក្រចេះ ហើយបានរៀបចំដោយផ្ទាល់ នូវការជម្លៀសកម្មាភិបាលយ៉ាងតិច ១០ នាក់ រួមទាំងក្មួយបង្កើតរបស់គាត់ឈ្មោះ ឃុន រ៉ុំ (លេខាកងពលធំ ១១៧) និងប្អូនជីដូនមួយគាត់ឈ្មោះ មាស មឿន (លេខាតំបន់ ៥០៥) ទៅភ្នំពេញ ដែលនៅទីនោះពួកគេត្រូវបានឃុំឃាំងភ្លាមៗនៅមន្ទីរសន្តិសុខ ស-២១[546]។ គាត់មានវត្តមានដោយផ្ទាល់នៅព្រលានយន្តហោះ នៅពេលដែលគេបញ្ជូនកម្មាភិបាលយ៉ាងហោចណាស់ពីរនាក់ ឡើងលើយន្តហោះនោះ[547]។

133. បន្ទាប់ពីកម្មាភិបាលដែលត្រូវបោសសម្អាត ត្រូវបានគេដកចេញហើយនោះ មាស មុត បានរៀបចំកិច្ចប្រជុំជាមួយកម្មភិបាល កងពលធំ ១១៧ និងតំបន់ ៥០៥ ដែលនៅសល់ ដោយក្នុងការប្រជុំនោះ មាស មុត បានប្រកាសថា គាត់បានដកចេញកម្មាភិបាល ដោយសារតែពួកគេជា "ជន

---

541 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ២០៣។

542 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ៨៣៤។

543 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ៨២៣, ៨២៥ [មេដឹកនាំកងពល ១៦៤ ខឹម, ទឹម សេង, គឹម ញ៉ាណ និង ហាន]។

544 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.អ កថាខណ្ឌ ៨២៥។

545

546 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២២, ៨៤៥, ៨៦០-៨៦២។

547 ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២២, ៨៦០។

ក្បត់"[548]។ បន្ទាប់មកគាត់បានដាក់ជំនួសអ្នកទាំងនោះវិញ ដោយតែងតាំងមេបញ្ជាការកងវរសេនាធំ ១៦៤ នៃកងពលធំរបស់គាត់ ឲ្យធ្វើជាមេបញ្ជាការកងពលធំ ១១៧ និងតំបន់ ៥០៥[549]។ មាស មុត បន្តនៅក្រចេះ ហើយគ្រប់គ្រងលើកងពលធំ១១៧ និងតំបន់ ៥០៥ ដែលនៅទីនោះគាត់បន្តបោសសម្អាតថ្នាក់ក្រោមៗទៀត ដូចជា ចេញបញ្ជាផ្ទាល់ឲ្យសម្លាប់កម្មាភិបាលឃោធាតំបន់ ៥០៥[550] និងត្រួតពិនិត្យមើលលើការបញ្ជូនកងទ័ព ប្រជាជនស៊ីវិល និងជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួន ទៅកាន់មន្ទីរសន្តិសុខ ស-២១[551]។

134. ក្នុងការពិភាក្សាសម្រេចលើយុត្តាធិការបុគ្គល ដីកាសម្រេចលើកលែងចោទប្រកាន់ បានសង្ខេបអំពីតួនាទីរបស់ ឌុច នៅក្នុងឧក្រិដ្ឋកម្មដូចតទៅ "ឌុច គ្រប់គ្រង ពិនិត្យមើលចម្លើយសារភាព សរសេរចំណារលើចម្លើយសារភាព និងស្នើទៅថ្នាក់ដឹកនាំដើម្បីសម្រេច ចាប់ជនសង្ស័យ ដែលត្រូវបានគេឆ្លើយដាក់ក្នុងចម្លើយសារភាព។ ឌុច សម្របសម្រួលនូវការចាប់ខ្លួន រៀបចំ និងបង្រៀនពីរបៀបសួរចម្លើយ តាមដានពិនិត្យការសួរចម្លើយ និងការសម្លាប់អ្នកទោសជាដើម"[552]។ ដូចដែលបានរៀបរាប់លម្អិតនៅទីនេះ[553] ការចូលរួមរបស់ មាស មុត យ៉ាងហោចណាស់ក៏ដោយផ្ទាល់ និងនៅក្បែរដូច សកម្មភាពនីមួយៗនៃសកម្មភាពទាំងអស់នេះដែរ ហើយតាមជាក់ស្តែង គាត់មានស្វ័យភាពខ្លាំងក្លាជាង ឌុច ក្នុងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ មិនមាន

---

[548] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២២, ៨៦៣។

[549] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២៣, ៨៤៥-៨៤៦, ៨៦៣-៨៦៥ [មាស មុត តែងតាំង គឹម ញ៉ាន់ និង សុខ ភាព]។

[550] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២៣, ៨៤៦, ៨៦៦-៨៦៨។

[551] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨៦៨-៨៦៩។

[552] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៧១ (ដោយលប់ការដកស្រង់) ជើងទំព័រ ១១២២-១១២៥ 1122-25 ដកស្រង់ សំណុំរឿង ០០១ ឯកសារE188 សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ឌុច កថាខណ្ឌ ១៥៤, ១៧៤, ១៧៧, ៣៩៥។ សូមមើលបន្ថែម សំណុំរឿង ០០១ ឯកសារ **D99** ដីកាដំណោះស្រាយសំណុំរឿង ឌុច កថាខណ្ឌ ៤៥, ៨២ (គ្រប់គ្រងនិងចារលើចម្លើយសារភាព) កថាខណ្ឌ ៥៧-៥៨ (ស្នើដល់ថ្នាក់លើឲ្យចាប់ខ្លួន ជនសង្ស័យដែលត្រូវបានឆ្លើយដាក់ក្នុងចម្លើយសារភាព) កថាខណ្ឌ ៥២-៥៣, ៥៦-៥៩ (សម្របសម្រួលលើការចាប់ខ្លួនអ្នកទោស និងបុគ្គលិកមន្ទីរសន្តិសុខស-២១) កថាខណ្ឌ ៦១ (បញ្ជាឲ្យចាប់ខ្លួនបុគ្គលិកមន្ទីរសន្តិសុខស-២១) កថាខណ្ឌ ៧៩, ៨៣, ៩០, ៩៧ (រៀបចំ និងណែនាំដល់អ្នកសួរចម្លើយ ត្រួតពិនិត្យលើការសួរចម្លើយ) កថាខណ្ឌ ៨២ (សួរចម្លើយដោយខ្លួនឯង) កថាខណ្ឌ ១០៧ -១១១, ១១៣, ១១៨, ១១៩, ១២១ (ត្រួតពិនិត្យលើការសម្លាប់) កថាខណ្ឌ ៩០ -៩៩ (ធ្វើទារុណកម្ម ឬបញ្ជាឲ្យធ្វើទារុណកម្ម)។

[553] សូមមើលផ្នែកខាងលើ, កថាខណ្ឌ ២៨៣២, ៩៦, ៩៨ -១០៧, ១២១-១៣៣។

មូលដ្ឋានសំអាងហេតុណាមួយ នៅពេលអនុវត្តយុត្តិសាស្ត្រដែលមានអត្ថិភាពទាំងអស់ លើបញ្ហាយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែលអាចចាត់ទុក មាស មុត ថាមានការទទួលខុសត្រូវតិចតួចជាង ឌុច ចំពោះឧក្រិដ្ឋកម្មនោះទេ។

## ច. ការសន្និដ្ឋានលើអង្គហេតុដោយខុសឆ្គង មានផលប៉ះពាល់ក្នុងការសម្រេចនៅលើបញ្ហាយុត្តាធិការបុគ្គល

135. ដីកាសម្រេចលើកលែងចោទប្រកាន់ មានការសន្និដ្ឋានអង្គហេតុមិនសមហេតុផលជាច្រើន លើបញ្ហាជាក់លាក់នានា ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃទៅលើយុត្តាធិការបុគ្គល។ ក្នុងករណីភាគច្រើន កំហុសឆ្គងអង្គហេតុទាំងអស់នេះ កើតចេញពីការដែលដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានត្រួតពិនិត្យមើលឲ្យបានច្រើន លើសពីភស្តុតាងមួយផ្នែកតូច ដែលមាននៅត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[554] ហើយភស្តុតាងពាក់ព័ន្ធដទៃផ្សេងទៀត ដែលមានក្នុងសំណុំរឿងនៅមុនកាលបរិច្ឆេទនេះ ក៏មិនត្រូវបានពិចារណាផងដែរ។

136. ក្នុងបណ្តឹងឧទ្ធរណ៍ មានសច្ចធារដែលអាចបដិសេធបានដែលថា ចៅក្រមបានវាយតម្លៃដោយត្រឹមត្រូវទៅលើភស្តុតាងទាំងអស់[555]។ ទោះបីជាអ្នកសម្រេចលើអង្គហេតុមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា ភស្តុតាងខ្លះមានភាពគួរឲ្យជឿជាក់ជាងភស្តុតាងផ្សេងក៏ដោយ[556] ប៉ុន្តែ ចាំបាច់ណាស់ដែលត្រូវបញ្ជាក់ថា ការសម្រេចលើអង្គហេតុនីមួយៗ ធ្វើឡើងដោយរបៀបណា[557]។ មិនមានឆន្ទានុសិទ្ធិណាដែលអាច ធ្វើមិនដឹងមិនឮលើភស្តុតាងពាក់ព័ន្ធយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលផ្ទុយពីការសម្រេចរបស់គាត់ ដោយមិនមានការពន្យល់ថា ហេតុអ្វីទើបភស្តុតាងដែលបានជ្រើសរើស

---

[554] ដូចដែលបានកត់សម្គាល់ពីខាងលើ នេះគឺជាកំហុសអង្គច្បាប់។ សូមមើល **កំហុសឆ្គងអង្គច្បាប់ ដោយការមិនបានពិចារណាភស្តុតាងដែលបានដាក់ក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។**

[555] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤ (និងការដកស្រង់នៅក្នុងនោះ)។

[556] សាលដីកាលើរឿងក្តី *Muvunyi I* កថាខណ្ឌ ១៤៤។

[557] សាលដីកាលើរឿងក្តី *Bemba* កថាខណ្ឌ ៥២។ សាលដីកាលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ 385។ សាលដីកាលើរឿងក្តី *Kunarac* កថាខណ្ឌ ៤១។

មានភាពប្រសើរជាងឡើយ[558]។ ការវិភាគមួយដែលកម្រិតត្រឹមផ្នែកនៃកំណត់ត្រាភស្តុតាងពាក់ព័ន្ធដែលបានជ្រើសរើស មិនគ្រប់គ្រាន់ដើម្បីបង្កើតបានជាទស្សនៈដែលមានសំអាងហេតុឡើយ[559]។

## ១. មាស មុត គឺជាលេខាកងពលធំ ១៦៤ (អតីតកងពលធំលេខ ៣) និងជាលេខាតំបន់ស្វយ័តកំពង់សោម ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩

137. ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា "មាស មុត បានក្លាយទៅជាលេខាកងពលលេខ ១៦៤ នៃកងទ័ពជើងទឹកប្រចាំនៅកំពង់សោម [...] យ៉ាងហោចណាស់រវាងខែមករា ឆ្នាំ ១៩៧៦ ដល់ខែមេសា ឆ្នាំ១៩៧៨ និងជាប្រធានគណៈកម្មាធិការតំបន់កំពង់សោមផងដែរ"[560]។ នៅពេលវិភាគអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទៅលើ មាស មុត ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា ក្នុងតួនាទីរបស់គាត់ជាលេខាកងពលធំ ១៦៤ មាស មុត "[...] ទទួលបន្ទុកខាងនយោបាយ ផ្តោតសំខាន់លើការងារផ្សព្វផ្សាយគោលនយោបាយរបស់បក្ស"[561] ហើយអនុលេខាមួយរូប ក្នុងចំណោមអនុលេខាចំនួនពីរនាក់របស់គាត់ ទទួលបន្ទុកខាងយោធា[562]។

---

[558] វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង ["ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ"] ។ សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤។ សាលដីកាលើរឿងក្តី *Muvunyi I* កថាខណ្ឌ ១៤៤, ១៤៧។ សាលដីកាលើរឿងក្តី *Gotovina & Markač* កថាខណ្ឌ ៦១។

[559] សាលដីកាលើរឿងក្តី *Perišić* កថាខណ្ឌ ៩២, ៩៥។

[560] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៨៨ (ដោយគូសបញ្ជាក់បន្ថែម) [មិនបានការលើកឡើងអំពីរយៈពេលនៃតួនាទីរបស់គាត់ជាប្រធានទីក្រុងកំពង់សោមឡើយ]។ សូមមើលផងដែរ កថាខណ្ឌ ១៨១។

[561] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤១៦។ សូមមើលផងដែរ កថាខណ្ឌ ១៨២ ["មាស មុត ត្រូវបានតែងតាំង ជាប្រធានកងពលលេខ ៣ (ទទួលបន្ទុកផ្នែកនយោបាយ)"]។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានទទួលស្គាល់ក្តី តែការសម្រេចនេះគឺផ្អែកដោយផ្ទាល់ ទៅលើចម្លើយរបស់ មាស មុត ចំនួនពីរ ដែលមិនបានដាក់នៅក្នុងសំណុំរឿង នៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឡើយ៖ ឯកសារ **D22.2.181** បទសម្ភាសន៍ជាមួយ មាស មុត ដោយ US POW/MIA ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ 5 Dec 2001, ERN(ភាសាខ្មែរ) 00741998, [មាស មុត អះអាងថា ឆាន ជាមេបញ្ជាការកងពលធំនៅក្នុងឆ្នាំ ១៩៧៥ សារឿន ជាមេបញ្ជាការរង ហើយគាត់គឺជាមន្ត្រីនយោបាយ]។ ឯកសារ **D22.2.182** បទសម្ភាសន៍ជាមួយ មាស មុត ដោយ US POW/MIA ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ ERN(ភាសាខ្មែរ) 00741991 ["កងពលធំលេខ ៣ បានស្រូបយកកងទ័ពពីតំបន់ ៣៧ ហើយ ឆាន បានក្លាយជាមេបញ្ជាការកងពលធំនេះ រីឯលោកឧត្តមសេនីយ៍ មុត បានក្លាយជាមន្ត្រីនយោបាយ"]

[562] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៨២, ៤១៦។

138. ការសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថា មាស មុត ប្រហែលជាមិនបាន កាន់តំណែងជាបញ្ជាការកងពលធំ ១៦៤ ទេ នៅមុនខែមករា ឆ្នាំ១៩៧៦ គឺ ទីមួយ ផ្ទុយជាមួយនឹង ការសន្និដ្ឋាននៅក្នុងផ្នែកដដែលនេះនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា (ក) កង ពលធំ ១៦៤ មានដើមកំណើតចេញពីកងពលធំលេខ ៣ ដែលត្រូវបានបង្កើតឡើងនៅក្នុងភូមិភាគ និរតី នៅក្នុងឆ្នាំ១៩៧៣ ឬដើមឆ្នាំ១៩៧៤ និង (ខ) "មាស មុត ត្រូវបានតែងតាំងជាប្រធាន [...] ហើយកងវរៈសេនាធំ និងកងវរៈសេនាតូច ត្រូវបានគ្រប់គ្រងដោយ មាស មុត"[563]។ បន្ទាប់មក ដីកាសម្រេចលើកលែងចោទប្រកាន់ បានសន្និដ្ឋានថា "ក្រោយថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលលេខ៣ ត្រូវបានបញ្ជាឲ្យទៅបោះទីតាំងនៅកំពង់សោម។ បន្ទាប់ពីផ្លាស់ប្តូរទៅកាន់កំពង់ សោម កងពលលេខ ៣ បានផ្លាស់ប្តូរឈ្មោះទៅជា កងពលមជ្ឈិមលេខ ១៦៤ [...] នាថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ហើយក្រោយមកក៏បានប្រែក្លាយ ជាកងទ័ពជើងទឹក នៅថ្ងៃទី0៩ ខែតុលា ឆ្នាំ ១៩៧៥ *ដែលដឹកនាំដោយ មាស មុត*"[564]។

139. ការសន្និដ្ឋានដែលថា មាស មុត ប្រហែលមិនមែនជាលេខាកងពលធំ ១៦៤ មុនខែមករា ឆ្នាំ១៩៧៦ ក៏ផ្ទុយគ្នាផងដែរពី ភស្តុតាងដែលមានចំនួនច្រើនលើសលប់នៅក្នុងសំណុំរឿង ដែលដីកាសម្រេច លើកលែងចោទប្រកាន់ មិនបានលើកឡើងស្ទើរតែទាល់តែសោះ។ ភស្តុតាងដែលដីកាសម្រេចលើក លែងចោទប្រកាន់ ពឹងផ្អែកដើម្បីកំណត់កត្តាកំណត់សំខាន់ខែមករា ឆ្នាំ១៩៧៦ ដល់ខែមេសា ឆ្នាំ ១៩៧៨ គឺជា ទូរលេខដែលនៅសល់ទីមួយរបស់ មាស មុត និងសារតាមទូរសព្ទដែលបានកត់ត្រា ចុងក្រោយរបស់គាត់[565]។ ការទំនាក់ទំនងទាំងអស់នេះមិនអាចសម្រេចកំណត់អំពីរយៈពេលនៃការ ដឹកនាំរបស់ មាស មុត នៅកងពលធំ ១៦៤ ឡើយ។ តាមពិតទៅ ភស្តុតាងដែលដីកាសម្រេចលើក លែងចោទប្រកាន់ ពឹងផ្អែកទៅលើ ដើម្បីធ្វើការសម្រេចខាងលើនោះ[566] បានទទួលស្គាល់យ៉ាង ច្បាស់ថា មាស មុត គឺជាលេខាកងពលធំលេខ៣/កងពលធំ ១៦៤ យ៉ាងហោចណាស់ចាប់តាំងពី

[563] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៨២-១៨៣។

[564] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៨៧ (ដោយដកចេញសម្រង់, ដោយគូសបញ្ជាក់បន្ថែម).

[565] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៨៨ ដកស្រង់ ឯកសារ **D1.3.30.2** របាយការណ៍ពី មាស មុត ជូនបង ៨៩ ថ្ងៃទី0៥ ខែមករា ឆ្នាំ១៩៧៦។ **D1.3.12.1** របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ទាញ ERN(ភាសាខ្មែរ) 00160081 [រៀបរាប់ មាស មុត ជាមេបញ្ជាការកងពលធំ ១៦៤]។ ឯកសារ **D1.3.30.25** សារទូរសព្ទសម្ងាត់ពី មុត ថ្ងៃទី0១ ខែមេសា ឆ្នាំ១៩៧៨។

[566] សូមមើលផ្នែកខាងលើ, កថាខណ្ឌ ១៣៧។

ឆ្នាំ ១៩៧៥[567] ហើយចំណុចនេះត្រូវបានគាំទ្រដោយភស្តុតាងដទៃៗទៀតយ៉ាងច្រើន ដែលត្រូវបានប្រមូលនៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[568]។ ភស្តុតាងក៏បានបង្ហាញផងដែរថា មាស មុត ត្រូវបានតែងតាំងជាលេខាតំបន់ស្វយ័តកំពង់សោម និងជាលេខាក្រុងកំពង់សោម នៅពេលដែលគាត់មកដល់ទីនោះ នៅក្នុងខែមេសា ឆ្នាំ១៩៧៥[569]។

140. ភស្តុតាងមានភាពច្បាស់លាស់ប្រហែលគ្នាថា មាស មុត បន្តគ្រប់គ្រងលើកងពលធំ ១៦៤ និងតំបន់កំពង់សោម រហូតដល់ខែមករា ឆ្នាំ១៩៧៩ ដោយចំណុចនេះត្រូវបានបញ្ជាក់ដោយកម្មាភិបាលកងពលធំ ១៦៤ ដែលមានមូលដ្ឋាននៅកំពង់សោម[570]។ មនុស្សជាច្រើនបានពន្យល់ថា ក្រោយពេលដែល មាស មុត ត្រូវបានតែងតាំងឲ្យទៅធ្វើការងារនៅអគ្គបញ្ជាការកងទ័ពបដិវត្តកម្ពុជា នៅទីក្រុងភ្នំពេញ និងត្រូវទទួលយកការចាត់តាំងទៅក្បែរព្រំដែនវៀតណាមមក គាត់នៅបន្ត

---

[567] ឯកសារ **D2/8** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន , ឆ.២១, ឆ.២៣, ឆ.២៧, ឆ.៣២, ឆ.៣៧, ឆ.៤៣, ឆ.៥៩។ ឯកសារ **D2/9** កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.៣០ ។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង , ឆ.១០, ឆ.១៣។ ឯកសារ **D4.1.911** កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច ទំព័រ ៣។ ឯកសារ **D1.3.30.29** M. Matsushita & S. Heder, *កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា* EN 00170723 [No. 18]។ ឯកសារ **D4.1.759** បទសម្ភាសន៍ជាមួយ ខែម ងួន ដោយ US POW/MIA EN 00387265-6។ ឯកសារ **D4.1.759** បទសម្ភាសន៍ជាមួយ ម៉ៅ វ៉ាន់ ដោយ US POW/MIA EN 00387267។ ឯកសារ **D4.1.746** បទសម្ភាសន៍ជាមួយ សំ សុក ដោយ US POW/MIA EN 00387462។ ឯកសារ **D4.1.750** បទសម្ភាសន៍ជាមួយបុគ្គលមិនស្គាល់ឈ្មោះ ដោយ US POW/MIA EN 00387278-9។

[568] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៦១។ សូមមើលជាឧទាហរណ៍ ឯកសារ **D114/186** កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ. ១៦ ។ ឯកសារ **D114/89** កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.១៥, ឆ.៦៦។ ឯកសារ **D114/82** កំណត់ហេតុស្តាប់ចម្លើយ កែវ សាន ឆ.៥។ ឯកសារ **D54/98** Heang Ret កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.៣៨ ។ ឯកសារ **D114/181** Sem Kol កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.៦ -ឆ.៨។ ឯកសារ **D54/43** កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៥។ ឯកសារ **D54/51** កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១។

[569] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៧២ (ជើងទំព័រ ២១៧ - ២២០), កថាខណ្ឌ ៧៥ - ៧៦ (ជើងទំព័រ ២២៦ - ២២៩, ២៣២ ) [សូមមើលភស្តុតាងដែលបានដកស្រង់]។

[570] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្តាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦១ (ជើងទំព័រ ១៨៦) កថាខណ្ឌ ៧៨ (ជើងទំព័រ ២៣៦) កថាខណ្ឌ ៨៦៦ (ជើងទំព័រ ៣៥១៥) [សូមមើលភស្តុតាងដែលបានដកស្រង់]។ សូមមើលផងដែរ **D54/79** កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.២៦ ។ ឯកសារ **D54/87** កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.៤៥, ឆ.១៧១ - ១៧២។ ឯកសារ **D1.3.30.29** M. Matsushita & S. Heder, *កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា* EN 00170723។ ឯកសារ **D59/1/1.8a** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រំ សារ៉ាត់, EN 00974227។ ឯកសារ **D54/48** កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.១៩។

ចេញបញ្ជាតាមរយៈ ទឹម សេង បញ្ជាការរងកងពលធំ ១៦៤[571]។ មាស មុត ខ្លួនគាត់ផ្ទាល់ក៏បាន បញ្ជាក់ថា គាត់មិនបានផ្ទេរការងារដឹកនាំកងពលធំ ១៦៤ ឡើយ នៅពេលដែលគាត់ផ្លាស់ទៅ ក្រចេះ[572]។ ការបន្តគ្រប់គ្រងរបស់ មាស មុត ទៅលើកងពលធំ ១៦៤ ក៏ត្រូវបានបង្ហាញផងដែរ ដោយអង្គហេតុដែលថា គាត់បានបញ្ជូន និងដឹកនាំបញ្ជាកងទ័ពកងពលធំ ១៦៤ យ៉ាងច្រើនទៅឯព្រំ ដែនវៀតណាម (រួមទាំង ក្រចេះផង) នៅក្នុងឆ្នាំ ១៩៧៨[573] ហើយគាត់បានតែងតាំងមេបញ្ជាការ កងវរៈសេនាធំពីរនាក់ ក្នុងកងពលធំ ១៦៤ ឲ្យកាន់តួនាទីដែលមានឋានន្តរសក្តិខ្ពស់ជាង នៅក្នុងកង ពលធំ ១១៧ និងតំបន់ ៥០៥ បន្ទាប់ពីបានបោសសម្អាតអតីតមេដឹកនាំនៅទីនោះរួចហើយ[574]។

141. ក្នុងនាមជាលេខាតំបន់ស្វយ័តកំពង់សោម និងជាលេខាកងពលធំ ១៦៤ មាស មុត គ្រប់គ្រងទាំង ការងារស៊ីវិល និងយោធា នៅក្នុងតំបន់កំពង់សោម[575]។ គាត់ទទួលបន្ទុកលើការការពារ និង សន្តិសុខកំពង់ផែកំពង់សោម នៅក្នុងអំឡុងរបបនេះទាំងមូល (កន្លងមកត្រូវបានដាក់ឲ្យនៅក្រោម

---

[571] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៧៨ (ជើងទំព័រ ២៣៦) [សូមមើល ភស្តុតាងដែលបានដកស្រង់]។ ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ ទឹម សេង, សូមមើល ឯកសារ **D256/7** ដីកាសន្និដ្ឋាន ស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ២២៤, ២២៦, ២៤៤។

[572] ឯកសារ **D54/16/1R** ខ្សែអាត់សម្លេងកិច្ចសម្ភាសន៍ រវាង មាស មុត ជាមួយ D. Kattenburg, ខែមេសា ឆ្នាំ២០០៩ 34:37-35:28 [នៅខែកុម្ភៈ ឆ្នាំ១៩៧៨ "ខ្ញុំនៅកាន់តំណែងរបស់ខ្ញុំ [កងពលធំ ១៦៤] ប៉ុន្តែខ្ញុំត្រូវបានចាត់តាំងបេសកម្មមួយទៀតនៅ ក្រចេះ"]។

[573] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២២ (ជើងទំព័រ ៣៥៦), កថាខណ្ឌ ១២៣ (ជើងទំព័រ ៣៦៣-៣៦៥) កថាខណ្ឌ ១២៤ (ជើងទំព័រ ៣៧០) កថាខណ្ឌ ៨៦៤ (ជើងទំព័រ ៣៥០២) និងប្រភពដែលបាន ដកស្រង់។

[574] មាស មុត បានតែងតាំង គឹម ញ៉ាន់ (មេបញ្ជាការកងវរៈសេនាធំ ៦៣ និងជាសមាជិកគណៈកម្មាធិការ កងពលធំ ១៦៤) ធ្វើ ជាលេខាកងពលធំ ១១៧ និង សុខ ភាព (មេបញ្ជាការកងវរៈសេនាធំ ៦៣) ជាលេខាតំបន់ ៥០៥។ សូមមើលឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨៦៤។

[575] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៧៦ - ៧៧, ២២០។

ក្រសួងពាណិជ្ជកម្ម)[576]។ មាស មុត គ្រប់គ្រងទាំងស្រុងលើកំពង់ផែ ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៨ រហូតដល់ខែមករា ឆ្នាំ១៩៧៩[577]។

## ២. មាស មុត គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៥ និងជាអនុលេខាអគ្គសេនាធិការ ចាប់ពីចុងឆ្នាំ ១៩៧៨

142. ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសឆ្គងដោយបញ្ជាក់ថា មានវិមតិសង្ស័យខ្លាំងចំពោះ មាស មុត ដែលអាចធ្លាប់ជាសមាជិកនៃគណៈកម្មាធិការអគ្គសេនាធិការ ហើយថា បើក្នុងករណី ដែលគាត់ពិតជាបានក្លាយជាសមាជិក ឬសូម្បីជានាយអគ្គសេនាធិការរង ក៏ហេតុការណ៍នេះមិន លើសពី៥០ថ្ងៃ មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំដែរ[578]។ តាមរយៈភស្តុតាងដែល បានយោងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់[579] និងភស្តុតាងដែលពាក់ព័ន្ធបំផុត ដែល បានដាក់ក្នុងសំណុំរឿងនៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[580] មិនមានវិមតិសង្ស័យអ្វី

---

[576] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ២២១ (ជើងទំព័រ ៦៦២ - ៦៦៥), ២៥៣។

[577] មាស មុត ចាត់តាំងកម្មាភិបាលកងពលធំ ១៦៤ ធ្វើជាអនុប្រធាន និងប្រធានកំពង់ផែកំពង់សោម ជំនួស ធុច រិន ហៅគ្រិនះ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៧៥ (ជើងទំព័រ ២៣០) កថាខណ្ឌ ២២១ (ជើងទំព័រ ៦៦៦ - ៦៦៧), ២២៤(ក)(គ)។

[578] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦៣, ៤១៨។

[579] សូមមើលជាពិសេស ឯកសារ **D1.3.27.1** កំណត់ហេតុកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥។ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច។

[580] សូមមើលជាឧទាហរណ៍ ឯកសារ **D54/110** កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៨ -ឆ.១០ [ពន្យល់ថា ក្នុងនាមជា មេបញ្ជាការកងពល មាស មុត គឺជាសមាជិកគណៈកម្មាធិការ អគ្គសេនាធិការកងទ័ព ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ ហើយ គាត់ផ្តល់ប្រឹក្សានិងចូលរួមក្នុងការរៀបចំ ផែនការការងារសេនាធិការ]។ ឯកសារ **D54/54** កំណត់ហេតុស្តាប់ចម្លើយ មាស រឿន , ឆ.៤-ឆ.៥ [រៀបរាប់ថា មាស មុត គឺជាសមាជិកគណៈកម្មាធិការ អគ្គសេនាធិការ ហើយមានសិទ្ធិអំណាចលើកងពល ធំលេខ ១ ភូមិភាគបស្ចិម ពាក់ព័ន្ធប្រតិបត្តិការលើផ្ទៃសមុទ្រ]។ ឯកសារ **D32/10** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សារ៉ន ឆ.១៥ [មេបញ្ជាការកងពលទាំងអស់ រួមទាំងមេបញ្ជាការវរៈសេនាតូច និងវរៈសេនាធំស្វយ័តដូចជា ម៉ៅ ជាដើម ជាសមាជិករបស់ សេនាធិការ] ។ ឯកសារ **D114/158** កំណត់ហេតុស្តាប់ចម្លើយ ឌុច ឆ.២៤ ["ក្រោយឆ្នាំ១៩៧៥ ពេលរៀបចំកងទ័ពមជ្ឈិម ខ្ញុំ និយាយពីគណៈកម្មាធិការសេនាធិការ។ គណៈកម្មាធិការសេនាធិការ លេខាគឺ សុន សេន។ បន្ទាប់មក ម៉ែន សាន ហៅ យ៉ា [...] សៀត ឆែ ហៅទុំ [...]។ សមាជិកគណៈកម្មាធិការសេនាធិការរបស់គេ មានតទៅទៀត ទី១គឺបងមុត ទទួលខុសត្រូវកង ទ័ពជើងទឹក ខាងសមុទ្រ។ មិត្ត ម៉េត ទទួលខុសត្រូវខាងអាកាស។ ឯចំណែកគណៈកម្មាធិការផ្សេងទៀត នៅត្រឹមតែជំនួយការ

ឡើយដែលថា មាស មុត ពិតជាសមាជិកនៃគណៈកម្មាធិការអគ្គសេនាធិការ ចាប់តាំងពីពេលចាប់ផ្តើមបង្កើតកងពលធំមជ្ឈិមរបស់កងទ័ពបដិវត្តកម្ពុជា នៅក្នុងខែកក្កដា-សីហា ឆ្នាំ១៩៧៥[581] និងបន្ទាប់មក ជាអនុប្រធានរបស់ សុន សេន យ៉ាងហោចណាស់ចាប់ពីចុងឆ្នាំ ១៩៧៨[582]។

143. ក្នុងនាមជាមេបញ្ជាការកងពលធំមជ្ឈិម និងជាប្រធានកងទ័ពជើងទឹក មាស មុត គឺជាសមាជិកអគ្គសេនាធិការដោយស្វ័យប្រវត្តិ[583]។ ក្នុងនាមជាសមាជិក មាស មុត បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអគ្គសេនាធិការយ៉ាងទៀតទាត់នៅទីក្រុងភ្នំពេញ[584] រួមទាំងកិច្ចប្រជុំពេញអង្គភាគ

---

សេនាធិការទេ"] ។ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680803 [អះអាងថា មាស មុត និង ស៊ូ ម៉េត គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍សេនាធិការ តាំងពីពេលចាប់ផ្តើមមក គឺមិនមែនជាជំនួយការទេ]។

[581] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥៣ -៥៥ និងប្រភពដែលបានដកស្រង់ ។

[582] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥២ -៥៣, ៥៦ -៥៨ និងប្រភពដែលបានដកស្រង់ (ជាពិសេស ជើងទំព័រ ១៦០ -១៦១, ១៦៨, ១៧២ -១៧៧)។ សូមមើលផងដែរ ឯកសារ **D114/297.1.23** ប្រតិចារឹក មឿង វ៉េត ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ 13.48.58-13.50.21 ["ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅសេនាធិការមាន សុន សេន ជាអគ្គបញ្ជាការ ហើយ មាស មុត ជាអគ្គបញ្ជាការរង និង ស៊ូ ម៉េត ជាអគ្គបញ្ជាការរងទទួលបន្ទុកទ័ពអាកាស"]។

[583] ឯកសារ **D54/110** កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៨ -ឆ.១០។ ឯកសារ **D32/10** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សារ៉ន ឆ.១៥ ។ ឯកសារ **D54/54** កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៤ -ឆ.៥។ ឯកសារ **D114/158** កំណត់ហេតុស្តាប់ចម្លើយ ឌុច ឆ.២៤។ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680803។ **D54/37** Soem Ny កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.៣០ -ឆ.៣១។

[584] ឯកសារ **D1.3.8.2 (D4.1.632)** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00162482។ ឯកសារ **D234/2.1.18** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00383773។ ឯកសារ **D1.3.8.3** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00021496។ **D1.3.8.4** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ សមមិត្ត ១៦៤, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ [មាស មុត ប្រហែលជាមានវត្តមាន ទោះបីជាមិនមានការលើកឡើងអំពីឈ្មោះ របស់អ្នកចូលរួមក្តី]។ ឯកសារ **D1.3.27.18** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00052391។ ឯកសារ **D1.3.27.20** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00052412។ ឯកសារ **D1.3.27.22** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ERN(ភាសាខ្មែរ) 00088930 [កិច្ចប្រជុំពេញអង្គ]។ ឯកសារ **D1.3.27.26** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ ERN(ភាសាខ្មែរ) 00052307។ កំណត់ហេតុកិច្ចប្រជុំពីរផ្សេងទៀត មិនបានលើកឡើងពីបញ្ជីឈ្មោះអ្នកចូលរួមទាំងស្រុងឡើយ៖ ឯកសារ **D1.3.8.7** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃ

ច្រើនផងដែរ[585] ។ ចំពោះសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការអគ្គសេនាធិការ ដីកាសម្រេចលើកលែងចោទប្រកាន់ មានភាពមិនស៊ីសង្វាក់គ្នាទេ។ កថាខណ្ឌ ១៦៣ បានពិភាក្សាអំពីបញ្ហាថាតើ មាស មុត គឺជាសមាជិកអគ្គសេនាធិការដែរឬទេ និងបានដកស្រង់ ឌុច ដែលជាប្រភពមូលដ្ឋានតែមួយគត់ដែលលើកឡើង ពីលទ្ធភាពនៃសមាជិកភាពបែបនេះ។ ប៉ុន្តែ នៅក្នុងផ្នែកសំអាងហេតុ និងសន្និដ្ឋាននៃដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៨ បានបញ្ជាក់ថា ដោយផ្អែកលើមូលដ្ឋាននៃកថាខណ្ឌ ១៦៣ ដដែលនេះថា "សាក្សីភាគតិចថាគាត់ជាអនុប្រធានសេនាធិការ"[586]។ ជាបឋម ជារឿងសមហេតុផលដែរថា មាស មុត មិនអាចត្រូវបានតម្លើងឋានៈជានាយអគ្គសេនាធិការរង ដោយមិនឆ្លងកាត់ជាសមាជិកអគ្គសេនាធិការជាដំបូងសិននោះឡើយ។ លើសពីនេះទៀត នៅក្នុងការស្តាប់ចម្លើយតែមួយគត់ដែលបានដកស្រង់ (ដូច្នេះ មានសាក្សីតែមួយរូបប៉ុណ្ណោះ មិនមែនសាក្សីភាគតិច ដូចលើកឡើងនៅក្នុងកថាខណ្ឌ ៤១៨ ឡើយ) ឌុច បានពិភាក្សាអំពីតួនាទីរបស់ មាស មុត ជាសមាជិកអគ្គសេនាធិការ តែមិនមែនជានាយសេនាធិការរងទេ[587]។ ដោយគ្មានវិមតិសង្ស័យអ្វី នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ យោងទៅរកសាក្សីភាគតិចដែលពិភាក្សាអំពីឋានៈរបស់ មាស មុត ជានាយអគ្គសេនាធិការរង គឺសាក្សីទាំង

---

ទី១៨ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.8** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦។ សូមមើលផងដែរ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៥៦ (ជើងទំព័រ ៤៤៦)។ ["មាស មុត ចូលរួមកិច្ចប្រជុំសេនាធិការជាញឹកញាប់ ដើម្បីពិភាក្សាពីផែនការបោសសម្អាត កងពលធំរបស់កងទ័ពបដិវត្តកម្ពុជា"]។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥៤-៥៥ និងភស្តុតាងដែលបានដកស្រង់។

[585] មាស មុត ដែលកំពុងជាប់រវល់ និងឈរជើងនៅឆ្ងាយពីទីក្រុងភ្នំពេញ មិនបានចូលរួមក្នុងកិច្ចប្រជុំ ដែលរៀបចំឡើងសម្រាប់អ្នក ដែលឈរជើងនៅក្នុងទីក្រុងភ្នំពេញ ឬនៅក្បែរទីក្រុងភ្នំពេញឡើយ៖ សូមមើលជាឧទាហរណ៍ ឯកសារ **D1.3.27.12** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ [អ្នកចូលរួមបីនាក់ បូក សុន សេន]។ ឯកសារ **D1.3.27.16** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ [អ្នកចូលរួមបួននាក់]។ ឯកសារ **D1.3.27.13** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ [អ្នកចូលរួមប្រាំមួយនាក់]។

[586] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦៣ ["ទាក់ទងនឹងសមាជិកភាពរបស់ មាស មុត នៅក្នុងសេនាធិការ យើងឃើញថាចំណុចនេះ នៅមានវិមតិសង្ស័យច្រើន។ [...] ឌុច បានលើកឡើងថា ប្រហែលជាទាល់តែ យ៉ាង និង ទុំ ត្រូវបានកម្ទេច ទើប*មានសមាជិក* ស៊ូ ម៉េត និង មាស មុត"] កថាខណ្ឌ ៤១៨ ["ប្រសិនបើជាការពិត ដូចការអះអាងរបស់សាក្សីភាគតិច ថាគាត់ជាអនុប្រធានសេនាធិការមែន [...] (កថាខណ្ឌ ១៦៣)"] (ដោយគូសបញ្ជាក់បន្ថែម).

[587] ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680802។

អស់នេះហើយដែលបានផ្តល់សក្ខីកម្ម នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ហើយលើកឡើងយ៉ាងច្បាស់អំពីតួនាទីនេះ[588]។

144. ទាក់ទងទៅនឹងរយៈពេលនៃសមាជិកភាពរបស់ មាស មុត ដីកាសម្រេចលើកលែងចោទប្រកាន់បញ្ជាក់ថា បើទោះបីជា មាស មុត គឺជាសមាជិក ឬជានាយអគ្គសេនាធិការរងក្តី ក៏ក្នុងរយៈពេលមិនលើសពី៥០ថ្ងៃ ឬមួយខែឡើយ[589]។ ប៉ុន្តែ ឌុច មិនបានលើកឡើងអំពីកាលបរិច្ឆេទណាមួយឡើយនៅក្នុងកំណត់ហេតុសួរចម្លើយដែលបានដកស្រង់នោះ ហើយ ឌុច ក៏មិនបានលើកឡើងសូម្បីតែអំពីកាលបរិច្ឆេទនៃការផ្លាស់ទី មែន សាន ហៅ យ៉ា ឬអំពីការសម្លាប់ សៀត ឆែ ហៅ ទុំ ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានអះអាងថា ក្រោយហេតុការណ៍នេះ ស៊ូ ម៉េត និង មាស មុត អាចក្លាយជាសមាជិកឬនាយរង នៅក្នុងសមាជបក្សថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ផ្ទុយទៅវិញ ឌុច បានបញ្ជាក់យ៉ាងច្បាស់ថា ទាំង មាស មុត និង ស៊ូ ម៉េត គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការពេញក្នុងរបបនេះទាំងស្រុងតែម្តង[590]។

145. ដោយផ្ទុយនឹងខ្លួនឯងផ្ទាល់នោះ ដីកាសម្រេចលើកលែងចោទប្រកាន់ ជាដំបូងបានយល់ស្របជាមួយ ឌុច ថា "សមាជិកភាព [...] សេនាធិការមានដូចជា មាស មុត ទទួលបន្ទុកខាងកងទ័ពជើងទឹក ស៊ូ ម៉េត ទទួលបន្ទុកខាងកងទ័ពជើងអាកាស"[591]។ ទោះជាបែបនេះក្តី នៅពេលបន្ទាប់មក

---

[588] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥២ -៥៣, ៥៦ -៥៨ និងប្រភពដែលបានដកស្រង់ (សូមមើលជាឧទាហរណ៍, ជើងទំព័រ ១៦០ -១៦១, ១៦៨, ១៧២ -១៧៧)។ ការនេះបានបង្ហាញជាថ្មីថា ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានទាត់ចោលភស្តុតាង ដែលបានដាក់ចូលសំណុំរឿង នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១ ឡើយ គឺគ្រាន់តែប្រើប្រាស់ឯកសារទាំងនោះ ដោយមិនដកស្រង់ប៉ុណ្ណោះ។

[589] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦៣, ៤១៨។

[590] ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680803 (ដោយគូសបញ្ជាក់បន្ថែម) ["បន្ទាប់មកទៀតទើបមានសមាជិកគឺ មាស មុត ទទួលបន្ទុកកងទ័ពជើងទឹក ស៊ូ ម៉េត ទទួលបន្ទុកជៀងអាកាស [...] មាស មុត និង ស៊ូ ម៉េត ជាសមាជិកអគ្គសេនាធិការ ទទួលបន្ទុកកងទ័ពជើងទឹក និងអាកាស [...] ភាពជាសមាជិកអគ្គសេនាធិការនេះ គឺត្រូវបានតែងតាំងសម្រាប់មួយរបបពេញតែម្តង"], FR 00794727 ["ឯកសារជាភាសាបារាំង មិនបានប្រើប្រាស់ពាក្យ "បន្ទាប់ពីអ្នកទាំងនោះ (បន្ទាប់មកទៀត)" ទេ ប៉ុន្តែបញ្ជាក់ថាក្រៅពី សុន សេន យ៉ាង និង ទុំ "សមាជិកដទៃទៀតគឺ មាស មុត និង ស៊ូ ម៉េត" (ការបកប្រែក្រៅផ្លូវការ)។ សូមមើលផងដែរ អំពីពេលវេលា ដែលសមាជិកភាពរបស់ មាស មុត បានចាប់ផ្តើម (ឆ្នាំ ១៩៧៥)៖ ឯកសារ **D114/158** កំណត់ហេតុស្តាប់ចម្លើយ ឌុច ឆ.២៤។ ឯកសារ **D54/110** កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.១០។

[591] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦០ ដកស្រង់ឯកសារ **D12** ឌុច, ERN(ភាសាខ្មែរ) 00680803។

ដីកាសម្រេចលើកលែងចោទប្រកាន់ បញ្ជាក់ថា មាស មុត "អាចត្រូវបានតែងតាំងជាគណៈជំនួយការ ផ្នែកនយោបាយរបស់សេនាធិការ នៅក្នុងអំឡុងពេលនៃសមាជរបស់មជ្ឈិមបក្សនាឆ្នាំ ១៩៧៥"[592]។ នេះគឺជាការទាយស្មាន និងមិនមានភាពស៊ីសង្វាក់គ្នាសោះ។ នៅក្នុងប្រភពដែលបានដកស្រង់ គឺកំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប៉ុល ពត ពិតជាបានស្នើឲ្យមាន "គណៈជំនួយការសេនាធិការ" ទទួលផ្នែកភស្តុភារ និងគោលនយោបាយកងទ័ព ប៉ុន្តែមិនបានលើកឡើងពីឈ្មោះនរណាម្នាក់ឡើយ[593]។ បន្ថែមពីលើភាពច្របូកច្របល់នេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ក៏បានអះអាងផងដែរថា "កម្មាភិបាលដែលអាចក្លាយជាជំនួយការ របស់សេនាធិការ គឺជាក្រុមមានចំនួនច្រើន ជ្រើសរើសចេញមកពីកម្មាភិបាល "ត្រឹមវរៈសេនាតូច វរៈសេនាធំ" ហើយ សុន សេន និង*លេខាកងពល* អាចជួយអប់រំពួកគេបាន"[594] ដែលកំណត់ថា មាស មុត គឺស្ថិតក្នុងឋានានុក្រមខ្ពស់ខ្លាំង ជាងជំនួយការសេនាធិការណាមួយ ក្នុងកងទ័ពបដិវត្តកម្ពុជា។ ជាចុងក្រោយ ដីកាសម្រេចលើកលែងចោទប្រកាន់ បានបញ្ជាក់ថា បើយោងតាម ឌុច "លេខាកងពលជាជំនួយការ របស់សេនាធិការ"[595]។ ទោះជាយ៉ាងនេះក្តី ការបញ្ជាក់នេះបានលើកឡើងដោយខុសឆ្គងពីចម្លើយរបស់ ឌុច ព្រោះ ឌុច យោងទៅជំនួយការមួយចំនួន (អ៊ិន លន ហៅ ណាត ស៊ុន ទី ហៅ ទាញ និង ពេជ្រ ចាន់ ហៅ សោម) ដែលជាលេខាកងពលធំផងដែរ និងយោងទៅជំនួយការដទៃៗទៀត ដូចជា ចាន់ ចក្រី និង ជ័យ ហាន ហៅ ឆាន (កូនចៅ មាស មុត នៅកងពលធំ ១៦៤)។ ប៉ុន្តែ ឌុច បានបញ្ជាក់ពីរដងនៅក្នុងចម្លើយនេះថា មាស មុត និង ស៊ូ ម៉េត ពិតជាសមាជិកគណៈកម្មាធិការ អគ្គសេនាធិការ មិនមែនជាជំនួយការនោះទេ[596]។

---

[592] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦២ ដកស្រង់ **D1.3.27.1** កំណត់ហេតុកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ដែលយោងខុសទៅរកទំព័រ ៥ (ERN(ភាសាខ្មែរ) 00019112)។

[593] ឯកសារ **D1.3.27.1** កំណត់ហេតុកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ERN(ភាសាខ្មែរ) 000119120 (ទំព័រ១៣) [សមមិត្តលេខា៖ "ការចាត់តាំងគណៈសេនាធិការ៖[...] ត្រូវដំណើរការតាមសមូហភាព ព្រោះការងារថ្មីទាមទារការដឹកនាំជាសមូហភាព [...] ត្រូវមានគណៈជំនួយការងារខាងនយោបាយ យោធា ភស្តុភារ"]។

[594] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៧ (ជើងទំព័រ ៤៥១) (ដោយគូសបញ្ជាក់បន្ថែម)។

[595] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៧ ដកស្រង់ ឯកសារ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680802។

[596] ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680804។

146. ដោយផ្អែកលើសក្ខីកម្មលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់របស់សាក្សីជាច្រើនរូប ដែលប្រមូលបាន នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ គ្មានវិមតិសង្ស័យអ្វីឡើយដែលថា មាស មុត ត្រូវបាន តម្លើងឋានៈទៅជា អនុប្រធានរបស់ សុន សេន នៅក្នុងគណៈកម្មាធិការ អគ្គសេនាធិការ នៅក្នុង ឆ្នាំ ១៩៧៨[597] ដោយ មាស មុត នៅរក្សាតួនាទីជាមេបញ្ជាការកងពលធំ ១៦៤ រហូតដល់ពេលចុង បញ្ចប់នៃរបបនេះ[598]។ ភាពមិនប្រាកដប្រជាតែមួយ ដែលទាក់ទងជាមួយកាលបរិច្ឆេទ ឬខែពិត ប្រាកដដែល មាស មុត ត្រូវបានតម្លើងឋានៈ។ ទោះបីជា មាស មុត បានអះអាងថា នៅក្នុងខែ កុម្ភៈ ឆ្នាំ១៩៧៨ គាត់ត្រូវបានបញ្ជូនទៅក្រចេះ[599]ក្តី តែសាក្សីភាគច្រើនបញ្ជាក់ថា នៅក្នុងខែកញ្ញា- តុលា ឆ្នាំ ១៩៧៨ ឬ "ចុងឆ្នាំ ១៩៧៨" ដែលគាត់ចេញពីកំពង់សោម ទៅចូលទីបញ្ជាការដ្ឋាន អគ្គសេនាធិការ ដោយចាប់ផ្តើមដឹកនាំបញ្ជាកងកម្លាំងកងពលធំ១១៧ នៅក្នុងពេលវាយប្រយុទ្ធ

[597] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥២ -៥៣, ៥៦ -៥៨ និងប្រភពដែល បានដកស្រង់ (ជាពិសេស ជើងទំព័រ១៦០-១៦១, ១៦៨, ១៧២ -១៧៧ ) រួមទាំងឯកសារ **D114/297.1.24** ប្រតិចារឹក មឿង វ៉េត ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ 09.41.46-09.46.58។ ឯកសារ **D114/297.1.23** ប្រតិចារឹក មឿង វ៉េត ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៦ 13.48.58-13.50.21។ ឯកសារ **D54/62** កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត ឆ.២២-ឆ.២៣, ឆ.២៥, ឆ.២៧។ ឯកសារ **D54/60.2** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ មឿង វ៉េត EN 00992989។ ឯកសារ **D54/63** កំណត់ហេតុស្តាប់ចម្លើយ មឿង វ៉េត, ឆ.៣១។ ឯកសារ **D54/100** កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.៩៦។ ឯកសារ **D54/99.1** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ EN 01115988។ ឯកសារ **D114/297.1.27** ប្រតិចារឹក សេង សឿន ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ 13.55.39-14.00.52។ ឯកសារ **D114/169** Seng Soeun កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.៥, ឆ.២៥។ ឯកសារ **D114/186** កំណត់ហេតុស្តាប់ចម្លើយ សាត ចក់, ឆ.១២៦ - ឆ.១២៧, ឆ.១២៩ - ឆ.១៣០។ ឯកសារ **D114/65** Chet Bunna កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.៩ - ឆ.១០, ឆ.១២។ ឯកសារ **D59/1/1.8a** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រំ សារ៉ាត់, EN 00974225-26។ ឯកសារ **D59/1/1.11a** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ហៀង វ៉េត ERN(ភាសាខ្មែរ) 00926542។

[598] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៦ (សូមមើលប្រភពដែលបានដកស្រង់ នៅជើងទំព័រ ១៦៩), កថាខណ្ឌ ៨៦៦។

[599] មាស មុត អះអាងថា គាត់នៅបន្តគ្រប់គ្រងលើកងពលធំ ១៦៤ បន្ទាប់ពីគាត់ចាកចេញពីកំពង់សោម ប៉ុន្តែគាត់បញ្ជាក់ថា ហេតុការណ៍នេះកើតឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨៖ ឯកសារ **D54/16/1R** ខ្សែអាត់សម្លេងកិច្ចសម្ភាសន៍ រវាង មាស មុត ជាមួយ D. Kattenburg, ខែមេសា ឆ្នាំ២០០៩ 34:37-35:28 ["នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានចេញពីកំពង់សោមបាត់ហើយ [...] ខ្ញុំ ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅខេត្តក្រចេះ [...] ខ្ញុំនៅកាន់តំណែងរបស់ខ្ញុំ [ក្នុងកងពលធំ ១៦៤] ប៉ុន្តែខ្ញុំត្រូវបានចាត់តាំង ឲ្យ បំពេញបេសកកម្មមួយទៀតនៅក្រចេះ"]។ សូមមើលផងដែរ ឯកសារ **D59/1/1.11a** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារ កម្ពុជា ជាមួយ ហៀង វ៉េត ERN(ភាសាខ្មែរ) 00926570 [ក្នុងឆ្នាំ ១៩៧៧]។

យ៉ាងខ្លាំងក្លានៅតាមព្រំដែនជាមួយវៀតណាម[600] មុនពេលដែលគាត់ធ្វើការបោសសម្អាតដោយផ្ទាល់ ទាំងនៅតំបន់ ៥០៥ (ក្រចេះ) និងកងពលធំ ១១៧ នៅក្នុងខែវិច្ឆិកា-ធ្នូ ឆ្នាំ ១៩៧៨ ហើយនឹងបន្តគ្រប់គ្រងទីនោះ រហូតដល់ពេលចុងបញ្ចប់នៃរបប[601]។

147. តាមពិតទៅ ឥទ្ធិពលរបស់ មាស មុត នៅក្នុងកងទ័ពបដិវត្តកម្ពុជា បានឈានទៅដល់កម្រិតខ្ពស់បំផុតនៅចុងឆ្នាំ ១៩៧៨ នៅពេលដែលគាត់ត្រូវបានប្រគល់ឲ្យការត្រួតត្រាទៅលើផ្នែកទាំងបី នៃកងទ័ពបដិវត្តកម្ពុជា ហើយត្រូវបានចាត់តាំងឲ្យធ្វើការបោសសម្អាតនៅក្នុងតំបន់ស្វយ័ត និងកងពលធំមជ្ឈិមដទៃទៀត។ នៅពេលនោះ បើយោងតាមសេចក្ដីណែនាំរបស់គណៈកម្មាធិការមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[602] មាស មុត អាចធ្វើសេចក្ដីសម្រេច "កម្ទេច" ទាំងក្នុង និងក្រៅជួរកងទ័ពបដិវត្តកម្ពុជាទាំងមូល មិនមែនត្រឹមតែកងទ័ពនៃកងពលធំ ១៦៤ ជនស៊ីវិលនៅកំពង់សោម និងជនបរទេសនៅលើផ្ទៃសមុទ្រនោះទេ។ ភស្តុតាងបានកំណត់ថា មាស មុត ពិតជាបានប្រើប្រាស់អំណាចរបស់គាត់ដើម្បីកម្ទេច ហើយបានប្រើបាស់អំណាចនេះនៅចុងឆ្នាំ ១៩៧៨ ដោយមានជំនួយពីកម្មាភិបាលកងពលធំ ១៦៤ ដែលស្ថិតក្រោមបញ្ជារបស់គាត់ ដើម្បីធ្វើការចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ បណ្ដាមេដឹកនាំយោធា នៃកងពលធំ ១១៧ រួមជាមួយកម្មាភិបាលស៊ីវិលកម្រិតកំពូល នៃតំបន់ ៥០៥ និងជនជាតិវៀតណាមចំនួន ៦ នាក់ផង[603]។ ហេតុ

---

[600] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥២ -៥៣, ៥៦, ១២១ -១២២, ៨៥៩ (ជើងទំព័រ ៣៤៦៦)។ សូមមើលជាឧទាហរណ៍ ឯកសារ **D59/1/1.8a** កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រុំ សារ៉ាត់, ERN(ភាសាខ្មែរ) 00926372 [នៅអំឡុងខែកញ្ញា ឆ្នាំ១៩៧៨ មាស មុត ធ្វើដំណើរទៅភ្នំពេញ ហើយគាត់ជាអគ្គមេបញ្ជាការរងអគ្គសេនាធិការ]។ ឯកសារ **D54/63** កំណត់ហេតុស្ដាប់ចម្លើយ មឿង វ៉េត ឆ.១១-ឆ.១២ ["មាស មុត ធ្វើការនៅសេនាធិការ ដូច្នេះគាត់មានអំណាចបញ្ជាដល់ កងកម្លាំងកងទ័ពទាំងបីផ្នែក [...] ឆ.១២ [នៅខែតុលា ឆ្នាំ១៩៧៨] យើងបានស្នើសុំជំនួយពី មាស មុត [...] នៅល្ងាចនោះគាត់បានបញ្ជូនយន្តហោះមួយគ្រឿង [ទៅក្រចេះ] ដើម្បីជួយយើង"]។ ឯកសារ **D54/23** កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក់ សុខ ឆ.៨-ឆ.៩ ["មាស មុត ត្រូវបានបញ្ជូនទៅក្រចេះ ដោយសារតែពេលនោះ ការចាប់ខ្លួនកម្មាភិបាលបានកើនឡើង [...]ឆ.៩៖ គាត់ទៅទីនោះនៅចុងឆ្នាំ ១៩៧៨"]។

[601] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥៨, ៨៧, ៨៩, ១២០-១២៣, ៨៤៥ - ៨៤៩, ៨៦០ - ៨៦៣, ៨៦៧ និងភស្តុតាងដែលបានដកស្រង់។

[602] សេចក្ដីណែនាំថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈកម្មាធិការមជ្ឈិម ត្រូវបានពិភាក្សាដូចនៅផ្នែកខាងលើ និងនៅផ្នែកខាងក្រោម កថាខណ្ឌ ១០០, ១៥២ [សូមមើលផងដែរ កថាខណ្ឌ ៨៣, ៩៨]។

[603] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥៨, ៨៧, ៨៩, ១២០-១២៣, ៥៥០, ៨៤៥-៨៤៩, ៨៦០-៨៦៣, ៨៦៧ និងភស្តុតាងដែលបានដកស្រង់។ សូមមើលផងដែរ អំពីសិទ្ធិអំណាចរបស់គាត់ ក្នុងការធ្វើ

ដូច្នេះ ការទាយស្មានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ អំពីចំនួនថ្ងៃ ឬខែដែល មាស មុត ជានាយរងសេនាធិការ នៅចុងឆ្នាំ ១៩៧៨ មិនមានភាពពាក់ព័ន្ធអ្វីឡើយ[604]។

## ៣. មាស មុត គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីខែមករា ឆ្នាំ១៩៧៦

148. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសឆ្គងក្នុងការសម្រេចថា មិនអាចកំណត់បានអំពីសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយថា មាស មុត គ្រាន់តែជា "ជំនួយការ" គណៈកម្មាធិការមជ្ឈិម ដែលមិនមានសិទ្ធិបោះឆ្នោត ឬចូលរួមក្នុងការពិភាក្សា ឬ "កម្មេច" ខ្លាំងដែលបានសន្មតនោះឡើយ[605]។ សមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម ត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដោយប្រភពដែលគួរឱ្យជឿជាក់បំផុត ចំពោះបញ្ហាមួយនេះ គឺ ខៀវ សំផន ដែលជាប្រមុខរដ្ឋ និងជាសមាជិកគណៈកម្មាធិការមជ្ឈិម ចាប់តាំងពីខែមករា ឆ្នាំ១៩៧៦ (ជាសមាជិកត្រៀមក្នុងឆ្នាំ ១៩៧១ - ១៩៧៦)។ ខៀវ សំផន មិនមានមូលហេតុអ្វីដែលត្រូវនិយាយបំផ្លើសអំពីតួនាទីរបស់ មាស មុត ឡើយ[606]។ ខៀវ សំផន ស្ថិតក្នុងស្ថានភាពមួយដែលល្អខ្លាំងជាង ឌុច ដែលអាចដឹងអំពីសមាជិកភាពរបស់គណៈកម្មាធិការមជ្ឈិម ព្រោះ ឌុច មិនមែនជាសមាជិកឡើយ ហើយគាត់គ្រាន់តែផ្អែកទៅលើការគិតរបស់គាត់ដែលថា មាស មុត គ្រាន់តែជាជំនួយការគណៈកម្មាធិការមជ្ឈិម ជាតួនាទីមួយដែលមិនមានចែង

សកម្មភាពក្នុងនាម សុន សេន នៅស្រុកមេមត់ ភូមិភាគបូព៌ា និងបង្ក្រាប "ពួកប៉ះបោរកម្ពុជាប្រជាធិបតេយ្យ"៖ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២៤ (ជើងទំព័រ ៣៧0)។

[604] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៦៣, ៤១៨។

[605] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១0៨-១១៥, ១១៧-១២២។

[606] ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156620 ["ខ្ញុំខ្លួនឯងក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ជាដំបូងជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦។"], ERN (ភាសាខ្មែរ) 00156619 ["មហាសន្និបាតលើកទីបី និងជាលើកចុងក្រោយ ត្រូវបានធ្វើនៅឆ្នាំ១៩៧៦ នៅភ្នំពេញនៅបូរីកីឡា"]។ សូមមើលផងដែរ អំពីការរៀបចំសមាជបក្សលើកទីបួន នៅក្នុងខែមករា ឆ្នាំ១៩៧៦ ដែលសមាជិកគណៈកម្មាធិការមជ្ឈិមថ្មី ត្រូវបានតែងតាំងឡើងអនុលោមតាមមាត្រា ២១(៣) និង ២៤ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា (ឯកសារ **D1.3.22.1**)៖ ឯកសារ **D4.1.871** *ទស្សនាវដ្តីទង់បដិវត្ត* ខែកញ្ញា ឆ្នាំ១៩៧៨ ERN(ភាសាខ្មែរ) 00147763 ["មហាសន្និបាតបក្សក្នុងខែមករា ឆ្នាំ ១៩៧៦"]។ ឯកសារ **D4.1.1006** *លក្ខន្តិកៈសម្ព័ន្ធយុវកក* ERN(ភាសាខ្មែរ) 00175610 ["ខែមករា ឆ្នាំ១៩៧៦"]។ ឯកសារ **D1.3.17.6** S. Heder and B. Tittemore, *Seven Candidates for Prosecution,* EN 00393581 ["មហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជានៅក្នុងខែមករា ឆ្នាំ១៩៧៦"]។ ឯកសារ **D1.3.17.1** E. Becker, *នៅពេលសង្គ្រាមរលត់ទៅ* ERN(ភាសាខ្មែរ) 00217254 [មហាសន្និបាតបក្សក្នុងខែមករា ឆ្នាំ១៩៧៦]។

នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា[607] ផ្អែកលើប្រភពបន្ទាប់បន្សំ និងចម្លើយសារភាពនៅមន្ទីរសន្តិសុខស-២១ ដែលទទួលបានដោយការធ្វើទារុណកម្ម[608]។ ខៀវ សំផន បានអះអាងយ៉ាងច្បាស់ថា មាស មុត គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[609]។ នៅពេលស្នើសុំឲ្យ

---

[607] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ មាត្រា ២៤ [បង្ហាញអំពី "សមាជិកពេញសិទ្ធិ និងសមាជិកត្រៀម"]។ សូមមើល ឯកសារ **D12** ឌុច កំណត់ហេតុស្តាប់ចម្លើយ ERN(ភាសាខ្មែរ) 00680804 [ឌុចអះអាងថាលក្ខន្តិកៈត្រូវបានរំលោភបំពាន ដោយសារបង្កើតនូវគណៈកម្មាធិការជំនួយការ]។

[608] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១១០-១១២, កថាខណ្ឌ ១១៧ - ១១៨, កថាខណ្ឌ ១២០ - ១២១។ ឯកសារ **D1.3.33.13** ឌុច កំណត់ហេតុស្តាប់ចម្លើយ ERN(ភាសាខ្មែរ) 00154926 ["ក្នុងចំណោមសមាជិកគណៈកម្មាធិការជំនួយការ នៃគណៈកម្មាធិការមជ្ឈិម មានជាពិសេសគឺ ឈឹម សំអោក ហៅ ប៉ង់ សំ ប៊ិត [...] មាស មុត [...] ស៊ូ សាម៉េត[...] សួង [...] និង វៀន អែម ហៅសារុន"]។ ឯកសារ **D1.3.33.10** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00195569 [នៅចុងឆ្នាំ ១៩៧៥ "ណាត់បាននិយាយថា គាត់ខកចិត្តដោយសារតែគាត់ មិនត្រូវបានគេតម្លើងឋានៈ។ ខ្ញុំមិនសូវជឿណាត់ ទេ។ ដូច្នេះហើយខ្ញុំបានសួរចម្លើយ កុយ ធួន ពីបញ្ហានេះ *នៅពេលដែលគាត់ជាប់ឃុំនៅស២១* ហើយគាត់បានបញ្ជាក់អះអាងពីចំនុចនេះ។ ប៉ង់ ក៏បានបញ្ជាក់អះអាងពីព័ត៌មាននេះដែរ នៅថ្ងៃមួយ *ដែលគាត់បានមកស២១*"] (ដោយគូសបញ្ជាក់បន្ថែម)។ ឯកសារ ឯកសារ **D12** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00680802 ["ណាត [...] តូចចិត្តនឹងបុគ្គលបួននាក់បានចូលជាជំនួយការមជ្ឈិម ប៉ុន្តែមិនមានគាត់។ [...] ទាំងអស់នេះគឺ ណាត ជាអ្នកនិយាយប្រាប់ខ្ញុំ។ ដូចគ្នាដែរ មេរបស់ខ្ញុំ សុនសេន ក៏បាននិយាយពីរឿងនេះប្រាប់ខ្ញុំដែរ"]។ ឯកសារ **D1.3.33.7** ចម្លើយរបស់ ឌុច នៅតុលាការយោធា ERN(ភាសាខ្មែរ 00185241។ ឯកសារ **D4.1.948** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00215271។ ឯកសារ **D4.1.947** កំណត់ហេតុស្តាប់ចម្លើយ ឌុច នៅតុលាការយោធា ERN(ភាសាខ្មែរ) 00155824។ *Contra*: **D10.1.64** សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយរបស់ជនត្រូវចោទ ERN(ភាសាខ្មែរ) 00404803, ជើងទំព័រ ៣៣ ["ឈ្មោះសមាជិកមជ្ឈិម ដែលខ្ញុំធ្លាប់ឮគឺ ខៀវ សំផន, ពក, ប៉ាល់, សារុន, សំ ប៊ិត, មាស មុត, ស៊ូ ម៉េត, និង សឿង""] (ដោយគូសបញ្ជាក់បន្ថែម)។ ឯកសារ **D4.1.405** កំណត់ហេតុស្តាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00244235 ["[ណាត] បង្ហាញពីការច្រណែននៅពេលដែល មាស មុត និង សំ ប៊ិត ត្រូវបានតែងតាំងជាសមាជិក គណៈកម្មាធិការមជ្ឈិម នៅឆ្នាំ ១៩៧៥"]។ អាចដែលថា ណាត បានប្រាប់ ឌុច នៅចុងឆ្នាំ ១៩៧៥ (ថា មាស មុត ដែលត្រូវបានតែងតាំងជាជំនួយការ គណៈកម្មាធិការមជ្ឈិម លែងពិតទៀតហើយ នៅពេលដែលមហាសន្និបាត បក្សកុម្មុយនីស្តលើកទីបួន ត្រូវបានធ្វើឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៦ (មិនមែននៅចុងឆ្នាំ ១៩៧៥ ទេ) ហើយតែងតាំង សមាជិកគណៈកម្មាធិការមជ្ឈិមដូចជា ខៀវ សំផន៖ សូមមើល ឯកសារ **D4.1.947** កំណត់ហេតុស្តាប់ចម្លើយ ឌុច នៅតុលាការយោធា ERN(ភាសាខ្មែរ) 00112435។ ឯកសារ **D12** ឌុច កំណត់ហេតុស្តាប់ចម្លើយ ERN(ភាសាខ្មែរ) 00680802

[609] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៤៩ -៥០។ ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156618។ ទោះបីជា ខៀវ សំផន មិនបានបង្ហាញច្បាស់លាស់ អំពីកាលបរិច្ឆេទ ឬរយៈពេលនៃសមាជិកភាពរបស់ មាស មុត ក្តី តែ ខៀវ សំផន បានយោងយ៉ាងច្បាស់ទៅលើរយៈពេល ដែលគាត់ខ្លួនឯងផ្ទាល់ គឺជាសមាជិកពេញសិទ្ធិ (ខែមករា ឆ្នាំ១៩៧៦ រហូតដល់ពេលបញ្ចប់នៃរបប)។ ចំណុចនេះត្រូវបានគាំទ្រដោយអង្គហេតុដែលថា សមាជិកពីររូបផ្សេងទៀតដែលគាត់បានដកស្រង់ (កុយ ធួន និង សឿ វ៉ាស៊ី ហៅ ឌឿន) ត្រូវបានបោសសម្អាតនិងសម្លាប់នៅស២១ ក្រោយខែមករា ឆ្នាំ១៩៧៦ ប៉ុន្តែនៅមុនមហាសន្និបាតបក្សលើកទីប្រាំ នៅចុងឆ្នាំ ១៩៧៨។ ឯកសារ

ផ្តល់ឈ្មោះសមាជិក គណៈកម្មាធិការមជ្ឈិម ខៀវ សំផន បានលើកឈ្មោះ មាស មុត មុនដំបូងគេ មុនពេលលើកឡើងពីឈ្មោះរបស់កម្មាភិបាលជាន់ខ្ពស់បួននាក់ផ្សេងទៀត[610]។

149. ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានផ្តល់សំអាងហេតុសម្រាប់ជាយុត្តិកម្មនៃការជ្រើសរើសចម្លើយរបស់ ឌុច ដោយមិនរើសចម្លើយរបស់ ខៀវ សំផន ទាក់ទងតួនាទីរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម។ គួរឲ្យកត់សម្គាល់ ដីកាសម្រេចលើកលែងចោទប្រកាន់ ហាក់ដូចជាវាយតម្លៃថា ចម្លើយរបស់ ខៀវ សំផន គួរឲ្យជឿជាក់ទាំងស្រុងទាក់ទងនឹងសមាជិកដទៃផ្សេងទៀតរបស់គណៈកម្មាធិការមជ្ឈិម ដែល ខៀវ សំផន បានលើកឡើង ដូចជា ឌឿន កុយ ធួន កែ ពក និង ប៉ង់។ ប្រភពតែមួយគត់ដែលសហចៅក្រមស៊ើបអង្កេតជាតិបានប្រើប្រាស់ ដើម្បីកំណត់ថា កុយ ធួន កែ ពក និង ឌឿន គឺពិតជាសមាជិកគណៈកម្មាធិការមជ្ឈិម គឺការសួរចម្លើយដដែលនេះរបស់ ខៀវ សំផន ដែលនិយាយអំពីសមាជិកភាពរបស់ មាស មុត[611] ហើយចម្លើយរបស់គាត់មួយផ្សេងទៀត គឺជាប្រភពមួយក្នុងចំណោមប្រភពចំនួនពីរ ដែលបង្ហាញភស្តុតាងអំពីសមាជិកភាពរបស់ប៉ង់[612]។ ហេតុដូច្នេះ មិនមានសំអាងហេតុសត្យានុម័តណាមួយសម្រាប់ដីកាសម្រេចលើកលែង

---

**D4.1.950** បញ្ជីឈ្មោះអ្នកទោសស២១ ដែលបានកែសម្រួល របស់ក.ស.ព (កុយ ធួន ល.៤១១៤ ចូលថ្ងៃទី២៥ ខែមករា ឆ្នាំ ១៩៧៧, ឌឿន ល.៩៥៤៦ ចូលថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧, ប៉ង់ ល. ១១១៧)។ ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោសស២១ របស់ក.ស.ច.ស (កុយ ធួន ល.១៤០២៧, ឌឿន ល.២១៨៣, ១៤៥៩៦ ចូលថ្ងៃទី១៦-១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧, ប៉ង់ ល. ១៤១៥៧)។

[610] ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន, ERN(ភាសាខ្មែរ) 00156619 ["គណៈកម្មាធិការមជ្ឈិម មានសមាជិកប្រមាណជា៣០នាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់នោះទេ។ ខ្ញុំចាំដូចជា មាស មុត (កូនប្រសាររបស់តា ម៉ុក ដែលជាលេខានៃកងពលមួយ ដែលឈរជើងនៅកំពត ហើយក្រោយឆ្នាំ ១៩៧៥ ត្រូវបានប្តូរទៅជាកងទ័ពជើងទឹក) និង សឿ វ៉ាស៊ី ហៅ ឌឿន (ជាប្រធានមន្ទីរ ៨៧០) ឬផងដែរ កុយ ធួន កែ ពក។ ខ្ញុំខ្លួនឯងក៏ជាសមាជិកនៃ គណៈកម្មាធិការមជ្ឈិម"]។ ឯកសារ **D4.1.1074** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156675 ["ឈឹម សំអោក ជាអ្នកជិតស្និទ្ធជាមួយ ប៉ុល ពត [...] ឈឹម សំអោក ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម"]។ សូមមើលផងដែរ ឯកសារ **D4.1.4** T. Carney, *The Organization of Power,* EN 00105152-53 [ដកស្រង់ តា មុត គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម រួមជាមួយអ្នកនៅក្រោមបង្គាប់របស់គាត់ នៅគណៈកម្មាធិការកំពង់សោម៖ ធុច រិន ហៅ គ្រិន សមាជិក និង ឡុញ សុខស៊ឹម ហៅ ចាប ឡុញ សមាជិកត្រៀម]។

[611] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១០៨ [ជើងទំព័រ ២៨៤ (កែ ពក និង កុយ ធួន) ២៨៦ (ឌឿន)] ពឹងផ្អែកទាំងស្រុងទៅលើ ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156618។

[612] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១០៨ [ជើងទំព័រ ២៨៧ (ប៉ង់) បញ្ជាក់ថា ប៉ង់ អាចជាសមាជិក (ខៀវ សំផន) ឬជាជំនួយការគណៈកម្មាធិការមជ្ឈិម (ឌុច)] យោងទៅរក ឯកសារ **D4.1.1074** កំណត់ហេតុស្តាប់

ចោទប្រកាន់ ក្នុងការពឹងផ្អែកតែទៅលើការប្រកាសរបស់ ខៀវ សំផន សម្រាប់ការកំណត់អំពីសមាជិកភាពនៃសមាជិកគណៈកម្មាធិការមជ្ឈិមដទៃ ប៉ុន្តែ បែជាមិនផ្ដល់ស្ថានទម្ងន់ដូចគ្នា ចំពោះការលើកឡើងរបស់ ខៀវ សំផន អំពីឈ្មោះ មាស មុត ថាជាសមាជិកគណៈកម្មាធិការមជ្ឈិមផងដែរនោះទេ។ ដោយសារតែតួនាទីយ៉ាងសំខាន់របស់គាត់នៅក្នុងកងទ័ពបដិវត្តកម្ពុជា ក្នុងនាមជាមេបញ្ជាការកងទ័ពជើងទឹក និងជាសមាជិកនៃគណៈកម្មាធិការ អគ្គសេនាធិការ និងការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាលេខាតំបន់ស្វយ័ត ជាការសមហេតុផលដែលថា មាស មុត គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម យ៉ាងហោចណាស់ចាប់តាំងពីខែមករា ឆ្នាំ១៩៧៦។ ដីកាសម្រេចលើកលែងចោទប្រកាន់បានទទួលស្គាល់យ៉ាងច្បាស់ថា គណៈកម្មាធិការមជ្ឈិមរួមមានសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមជាង៣០នាក់ រួមបញ្ចូលទាំង*លេខាតំបន់* ផងដែរ[613]។

150. ដើម្បីកាត់បន្ថយជាអតិប្បរមាតួនាទីរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម ដីកាសម្រេចលើកលែងចោទប្រកាន់ ក៏ពឹងផ្អែកផងដែរទៅលើចម្លើយផ្ទាល់ខ្លួនរបស់ មាស មុត នៅក្នុងអត្ថបទសារព័ត៌មានមួយ ដែលគាត់បានបដិសេធអំពីសមាជិកភាពនេះ និងបានអះអាងថា គាត់គឺជាបក្ខជនសាមញ្ញមួយរូប[614]។ ប៉ុន្តែ ការបដិសេធជាប្រយោជន៍ខ្លួនឯងនេះ មិនត្រូវបានគាំទ្រដោយភស្តុតាងដទៃផ្សេងឡើយ ហើយសមនឹងទទួលបានការផ្ដល់តម្លៃតិចតួចប៉ុណ្ណោះ។ នៅក្នុងការសម្ភាសន៍ដដែលនេះ មាស មុត បានទទួលស្គាល់ថា គាត់បានជួប សុន សេន "ដើម្បីបំពេញការងាររបស់មជ្ឈិមបក្ស"[615]។ ដីកាសម្រេចលើកលែងចោទប្រកាន់ បានកត់សម្គាល់ថា មិនមានឯកសារពីសម័យនោះ ដែលបង្ហាញជាផ្លូវការពីឈ្មោះរបស់ មាស មុត ថាជាសមាជិក

ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156675 និងឯកសារ **D1.3.33.13** កំណត់ហេតុស្ដាប់ចម្លើយ ឌុច ERN(ភាសាខ្មែរ) 00154926។

[613] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១០៩។

[614] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១១៥ (ជើងទំព័រ ៣០៩) ដកស្រង់ ឯកសារ **D1.3.7.8** Meas Muth Statement, *Let Bygones Be Bygones* (Cambodia Daily), ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨។

[615] ឯកសារ **D1.3.7.8** Meas Muth Statement, *Let Bygones Be Bygones* (Cambodia Daily)ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨ EN 00165821 ["មាស មុត ទទួលស្គាល់ថា គាត់បានជួប សុន សេន "ប៉ុន្មានដងដែរ" ដើម្បីអនុវត្តការងាររបស់ គណៈកម្មាធិការមជ្ឈិម"]។

គណៈកម្មាធិការមជ្ឈឹមឡើយ[616]។ ទោះជាយ៉ាងនេះក្តី មិនមានបញ្ជីឈ្មោះសមាជិកទាំងអស់របស់គណៈកម្មាធិការមជ្ឈឹម ដែលនៅសល់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

151. សមាជិកភាពរបស់ មាស មុត នៅគណៈកម្មាធិការមជ្ឈឹម មានឥទ្ធិពលសំខាន់ទៅលើបញ្ហាយុត្តាធិការបុគ្គល ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទាល់បានទទួលស្គាល់ថា សមាជិកភាពនៅក្នុងគណៈកម្មាធិការមជ្ឈឹម ល្មមគ្រប់គ្រាន់សម្រាប់កំណត់ថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់"។ តាមពិតទៅ ដីកាសម្រេចលើកលែងចោទប្រកាន់បានបញ្ជាក់ថា ពាក្យ "មេដឹកនាំជាន់ខ្ពស់" នៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មានន័យថា "កម្រិតយកតែមេដឹកនាំមួយចំនួនតូចតែប៉ុណ្ណោះ ដែលអាចចាត់ចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នេះសំដៅទៅលើតែសមាជិកគណៈកម្មាធិការមជ្ឈឹមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស"[617]។

152. ក្នុងនាមជាសមាជិកម្នាក់ក្នុងចំណោមសមាជិក៣០ នាក់ នៃគណៈកម្មាធិការមជ្ឈឹម មាស មុត បានចូលរួមក្នុងការអនុម័តសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលសម្រេចផ្តល់សិទ្ធិ "កម្ទេច" មនុស្សទាំងក្នុងជួរ និងក្រៅជួរ[618]។ ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈឹម និងគណៈកម្មាធិការអគ្គសេនាធិការ មាស មុត ស្ថិតក្នុងឋានានុក្រមខ្ពស់គ្រប់គ្រាន់ក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា ដោយមានអំណាច និងសិទ្ធិ ក្នុងការចាប់ខ្លួន សម្លាប់ខ្មាំងផ្ទៃក្នុង និងខាងក្រៅ ហើយអាចចាត់ទុកថាជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ ចំពោះឧក្រិដ្ឋកម្មនានានៃរបបកម្ពុជាប្រជាធិបតេយ្យ។

153. ដីកាសម្រេចលើកលែងចោទប្រកាន់ បានរៀបរាប់ពី អៀង ធិរិទ្ធ ដែលស្ថិតក្នុងចំពោះ "មេដឹកនាំជាន់ខ្ពស់" កម្ពុជាប្រជាធិបតេយ្យ ដោយសារតែគាត់គឺជាសមាជិក "គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា"[619]។ ទោះជាយ៉ាងនេះក្តី ដីកាដំណោះស្រាយសំណុំរឿង ០០២ ដែលចុះ

---

[616] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១៥។

[617] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥។

[618] ឯកសារ **D1.3.19.1** សេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

[619] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥ *in fine* [វ៉ាន់ រិទ្ធ អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក៏ត្រូវបានរៀបរាប់ផងដែរ គឺមិនមែនជាសមាជិកគណៈកម្មាធិការមជ្ឈឹមឡើយ យ៉ាងហោចណាស់នៅមុនចុងឆ្នាំ ១៩៧៨]។

ហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប នៅក្នុងខែកញ្ញា ឆ្នាំ២០១០ បានសម្រេចថា "អៀង ធិរិទ្ធ មិនមែនជាសមាជិកនៅក្នុង គណៈអចិន្ត្រៃយ៍ទេ ហើយក៏មិនមែនជាសមាជិក របស់គណៈមជ្ឈឹមដែរ" ដោយដកស្រង់ចម្លើយរបស់ ខៀវ សំផន និង ឌុច[620]។ ទោះបីជា អៀង ធិរិទ្ធ ស្ថិតក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ទាបជាង មាស មុត ខ្លាំងក្តី តែដីកាដំណោះស្រាយសំណុំរឿង ០០២ នៅតែសម្រេចថា អៀង ធិរិទ្ធ គឺជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ "ដោយសារអំណាចឋានានុក្រមជាក់ស្តែង និងតាមច្បាប់"[621]។ ដីកាដំណោះស្រាយបានសម្រេចបន្ថែមទៀតថា អៀង ធិរិទ្ធ ក៏ស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ផងដែរ[622]។

154. ដីកាសម្រេចលើកលែងចោទប្រកាន់ បានបញ្ជាក់ថា មាស មុត "នៅក្រោមកម្មាភិបាលប្រមាណ ៥០នាក់" រួមមាន សមាជិកត្រៀម និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ៩ នាក់ សមាជិកត្រៀម និងសមាជិកពេញសិទ្ធិជាង៣០នាក់ របស់គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការកងទ័ព៦នាក់ និងលេខា អនុលេខា និងសមាជិកគណៈកម្មាធិការអគ្គសេនាធិការ[623]។ ដូចដែលបានបង្ហាញពីខាងលើ ការអះអាងនេះមិនត្រឹមត្រូវទេ ដោយសារតែ មាស មុត គឺជាសមាជិកគណៈកម្មាធិការមជ្ឈឹម (ស្ថាប័នខ្ពស់បំផុតទីពីរនៅក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា និងណែនាំដល់គ្រប់គណៈកម្មាធិការភូមិភាគ និងតំបន់)[624] និងគណៈកម្មាធិការអគ្គសេនាធិការ។

[620] ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១២០៧ [លើកឡើងថា សៅ សារ៉ុន គឺជាសាក្សីតែមួយរូបគត់ដែលបញ្ជាក់ថា អៀង ធិរិទ្ធ គឺជាសមាជិកគណៈកម្មាធិការមជ្ឈឹម ប៉ុន្តែសហចៅក្រមស៊ើបអង្កេត យកតាមចម្លើយរបស់ ខៀវ សំផន និង ឌុច ដែលនិយាយផ្ទុយពីនេះ]។

[621] ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១៣២៧។

[622] ឯកសារ **D10.1.101** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១៣២៨។

[623] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤១៩។

[624] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ មាត្រា ២៣។ ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ERN(ភាសាខ្មែរ) 00156617។

## ធ. កំហុសឆ្គងអង្គហេតុ នៅក្នុងផ្នែកការពិនិត្យទៅលើជនរងគ្រោះក្នុងដីកាសម្រេចលើកលែងចោទប្រកាន់

155. ដីកាសម្រេចលើកលែងចោទប្រកាន់ បានសម្រេចដោយត្រឹមត្រូវថា ចំនួនជនរងគ្រោះគឺជាកត្តាមួយដែលសំខាន់ក្នុងការសម្រេចលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ក្នុងគោលបំណងនៃការវាយតម្លៃលើយុត្តាធិការបុគ្គល[625]។ ទោះជាយ៉ាងនេះក្តី នៅក្នុងសំអាងហេតុរបស់ខ្លួនក្នុងការសម្រេចថា មាស មុត ស្ថិតក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដីកាសម្រេចលើកលែងចោទប្រកាន់ យោងតែទៅលើការសន្និដ្ឋានលើអង្គហេតុស្តីពីចំនួនជនរងគ្រោះ ដែលមានភាពកម្រិតកំណត់យ៉ាងខ្លាំងជ្រុលហួសហេតុរបស់ខ្លួន ដែលផ្តោតតែទៅលើការស្លាប់របស់ជនបរទេស ដែលត្រូវបានចាប់ខ្លួននៅលើសមុទ្រ និងកងទ័ពកងពលធំ ១៦៤ ដែលត្រូវបានបោសសម្អាត នៅមន្ទីរសន្តិសុខស-២១[626]។ ដោយផ្អែកលើមូលដ្ឋាននេះ ដីកាសម្រេចលើកលែងចោទប្រកាន់បានសន្និដ្ឋានថា "ចំនួនជនរងគ្រោះនៃអំពើផ្ទាល់របស់ មាស មុត មានភាពខុសគ្នាឆ្ងាយណាស់ រវាងផលវិបាកនៃអំពើផ្ទាល់នៃទង្វើរបស់ ឌុច"[627]។ នៅផ្នែកផ្សេងទៀតក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ មានការសន្និដ្ឋានបែបកម្រិតកំណត់ខ្លះ ទាក់ទងកម្មករនៅការដ្ឋានវាយថ្មស្ទឹងហាវ ព្រមទាំងជនបរទេសដែលត្រូវបានចាប់ខ្លួនលើផ្ទៃសមុទ្រ និងនៅតាមបណ្តាកោះ និងបានធ្វើការស្ទាបស្ទង់បន្តិចបន្តួចទៅលើភស្តុតាងទាក់ទងនឹងជនរងគ្រោះដែលអាចមាននៅវត្តឥន្ទញ្ញាណ[628]។

156. ការប្រព្រឹត្តិទៅលើជនរងគ្រោះនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ បង្កើតបានជាកំហុសអង្គហេតុ យ៉ាងហោចណាស់ដោយសារសំអាងហេតុបួន (១) នៅក្នុងការវិភាគចុងក្រោយរបស់ខ្លួន ដីកាសម្រេចលើកលែងចោទប្រកាន់បានកាត់បន្ថយជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលមិនបានកើតឡើងនៅមន្ទីរសន្តិសុខស-២១ (២) ដីកាសម្រេចលើកលែងចោទប្រកាន់ មិនបានពិចារណាទាល់តែ

---

[625] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៦៥ -៣៦៦ យោងទៅរក សំណុំរឿង ០០១ ឯកសារ**E188** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ឌុច កថាខណ្ឌ ២២។

[626] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៦ [ពាក្យប្រើប្រាស់សម្រាប់ "ជនបរទេស" ដែលត្រូវបានចាប់មកពីសមុទ្រគឺ "មួយចំនួនទៀត"]។

[627] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[628] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៨០ -២៨៦ (វត្តឥន្ទញ្ញាណ) កថាខណ្ឌ ២៩៩ - ៣០៥ 299-305 (ស្ទឹងហាវ) កថាខណ្ឌ ៣០៧ - ៣២២ (ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ)។

សោះចំពោះជនរងគ្រោះនៅតាមហេតុការណ៍ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មជាច្រើន នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣ (៣) តួលេខនៅមន្ទីរសន្តិសុខស-២១ ដែលដីកាសម្រេចលើកលែងចោទប្រកាន់បានផ្តល់ ប៉ាន់ប្រមាណទាបជាងខ្លាំងពីចំនួនអ្នកស្លាប់នៅមន្ទីរសន្តិសុខស-២១ ដែល មាស មុត ត្រូវទទួលខុសត្រូវយ៉ាងហោចណាស់ក៏ផ្នែកខ្លះ និង (៤) នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ ធ្វើការសម្រេច ឬស្ទាបស្ទង់ទៅលើភស្តុតាងទាក់ទងនឹងជនរងគ្រោះនៅទីតាំងឧក្រិដ្ឋកម្មដទៃ ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានធ្វើការពិចារណាទៅលើភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងឡើយ ដែលបណ្តាលឱ្យមានការសម្រេចលើអង្គហេតុខុសឆ្គង។ ជារួម កំហុសឆ្គងទាំងអស់នេះបណ្តាលឱ្យដីកាសម្រេចលើកលែងចោទប្រកាន់វាយតម្លៃទាបពេកទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនានាដែល មាស មុត ត្រូវទទួលខុសត្រូវ។

157. ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសឆ្គងក្នុងការពិចារណា តែទៅលើជោគវាសនារបស់មនុស្ស ដែលត្រូវបានបញ្ជូនពីកំពង់សោម ទៅកាន់មន្ទីរសន្តិសុខស-២១។ សុន សេន និងមជ្ឈឹមបក្ស បានផ្តល់ដល់ មាស មុត នូវសិទ្ធិអំណាច និងស្វយភាព ក្នុងការអនុវត្តការបោសសម្អាត កម្មាភិបាលកងពលធំ ១៦៤ និងត្រួតត្រា និងដាក់ទណ្ឌកម្មទៅលើប្រជាជនស៊ីវិលនៅកំពង់សោម[629]។ សុន សេន បានប្រគល់ប្រហែលគ្នានេះទៅឱ្យ មាស មុត នូវសិទ្ធិអំណាចក្នុងការចាប់ខ្លួន និងកម្ទេចជនបរទេសដែលត្រូវបានចាប់ខ្លួននៅលើផ្ទៃសមុទ្រ និងនៅតាមបណ្តាកោះ ដែលអះអាងថាជាកម្មសិទ្ធិរបស់កម្ពុជាប្រជាធិបតេយ្យ[630]។ ហេតុដូច្នេះ មានត្រឹមតែមួយភាគតូចប៉ុណ្ណោះនៃកម្មាភិបាលកងពលធំ ១៦៤ (៦៧) ប្រជាជនស៊ីវិលនៅកំពង់សោម និងជនបរទេសដែលត្រូវបានចាប់ខ្លួននៅលើផ្ទៃសមុទ្រ ដែលត្រូវបានគេបញ្ជូនទៅភ្នំពេញ ហើយសម្លាប់នៅមន្ទីរសន្តិសុខស-២១។ ភាគច្រើននៃជនរងគ្រោះ ត្រូវបានដាក់ឱ្យទៅជាទាសករ ចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម និង/ឬសម្លាប់ នៅការដ្ឋាន ទីតាំងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខកំពង់សោម ឬត្រូវបានសម្លាប់នៅក្នុងសមុទ្រ ឬនៅលើកោះក្បែរៗនោះ។

[629] សូមមើលផ្នែកខាងលើ, កថាខណ្ឌ ៩៦, ១០៣-១០៧។

[630] សូមមើលផ្នែកខាងលើ, កថាខណ្ឌ ៩៨-១០២។

158. ដូចដែលបានរៀបរាប់លម្អិតខាងលើ[631] ដីកាសម្រេចលើកលែងចោទប្រកាន់ក៏មានកំហុសឆ្គងផងដែរ ដោយមិនបានពិចារណាទៅលើ ព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មជាច្រើន ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ០៣ និងមិនបានពិចារណាអំពីកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ[632]។ ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់ បានធ្វើការពិចារណាទៅលើចំណុចទាំងអស់នេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ពិតជានឹងសម្រេចថា មាស មុត ត្រូវទទួលខុសត្រូវចំពោះ *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ* ចំពោះជនរងគ្រោះជាច្រើន (ទាំងជនស៊ីវិលនិងកងទ័ព ដែលមានចំនួនដល់រាប់រយនាក់) នៅតំបន់កំពង់សោម[633]។ នៅ*មន្ទីរសន្តិសុខទឹកសាប* មានមនុស្សប្រមាណជាងមួយពាន់នាក់ រួមទាំងទារក និងកុមារ ដែលត្រូវបានឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌។ មនុស្សមួយចំនួនត្រូវបានធ្វើទារុណកម្ម ហើយយ៉ាងហោចណាស់មនុស្សប្រមាណមួយពាន់នាក់ ត្រូវបានសម្លាប់។ ក្រុមជនរងគ្រោះរួមមាន យុទ្ធជនកងពលធំ១៦៤ ដែលត្រូវបានបោសសម្អាត[634] អតីតអ្នករដ្ឋការ និងទាហាន លន់ នល់ ប្រជាជនស៊ីវិល និងជនជាតិវៀតណាម ថៃ និងជនជាតិបរទេសដទៃផ្សេងទៀត ដែលត្រូវបានចាប់ខ្លួននៅលើផ្ទៃសមុទ្រ[635]។ នៅ*ទីតាំងសម្លាប់មនុស្ស និងការដ្ឋានរាម* កម្មកររាប់ពាន់នាក់[636] រួមមានទាំងកុមារ និងមនុស្សចាស់ ត្រូវបានដាក់ឲ្យទៅជាទាសករ ក្នុងស្ថានភាពអមនុស្ស

---

[631] *សូមមើល* **កំហុសឆ្គងអង្គច្បាប់ ដោយការមិនបានពិចារណា និងការមិនបានចេញសេចក្តីសម្រេច លើអង្គហេតុទាំងអស់ ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង ០០៣។**

[632] ទាំងអស់នេះគឺ (១) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ការរំលោភផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពាពាហ៍ដោយបង្ខំ) (២) មន្ទីរសន្តិសុខទឹកសាប (៣) ការដ្ឋានរាម (រួមទាំងបិតត្រាំង កងកេង និងចំការធូរេន) (៤) ការបោសសម្អាតកងពលធំ ១១៧ (រួមទាំងកម្មាភិបាលតំបន់ ៥០៥) កងពលធំ ៥០២ និងកងពលធំ ៣១០។

[633] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៧១ - ៧២។

[634] ការកំណត់ថាតើជនរងគ្រោះស្ថិតក្នុងប្រភេទនៃបុគ្គល ដែលខ្មែរក្រហមកំណត់គោលដៅដែរឬអត់នោះ គឺមានភាពពាក់ព័ន្ធសម្រាប់ការកំណត់ប្រភេទនៃបទល្មើស ដូចជាការធ្វើទុក្ខបុកម្នេញ (ផ្អែកលើមូលហេតុនយោបាយ សាសនា ឬពូជសាសន៍) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពាន់ធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

[635] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៧៣-៧៥។

[636] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៧៦-៧៨។ មាស មុត ខ្លួនគាត់ផ្ទាល់បានរាយការណ៍ថា កម្លាំងផលិតស្រូវរបស់គាត់នៅកំពង់សោម មានចំនួន ១៧,០០០៖ ឯកសារ **D1.3.27.18** កំណត់ហេតុកិច្ចប្រជុំ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ERN(ភាសាខ្មែរ) 00019121។ ដូចដែលបានកត់សម្គាល់ខាងលើ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានសន្មតថា បុគ្គលទាំងអស់នេះសុទ្ធតែមានមូលដ្ឋាននៅតំបន់រាមក្តី តែគាត់បានកត់សម្គាល់ថា តំបន់នេះគឺជាតំបន់ផលិតស្រូវយ៉ាងសំខាន់

ធម៌។ យ៉ាងហោចណាស់មានមនុស្សរាប់រយនាក់ បានបាត់ខ្លួនពីការដ្ឋាន ដែលប្រហែលជាត្រូវបានសម្លាប់ នៅតាមទីតាំងសម្លាប់មនុស្សក្នុងស្រុក ដូចជា នៅទីតាំងសម្លាប់មនុស្សទឹកសាប ចំការធូរេន និងសេអ៊ី។ ជនរងគ្រោះរួមមានកងទ័ពកងពលធំ ១៦៤ ដែលត្រូវបានរំសាយ និងក្រុមគ្រួសាររបស់ពួកគេ ជនជាតិថៃ និងជនជាតិវៀតណាម ដែលត្រូវបានចាប់ខ្លួននៅលើផ្ទៃសមុទ្រ និងប្រជាជនស៊ីវិលក្នុងតំបន់ ដូចជាប្រជាជន១៧មេសា និងខ្មែរក្រោម[637]។ ក្នុងអំឡុងពេល _បោសសម្អាតកងពលធំ ១១៧ ៥០២ និង ៣១០_ ក្រៅពីអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១[638] មានកងទ័ពជាង១៥០នាក់ ត្រូវបានសម្លាប់នៅនឹងកន្លែង[639]។

159. _ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ:_ បន្ថែមលើមនុស្ស "មួយចំនួនទៀត" ដែលដីកាសម្រេចនេះសន្និដ្ឋានថា ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១[640] ដីកាសម្រេចលើកលែងចោទប្រកាន់ក៏កំណត់ពី "ចំនួនជងរងគ្រោះ" ដោយសារឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ដោយសំអាងតែទៅលើរបាយការណ៍ចំនួនពីរច្បាប់ដែល មាស មុត រាយការណ៍ទៅ សុន សេន។ ឯកសារទាំងនេះរាយការណ៍ពីការបាញ់ពន្លិច និងការចាប់ទូកវៀតណាម ការចាប់ និងការសម្លាប់ជនជាតិវៀតណាមចំនួន ១២០ (មួយរយម្ភៃ) នាក់ និងការចាប់ទូកថៃ ១ (មួយ) គ្រឿង[641]។ នៅកន្លែងផ្សេងទៀតត្រង់ផ្នែកនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏ពិនិត្យមើលភ័ស្តុតាងនៃការរឹបអូស (i) ទូកថៃចំនួន ២ (ពីរ) គ្រឿងទៀត និងការសម្លាប់មនុស្សនៅលើទូក[642] (ii) ទូកឈ្មោះ "ស្ត្រីកញ្ចោង" ដែលដឹកពួកបស្ចិមប្រទេសចំនួន

---

នៅក្នុងតំបន់កំពង់សោម ហើយថាចំនួននេះជាកត្តាចង្អុលបង្ហាញ អំពីទំហំដ៏ធំធេងនៃចំនួនមនុស្ស ដែលត្រូវបានដាក់ឱ្យទៅជាទាសករនៅក្នុងតំបន់នេះ។ សូមមើលបន្ថែម ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៨០, ៣៩១, ៤៦៨។

[637] សូមមើលផ្នែកខាងលើ, កថាខណ្ឌ ៧៦ - ៧៨។

[638] *សូមមើលផ្នែកខាងក្រោម* កថាខណ្ឌ ១៧០។

[639] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៧៩-៨០។

[640] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៦។

[641] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១៣-៤ *ដែលយោងទៅ*ឯកសារ **D1.3.34.64** ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅ សុន សេន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ EN ERN 00233649។ ឯកសារ **D1.3.30.25** ទូរស័ព្ទសម្ងាត់ពី មាស មុត ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ EN ERN 00143507។

[642] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៨ *ដែលយោងទៅ*ឯកសារ **D1.3.34.28** ទូរលេខពី ស៊ីម ជួន មាស មុត ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧។

៣ (បី) នាក់ នៅក្នុងខែសីហា ឆ្នាំ១៩៧៨[643] (ប៉ុន្តែ ពុំបានកត់ត្រាពីការស្លាប់ជនបរទេសម្នាក់ នៅលើទូក នៅក្នុងដែនសមុទ្រ និងអ្នកដែលបានចាប់ខ្លួនពីរនាក់ទៀត ដែលក្រោយមក ត្រូវបាន សម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ដែលមានឈ្មោះនៅក្នុងឯកសារដដែលនេះទេ)[644] និង (iii) ជន ជាតិអាមេរិកកាំងម្នាក់ទៀតដែលមិនស្គាល់អត្តសញ្ញាណ នៅក្នុងខែមេសា ឆ្នាំ១៩៧៨ នៅជិត កោះកុង[645]។ ឯកសារនេះក៏យោងទៅរបាយការណ៍មួយស្តីពីការរឹបអូសទូកនេសាទថៃមួយគ្រឿង [646] និងបញ្ជីឈ្មោះជនជាតិវៀតណាមចំនួន ១២ នាក់ ដែលបញ្ជូនពីកំពង់សោមមកមន្ទីរសន្តិសុខ ស-២១ ដែលបញ្ជាក់ថា ក្នុងចំណោមនោះ ១០ នាក់ "អាចបញ្ជូនពីកងពលលេខ ១"[647]។

---

[643] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣១២ *ដែលយោងទៅ*ឯកសារ **D11/2** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill។

[644] ឯកសារ **D11/2** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill, EN ERN 00681116 [ដែលបញ្ជាក់ លម្អិតថា លោក Stuart Glass ត្រូវគ្រាប់កាំភ្លើង ហើយបានស្លាប់នៅជិតកោះតាង លោក Kerry G. Hamill ដែលជាបើកបរទូក និងសហកម្មសិទ្ធិករម្នាក់ទៀត ព្រមទាំងលោក John Dewhirst ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនមកដល់កមន្ទីរសន្តិសុខ ស-២១]។ *សូមមើលផងដែរ* ឯកសារ **D11/2.3** ចម្លើយសារភាពរបស់ John D. Dewhirst ពីស-២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៨ EN ERN 00681102។ ឯកសារ **D1.3.33.3** កំណត់ហេតុនៃការសួរចម្លើយ ឌុច EN ERN 00147526-27។ ឯកសារ **D1.3.33.4** កំណត់ហេតុនៃការសួរចម្លើយ ឌុច EN ERN 00198221។ ឯកសារ **D4.1.378** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ EN ERN 00163633-34។

[645] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៩ *ដែលយោងទៅ*ឯកសារ **D22.1.14** *ការចាប់ខ្លួនបុគ្គលិកជនជាតិអាមេរិកកាំងម្នាក់ដែលជាភ្នាក់ងារស៊ើបការណ៍របស់ ស.រ.អា* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨ (ដីកាសម្រេចលើកលែងចោទប្រកាន់បានប្រើប្រាស់ឯកសារនេះ ទោះបីជាវាជាឯកសារដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ មកហើយក្តី)។

[646] ឯកសារ **D266**ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២១ *ដែលយោងទៅ*ឯកសារ **D1.3.34.10** ទូរលេខពី មាស មុត ជំរាបបង សុន សេន ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦ ។

[647] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០៧ *ដែលយោងទៅ*ឯកសារ **D1.3.28.5** បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ FR ERN 00864736-7, KH ERN 00040774-5 [មិនមាន EN ERN ទេ] [រាយឈ្មោះចារកិច្ច "យួន" ១០ នាក់មកពីកំពង់សោម និង "យួន" ពីរនាក់ ដែលទទួលមកពីកងពលលេខ ១៦៤ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៨]។ បញ្ជីឈ្មោះនេះពុំបានបញ្ជាក់ថា យួន ១០ នាក់នេះមកពីកងពលលេខ ១ នៅក្នុងភូមិភាគបស្ចិមទេ។ បើទោះបីជាយ៉ាងនេះក្តី វាគ្រាន់តែបញ្ជាក់ពីអំណាចផ្ទាក់លើរបស់ មាស មុត និងកងពលលេខ ១៦៤ ទៅលើកងពលលេខ ១ ឱ្យតែមានការពាក់ព័ន្ធនឹងការចាប់ខ្លួននៅតាមដែនសមុទ្រ ដោយសារតែអ្នកដែលគេចាប់ខ្លួន ត្រូវបានផ្ទាក់ដឹកនាំកងពលលេខ ១ ប្រគល់ខ្លួនទៅឱ្យកងពលលេខ ១៦៤ នៅកំពង់សោម ដូចដែលសាក្សី មាស រឿន បានបញ្ជាក់អះអាង (*សូមមើល ឧ.* ឯកសារ **D98/3.1.178** ប្រតិចារឹកសវនាការ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ម៉ោង ១០.២០.២៩ ដល់ម៉ោង ១០.២៦.០២)។

160. ប៉ុន្តែ ការវាយតម្លៃរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ចំនួនជនបរទេស ដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួន ដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ចោលនៅក្នុងសមុទ្រ និងនៅតាមកោះនានាក្នុងតំបន់កំពង់សោម និងនៅមន្ទីរសន្តិសុខស-២១។

161. ភស្តុតាងយ៉ាងច្រើន ដែលដីកាសម្រេចលើកលែងចោទប្រកាន់ខកខានពុំបានពិចារណានោះគឺ សំណុំរឿងនៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ឧទាហរណ៍ ដីកាសម្រេចលើកលែងចោទប្រកាន់មិនគិតពីប្រភពមួយចំនួនមកពីមន្ទីរសន្តិសុខស-២១ ដែលបញ្ជាក់ថា យ៉ាងហោចណាស់ក៏មានជនស៊ីវិល និងទាហានវៀតណាមចំនួន ៨៥ នាក់ រួមទាំងកូនក្មេងផង ត្រូវបានគេបញ្ជូនមកពីកំពង់សោម តែងតែត្រូវបានគេធ្វើទារុណកម្ម ហើយបន្ទាប់មកត្រូវបានគេសម្លាប់ចោលនៅមន្ទីរសន្តិសុខស-២១[648]។ ឯកសារដដែលនេះ (បញ្ជីឈ្មោះនៅមន្ទីរសន្តិសុខស-២១ របស់ ក.ស.ព) ក៏បាន

---

[648] នេះមិនទាន់គិតពីចំនួនទារក/កុមារជាច្រើនផង ដោយសារថា ពួកគេមិនត្រូវបាន សួស ធី កត់ត្រានៅមកមន្ទីរសន្តិសុខស-២១ នោះទេ។ ឯកសារ **D4.1.950** បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលបានកែប្រែដោយ ក.ស.ព ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០០៩ [“គិញ”យួន, អ្នកចាប់ត្រី ឬទាហានចំនួន ៨៥ នាក់ដែលត្រូវបានចាប់ខ្លួននៅកំពង់សោមគឺស្ថិតនៅ លេខរៀង ៣១៧, ៥៧០, ៥៧២, ១៤០៩-១១, ១៥០០, ១៥០៣, ១៧៣៦-៣៨, ១៧៨១, ១៧៨៨, ២៥៥៨, ៣១៣៨, ៣២១២, ៣២៤៣, ៣៩០៧, ៤០៣៩, ៤៥៦០, ៤៥៨៤, ៤៥៨៧, ៤៥៨៩, ៤៧៣១, ៤៨០៧, ៤៩៣៩, ៥០៥៦, ៥៨៥៩, ៦១៦៦, ៦១៦៩, ៦១៧៤, ៦១៧៦, ៦១៨៧, ៦១៨៩, ៦១៩៣-៤, ៦២០០, ៦២០៥, ៦២១០, ៦២១២-៣, ៦២២៨, ៦២៣៦, ៦២៣៨, ៦២៤៦, ៦២៤៨, ៦២៥១, ៦២៥៥, ៦២៥៧, ៦២៦១-៥, ៦២៦៧, ៦២៧០, ៦២៨១, ៦២៨៥, ៦២៨៧, ៦៣១៥, ៧៣៨៥, ៧៣៨៨, ៧៣៩៣, ៧៣៩៦, ៧៥៨០, ៧៦៤៣, ៨៥០៤, ១០៣២៦-៧, ១០៦២១, ១០៧២១, ១០៩៦៤, ១០៩៧៨, ១០៩៩០, ១០៩៩៣, ១១០០៨, ១១០១២, ១១៧២៥, ១១៧២៧, ១១៧៤១, ១១៧៤៦, ១១៩០៨-៩, ១២០៦៩]។ ឯកសារ **D1.3.1.13** ចម្លើយសារភាពនៅមន្ទីរសន្តិសុខស-២១ របស់ឈ្មោះ វិញ-មិញចូវ (ឈ្លើយសឹកទាហានជើងទឹកជាតិវៀតណាម) ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D10.1.6** សេចក្តីសារភាពនៅមន្ទីរសន្តិសុខ ស-២១ របស់ចារនារីយួនឈ្មោះ ង្វៀង ធីបាច់វេ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ **D4.1.987** ចម្លើយសារភាពនៅមន្ទីរស-២១ របស់អ្នកទោសវៀតណាម *ប្រមូលផ្តុំក្រោមចំណងជើងថា ភស្តុតាងស្តីពីការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៨ EN ERN 00420557-64, EN ERN 00420577-82។ *សូមមើល ផងដែរ* ក្នុងចំណោមឯកសារទាំងឡាយដែលបានប្រើប្រាស់នៅក្នុង ដីកាសម្រេចលើកលែងចោទប្រកាន់ (ប៉ុន្តែ ពុំបានប្រើបាស់ជាចាំបាច់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាមនោះទេ)៖ ឯកសារ **D1.3.32.9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល EN ERN 00163814 [រៀបរាប់ពីការឃុំឃាំងអ្នកនេសាទជនជាតិវៀតណាមនៅមន្ទីរសន្តិសុខស-២១ ក្នុងឆ្នាំ១៩៧៨]។ ឯកសារ **D1.3.32.21** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ EN ERN 00177587 [បញ្ជាក់ថា អ្នកទោសវៀតណាមត្រូវបានគេសម្លាប់នៅខាងក្រៅបរិវេណមន្ទីរសន្តិសុខ ស-២១]។ ឯកសារ **D4.1.1109** កំណត់ហេតុនៃការសួរចម្លើយ ឌុច EN

កត់ត្រាចំនួនជនជាតិថៃយ៉ាងហោចណាស់ ៤៥ នាក់ ដែលបានបញ្ជូនពីកំពង់សោមទៅមន្ទីរសន្តិសុខស-២១[649]។ ភស្តុតាងបង្ហាញថា ស្ទើរតែទាំងអស់នៃអ្នកទោសវៀតណាម និងថៃចំនួន ៥១ នាក់ដែលបានបញ្ជូនពីកំពង់សោមទៅមន្ទីរសន្តិសុខស-២១ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦[650]។ លើសពីនេះទៀត របាយការណ៍វិភាគមួយច្បាប់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា កត់ត្រាពីចំនួនជនជាតិវៀតណាមយ៉ាងហោចណាស់ ៣៤ នាក់ បញ្ជូនមកពីកំពង់សោម ត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខស-២១ នៅចន្លោះពីថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ ដល់ទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨[651]។ របាយការណ៍ Stony Beach មួយច្បាប់បញ្ជាក់ថា នៅដើមខែមេសា/ឧសភា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំកងពល ១៦៤ បានសម្រេចកម្ទេចជនស៊ីវិលវៀតណាម ១០ នាក់ ដែលចាប់បាន រួមមានស្ត្រី និងកុមារផងដែរ[652]។ ចុងក្រោយបំផុត ដីកាសម្រេចលើកលែងចោទប្រកាន់ពុំមានការពាក់ព័ន្ធឡើយ[653]

---

ERN 00177587 ["[ជនជាតិវៀតណាមដែលត្រូវបានខ្ញុំខ្លួន] មានប្រហែលរាប់រយនាក់ ហើយអ្នកទាំងអស់នោះត្រូវបានសម្លាប់ចោល"]។ ឯកសារ **D4.1.244** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ EN ERN 00161591 [ពន្យល់ថាទាហានវៀតណាមគេទុកកន្លះខែ សួរចម្លើយរួចបានយកទៅសម្លាប់]។ ឯកសារ **D4.1.245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន EN ERN 00161556 ["អានោះសួរតែម៉ាថ្ងៃពីរថ្ងៃអីបាត់ហើយ ចប់ហើយ"]។

[649] ឯកសារ **D4.1.950** បញ្ជីឈ្មោះអ្នកទោសបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលបានកែប្រែដោយ ក.ស.ព ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ [ស្ថិតនៅលេខរៀង ២, ៣, ៥, ២៦០, ២៩៤, ៣៤៦ (៣៤៧), ៣៤៨ (៦០៦), ៥៣៩, ៩១១, ១២៣១, ១៧៨០ (១៧៨១), ៣០១៣, ៣៣៩៩, ៣៤០០, ៣៥៤៧, ៤០៣៩ (៤០៩០), ៤៤២៨, ៤៤៥៩, ៤៥០៥, ៤៥០៧, ៤៦៣៣, ៤៩៤២, ៤៩៦៩, ៥៣១១ (៥៣០៦), ៥៨៥៨, ៥៨៦១, ៥៨៧៩, ៧១៩៩, ៧៥០៧, ៧៩៦៩, ៨២១៣, ៨៤១៥ (៨៤១៦), ៨៥០៣ (៨៥៨៦), ៨៥១១, ៨៥៦៨ (៨៥៦៧), ៨៨៨៨, ៩៧៧០, ៩៧៨៦, ៩៨៣៧, ៩៩៦៩, ១០៥៥០, ១០៦៥៥, ១១៧២០ (១១៧២១), ១២២៧៣ (១២២៧១)]។

[650] ឯកសារ **D1.3.3.2** បញ្ជីឈ្មោះអ្នកទោសសម្លាប់នៅមន្ទីរសន្តិសុខស-២១ EN ERN 00874373-75 [ពីលេខរៀងទី ១ ដល់ទី ៣១ គឺជាអ្នកនេសាទថៃទាំងអស់ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់ចោលនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦], EN ERN 00874556-60 [លេខរៀងទី ២៣៤-២៨៤ គឺជាជនជាតិវៀតណាមចំនួន ១៧ នាក់ និងជនជាតិថៃចំនួន ៣៤ នាក់ ដែលបានបញ្ជូនមកពីកំពង់សោម នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់ចោលនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦]។

[651] ឯកសារ **D4.1.5** របាយការណ៍វិភាគដោយមជ្ឈមណ្ឌលឯកសារកម្ពុជា *បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១* [រាយឈ្មោះជនជាតិវៀតណាម ១១៣ នាក់ ភាគច្រើនជា "គិញ" រួមទាំងគិញយ៉ាងហោចណាស់ ៣៤ នាក់ បញ្ជូនមកពីកំពង់សោម ត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខស-២១ នៅចន្លោះពីថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ ដល់ទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨]។

[652] ឯកសារ **D4.1.754** កងទ័ពកងពល ១៦៤ ដែលមិនស្គាល់ឈ្មោះ, ចម្លើយរបស់ឈ្លើយសឹកអាមេរិក// MIA, EN ERN 00387429។

ដោយពុំផ្តល់ការពន្យល់ណាមួយចំពោះភ័ស្តុតាងរបស់ អ៊ិន សារឿន អំពីចំណាប់ខ្មាំងជនជាតិថៃ ដែលត្រូវបានសម្លាប់នៅចម្ការធូរេនទី ១ នោះទេ[654]។

162. ដីកាសម្រេចលើកលែងចោទប្រកាន់ក៏មិនគិតពីភ័ស្តុតាងរបស់ពួកបស្ចិមប្រទេសដែលចាប់បាននៅក្នុងដែនសមុទ្រ ហើយដែលបានបញ្ជូនមកកាន់មន្ទីរសន្តិសុខស-២១[655]។ ប្រភពឯកសារនានាមកពីមន្ទីរសន្តិសុខស-២១ នៅក្នុងសំណុំរឿង មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ បង្ហាញថា បុរសបីនាក់[656] ត្រូវបានឃុំខ្លួន ហើយទំនងជាត្រូវបានគេធ្វើទារុណកម្មនៅទីនោះ។

163. ទោះជាយ៉ាងណាក៏ដោយ សំខាន់បំផុតបណ្តាលមកពីការពុំព្រមពិចារណាទៅលើភ័ស្តុតាងដែលមានបន្ទាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលដីកាសម្រេចលើកលែងចោទប្រកាន់ស្មានខុសទៅលើកម្រិតនៃយុទ្ធនាការរបស់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ។ សរុបមក ភ័ស្តុតាងនៅក្នុងសំណុំរឿងនេះបង្ហាញថា មនុស្សរាប់ពាន់នាក់[657] (មានជនជាតិថៃ ជនជាតិវៀតណាម ជនជាតិអាស៊ី និងជនជាតិលោកខាងលិចជាច្រើននាក់ទៀត រួមទាំងស្ត្រី កុមារ និងមនុស្ស[658]) ត្រូវបាន

---

[653] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រយោងលេខ ៥។

[654] ឯកសារ **D2/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ឆ១៧, ១០, ១១, ៤៣។

[655] *សូមមើល ជាទូទៅ* ឯកសារ **D1.3.33.3** កំណត់ហេតុនៃការសួរចម្លើយ ឌុច EN ERN 00147526-27។ ឯកសារ **D1.3.33.4** កំណត់ហេតុនៃការសួរចម្លើយ ឌុច EN ERN 00198221។ ឯកសារ **D4.1.742** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន EN ERN 00401827។

[656] ឯកសារ **D1.3.28.140** បញ្ជីឈ្មោះអ្នកទោសស-២១ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ EN ERN 01236389 [បញ្ជាក់នៅលេខរៀងទី ១ ថាជា Christopher E. Delance និងលេខរៀងទី ២ ថាជា Michael S. Deeds។ ឈ្មោះអ្នកទោសចូលថ្ងៃ ២៦-១១-៧៨]។ ឯកសារ **D11/4.2.4** ចំចម្លើយរបស់លោក Michael S. Deeds នៅមន្ទីរស-២១។ ឯកសារ **D11/4.2.1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Timothy S. Deeds, EN ERN 00741656។ ឯកសារ **D4.1.245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន EN ERN 00161555-56 [បានឃើញ ឌុច សួរចម្លើយដោយផ្ទាល់ និងបានទាត់អ្នកទោសឈ្មោះ David Scott]។

[657] នៅក្នុងដីកាដំណោះស្រាយលើសំណុំរឿង ០០៣ ស.ច.ស.អ បានគណនាតាមវិធីបុរាណក្នុងកម្រិតអប្បរមាថា មានជនរងគ្រោះជាជនជាតិថៃចំនួន ១.២០០ នាក់ និងជនជាតិវៀតណាម ៣.២៧៦ នាក់ (ឯកសារ **D267**, ដីកាដំណោះស្រាយ, កថាខណ្ឌ ២៥៣, ២៥៥-៧, ៤៦៤) ប៉ុន្តែ ខ្លួនគាត់ផ្ទាល់បានលើកឡើងថា "បើតាមតថភាពជាក់ស្តែង ទំនងជាលើសពីនេះឆ្ងាយណាស់" ហើយថា "ចំនួនអ្នកស្លាប់ និងអ្នករបួស ជាពិសេសជនជាតិវៀតណាម គឺអាស្រ័យថាតើជនជាតិថៃ និងជនជាតិវៀតណាមប៉ុន្មាននាក់ ដែលបានចូលមកក្នុងដែនទឹកទាំងនោះ ត្រូវបានចាប់ខ្លួន"។

[658] *សូមមើល ឧ.* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤១, ១៤៣, ១៤៦, ១៤៨-៩, ៤០៣,

គេសម្លាប់ចោលភ្លាមៗនៅក្នុងសមុទ្រ[659] ឬនៅតាមកោះនានា (ពិសេសនៅកោះរ៉ុង កោះតាង និង កោះពូឡូវ៉ៃ[660]) ក្នុងតំបន់កំពង់សោម (នៅរាម អូរឈើទាល ទីបញ្ជាការកងពល ចម្ការធូរេនទីមួយ ឬនៅទឹកសាប (ដែលអ្នកខ្លះត្រូវបានឃុំឃាំង និងបង្ខំឱ្យធ្វើការសិន) និងនៅវត្តឥន្ទញាណ[661]) ឬ បញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដែលពួកគេត្រូវបានឃុំឃាំងខ្លួនក្នុងស្ថានភាពអមនុស្សធម៌ ត្រូវ បានធ្វើទារុណកម្មជាញឹកញាប់ ហើយបន្ទាប់មក ត្រូវបានគេសម្លាប់ចោល[662]។ ដូចបានបញ្ជាក់ លម្អិតនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ សអ.ព. កំណត់ត្រានៅសេសសល់បង្ហាញថា មាស មុត បានបញ្ជូនជនជាតិវៀតណាម ១៨៨ នាក់[663] ជនជាតិថៃ ៥៨ នាក់[664] និងជនជាតិលោកខាងលិច ៨ នាក់[665] ទៅកាន់មន្ទីរសន្តិសុខស-២១។

164. អតីតកម្មាភិបាលខ្មែរក្រហមឈ្មោះ ប៉ាក សុខ និង ឯក នី បានអះអាងរៀងៗខ្លួនថា មនុស្ស "រាប់ពាន់" នាក់ត្រូវបានកងទ័ពជើងទឹកនៃកម្ពុជាមប្រជាធិបតេយ្យសម្លាប់ចោល[666]។ រយៈពេល

---

៤១៣, ៤១៨, ៤២៨។

[659] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៩(ក), ៣៨០, ៣៨៥, ៣៨៧, ៣៨៩, ៣៩៩-៤០០។

[660] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣០៨, ៣៧០, ៣៧៩(ខ), ៣៨០, ៣៨៥, ៣៨៧, ៣៩២, ៣៩៥, ៤០១-៤០៦។

[661] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៧៩(គ), ៣៨០, ៣៨៤, ៣៨៧, ៣៩០, ៣៩២-៣, ៣៩៥, ៣៩៨, ៤១០-១៦, ៤៥៧-៦០, ៥០០-១, ៧១៦-៨។

[662] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៣៨៧, ៣៩០-១, ៤១៧-២០, ៥៤៤-៦, ៥៤៨-៩។ ពាក់ព័ន្ធនឹងស្ថានភាពនៃការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់នៅមន្ទីរសន្តិសុខស-២១ *សូមមើល* ឯកសារ **D256/7** ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥៥៣-៩៣។

[663] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១២៦, ១៤២ (លេខយោងជើងទំព័រ ៤១២), ១៧៣, ៥៥១, ឧបសម្ព័ន្ធ D.5 (ឯកសារ **D256/7.10**)។ ចំពោះតួលេខដែលបានដកស្រង់ថា ១៩៤ នោះគឺរាប់បញ្ចូលទាំងមនុស្ស ៦ (ប្រាំមួយ) នាក់ដែលបញ្ជូនមកពីក្រចេះ។

[664] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៧, ១៧៣, ៤១៩, ៥៥១, ឧបសម្ព័ន្ធ D.6 (ឯកសារ **D256/7.11**)។

[665] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៤៨-៩, ១៧៣, ៥៤៩, ៥៥១, ឧបសម្ព័ន្ធ D.7 (ឯកសារ **D256/7.12**)។

[666] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.១១-៣។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥៨, ៦០-២។ ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៣, ឆ.៧, ឆ.៩។

មួយឆ្នាំឈរជើងនៅលើកោះរង់សន្ទឹម ក្នុងឆ្នាំ១៩៧៦ មូល ឈិន បានឃើញអ្នកនេសាទជនជាតិថៃ ពី ១០ ទៅ ១៥ នាក់ត្រូវបានគេសម្លាប់រៀងរាល់ពីរ ឬបីថ្ងៃម្តង[667]។ អ្វីដែលឃោរឃៅបំផុតគឺរឿងរ៉ាវដែលសាក្សីផ្ទាល់ភ្នែក ប៉ាក សុខ បានឃើញកងទ័ពម្នាក់សម្លាប់ទារកម្នាក់ដែលកំពុងតែស្រែកយំ ដោយបោះទារកនោះចូលទៅក្នុងទឹកសមុទ្រ[668] និងសម្លាប់កូនក្មេងដោយបោកផ្ទប់ទៅនឹងដើមឈើនៅលើកោះតាង[669]។

165. *ការដ្ឋានស្ទឹងហាវ:* ដីកាសម្រេចលើកលែងចោទប្រកាន់សន្និដ្ឋានថា មានកម្មករ ១០០ (មួយរយ) នាក់នៅ "ការដ្ឋានវាយថ្មស្ទឹងហាវ" ជាយុទ្ធជនរបស់កងពលលេខ ១៦៤ និងជនស៊ីវិល រួមទាំងអ្នក "ជាប់និន្នាការមិនល្អ" សមាជិកក្រុមគ្រួសាររបស់កងទ័ព អតីតទាហានរបប លន់ នល់ និងស្ត្រីផងដែរ[670]។ ការសន្និដ្ឋានទាំងនេះប៉ាន់ស្មានទាបយ៉ាងខ្លាំង ថាតើមានកងទ័ព និងជនស៊ីវិលប៉ុន្មាននាក់ ដែលកងពលលេខ ១៨៤ បានដាក់ឲ្យទៅជាទាសករ និងបានឃុំឃាំងខ្លួននៅក្នុងស្ថានភាពគួរឲ្យរន្ធត់ ហើយពេលខ្លះត្រូវបានសម្លាប់ចោលនៅស្ទឹងហាវនោះ។ ទីមួយ ដោយការពិចារណាតែទៅលើកម្មករចំនួន ១០០ (មួយរយ) នាក់នៅឯ "ការដ្ឋានវាយថ្ម" នោះដីកាសម្រេចលើកលែងចោទប្រកាន់មិនអើពើចំពោះកន្លែងធ្វើពលកម្មទាំងអស់ នៅការដ្ឋានស្ទឹងហាវផ្សេងៗទៀត។ ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់តែផ្នែកខ្លះ[671] ការដ្ឋានស្ទឹងហាវទាំងអស់រួមមានកន្លែងធ្វើការខុសៗគ្នាជាច្រើនកន្លែង ការកសាងកំពង់ផែយោធាថ្មី រួមទាំងផ្លូវមួយខ្សែភ្ជាប់ពី

[667] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៦០-៥។

[668] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២២។ ឯកសារ **D114/297.1.21** ប៉ាក សុខ ប្រចារឹក ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ម៉ោង ១៤.៣៦.៣៨-១៤.៣៨.១៦។

[669] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២០។ ឯកសារ **D114/297.1.20,** ប៉ាក សុខ, ប្រតិចារឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង ១១.០៣.០៧-១១.០៦.៥៩។

[670] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣០២។

[671] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៩ "ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងពាក់ព័ន្ធ មានទីតាំងនៅក្នុងឃុំស្ទឹងហាវ [...]។ ទីតាំងការដ្ឋានវាយថ្មនេះ [...] មានរណ្តៅយ៉ាងហោចណាស់ចំនួន ៣ (បី) កន្លែង [...] និងទីតាំងមូលដ្ឋានមួយកន្លែងរបស់ទាហានកងពលលេខ ១៦៤។ កន្លែងវាយថ្មនេះស្ថិតនៅជិតនឹងកំពង់ផែកងទ័ពជើងទឹក ដែលជាផ្នែកមួយនៃគម្រោងសាងសង់កំពង់ផែនានារបស់កម្ពុជាប្រជាធិបតេយ្យ", កថាខណ្ឌ ៣០០ ["កងវរៈសេនាតូចលេខ ៤៥០ នេះទទួលបន្ទុកខាងកសាងផែស្ទឹងហាវចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨"], កថាខណ្ឌ ៣០១ [សំដៅទៅ "សម្ភារៈសំណង់សម្រាប់កសាងកំពង់ផែនៅស្ទឹងហាវ និងសម្រាប់ធ្វើផ្លូវមួយដែលតភ្ជាប់កំពង់ផែស្ទឹងហាវទៅកាន់កន្លែងចម្រាញ់ប្រេងកាត"], កថាខណ្ឌ ៣០២ ["ស្ត្រីក៏ត្រូវបានគេប្រើឲ្យធ្វើផ្លូវនោះដែរ"], កថាខណ្ឌ ៣០៤ ["គម្រោងកសាងផ្លូវស្ទឹងហាវ"]។

កំពង់ផែថ្មីទៅរោងចក្រចម្រាញ់ប្រេងកាត និងគម្រោងបន្ទាប់បន្សំមួយចំនួនទៀត រួមមានការកសាងផ្លូវរទេះភ្លើងថ្មី និងការលើកទំនប់[672]។ មានគុកមួយកន្លែងរបស់កងពលលេខ ១៦៤ នៅទីនោះផងដែរ[673]។

166. ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់បានពិនិត្យភ័ស្តុតាងពាក់ព័ន្ធទាំងអស់នៅក្នុងសំណុំរឿង នោះដីកាសម្រេចលើកលែងចោទប្រកាន់ឈានដល់ការសេចក្តីសន្និដ្ឋានតែមួយគត់ថាមានមនុស្សជាច្រើនរយនាក់ ហើយប្រហែលជាអាចមានដល់ទៅរាប់ពាន់ឯណោះ ត្រូវបានគេដាក់ឱ្យទៅជាទាសករនៅក្នុងស្ថានភាពអមនុស្សធម៌នៅស្ទឹងហាវ[674]។ កម្លាំងពលកម្មសំខាន់ៗរួមមានកងទ័ពដែលគេដកចេញ (ហើយខ្លះជាកងទ័ពសកម្ម) មកពីកងពលលេខ ១៦៤[675] និងជនស៊ីវិលរួមទាំងប្រជាជន ១៧ មេសា ផងដែរ[676]។ តាមពិតទៅ ដីកាសម្រេចលើកលែងចោទប្រកាន់មិនពិចារណាទៅលើភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដែលបង្ហាញថា ស្ត្រី ១៧ មេសា ចំនួនពី ៤០-៥០ នាក់ ធ្វើការនៅការដ្ឋានសាងសង់ផ្លូវនៅស្ទឹងហាវ[677]។ មនុស្សជាច្រើនរយនាក់ទៀតត្រូវបានឃុំឃាំងនៅក្នុងគុកនេះ អ្នកខ្លះត្រូវបានគេធ្វើទារុណកម្ម[678] ហើយមួយចំនួនតូចត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១[679]។ ទោះបីជាមិនអាចផ្តល់ការប៉ាន់

[672] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៩៤-៩៩, ៦០១-២។

[673] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៩៥, ៦៣៦។

[674] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦១៣-៤, សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតស្តីពីស្ថានភាពនានានៅស្ទឹងហាវ *សូមមើល* ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦១៥-៩, ៦២២, ៦២៤-៣១។

[675] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៤២, ៣៥២-៣, ៣៦៤, ៣៦៦, ៦១១, ៦១៣, ៦២១-៣០។

[676] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៣១។

[677] *សូមមើល ឧ.* ឯកសារ **D2/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ឆ.១១ ["ចំពោះមនុស្សដែលធ្វើការ [នៅក្នុងគម្រោងសាងសង់ផ្លូវនេះ] មិនទៀងទេ។ អ្នកដែលគ្មានបច្ចេកទេសមានប្រហែល ៣០ នាក់។ ចំពោះអ្នកបច្ចេកទេស គឺនៅក្នុងគ្រឿងចក្រមួយមានអ្នកបច្ចេកទេសពីរនាក់។ ស៖ នៅក្នុងកិច្ចសម្ភាសន៍លើកមុន លោកនិយាយថា មានមនុស្សស្ត្រី ៤០ ទៅ ៥០ នាក់ដែលចូលរួមក្នុងការសាងសង់ផ្លូវនេះ?], ឆ.១២៖ បាទ, កម្លាំងនោះមិនមែនធ្វើការជាប្រចាំទេ គឺគេមកជួយម្តងម្កាលប៉ុណ្ណោះ"]។ សូមមើលបន្ថែម ឯកសារ **D1.3.13.8** កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ សាក្សី ប៉ែន សារិន EN EGN 00217560 ["មនុស្សស្រីប្រហែលពី ៤០ ទៅ ៥០ នាក់ គឺជាស្ត្រី ១៧ មេសា"]។

[678] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៣៦-៤១។

[679] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៤២។

ប្រមាណពិតប្រាកដអំពីចំនួនអ្នកស្លាប់ និងអ្នកបាត់ខ្លួនក្តី ក៏ភ័ស្តុតាងបង្ហាញថា ការស្លាប់ និងការបាត់ខ្លួនគឺជារឿងធម្មតាទៅហើយ[680] ។

167. *__មន្ទីរសន្តិសុខវត្តឥន្ទញាណៈ__* ដូចបានពិភាក្សារួចមកហើយ ការវិភាគរបស់ដីកាសម្រេចលើកលែងចោទប្រកាន់អំពីឧក្រិដ្ឋកម្មនៅវត្តឥន្ទញាណ ពុំបង្កើតបានជាសេចក្តីសន្និដ្ឋានមួយដែលសមហេតុផលនោះឡើយ[681]។ ទោះជាយ៉ាងណាក្តី ការវិភាគនេះបង្ហាញទៅលើភ័ស្តុតាងមានកម្រិត ទាក់ទងនឹងអត្ថិភាពនៃអ្នកទោសនៅវត្តឥន្ទញាណ រួមទាំងភ័ស្តុតាងនៃការប្រើប្រាស់វត្តឥន្ទញាណ ជាមន្ទីរសន្តិសុខ ឬជាកន្លែងឃុំឃាំងបណ្តោះអាសន្ន[682] ដែលស្តែងឲ្យឃើញពីការឃុំខ្លួនអ្នកទោសនៅក្នុងឆ្នាំ១៩៧៧[683] "ខ្ទោះប្រហែល ១០ (ដប់) និងឈាម ហើយមានជញ្ជាំងមួយសម្រាប់ដាក់ច្រវ៉ាក់ព្យួរកអ្នកទោស [...][684]" និង "មានខ្ទោះប្រហែល ៥០ ទៅ ៦០ [...] ហើយមានបន្ទប់សម្រាប់ដាក់មនុស្សប្រហែល ១០ នាក់ក្នុងមួយជួរ"[685]។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏យោងផងដែរទៅសាកសពចំនួន ២០០ (ពីររយ) ដែលត្រូវបានគាស់ចេញពីក្បែរវត្តនោះនៅដើមទសវត្សរ៍ ១៩៨០[686]។ ប៉ុន្តែ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានពុំបានស្វែងរកណាមួយអំពីការ

---

[680] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៦៣៣-៥, ៦៤៣, ៦៤៧។

[681] *សូមមើល ខាងលើ*, កថាខណ្ឌ ២១-២។

[682] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩២ *យោងទៅ*ឯកសារ **D1.3.13.1**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ប៉ូច កុយ, ទំព័រ ២។ ឯកសារ **D1.3.13.8**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ប៉ែន សារិន, ទំព័រ ៤។ ឯកសារ **D1.3.13.13**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ទូច សឿលី, ទំព័រ ៧-៨។

[683] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩០, ២៩៤ *យោងទៅ*ឯកសារ **D2/15**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ទំព័រ ៧។

[684] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩៤ *យោងទៅ*ឯកសារ **D1.3.13.1**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ប៉ូច កុយ, ទំព័រ ២។ *សូមមើល ផងដែរ* ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩០។

[685] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩៥ *យោងទៅ*ឯកសារ **D1.3.13.1**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ប៉ូច កុយ, ទំព័រ ២។

[686] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩៦ *យោងទៅ*ឯកសារ **D1.3.13.1**, កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ ក.ស.ព ជាមួយ ប៉ូច កុយ, ទំព័រ ២។ ឯកសារ **D2/4**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ, កថាខណ្ឌ ៧-៨។

ប្រើប្រាស់វត្តនោះជាមន្ទីរសន្តិសុខ (និងពីចំនួន ឬប្រភេទអ្នកទោសដែលគេឃុំឃាំងនោះទីនោះ[687] ឬថាតើមានការសម្លាប់ណាមួយបានប្រព្រឹត្តឡើងនោះទីនោះ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ[688]។ នៅក្នុងដំណើរការនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏គិតពីការវាយតម្លៃអំពីចំនួនអ្នកទោសនៅវត្តឥន្ទញ្ញាណ ដែលបានដាក់ទៅក្នុងសំណុំរឿង មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១[689]។

168. ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់ បានពិនិត្យភ័ស្តុតាងពាក់ព័ន្ធទាំងអស់ នោះនឹងមានការសន្និដ្ឋានប្រកបដោយហេតុផលតែមួយគត់ថា មន្ទីរសន្តិសុខនេះមានលទ្ធភាពដាក់អ្នកទោសបានជាង ២០០ (ពីររយ) នាក់ក្នុងមួយលើកៗ[690] ហើយចំនួនអ្នកដែលត្រូវបានឃុំឃាំងក្នុងស្ថានភាពយ៉ាងអមនុស្សធម៌បំផុត[691] នៅវត្តឥន្ទញ្ញាណ គឺលើសឆ្ងាយពីសាកសពចំនួន ៥០០-១០០ សាកសព ដែលបានរកឃើញនៅទីតាំងនេះភ្លាមៗ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ[692]។ អ្នកទោសនៅវត្តឥន្ទញ្ញាណរួមមាន ស្ត្រី និងកុមារ[693] និងមានកងទ័ពរបស់កងពលលេខ ១៦៤

---

[687] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៨៩, ២៩២-៣។

[688] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ២៩៦។

[689] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ, ឆ.២២-៤៖ ["ពេលមកដល់ ខ្ញុំឃើញអគារនេះមានជញ្ជាំងពីខាងក្រៅជុំវិញ ហើយខាងក្នុងអគារគេសង់ជាបន្ទប់បន្ទប់ឃុំឃាំងចំនួន៥។ រួចហើយ ខ្ញុំបានឃើញខ្នោះជើងនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ [...], ឆ.២៣៖ ខ្ញុំបានឃើញមានមួយក្រុមដប់ខ្នោះ [...]។ ស៖ តាមយើងយល់ លោកថាក្នុងមួយក្រុមមានដប់ខ្នោះ នៅក្នុងបន្ទប់នីមួយៗ តើដូច្នេះមែនទេ? ឆ.២៤៖ ខ្ញុំឃើញនៅក្នុងបន្ទប់នីមួយៗមានខ្នោះពីរក្រុម ក្នុងមួយក្រុមមាន១០ខ្នោះ"]។ *សូមមើលផងដែរ* ឯកសារ **D2/22**, របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ, EN ERN 00634142 ["ភ័ស្តុតាងបញ្ជាក់ថា វត្តឥន្ទញ្ញាណមានទីធ្លាទូលំទូលាយ ដែលអាចដាក់អ្នកចាប់ឃុំឃាំងលើសពី ១០០ នាក់ម្តងៗ នៅក្នុងមួយបន្ទប់ ឬកន្លែងនានា ក្នុងអគារទាំងបីដែលនៅមាននៅឡើយ" (ស.ព.អ កត់សម្គាល់ឃើញថា នៅក្នុងដំណាក់កាលនេះ ក.ស.ច.ស មិនបានទទួលភ័ស្តុតាងពី នួន យឹម ដែលបានឃើញសាកសពចំនួន ១០០ នាក់ នៅក្នុងសាលាឆាន់វត្តឥន្ទញ្ញាណនោះទេ)]។

[690] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៦២។

[691] សម្រាប់ព័ត៌មានលម្អិតស្តីពីស្ថានភាពឃុំឃាំងខ្លួននៅវត្តឥន្ទញ្ញាណ *សូមមើល* ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៤៨, ៤៦១-២, ៤៦៥៧-៥។

[692] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៦៤, ៤៧៦-៨០។

[693] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៦១, ៤៧៨។

ដែលគេដកចេញ[694] ប៉ុន្តែ ក៏មានជនស៊ីវិល[695] និងបរទេសដែលគេចាប់បាននៅតាមដែនសមុទ្រផង ដែរ[696] ។

169. *មន្ទីរសន្តិសុខស-២១*៖ ដីកាសម្រេចលើកលែងចោទប្រកាន់ប៉ាន់ប្រមាណខុសយ៉ាងខ្លាំងទៅលើចំនួនអ្នកទោសនៅមន្ទីរសន្តិសុខស-២១ ដែល មាស មុត ជាអ្នកទទួលខុសត្រូវ។ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ថា មានអ្នកទោសចំនួន ៦៧ នាក់មកពីកងពលលេខ ១៦៤ ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខស-២១[697] ក្តី ក៏ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានពុំបានរាប់បញ្ចូលអតីតទាហាន ឬមន្ត្រីរដ្ឋការរបប លន់ នល់ និងសាច់ញាតិរបស់ពួកគេចំនួន ២១ នាក់[698] ជនស៊ីវិលចំនួន ៧៣ នាក់ (និងកម្មករកំពង់ផែកំពង់សោមចំនួន ២៥១ នាក់)[699] ព្រមទាំងបុគ្គលពីរនាក់មកពីកងពលលេខ ១ និងលេខ ២ នៃភូមិភាគបស្ចិម ដែលស្ថិតក្រោមការត្រួតត្រារបស់ មាស មុត ក្នុងឋានៈជាលេខាកងពលលេខ ១៦៤ និងតំបន់ស្វយ័តកំពង់សោម ត្រូវបានបញ្ជូនពីកំពង់សោម យកទៅសម្លាប់នៅមន្ទីរសន្តិសុខស-២១ នោះទេ។ ចុងក្រោយបំផុត ដីកាសម្រេចលើកលែងចោទប្រកាន់ពុំបានទទួលយកភស្តុតាងដែលបញ្ជាក់ថា មនុស្សចំនួន ៣៨ នាក់មកពីខេត្តក្រចេះ ត្រូវបាន មាស មុត ចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរសន្តិសុខស-២១ នៅក្នុងខែធ្នូ

---

[694] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៥០-៥ [*សូមមើល ផងដែរ* កថាខណ្ឌ ៣៤៥-៧, ៣៥១, ៣៦៤, ៣៦៦]។

[695] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៤៥៦។

[696] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៣៩០, ៤៥៧-៦០។

[697] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤២៦៖ ["យើងបានឃើញថា កងពលលេខ ១៦៤ មានកងទ័ពប្រហែល ៤២ (សែសិបពីរ) ទៅ ៦៧ (ហុកសិបប្រាំពីរ) នាក់"] ។ *សូមមើល* ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១១៩, ១៧៣, ៥៥១, ឧបសម្ព័ន្ធ D.1 (ឯកសារ **D256/7.6**)។

[698] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧៣, ៥៤៧, ៥៥១, ឧបសម្ព័ន្ធ D.8 (ឯកសារ **D256/7.13**)។

[699] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧៣, ៥៤៧, ៥៤៩, ៥៥១, ឧបសម្ព័ន្ធ D.9 (ឯកសារ **D256/7.14**), ឧបសម្ព័ន្ធ D.10 (ឯកសារ **D256/7.15**)។ ដីកាសម្រេចលើកលែងចោទប្រកាន់ពុំបាននិយាយពីជនរងគ្រោះទាំងនោះទេ។

ឆ្នាំ១៩៧៨ រួមទាំងជនជាតិវៀតណាមចំនួន ៦ (ប្រាំមួយ) នាក់[700] កម្មាភិបាល ១០ (ដប់) នាក់ មកពីកងពលលេខ ១១៧ និងតំបន់ ៥០៥ ព្រមទាំងជនស៊ីវិលចំនួន ២២ (ម្ភៃពីរ) នាក់នោះទេ[701]។

170. លើសពីនេះទៀត ថ្វីបើមានការសន្និដ្ឋានផ្នែកអង្គហេតុដែលតម្រូវឲ្យមាន ដើម្បីបង្ហាញពីការចូលរួមរបស់ មាស មុត នៅក្នុងសហឧក្រិដ្ឋកម្មរួម ដើម្បីចាប់ខ្លួន ឃុំខ្លួន និងសម្លាប់អ្នកដែលគេចាត់ទុកថាជាខ្មាំងនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជាក្តី[702] ក៏ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានពុំបានពិចារណាពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ ភាគច្រើនមកលើសមាជិកដទៃទៀតប្រហែលចំនួន ៤.៨០០ នាក់ របស់កងពលមជ្ឈិម កងវរៈសេនាធំឯករាជ្យ និងបុគ្គលិកអគ្គសេនាធិការដ្ឋាននៃកងទ័ពបដិវត្តន៍កម្ពុជា រួមទាំងចំនួន ៣៥៧ នាក់មកពីកងពលលេខ ៥០២ ចំនួន ១.១១៧ នាក់មកពីកងពលលេខ ៣១០ និងចំនួន ៣៥ នាក់មកពីកងពលលេខ ៨០១[703]។

## ៥. កំហុសអង្គច្បាប់ដោយការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវជាន់ខ្ពស់តែម្នាក់គត់

171. ដីកាសម្រេចលើកលែងចោទប្រកាន់ គួរត្រូវបានបកស្រាយដើម្បីផ្តល់ជាមូលចំពោះការសម្រេចថា មាស មុត ស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក: ថា *ការប៉ាន់ប្រមាណ* និងចំពោះបញ្ហាអង្គច្បាប់ គឺអំពី "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលអាចអនុវត្តបានចំពោះតែ ឌុច ម្នាក់គត់នោះ។ នៅក្នុងការស្រាវជ្រាវអំពីប្រវត្តិនៃការចរចារបស់ អ.វ.ត.ក ដីកាសម្រេចលើកលែងចោទប្រកាន់សង្កត់ធ្ងន់ធ្ងន់លើ "ពាក្យ 'ជនដែលទទួលខុសត្រូវខ្ពស់បំផុត' ត្រូវបានដាក់បញ្ចូលសម្រាប់

[700] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៥៥០, ៨៦៩។

[701] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១២២, ១៧៣, ៨៦១ (កម្មាភិបាលកងពលលេខ ១១៧ ចំនួន ៦ នាក់ និងកម្មាភិបាលតំបន់ ៥០៥ ចំនួន ៤ នាក់), កថាខណ្ឌ ៨៦៨ (ជនស៊ីវិលចំនួន ២២ នាក់), ឧបសម្ព័ន្ធ D.2 (ឯកសារ **D256/7.7**), ឧបសម្ព័ន្ធ D.4 (ឯកសារ **D256/7.9**)។

[702] *សូមមើល ខាងលើ*, កថាខណ្ឌ ២៨-៣០។ *សូមមើល បន្ថែមទៀត*, ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ៨៨-១២៤, ៥៥២, ១១១១-២៣។

[703] ឯកសារ **D256/7**, ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១៧២, ៥៥២។ ស.ព.អ កត់សម្គាល់ថា ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់បញ្ជាក់អះអាងថា អ្នកមកពីកងពលលេខ ៨០១ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ក្តី ក៏គាត់ពុំបានរកឃើញ ការជាប់ទាក់ទងតាមផ្លូវច្បាប់ និងភាពជាក់ស្តែងរវាងកងពលលេខ ៨០១ និង មាស មុត នោះដែរ (ឯកសារ **D266**,ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៤១-៣៥១)។

ករណីពិសេសលើ [...] កាំង ហ្គេកអ៊ាវ *ហៅ* ឌុច [...] នេះមានន័យថា ប្រសិនបើអតីតប្រធានមន្ទីរសន្តិសុខស-២១ មិនត្រូវបានរកឃើញទេ ច្បាស់ណាស់ថា កម្រងពាក្យនេះនឹងមិនមានវត្តមាននៅក្នុងច្បាប់របស់ អ.វ.ត.ក ឡើយ”[704]។ ដីកាសម្រេចលើកលែងចោទប្រកាន់អះអាងថា “ភាគីទាំងពីរ [មានន័យថា ភាគីដែលចរចាគ្នា] ហាក់មានជំហរស្រដៀងគ្នាអំពីបុគ្គលដែលនឹងស្ថិតក្រោមយុត្តាធិការបុគ្គលនៃ អ.វ.ត.ក គឺជាមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលជាកម្មាភិបាលម្នាក់និងជាជនទទួលខុសត្រូវខ្ពស់បំផុត”[705] ហើយបន្តសន្និដ្ឋានថា “ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ*នឹងមិនរាលដាលដល់កម្មាភិបាលថ្នាក់ក្រោមឡើយ ក្រៅពី ឌុច* ដែលមានឈ្មោះក្នុងគំនិតនៃអ្នកធ្វើច្បាប់រួចទៅហើយ”[706]។

172. ការអះអាងទាំងឡាយរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ថា ឌុច គឺជាបុគ្គលតែម្នាក់គត់ដែលស្ថិតនៅក្នុងប្រភេទជនដែល “ទទួលខុសត្រូវខ្ពស់បំផុត”[707] ចំពោះឧក្រិដ្ឋកម្មទាំងឡាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយ “ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ នឹងមិនរាលដាលដល់កម្មាភិបាលថ្នាក់ក្រោមឡើយ ក្រៅពី ឌុច” នោះ ពុំបានយោងទៅភ័ស្តុតាងដែលបញ្ជាក់ថា នេះគឺជាចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង ឬរដ្ឋសភាកម្ពុជា នៅពេលខ្លួនសម្រេចអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ។ ការអះអាងណាមួយបែបនេះ គឺពុំត្រឹមត្រូវឡើយសម្រាប់មូលហេតុយ៉ាងហោចណាស់ចំនួនបី: (១) ការអះអាងទាំងនេះ គឺពុំស្របគ្នានឹងភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (២) ការអះអាងបែបនេះ គឺពុំស្របគ្នាទៅនឹងការយល់ឃើញជាក់លាក់របស់រាជរដ្ឋាភិបាលកម្ពុជាផង និងរបស់អង្គការសហប្រជាជាតិផង អំពីយុត្តាធិការបុគ្គល នៅពេលដែល អ.វ.ត.ក ត្រូវបានបង្កើតឡើង និង (៣) ការអះអាងទាំងនេះផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍ដោយផ្ទាល់របស់ ស.ច.ស.ជ ថា ពុំមានហេតុផលអ្វីដែលត្រូវលើកឡើងថា យុត្តាធិការបុគ្គលមានគោលបំណងដើម្បីកំណត់ពីចំនួនបុគ្គលដែលមានឈ្មោះជាក់លាក់មួយនោះទេ។ កត្តានីមួយៗក្នុងចំណោមកត្តាទាំងនេះ នឹងត្រូវបានលើកយកមកបកស្រាយតាមលំដាប់លំដោយ។

---

[704] ឯកសារ **D266**,ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៩៦ (សេចក្តីបញ្ជាក់បន្ថែមត្រូវបានលុបចោល)។

[705] ឯកសារ **D266**,ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៩៦។

[706] ឯកសារ **D266**,ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៤០១។

[707] ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលយកយុត្តិសាស្ត្ររបស់ អ.ជ.ស.ដ ដែលកំណត់ថា មេដឹកនាំជាន់ខ្ពស់ក៏ត្រូវតែ “ទទួលខុសត្រូវខ្ពស់បំផុត” ដែរ។ *សូមមើល* ឯកសារ **D266**,ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៦៥។

## ១. ការលើកឡើងថា ឌុច ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ផ្ទុយទៅនឹងភាសាដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

173. យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានបង្កើតឡើងស្របតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ("កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក") ដែលត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាតាមរយៈច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")[708]។ ទាំងកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា យុត្តាធិការត្រូវបានកម្រិតចំពោះមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ("ក.ប") និង *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់[709]។

174. ហេតុដូច្នេះ ការលើកឡើងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ថា មានតែ ឌុច ម្នាក់គត់ដែលត្រូវបានគិតជាមុនឱ្យស្ថិតនៅក្នុងប្រភេទនៃ "*ជនទាំងឡាយ*ដែលទទួលខុសត្រូវខ្ពស់បំផុត"[710] នោះ គឺផ្ទុយនឹងភាសាដ៏ច្បាស់លាស់នៃនៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលត្រូវបានសរសេរក្នុងទម្រង់ពហុវចនៈ និងយោងយ៉ាងច្បាស់លាស់ទៅជំពូកមនុស្សមួយប្រភេទ ជាជាងសំដៅទៅបុគ្គលម្នាក់ទៅវិញនោះ[711]។ ភាសាដូចគ្នានេះក៏លេចឡើងនៅក្នុង

[708] ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៣-១៤។ កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[709] កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក, មាត្រា ១ (មានបញ្ជាក់បន្ថែម)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១, មាត្រា ២*ថ្មី* (មានបញ្ជាក់បន្ថែម)។

[710] ពហុភាសានេះមានទាំងបីភាសា (អង់គ្លេស បារាំង និងខ្មែរ) នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ អត្ថបទជាភាសាបារាំងសំដៅទៅ "les principaux responsables" ហើយអត្ថបទជាភាសាខ្មែរបញ្ជាក់ច្បាស់លាស់ចំពោះ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។

[711] កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក, បុព្វកថា ["ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តី [...] ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"], មាត្រា ១, មាត្រា ២(១), មាត្រា ៥(៣), មាត្រា ៦(៣)។ ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ឃ្លាញញត្តិនេះជាច្រើនលើកច្រើនសារ នៅក្នុងឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៣, ៣៦១, ៣៦២, ៣៦៣, ៣៦៤, ៣៧៣, ៣៩៦, ៣៩៧, ៤០៥។

ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផងដែរ[712]។ អត្ថបទនៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក ត្រូវបានចាត់ទុកថាជាការបញ្ជាក់ពិតប្រាកដអំពីចេតនារបស់ភាគីទាំងពីរនៃកិច្ចព្រមព្រៀងនេះ គឺរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប[713]។ ប្រសិនបើភាគីទាំងពីរបានឈានដល់ការសន្និដ្ឋានថា ឌុច គឺជាបេក្ខជនតែម្នាក់គត់សម្រាប់ជនទាំងឡាយ ដែលអាចជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់គោលបំណងទាំងឡាយនៃការវិនិច្ឆ័យទោសនៅ អ.វ.ត.ក ម្ល៉េះ ភាគីទាំងនេះអាចបានចែងយ៉ាងច្បាស់លាស់សម្រាប់បញ្ហានេះនៅក្នុងកិច្ចព្រមព្រៀងរបស់ខ្លួន ដែលបន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួចស្រេចទៅហើយ។ អត្ថបទនៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក បញ្ជាក់ច្បាស់ថា ភាគីទាំងពីរពុំមានបំណងដូច្នេះទេ។

---

[712] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១, មាត្រា ២ថ្មី។ *សូមមើល ផងដែរ* ឯកសារ **D266**, ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ៣៦២-៣៦៣។

[713] អនុញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា, ទីក្រុងវីយែន, ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ (“អនុញ្ញាទីក្រុងវីយែន”) , មាត្រា ៣១(១) ចែងថា៖ [“សន្ធិសញ្ញាត្រូវតែបកស្រាយដោយសុទ្ធចិត្តឲ្យស្របជាមួយនឹងអត្ថន័យធម្មតាដែលបានផ្តល់ចំពោះពាក្យពេចន៍នៃសន្ធិសញ្ញានេះ នៅក្នុងបរិបទនៃពាក្យពេចន៍ទាំងនេះ និងឲ្យស្របទៅនឹងកម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញានេះ”]។ ភាគីទាំងអស់យល់ស្របគ្នាយ៉ាងច្បាស់លាស់ថា អនុញ្ញាទីក្រុងវីយែនអនុវត្តចំពោះកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក។ *សូមមើល* កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា ២(២)។ *សូមមើល ផងដែរ* ជម្លោះដែនដី (*ប្រទេស Libyan Arab Jamahiriya v ទល់នឹង ប្រទេស ឆាត*), សាលក្រម ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៤ របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៩៤ ទំព័រ ៦ កថាខណ្ឌ ៤១ [“ការបកស្រាយត្រូវតែសំអាងឲ្យលើសពីអ្វីៗទាំងអស់ ដោយយោងទៅលើបរិបទនៃសន្ធិសញ្ញានេះ”]។ នីត្យានុកូលភាពនៃការប្រើប្រាស់កម្លាំង (*ប្រទេសស៊ែប៊ី និងម៉ុងតេណេក្រូ ទល់នឹង ប្រទេសបែលហ្ស៊ិក*), អញ្ញត្រកម្ម, សាលក្រម ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤, របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ២០០៤ ទំព័រ ២៩៧ កថាខណ្ឌ ១០០។ ការបកស្រាយអំពីសន្ធិសញ្ញាស្តីពីសន្តិភាព (ដំណាក់កាលទីពីរ), ការផ្តល់មតិយោបល់, ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ១៩៥០, របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ១៩៥០ ទំព័រ ២២៩ [“វាជាកាតព្វកិច្ចរបស់តុលាការនេះដែលត្រូវបកស្រាយសន្ធិសញ្ញានានា មិនមែនកែប្រែសន្ធិសញ្ញាទាំងនេះទេ”]។ សេចក្តីព្រាងដោយគណៈកម្មាធិការច្បាប់អន្តរជាតិ ទៅលើមាត្រាមួយចំនួនអំពីច្បាប់ស្តីពីសន្ធិសញ្ញា រួមទាំងសេចក្តីអត្ថាធិប្បាយ, សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ, ឆ្នាំ១៩៦៦, វ៉ុលលេខ II, ទំព័រ ២២០, កថាខណ្ឌ ១១ [“មាត្រា ២៧ [...]មាត្រា ២៧ (បច្ចុប្បន្នមាត្រា ៣១)] ដូចដែលបានបញ្ជាក់រួចមកហើយនោះ ត្រូវបានសំអាងទៅលើទស្សនៈដែលថា អត្ថបទនេះត្រូវតែចាត់ទុកថាជាការបញ្ជាក់ច្បាស់លាស់អំពីចេតនាទាំងឡាយរបស់ភាគីទាំងអស់ ហើយជាលទ្ធផល ចំណុចចាប់ផ្តើមនៃការបកស្រាយ គឺការពន្យល់អត្ថាធិប្បាយអំពីអត្ថន័យនៃបរិបទនេះ មិនមែន*ចាប់ផ្តើម*ការស៊ើបអង្កេតទៅលើចេតនាទាំងឡាយរបស់ភាគីនោះទេ។ វិទ្យាស្ថានច្បាប់អន្តរជាតិបានសម្រេចយកតាមនេះ គឺវិធីសាស្ត្រដែលយោងទៅតាមបរិបទ ចំពោះការបកស្រាយសន្ធិសញ្ញា”

## ២. ការសម្រេចថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ មិនស៊ីសង្វាក់គ្នាជាមួយ ការយល់ដឹងជាក់លាក់អំពីយុត្តាធិការបុគ្គលរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប នៅពេលបង្កើត អ.វ.ត.ក

*<u>រាជរដ្ឋាភិបាលកម្ពុជា</u>*

175. ដីកាលើកលែងការចោទប្រកាន់អះអាងថា ការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជា នៅមុនពេលចាប់ផ្តើមកិច្ចព្រមព្រៀង អ.វ.ត.ក គួរមានអានុភាពលើការយល់ឃើញរបស់ អ.ស.ប។ ដីកាលើកលែងការចោទប្រកាន់នេះសំដៅលើ "ចេតនារបស់ភាគីជាតិជាអ្នកតាក់តែងច្បាប់"[714] ដែលកំណត់អត្តសញ្ញាណ ឌុច ជាកម្មាភិបាលថ្នាក់ទាបតែមួយគត់ ដែលអាចជាកម្មវត្ថុនៃយុត្តាធិការរបស់ អ.វ.ត.ក[715] និងសន្និដ្ឋានថា កត្តាសំខាន់មួយនៅក្នុងការបកស្រាយបទប្បញ្ញត្តិនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺ "ជំហររបស់ភាគី ជាពិសេស ភាគីជាតិតាំងពីមុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្តោតលើការផ្សះផ្សាជាតិ និងការស្វែងរកយុត្តិធម៌"[716]។

176. ទឡ្ហីករណ៍នេះមានកំហុសដោយសារហេតុផលចំនួនពីរ។ ហេតុផលទី១ យោងតាមអង្គច្បាប់ និងអនុលោមតាមគោលការណ៍នៃសមភាពអធិបតេយ្យ[717] ភាគីនៃកិច្ចចរចាសន្ធិសញ្ញា គឺជាអ្នកចូលរួមស្មើភាព ហើយដូចបានកត់សម្គាល់ខាងលើ អត្ថបទនៃសន្ធិសញ្ញាដែលបានចុះហត្ថលេខា ត្រូវបានសន្មតថាជាកំណត់ហេតុសម្តែងបំណង[718]។ ប៉ុន្តែ សំខាន់ជាងនេះ ប្រវត្តិនៃការចរចា និងការ

---

[714] ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤០០។

[715] ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤០១។

[716] ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤០៧។

[717] *សូមមើល* ឧទា. ធម្មនុញ្ញអង្គការសហប្រជាជាតិ សានហ្វ្រានស៊ីស្កូ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ មាត្រា ២(១) ["អង្គការនេះគឺផ្អែកលើគោលការណ៍សមភាពអធិបតេយ្យរបស់សមាជិកទាំងអស់"]។ សេចក្តីសម្រេចចិត្តលេខ ២៦២៥ របស់មហាសន្និបាត អ.ស.ប *សេចក្តីប្រកាសស្តីពីគោលការណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធនឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋ អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ* A/RES/25/2625 ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧០ ទំព័រ ១២៤ ["រដ្ឋទាំងអស់ទទួលបានសមភាពអធិបតេយ្យ ដោយមានសិទ្ធិ និងភារកិច្ចស្មើៗគ្នា ហើយគឺជាសមាជិកដូចគ្នានៅក្នុងសហគមន៍អន្តរជាតិ"]។

[718] *សូមមើល ដូចខាងលើ* កថាខណ្ឌ ១៧៤ អនុសញ្ញាទីក្រុងវីយែន មាត្រា ៣២ ["អាចធ្វើការបកស្រាយតាមមធ្យោបាយ *បន្ថែម* រួមទាំងការងារត្រៀមរៀបចំសន្ធិសញ្ញា និងកាលៈទេសៈនៃការចុះហត្ថលេខាដើម្បីបញ្ជាក់អត្ថន័យដែលកើតចេញពីការអនុវត្តម

ជជែកវែកញែកស្ដីពីការអនុម័តច្បាប់ អ.វ.ត.ក មានលក្ខណៈស្រពិចស្រពិល។ រាជរដ្ឋាភិបាលកម្ពុជា មិនមានចេតនាថា ប្រភេទទាំងមូលនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និងកម្រិតត្រឹមតែ ឌុច ឬ បុគ្គលតែម្នាក់នោះឡើយ។ ផ្ទុយមកវិញ ចេតនានេះគឺទុកឱ្យទៅក្រុម អ.វ.ត.ក ធ្វើការសម្រេចដោយឯករាជ្យ ដោយផ្អែកលើភ័ស្តុតាងថាតើបុគ្គលណា និងបុគ្គលប៉ុន្មាននាក់ ដែលស្ថិតនៅក្នុងប្រភេទនេះ។ អ.ស.ប ប្រកាន់ជំហរដូចគ្នា។

177. ការថ្លែងបង្ហាញនៅចំពោះមុខសភាជាតិ ធ្វើឡើងដោយឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាភាគីចរចាចំបងនៅក្នុងកិច្ចពិភាក្សាជជែកជាមួយ អ.ស.ប គឺជាភ័ស្តុតាងដ៏ប្រពៃបំផុតបង្ហាញបំណងរបស់រដ្ឋាភិបាលកម្ពុជា នៅពេលបង្កើតកិច្ចព្រមព្រៀង អ.វ.ត.ក។ សុខ អាន បានថ្លែងយ៉ាងស៊ីសង្វាក់គ្នាថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទមានកម្រិត តែបើកចំហ។

178. ថ្លែងក្នុងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២000 គឺ រយៈពេលជាង ១៨ ខែ ក្រោយចាប់ខ្លួន ឌុច[719] និងនៅមុនពេលអនុម័តច្បាប់ អ.វ.ត.ក ក្នុងឆ្នាំ២០០១ តែបន្តិច[720] សុខ អាន បានថ្លែង ដោយពុំបានសំដៅលើ ឌុច ថា៖

> ក្របខ័ណ្ឌសមត្ថកិច្ចផ្អែកមូលដ្ឋានលើទិដ្ឋភាពផ្លូវច្បាប់ធំៗចំនួនបី៖ ទី១ អ្វីដែលយើងហៅថា ទិដ្ឋភាពសមត្ថកិច្ចបុគ្គល ("La compétence personelle") ដែលត្រូវកំណត់គោលដៅដែលជាកម្មវត្ថុនៃការជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញ។ ដូច្នេះ ទិដ្ឋភាពមួយនេះបញ្ជាក់យ៉ាងច្បាស់ថា

មាត្រា ៣១ ឬ ដើម្បីកំណត់អត្ថន័យនៅពេលការបកស្រាយអនុលោមតាមមាត្រា ៣១៖ (ក) ធ្វើឱ្យអត្ថន័យមានភាពស្រពិចស្រពិល ឬ មិនច្បាស់លាស់ ឬ (ខ) នាំឱ្យមានលទ្ធផលដែលឆ្គាំឆ្គង ឬ មិនសមហេតុផលច្បាស់ក្រឡែត"។ (ការគូសបញ្ជាក់បន្ថែម)]។

[719] ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤០២ ["ឌុច [...] ត្រូវបានចាប់ខ្លួននៅក្នុងខែឧសភា ឆ្នាំ១៩៩៩"]។ *សូមមើល ផងដែរ* សំណុំរឿង 001 ឯកសារ E188 សាលក្រម *ឌុច* កថាខណ្ឌ ៦២៣។

[720] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានអនុម័តនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ (នស/រកម/០៨០១/១២) បោះពុម្ពឡើងវិញនៅក្នុង*ស្វែងរកការពិត* មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៣ ទំព័រ ៦៥-៧៧។

មានតែមេដឹកនាំជាន់ខ្ពស់ និង*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*ចំពោះ [បទឧក្រិដ្ឋ] ដែលនឹងត្រូវយកមកជំនុំជម្រះ[721]។

179. ក្នុងអំឡុងពេលពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាកម្ពុជានៅក្នុងខែតុលា ឆ្នាំ២០០៤ ស្ដីពីការធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក ឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង អ.វ.ត.ក អ្នកធ្វើច្បាប់មួយចំនួនបានស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺថាតើអ្នកធ្វើសេចក្ដីព្រាងមានន័យយ៉ាងដូចម្ដេចចំពោះឃ្លា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នោះ៖

ឯកឧត្ដម លី ធុច៖ "ប្រជាជនយើង និងសង្គមស៊ីវិលចង់ស្នើសុំឱ្យ ឯកឧត្ដម បញ្ជាក់ឱ្យបានច្បាស់ថា តើបុគ្គលណាជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត? តើពួកគេរួមបញ្ចូលប្រធានអង្គភាពអង្គការចាត់តាំងផងដែរឬទេ"?[722]

ឯកឧត្ដម កែវ រ៉េមី៖ "តើបុគ្គលណាជាមេដឹកនាំជាន់ខ្ពស់? [...] តើប្រធានភូមិភាគនឹងត្រូវនាំយកមកកាត់ទោសដែរឬទេ? [ឬក៏] ច្បាប់នេះ [កំពុង] ធ្វើឡើងដើម្បីជំនុំជម្រះមេដឹកនាំតែ ៤ ឬ ៥ នាក់តែប៉ុណ្ណោះ។ តើបុគ្គលណាផ្សេងទៀតនឹងត្រូវយកមកកាត់ទោស? តើវាមានភាពយុត្តិធម៌ដែរឬទេ ប្រសិនបើយើងកាត់ទោសតែមនុស្ស ៣ ឬ ៤ នាក់"?[723]

ឯកឧត្ដម អេង ឆៃអ៊ាង៖ "ខ្ញុំក៏មិនយល់ច្បាប់អំពី*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះដែរ*។ តើជនទាំងនោះនឹងត្រូវទទួលខុសត្រូវត្រឹមកម្រិតណា? [...] ខ្ញុំចង់ឱ្យតំណាងរដ្ឋាភិបាលបញ្ជាក់ថាតើជនទាំងនោះត្រូវទទួលខុសត្រូវធំធេងបំផុតត្រឹមកម្រិតណា។ [...] ខ្ញុំចង់ថាកុំឱ្យប្រជាជនមានភាពស្រពិចស្រពិល។ ប្រសិនបើយើងសង្កត់ធ្ងន់តែថ្នាក់ខ្ពស់បំផុតប៉ុណ្ណោះ យើងមានន័យថាជា ប៉ុល ពត ដែលបានស្លាប់បាត់ទៅហើយ"។[724]

---

[721] ការបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់ហេតុស្ដីពីសម័យប្រជុំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ *ស្វែងរកការពិត* មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៤ ចុះខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៤៤។

[722] ប្រតិចារឹកបកប្រែដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សម័យប្រជុំលើកទី១ នៃនីតិកាលទី៣ នៃរដ្ឋសភាកម្ពុជា ចុះថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០០ ("ប្រតិចារឹករដ្ឋសភាឆ្នាំ២០០៤") ទំព័រ ៩។

[723] ប្រតិចារឹក សភាជាតិ ឆ្នាំ ២០០៤ ទំព័រ ១៤។

[724] ប្រតិចារឹក សភាជាតិ ឆ្នាំ ២០០៤ ទំព័រ ២៧។

180. ផ្ទុយពីការអះអាងធ្វើឡើងនៅក្នុងដីកាលើកលែងការចោទប្រកាន់[725] សុខ អាន បានឆ្លើយតបដោយគ្មានស្រពិចស្រពិលថា យុត្តាធិការនេះមិនកម្រិតត្រឹមមេដឹកនាំជាន់ខ្ពស់នោះទេ ហើយក៏គ្មានការកំណត់ចំនួនមនុស្ស ដែលអាចស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក និងបញ្ជីឈ្មោះគោលដៅសក្តានុពលនៃការស៊ើបអង្កេតនោះដែរ។ គាត់ក៏បានបញ្ជាក់ច្បាស់ផងដែរថា ប្រភេទនៃជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើគោលការណ៍សក្តានុពលច្រើន។ តាមពាក្យពេចន៍របស់គាត់

> ប្រសិនបើយើងសួរសំណួរ "តើបុគ្គលណានឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ? ទាំងអង្គការសហប្រជាជាតិ ឬ ទាំងក្រុមការងាររបស់រាជរដ្ឋាភិបាល ពុំអាចផ្តល់ចម្លើយតបបាននោះទេ។ ដោយសារនេះជាភារកិច្ចរបស់តុលាការ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ប្រសិនបើយើងរៀបរាប់ឈ្មោះមនុស្សសម្រាប់ចោទប្រកាន់កាត់ទោសជំនួសតុលាការ យើងរំលោភអំណាចតុលាការ។ ហេតុដូច្នេះ យើងមិនអាចកំណត់ថា បុគ្គល ក ខ គ ឬ ឃ ជាបុគ្គលដែលនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនោះឡើយ។ ដើម្បីជាដំណោះស្រាយ យើងបានកំណត់គោលដៅចំនួនពីរ៖ *មេដឹកនាំជាន់ខ្ពស់* និង *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ នៅពេលពិចារណា *មេដឹកនាំជាន់ខ្ពស់* យើងសំដៅលើបុគ្គលមិនលើសពី ១០ នាក់ ប៉ុន្តែ យើងពុំបញ្ជាក់ឲ្យបានច្បាស់ថាពួកគេគឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នោះទេ។ នេះគឺជាការងាររបស់សហព្រះរាជអាជ្ញាដែលត្រូវសម្រេចថាតើបុគ្គលណាខ្លះគឺជាមេដឹកនាំជាន់ខ្ពស់ [...] ទោះបីជាយ៉ាងនេះក្តី នៅមានក្រុមគោលដៅទី២ទៀត។ ពួកគេពុំមែនជាមេដឹកនាំជាន់ខ្ពស់នោះទេ ប៉ុន្តែពួកគេប្រព្រឹត្តអំពើឃោរឃៅ។ ហេតុដូច្នេះហើយទើបយើងប្រើប្រាស់ *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ គ្មានចំនួនមនុស្សជាក់លាក់នៅក្នុងក្រុមទី២ ដែលនឹងត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនោះឡើយ"[726]។

181. ជាការពិតណាស់ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថា ការសម្រេចថាតើបុគ្គលទាំងឡាយណា ដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក គឺជាបញ្ហានៃការសម្រេចដោយឯករាជ្យ

[725] ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៣៩៨ *ដកស្រង់* ប្រតិចារឹករដ្ឋសភាឆ្នាំ២០០៤ (សំណៅភាសាខ្មែរ) ដើម្បីគាំទ្រការលើកឡើងថា "[បញ្ហាយុត្តាធិការដ៏ចង្អៀតនេះ ត្រូវបានលើកឡើងដោយតំណាង[រាជរដ្ឋាភិបាលកម្ពុជា] នាពេលប្រជុំនៅរដ្ឋសភា ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាង[ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា] ឈរលើមូលដ្ឋាននៃខ្លឹមសារដ៏ជាក់លាក់ថា ជនមុខសញ្ញាត្រូវតែមានចំនួនតិច និងមិនទូលំទូលាយដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះ។ ជំហរនេះបានបង្ហាញជាដដែលៗបន្តបន្ទាប់មកទៀត]"។

[726] ប្រតិចារឹក សភាជាតិ ឆ្នាំ ២០០៤ ទំព័រ ១, ២០-៣១ (ការគូសបញ្ជាក់បន្ថែម)។

របស់ចៅក្រមនៅក្នុងតុលាការ។ នៅក្នុងខែមីនា ឆ្នាំ១៩៩៩ គាត់បានជម្រាបអគ្គលេខាធិការ អ.ស.ប ថា៖

> រាជរដ្ឋាភិបាលកម្ពុជាពុំមានអំណាចកំណត់កាតព្វកិច្ចលើសាលាក្ដីមានសមត្ថកិច្ចនោះឡើយ [...] បញ្ហាថាតើត្រូវកាត់ទោស តាម៉ុក តែម្នាក់ឯង ឬ មេដឹកនាំខ្មែរក្រហមផ្សេងទៀតដែរឬទេនោះគឺអាស្រ័យលើសមត្ថកិច្ចរបស់សាលាក្ដីទាំងស្រុង។ រាជរដ្ឋាភិបាលកម្ពុជានឹងមិនដាក់សម្ពាធ ឬ ជ្រៀតជ្រែក ទោះក្នុងទម្រង់ណាក៏ដោយ លើកិច្ចនីតិវិធីទូទៅរបស់តុលាការ ដែលមានភាពឯករាជ្យទាំងស្រុងពីអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ[727]។

182. មួយខែក្រោយមក នៅក្នុងកិច្ចប្រជុំនាខែមេសា ឆ្នាំ១៩៩៩ ជាមួយសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក John Kerry ដែលបានចូលរួមនៅក្នុងការចរចា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ជូន John Kerry ថា៖

> ការចោទប្រកាន់ និងការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្សេងទៀតគឺជាសមត្ថកិច្ចរបស់តុលាការតែមួយគត់។ រាជរដ្ឋាភិបាលកម្ពុជាពុំមានសិទ្ធិបញ្ជាឲ្យស្ថាប័នតុលាការ ធ្វើនេះ ឬ ធ្វើនោះឡើយ[728]។

<u>*អង្គការសហប្រជាជាតិ*</u>

---

[727] លិខិតចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ ពីនាយករដ្ឋមន្ត្រីកម្ពុជាផ្ញើជូនអគ្គលេខាធិការ ឯកសារ អ.ស.ប លេខ A/53/875 S/1999/324 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ២-៣។ *កំណត់សម្គាល់* នៅក្នុងកថាខណ្ឌ ៤ ហ៊ុន សែន បានស្នើសុំឲ្យចែកចាយលិខិតនេះជាឯកសារមហាសន្និបាត។

[728] សេចក្តីថ្លែងការណ៍ធ្វើឡើងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៩ ដោយខុទ្ទកាល័យ សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ឯកសារ អ.ស.ប លេខ A/53/916 ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៩។ លើសពីនេះ "ក្រោយពេលទទួលបានការធានាបែបនេះពីសម្ដេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រឹទ្ធសមាជិក John Kerry បានស្វាគមន៍ជំហរវិជ្ជមានរបស់នាយករដ្ឋមន្ត្រីកម្ពុជា"។ *សូមមើលផងដែរ* សារព័ត៌មានអន្តរជាតិ Kyodo *ហ៊ុន សែន សោកស្ដាយដែលបានលើកឡើងអំពីចំនួនមេដឹកនាំខ្មែរក្រហមដែលត្រូវយកមកកាត់ទោស* ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០០ [នៅក្នុងកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានជប៉ុន៖ "នាយករដ្ឋមន្ត្រីបានសម្ដែងការសោកស្ដាយកាលពីថ្ងៃសុក្រដោយបានលើកឡើងថា វាស្ថិតនៅក្នុងដែនកំណត់របស់តុលាការ" គាត់] តាមសម្ដីគាត់ [...] ហ៊ុន សែន បានលើកឡើងថា បុគ្គលណាដែលបញ្ជាក់ចំនួនមេដឹកនាំដែលត្រូវកាត់ទោស "គឺខុស ហើយរួមទាំង អ្នកជំនាញច្បាប់ អ.ស.ប ផងដែរ ដែលលើកឡើងថាចន្លោះពីមនុស្ស ២០ ឬ ៣០នាក់"។ នាយករដ្ឋមន្ត្រីលើកឡើងថា នៅពេលផ្ដល់ចំនួនមេដឹកនាំខ្មែរក្រហមជាក់លាក់ "យើងបំពានតុលាការ"]។

183. អ.ស.ប ដែលជាភាគីទីពីរនៃកិច្ចចរចា មានការយល់ឃើញដូចគ្នា។ នៅក្នុងដំណើរការដើមដំបូងក្នុងឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញចាត់តាំងដោយអគ្គលេខាធិការ ឲ្យពិនិត្យស្រាវជ្រាវមើលជម្រើសណាខ្លះដែលសមបំផុតក្នុងការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា បានថ្លែងថា៖

> បុគ្គលដែលមិនស្ថិតនៅក្នុងតារាងរចនាសម្ព័ន្ធមេដឹកនាំជាន់ខ្ពស់ អាចដើរតួនាទីសំខាន់នៅក្នុងអំពើឃោរឃៅទាំងនេះ។ ជាពិសេស ចំណុចនេះហាក់ដូចជាត្រឹមត្រូវមែនពាក់ព័ន្ធនឹងមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ [...]
>
> ក្រុមអ្នកជំនាញផ្តល់អនុសាសន៍ថា សាលាក្តីណាក៏ដោយផ្តោតលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រង។ នេះរួមទាំងមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវលើការបំពារបំពាន ព្រមទាំង ជនទាំងឡាយដែលស្ថិតនៅថ្នាក់ក្រោមៗ ដែលត្រូវបានឆ្លើយដាក់ថាជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរទាំងនោះ។ យើងពុំមានបំណងកម្រិតចំនួនលើបុគ្គលបែបនេះ ដែលអាចជាគោលដៅនៃការស៊ើបអង្កេតបានឡើយ។ ក៏ប៉ុន្តែ យោងតាមក្រុមអ្នកជំនាញ ក្រោយកិច្ចពិគ្រោះយោបល់ និងការស្រាវជ្រាវបង្ហាញថា ចំនួនបុគ្គលដែលត្រូវជំនុំជម្រះអាចស្ថិតនៅក្នុងចន្លោះប្រហែលពី ២០ ទៅ ៣០ នាក់[729]។

184. អនុសាសន៍ទាំងនេះបង្កើតបានជាមូលដ្ឋាននៃជំហរចរចារបស់ អ.ស.ប នៅពេលនោះ។ David Scheffer បានរម្លឹកនៅក្នុងអត្ថបទមួយបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១១ ដែលពិពណ៌នាលម្អិតការចូលរួមរបស់គាត់នៅក្នុងការចរចាថា "យើងផ្តោតអារម្មណ៍លើតែមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ដែលបង្ហាញថាមានការទទួលខុសត្រូវខ្ពស់ *ព្រមទាំង អ្នកមុខអ្នកការថ្នាក់កំពូលផ្សេងទៀត ដូច ឌុច* ដែលមានតួនាទីដ៏មានឥទ្ធិពលចូលរួមចំណែកនៅក្នុងអំពើឃោរឃៅបែបនេះ"[730]។ គាត់ដឹង

---

[729] របាយការណ៍ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៣៥ ឯកសារ អ.ស.ប លេខ A/50/850 S/1999/231 ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ (របាយការណ៍ក្រុមអ្នកជំនាញ អ.ស.ប) កថាខណ្ឌ ១០៩-១១០ (ការគូសបញ្ជាក់បន្ថែម)។

[730] ឯកសារ D170.1.7 Scheffer D.J., *ប្រវត្តិចរចានៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក* អ្នកតាមដានសាលាក្តីកម្ពុជា ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ("អត្ថបទរបស់ Scheffer") EN 01168933 (ការគូសបញ្ជាក់ត្រូវបានលុបចោល និងបន្ថែម) [*សូមមើលផងដែរ* EN 01168930-1]។

ច្បាស់ថា "ព្រះរាជអាជ្ញាត្រូវរក្សាឆន្ទានុសិទ្ធិលើការចោទប្រកាន់បុគ្គលណាខ្លះ"[731] ហើយជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតគឺជា "ក្រុម" បុគ្គល[732]។ ច្បាស់ណាស់ថា តាមការយល់របស់ អ.ស.ប គឺថា ប្រភេទនេះនឹងមិនកម្រិតត្រឹម ឌុច នោះទេ។

185. នៅត្រឹមខែមីនា ឆ្នាំ២០០០ រដ្ឋាភិបាលកម្ពុជាបានស្នើពាក្យពេចន៍ "ជនទាំងឡាយដែលទទួលខុសត្រូវ" ដែលបានពង្រីកប្រភេទនេះលើសពីបំណងរបស់ អ.ស.ប ហើយអគ្គលេខាធិការ អ.ស.ប Kofi Annan និងទីប្រឹក្សាច្បាប់ អ.ស.ប Hans Corell លោកទាំងពីរបានបង្ហាញការព្រួយបារម្ភជូនរាជរដ្ឋាភិបាលកម្ពុជាថា បច្ចុប្បន្ន ក្រុមនេះគឺមានចំនួនច្រើនពេក។ នៅក្នុងអំឡុងពេលចរចាចុងក្រោយត្រង់ចំណុចនេះ រាជរដ្ឋាភិបាល និង អ.ស.ប ពុំបានព្យាយាមធ្វើការកម្រិតឱ្យបានច្បាស់លើប្រភេទនោះ ត្រឹម ឌុច នោះឡើយ[733]។ ផ្ទុយមកវិញ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ អ.វ.ត.ក ជាមួយនឹងពាក្យពេចន៍ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[734]។ អ្វីដែលគួរឱ្យកត់សម្គាល់ Scheffer បានរម្លឹកឡើងវិញថា៖

> ក្នុងនាមជាសមាជិកនៃការចរចាអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំដឹងថា អ្នកចរចា នៃ អ.ស.ប មិនបានសម្បទានចំពោះការបកស្រាយលើពាក្យពេចន៍ស្តីពីយុត្តាធិការបុគ្គល ដោយកម្រិតក្រុមជនសង្ស័យត្រឹមបុគ្គលចំនួន ៥ រូបជាក់លាក់បុណ្ណោះ[735]។

186. ជាក់ស្តែង វាមានភាពសមហេតុផលក្នុងការសន្និដ្ឋានថា អ្នកធ្វើច្បាប់កម្ពុជា និងអ្នកចរចា អ.ស.ប បានទទួលស្គាល់និយាមសិទ្ធិមនុស្សជាមូលដ្ឋាន ដូចបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីប្រកាសជាសាកល

---

[731] ឯកសារ D170.1.7 អត្ថបទរបស់ Scheffer EN 01168931។

[732] ឯកសារ D170.1.7 អត្ថបទរបស់ Scheffer EN 01168931 ["ក្រុមទាំងពីរ-ក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ-ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់សាលាក្តី។ ខ្ញុំពុំនឹងឃើញការលើកឡើងណាមួយផ្សេងពីនេះទេ"] EN 01168932, 4 [សំដៅលើ "រូបមន្តពីក្រុម"]។

[733] ឯកសារ D170.1.7 អត្ថបទរបស់ Scheffer EN 01168933-6។

[734] ឯកសារ D170.1.7 អត្ថបទរបស់ Scheffer EN 01168936។

[735] ឯកសារ D170.1.7 អត្ថបទរបស់ Scheffer EN 01168938 [នេះសំដៅលើ ឌុច ដែលត្រូវបានសម្រេចពិរុទ្ធភាពរួចហើយនៅក្នុងឆ្នាំ២០១០ ហើយនឹងសំដៅលើបុគ្គលទាំងបួនរូបដែលត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះរួចហើយ ហើយកំពុងជាប់ឃុំនៅ អ.វ.ត.ក នៅពេលនោះ ពោលគឺ នួន ជា អៀង សារី ខៀវ សំផន និងអៀង ធីរិទ្ធ]។

នៃសិទ្ធិមនុស្ស[736] កតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[737] និងលិខិតុបករណ៍សិទ្ធិមនុស្សប្រចាំតំបន់[738] និងចែងនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[739] ថា បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ ការព្រមព្រៀងថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" យោងតាមអង្គច្បាប់ អាចសំដៅត្រឹមតែ ឌុច ដោយមិនគិតថាភ័ស្តុតាងបានបង្ហាញអ្វីខ្លះអំពីការទទួលខុសត្រូវរបស់បុគ្គលផ្សេងៗ នឹងមិនមែនជាការប្រព្រឹត្តិស្មើភាពគ្នាលើ ឌុច និងបុគ្គលផ្សេងទៀត ហើយនឹងរំលោភគោលការណ៍ទាំងនេះ និងកិច្ចការពារនានា។

187. សរុបមក ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក បង្ហាញថា ចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប នៅពេលបង្កើតកិច្ចព្រមព្រៀង អ.វ.ត.ក គឺ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទបើកចំហ ដែលសមាជិកភាពនៅក្នុងក្រុមនេះនឹងត្រូវកំណត់ដោយសហព្រះរាជអាជ្ញា និងចៅក្រម នៃ អ. វ.ត.ក ដោយផ្អែកលើភ័ស្តុតាងទាំងមូល ហើយដោយបំពេញកិច្ចមិនលម្អៀង និងឯករាជ្យ[740]។ ប្រវត្តិនៃការចរចាបង្ហាញច្បាស់ថា គ្មានភាគីណាមួយមានចេតនាបកស្រាយទៅតាមការធ្វើឡើងនៅក្នុងដីកាលើកលែងការចោទប្រកាន់នោះឡើយ។

---

[736] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៧។

[737] កតាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស មាត្រា ១៤(១)។

[738] *សូមមើល ឧទា.* សេចក្តីប្រកាសរបស់អាមេរិកស្តីពីសិទ្ធិមនុស្ស និងភារកិច្ចរបស់មនុស្ស ដែលអនុម័តដោយសន្និសីទអន្តរជាតិលើកទី៩របស់រដ្ឋអាមេរិក Bogota ឆ្នាំ១៩៤៨ មាត្រា II។ ធម្មនុញ្ញអាហ្វ្រិក (Banjul) ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន រ៉ូម ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០០ បុព្វកថា ["ដោយគោរពលើគោលការណ៍ជាមូលដ្ឋាន ក្នុងនោះ បុគ្គលគ្រប់រូបមានសមភាពនៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារស្មើគ្នាចំពោះមុខច្បាប់"]។

[739] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ ["ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់"]។

[740] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣) ["ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត [...] ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬ ស្វែងរកការណែនាំពីរដ្ឋាភិបាល ឬ ប្រភពណាមួយផ្សេងទៀតឡើយ"]។ ច្បាប់ អ.វ.ត.ក មាត្រា ១០*ថ្មី* ["ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬ ស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬ ពីប្រភពណាមួយផ្សេងទៀតឡើយ"]។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៥១ ["អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"] មាត្រា ១២៨ ["អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"] មាត្រា ១២៩ ["មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី"] មាត្រា ១៣០ ["គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ"]។ ធម្មនុញ្ញសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ បុព្វកថា មាត្រា ១(៧)

188. នៅក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀង អ.វ.ត.ក ភាគីទាំងសងខាងមានកាតព្វកិច្ចគោរពទៅតាមបទប្បញ្ញត្តិ[741] ហើយ នៅពេលនេះ គ្មានភាគីខាងណាមួយអាចផ្លាស់ប្តូរដោយឯកតោភាគីលើវិសាលភាពនៃយុត្តាធិការបុគ្គលនោះឡើយ[742]។ ជាក់ស្តែង កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "នៅក្នុងករណីចាំបាច់ មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មបែបនេះ ត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ"[743]។ បទប្បញ្ញត្តិនេះចែងច្បាស់ថា ការផ្លាស់ប្តូរគោលនយោបាយមួយពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក (ដែលរួមបញ្ចូលយុត្តាធិការបុគ្គល) ត្រូវទទួលការឯកភាពពីភាគី *ទាំងសងខាង* ក្រោយការពិភាក្សាដោយមានការចូលរួមរបស់ភាគី *ទាំងសងខាង*។ មកទល់បច្ចុប្បន្ន ទាំងភាគីរាជរដ្ឋាភិបាល ឬ អ.ស.ប ពុំបានព្យាយាមធ្វើវិសោធនកម្មលើបទប្បញ្ញត្តិពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក នោះទេ ហើយច្បាប់ អ.វ.ត.ក កំណត់យុត្តាធិការបុគ្គល នៃ អ.វ.ត.ក និងគឺជាច្បាប់ដែល អ.ប.ជ ត្រូវអនុវត្តតាមនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

## ៣. ការសន្និដ្ឋានថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ផ្ទុយពីការសន្និដ្ឋានដោយផ្ទាល់របស់ ស.ច.ស.ជ នៅក្នុងដីកាលើកលែងការចោទប្រកាន់ ព្រមទាំង ដីកាដំណោះស្រាយនៃ សំណុំរឿង ០០៤/០១ និងដីកាលើកលែងការចោទប្រកាន់របស់សំណុំរឿង ០០៤/០២

189. ការអះអាងនៅក្នុងដីកាលើកលែងការចោទប្រកាន់ថា ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់ ក៏ផ្ទុយពីការសន្និដ្ឋានដោយផ្ទាល់របស់ ស.ច.ស.ជ នៅក្នុងដីកាលើកលែងការចោទប្រកាន់ក្នុង

---

["គោលបំណងនៃអាស៊ាន គឺ [...] ដើម្បី [...] លើកកម្ពស់ [...] នីតិរដ្ឋ"]។ របាយការណ៍ក្រុមអ្នកជំនាញ អ.ស.ប កថាខណ្ឌ ៩៧ ["យុត្តិធម៌ត្រឹមត្រូវ និងមិនលម្អៀង តម្រូវឲ្យធ្វើសេចក្តីសម្រេចឯករាជ្យចំពោះការចោទប្រកាន់បុគ្គលទៅជំនុំជម្រះ និងការផ្តន្ទាទោសដោយពុំមានសម្ពាធនយោបាយ"]។ *សូមមើល បន្ថែម* សេចក្តីថ្លែងការណ៍របស់រដ្ឋធានីប៉េកាំងស្តីពីគោលការណ៍ឯករាជនៃតុលាការនៅក្នុងតំបន់ Lawasia សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧ មាត្រា ៣(ក) ៤-៥។ ក្រម New Delhi ស្តីពីបទដ្ឋានអប្បបរមានៃឯករាជ្យតុលាការ ដែលអនុម័តដោយសេចក្តីសម្រេចមហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និង ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ កថាខណ្ឌ ១-២, ៤។

[741] អនុសញ្ញាទីក្រុងវីយែន មាត្រា ២៦ ["ការគោរពតាមកិច្ចសន្យា៖ គ្រប់សន្ធិសញ្ញាជាធរមានចងកាតព្វកិច្ចលើភាគី ហើយត្រូវគោរពតាមដោយសុទ្ធចិត្ត"]។ *សូមមើល ផងដែរ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(២)។

[742] អនុសញ្ញាទីក្រុងវីយែន មាត្រា ៣៩ ["សន្ធិសញ្ញាអាចធ្វើវិសោធនកម្មតាមការព្រមព្រៀងរបស់ភាគី"]។ គោលការណ៍ *គោរពតាមកិច្ចសន្យា* មានន័យក្នុងនោះថា ចាំបាច់ត្រូវបំពេញតាមដោយឯកតោភាគី។

[743] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(៣)។

សំណុំរឿង ០០៤/០២ ដែលទទួលស្គាល់ថា នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសន្និដ្ឋានដោយប្រយោលថា "វាពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការបង្កើត អ.វ.ត.ក នាំឱ្យមានការយល់ឃើញតាមផ្លូវច្បាប់ជារួមថា មានតែបុគ្គល (មានឈ្មោះ) មួយចំនួនប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ពោលគឺ ការជ្រើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកន្លងមក និងបច្ចុប្បន្ន ជាបញ្ហាឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស ហើយបានផ្អែកសុទ្ធសាធលើអង្គហេតុនៃរឿងក្តីនីមួយៗ"[744]។ ពាក្យពេចន៍ដូចគ្នានេះឃើញមាននៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ដែលចុះហត្ថលេខាដោយ ស.ច.ស.ជ និង ស.ច.ស.អ[745]។

190. ម្យ៉ាងវិញទៀត នៅក្នុងដីកាលើកលែងការចោទប្រកាន់ ស.ច.ស.ជ បានគូសបញ្ជាក់ត្រឹមត្រូវជាច្រើនលើកថា បញ្ហាថាតើនរណាអាចស្ថិតនៅក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ពុំត្រូវបានធ្វើបុរេវិនិច្ឆ័យដោយកិច្ចព្រមព្រៀង អ.វ.ត.ក នោះទេ។ ប៉ុន្តែ៖

> ការកំណត់លក្ខណវិនិច្ឆ័យថាជា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាទម្រង់នៃអំណាចឆន្ទានុសិទ្ធិនៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងការស៊ើបអង្កេតដោយឯករាជ្យពីសំណាក់សហចៅក្រមស៊ើបអង្កេត[746]។

ការសម្រេចទាំងនេះត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត។ វាបង្ហាញច្បាស់ថា ទាំងរាជរដ្ឋាភិបាល ទាំងអង្គការសហប្រជាជាតិមិនជឿថា កិច្ចព្រមព្រៀង ឬ ច្បាប់ អ.វ.ត.ក មានន័យថា "មានតែចំនួនបុគ្គល (មានឈ្មោះ) ជាក់លាក់ ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ"។ អ.ប.ជ ក៏ធ្លាប់បានយល់ឃើញដូចគ្នាចំពោះ "ភាពបត់បែន" នៅក្នុងប្រភេទនេះដែរ[747]។

---

744 សំណុំរឿង ០០៤/២-ឯកសារ D359 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤៦១។

745 ឯកសារ D261 ដីកាដំណោះស្រាយ (សំអាងហេតុ) នៅក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ៣៧។

746 ឯកសារ D266 ដីកាលើកលែងការចោទប្រកាន់ កថាខណ្ឌ ៣៦៤ [*សូមមើលផងដែរ* កថាខណ្ឌ ១៦៨ ៤០៥]។

747 ឯកសារ D308/1/3/20 សេចក្តីពិចារណាពាក់ព័ន្ធនឹងដីកាដំណោះស្រាយរបស់ អ.ប.ជ លើករណី អ៊ឹម ចែម កថាខណ្ឌ ២០ (ការសម្រេចជាឯកច្ឆ័ន្ទ) ["មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ [...]។ ភាពបត់បែននៃពាក្យទាំងនេះតម្រូវឱ្យ [ស.ច.ស] មានសិទ្ធិអំណាចមួយចំនួន (ការដកស្រង់ក្នុងអត្ថបទត្រូវបានលុបចោល)។

## V. សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងដីកាដំណោះស្រាយខ្វែងគ្នា

191. យោងតាមសំអាងហេតុដូចលើកឡើងយ៉ាងជាក់លាក់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ស.ព.អ សន្និដ្ឋានថា ការសន្និដ្ឋាននៅក្នុងដីកាលើកលែងការចោទប្រកាន់អំពីយុត្តាធិការបុគ្គល គួរត្រូវបានច្រានចោល។ ប្រសិនបើយល់ព្រមតាមបណ្តឹងឧទ្ធរណ៍នេះ វាបង្ហាញច្បាស់ថា សំណុំរឿងគួរបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត។ ទោះបីជាយ៉ាងនេះក៏ដោយ ស.ព.អ យល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏នឹងជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត និង ស.ព.ជ ផងដែរ។ ស.ព.អ កត់សម្គាល់ឃើញថា អាចមានសេណារីអូពីក្នុងករណីក្រោយពេល អ.ប.ជ សម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់នៅក្នុងរឿងក្តីនេះរួចហើយ ដីកាដំណោះស្រាយខ្វែងគ្នាទាំងពីរនឹងនៅមានអានុភាពអនុវត្តដដែល។ សេណារីអូទីមួយ អាចកើតឡើងប្រសិនបើ អ.ប.ជ មិនអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីចេញសេចក្តីសម្រេច ទៅតាមកិច្ចព្រមព្រៀង ច្បាប់ និងវិធានផ្ទៃក្នុង។ សេណារីអូទីពីរនឹងកើតឡើងនៅពេល អ.ប.ជ បានសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍ទាំងអស់ ដោយសន្និដ្ឋានថា ចៅក្រម ស.ច.ស.អ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន និង ស.ច.ស.ជ នៅក្នុងដីកាលើកលែងការចោទប្រកាន់របស់ខ្លួន បានបំពេញកិច្ចស្របតាមឆន្ទានុសិទ្ធិ។ ដូចនឹងពន្យល់ក្នុងចំណុចខាងក្រោម ប្រសិនបើស្ថានភាពណាមួយកើតឡើង បទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រ អ.ជ.ត.ក តម្រូវថា រឿងក្តីនេះបន្តទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ លទ្ធផលគឺស្របជាមួយនឹងគោលនយោបាយ ដែលមានភ័ស្តុតាងបង្ហាញនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្រផ្សេងទៀត នៃ អ.វ.ត.ក។

192. វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា៖

> សេចក្តីសម្រេចរបស់[អង្គបុរេ]ជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

ក. ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ។

ខ. ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

193. វិធាន ១(២) ចែងបន្ថែមទៀតថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬ តាមរយៈតំណាង"។ ហេតុដូច្នេះ វិធាន ៧៧(១៣)(ខ) អនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយ ស.ច.ស តែម្នាក់ ដូចរឿងក្ដីក្នុងពេលបច្ចុប្បន្ន។

194. វិធាន ៧៧(១៣)(ខ) ចែងច្បាស់ថា ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយសេចក្ដីសម្រេចដែលមានសម្លេងភាគច្រើនលើសលប់នោះទេ រឿងក្ដីប្រឆាំងនឹង មាស មុត ត្រូវបញ្ជូនទៅជំនុំជម្រះ។ ទោះបីជាពាក្យពេចន៍ "ដីកា" នៅក្នុងវិធាន ៧៧(១៣)(ក) ទំនងជាត្រូវបានយល់ថារួមបញ្ចូលទាំងដីកាលើកលែងការចោទប្រកាន់ផងដែរ[748]។ វិធាន ៧៧(១៣)(ខ) គឺជា *ច្បាប់ពិសេស* ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះ មានអានុភាពអនុវត្តលើពាក្យ

---

[748] ស.ព.អ កត់សម្គាល់ថា សំណៅភាសាបារាំងនៃវិធាន ៧៧(១៣) និង ៧៧(១៣)(ក) ចែងថា "Lorsque la majorité requise n'est pas atteinte, la Chambre préliminaire est présumée avoir rendu une décision s'interprétant comme suit: a) Concernant un appel contre une ordonnance ou une requête en annulation d'un acte d'instruction, *autre que l'ordonnance de clôture*, l'ordonnance ou l'acte d'instruction demeure" ដូច្នេះ មិនរាប់បញ្ចូលដីកាលើកលែងការចោទប្រកាន់នៅក្នុងវិសាលភាពនៃវិធាន ៧៧(១៣)(ក)។ សំណៅភាសាខ្មែរ ដូចគ្នានឹង ភាសាអង់គ្លេស សំដៅលើ "ដីកា ឬ កិច្ចស៊ើបសួរជាជាង*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ*" ដោយទុកដីកាលើកលែងការចោទប្រកាន់នៅក្នុងវិសាលភាពនៃវិធាននោះ។ នៅក្នុងសំណុំរឿង ០០៤/១ ក្នុងករណី អ.ប.ជ ពុំអាចរកចេញសេចក្ដីសម្រេចមានសម្លេងភាគច្រើនលើសលប់លើបណ្ដឹងឧទ្ធរណ៍ ស.ព.អ ចំពោះដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ឯកសារ D261 (ដីកាលើកលែងការចោទប្រកាន់) អ.ប.ជ "បានប្រកាសជាឯកតោភាគីថា ដីកាដំណោះស្រាយ (សំអាងហេតុ) លើកលែងបទចោទប្រឆាំងនឹង អ៊ឹម ចែម ត្រូវមានអានុភាព" ស្របតាមវិធាន ៧៧(១៣)(ក)។ *សូមមើល* សំណុំរឿង ០០៤/១ ឯកសារ D308/3/1/20 សេចក្ដីពិចារណាលើដីកាដំណោះស្រាយ អ.ប.ជ របស់ អ៊ឹម ចែម ទំព័រ ២៧ (ការសម្រេចជាឯកច្ឆ័ន្ទ)។

ពេចន៍ទូទៅនៅក្នុងវិធាន ៧៧(១៣)(ក)។ "ដីកាលើកលែងការចោទប្រកាន់" និង "ដីកាដំណោះស្រាយ" ដូចនឹង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" គឺជាពាក្យពេចន៍ជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង[749]។ ប្រសិនបើអ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង មានបំណងលើកឡើងជាក់លាក់អំពីអានុភាពនៃការខកខានរបស់ អ.ប.ជ ក្នុងការច្រានចោលដីកាលើកលែងការចោទប្រកាន់ អ.ប.ជ ប្រាកដណាស់ថានឹងបានចែងដូច្នោះបាត់ទៅហើយ។ ហេតុដូច្នេះ ទោះបីក្នុងករណីដីកាលើកលែងការចោទប្រកាន់ដែលត្រូវបានប្តឹងឧទ្ធរណ៍ តែមិនទទួលបានជោគជ័យ "នៅមានសុពលភាព" ថាជាកំណត់ហេតុនៃការអនុវត្តឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស ណាមួយ និងជាសេចក្តីសម្រេចមិនចូលរួមនៅក្នុងដីកាបញ្ជូនរឿងជំនុំជម្រះ វិធាន ៧៧(១៣)(ខ) ចង្អុលបញ្ជាក់ជាជម្រើសគោលនយោបាយថា នៅក្នុងករណីមានដីកាដំណោះស្រាយខ្វែងគ្នា អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយរឿងក្តីនោះត្រូវយកមកជំនុំជម្រះ។

195. យុត្តិសាស្ត្រ អ.ជ.ត.ក បញ្ជាក់ការបកស្រាយនេះ។ នៅក្នុងសាលដីកាលើសំណុំរឿង ០០១ អ.ជ.ត.ក បានសម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬ ក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬ មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិន អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[750]។

---

[749] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ១៣១-១៣២។

[750] សំណុំរឿង ០០១ ឯកសារ F28 សាលដីកា *ខាងលើ* កថាខណ្ឌ ៦៥ ដកស្រង់ ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ វិធាន ៧២(៤)(ឃ)។ ទោះបីជាការរកឃើញនេះផ្អែកលើការពិភាក្សាអំពីសេណារីយ៉ូដែល ស.ច.ស មួយរូប ឬ ទាំងពីរ បានបញ្ជូនបញ្ហានៃដីកាលើកលែងការចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទុយគ្នា ទៅ អ.ប.ជ អនុលោមតាមវិធាន ៧២ ក៏ដោយ ក៏លទ្ធផលផ្អែកលើសារធាតុអាចអនុវត្តបានដូចគ្នានឹងស្ថានភាពបច្ចុប្បន្ន ក្នុងករណីដែល អ.ប.ជ បានទទួលបណ្តឹងឧទ្ធរណ៍ពីភាគី ដោយសារវិធីដែល អ.ប.ជ បានទទួលបញ្ហាចោទដូចគ្នា មិនថា ចៅក្រមមានកំហុសនៅក្នុងការចេញដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំពាក់ព័ន្ធនោះទេ។

196. ទោះបីជា អ.ជ.ត.ក បានប្រើឃ្លាថា "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ដោយសារបានដកស្រង់ដោយផ្ទាល់ចេញពីច្បាប់ អ.វ.ត.ក ក៏ដោយ ការបកស្រាយសមហេតុផលតែមួយគត់នៃសេចក្ដីថ្លែងការណ៍នេះគឺ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបន្តទៅជំនុំជម្រះ ពោលគឺ យើងពុំឃើញមាននីតិវិធីផ្សេងអាចឲ្យ "បន្តទៅមុខ" នៅក្នុងដំណាក់កាលនេះ ដែល អ.ជ.ត.ក កំពុងពិភាក្សា (*ពោលគឺ* នៅពេលមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់ខ្វែងគ្នា)។ ដោយហេតុថា វិធានផ្ទៃក្នុងកំណត់និយមន័យថា "ដំណាក់កាលជំនុំជម្រះ" "សំដៅទៅលើកាលបរិច្ឆេទ ចាប់ពីពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង"[751] អ.ជ.ត.ក ទំនងជាពិចារណា "ការស៊ើបអង្កេត" ថាបន្តទៅមុខរហូតដល់ពេលដែល អ.ប.ជ បំពេញភារកិច្ចដាក់ប្ដឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៧(១៣)(ខ)។

197. លទ្ធផលនេះក៏ស្របគ្នាជាមួយស្មារតី និងរចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដែលបានគោរពតាមយ៉ាងរឹងមាំលើគោលការណ៍ដែលថា ស.ច.ស និងសហព្រះរាជអាជ្ញាអាចបំពេញកិច្ចដោយឯករាជ្យ ជម្រុញឲ្យកិច្ចដំណើរការនីតិវិធីទៅមុខ និងគោលនយោបាយចង់ឲ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខ ក្នុងករណីការខ្វែងយោបល់គ្នាពុំអាចរកដំណោះស្រាយបាន[752]។ អ.ប.ជ បានតម្កល់គោលការណ៍ម្ដងហើយម្ដងទៀតនាពេលកន្លងមក[753]។

---

751 វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ១៣៣។

752 *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤) ៦(៤) ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២០*ថ្មី* ២៣*ថ្មី*។ វិធាន ៧១ ៧២ ៧៧(១៣)។

753 *សូមមើល ឧទា.* ឯកសារ D1/1.3 ការពិចារណារបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១៦ ២៦ ៤៥។ សំណុំរឿង ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី កថាខណ្ឌ ២៧៤-២៧៦។ ឯកសារ D120/3/1/4.1.12 សេចក្ដីសម្រេចលើសំណើសុំបន្ទាប់របស់ អ៊ឹម ចែម សុំផ្អាកការអនុវត្តដីកាកោះហៅគាត់ឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ ឯកសារ D117/1/1/2 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៦។ ឯកសារ D128/1/7.1.4 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ [កោសលុប] ប្រឆាំងនឹងការបញ្ជាក់បំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសុពលភាពនៃដីកាកោះចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៧។ ឯកសារ D128/1/7.1.5 សាលដីកាលលើបណ្ដឹងឧទ្ធរណ៍ [កោសលុប] ប្រឆាំងនឹងសេចក្ដីសម្រេចច្រានចោលសំណើសុំ

198. នៅក្នុងស្ថានភាពបច្ចុប្បន្ន ដែលមានដីកាលើកលែងការចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះធ្វើឡើងក្នុងពេលស្របគ្នាដោយ ស.ច.ស មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ផ្តល់ការមគ្គុទេសក៍យ៉ាងជាក់លាក់អំពីកិច្ចការដែលត្រូវបំពេញប្រសិនបើ អ.ប.ជ មិនអាចដោះស្រាយការខ្វែងយោបល់គ្នារវាង ស.ច.ស ឬ សហព្រះរាជអាជ្ញា។ មាត្រានេះចែងថា "ការស៊ើបអង្កេត ឬ ការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត"[754]។ មិនថាមានការយល់ថា ការផ្ទេរដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងជាផ្នែកមួយនៃការស៊ើបអង្កេត ដូច អ.ជ.ត.ក បានធ្វើឡើង ឬ ផ្នែកមួយនៃការចោទប្រកាន់ វាបង្ហាញច្បាស់ថា ប្រសិនបើ អ.ប.ជ ខកខានមិនបានច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមសម្លេងភាគច្រើនលើសលប់ទេនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលបណ្តឹងយករឿងក្តីនេះមកជំនុំជម្រះ។

## VI. សេចក្តីសន្និដ្ឋាន

199. ដូចបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានស្ថាពររបស់ ស.ព.អ មាស មុត គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម មេបញ្ជាការកងពលធំលេខ ១៦៤ លេខាតំបន់ស្វយ័តកំពង់សោម និងជាសមាជិក ហើយបន្ទាប់មក អនុប្រធានអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា[755]។ នៅក្នុងនាទីជាន់ខ្ពស់ទាំងនោះ គាត់បានបញ្ជាដោយស្ម័គ្រចិត្តឱ្យចាប់ខ្លួន ដាក់ពន្ធនាគារ ដាក់ឱ្យទៅជាទាសករ និង/ឬ ការកាប់សម្លាប់ជនរងគ្រោះរាប់សិបពាន់នាក់ នៅក្នុងតំបន់នានាដែលគាត់គ្រប់គ្រង[756]។ មាស មុត បានរៀបចំ និងដឹកនាំយុទ្ធនាការប្រល័យពូជសាសន៍ប្រឆាំងនឹងវៀតណាមដែលចាត់ខ្លួននៅសមុទ្រដោយកងពលធំ

---

ព័ត៌មានពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១១។

[754] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ ចំណុចនេះក៏ឆ្លុះបង្ហាញនូវការយល់ឃើញរបស់អ្នកចរចាចំបងមួយរូប នៅក្នុងចំណោមអ្នកចរចាកិច្ចព្រមព្រៀង អ.វ.ត.ក គឺ លោក David Scheffer ដែលបានលើកឡើងថា អនុលោមតាមវិធានសម្លេងភាគច្រើនលើសលប់ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬ ការស៊ើបអង្កេតជាប់គាំង គឺប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចដោយសម្លេងភាគច្រើនលើសលប់ថា ខ្លួនគួរបញ្ចប់"។ *សូមមើល* David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី៣ វ៉ុលលីម III ឆ្នាំ២០០៨ ទំព័រ ២៤៦។

[755] ឯកសារ D256/7 ដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព កថាខណ្ឌ ៤៨-៨៧។

[756] *សូមមើល ឧទា.* ឯកសារ D256/7 កថាខណ្ឌ ៨៨-១៩៧ ២២១ ៤០០ ៤០២ ៤២២ ៦១៣ ៦៥៦ ៦៧៤-៥ ៦៩១ ១០៧៨-៩ ១០៨៩-៩២។

លេខ ១៦៤ និងកងពលលេខ ១ នៃភូមិភាគបស្ចិម[757] និងបានបញ្ជាឲ្យដាក់ពន្ធនាគារ ការកាប់សម្លាប់ ឬ ការផ្ទេរជនជាតិថៃ និងជនបរទេសជាងមួយពាន់នាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ ទៅកាន់ ស-២១[758]។ គាត់បានបង្កើត និងគ្រប់គ្រងមន្ទីរសន្តិសុខ និងការដ្ឋានការងារមួយចំនួននៅក្នុងតំបន់កំពង់សោម ដែលនៅទីនោះអ្នកដែលត្រូវចាត់ទុកថាជាខ្មាំងផ្ទៃក្នុង និងខាងក្រៅ ត្រូវបានដាក់ពន្ធនាគារនៅក្នុងលក្ខខណ្ឌអមនុស្សធម៌បំផុត ដាក់ឲ្យទៅជាទាសករធ្វើទារុណកម្ម និង/ឬ សម្លាប់ចោល[759]។ គាត់ក៏បានបង្ខំជនទាំងឡាយដែលនៅក្រោមការគ្រប់គ្រងរបស់គាត់ ឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី/ប្រពន្ធ ដែលត្រូវបានជ្រើសរើសដោយ ប.ក.ក និង ឲ្យរួមដំណេក ដោយគ្មានការយល់ព្រមពិតប្រាកដពីពួកគេនៅក្នុងករណីទាំងពីរនេះ[760]។ ក្នុងនាមជាអនុប្រធានអគ្គសេនាធិការ គាត់បានធ្វើការបោសសម្អាតថ្នាក់ដឹកនាំនៃកងពលធំលេខ ១១៧ និងតំបន់ស្វយ័ត ៥០៥ និងបុគ្គលិកនៅក្រោមបង្គាប់នៅចុងឆ្នាំ១៩៧៨ ហើយបញ្ជូនជនស៊ីវិលក្នុងមូលដ្ឋាន និងជនជាតិវៀតណាដែលចាប់ខ្លួនបាន ទៅ ស-២១[761]។ បន្ទាប់មក មាស មុត បានគ្រប់គ្រងលើតំបន់ស្វយ័តទីពីរ។

200. ដោយសារដីកាលើកលែងការចោទប្រកាន់ពុំពិចារណាលើភស្តុតាងទាំងអស់ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ហើយនឹងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ បទឧក្រិដ្ឋមួយផ្នែកធំដែលប្រព្រឹត្តដោយ មាស មុត ពុំត្រូវបានយកមកពិចារណាទាល់តែសោះ។ បទឧក្រិដ្ឋនៅសេសសល់ដែលដីកាលើកលែងការចោទប្រកាន់បានលើកយកមកពិចារណា ពុំត្រូវបានវិភាគសមស្រប ហើយបទឧក្រិដ្ឋទាំងនោះ ពុំត្រូវបានកំណត់បទចោទតាមផ្លូវច្បាប់។ អាស្រ័យហេតុនេះ ដីកាលើកលែងការចោទប្រកាន់ខកខានមិនបានពិចារណាឲ្យបានសមស្របលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទាំងនោះ ហើយនឹងកម្រិតនៃការទទួលខុស

[757] ឯកសារ D256/7 កថាខណ្ឌ ១២៥-៤២ ៣១៦-៧ ៣៦៣ ៤០០ ៤០២ ៤២២ ៧៣៦-៧ ៧៨១-៩៨ ៨៤៩ ១១២៣ ១១៣៦ ១០៧០-៤។

[758] ឯកសារ D256/7 កថាខណ្ឌ ១៤៣-៩ ១៧៣-៥ ២៤៥ ៣០២-៥ ៣៧៦-៨០ ៣៨៥-៩៥ ៤០១-២០ ៤២៥-៣០ ៤៥៧-៨ ៤៨៥ ៤៩១-៣ ៥០០-២ ៥១៦-៩ ៥៤៤-៩ ៥៨២-៩ ៥៥៩ ៦៥៩ ៧១៦-៩ ៧៩២-៨ ១០៧៧ ១០៩១-២ ១១២៣ ១១៣៦។

[759] ឯកសារ D256/7 កថាខណ្ឌ ១១៦ ១២៥ ១៥០-៦៣ ១៧១-២ ១៧៧-៩៧ ៣២៨-៤៨ ៣៥១-៣ ៣៦៦ ៥៤២-៣ ៣៨៥ ៣៥៦-៦០ ៥៥០-២ ៦៩០-៤ ៨៤៥-៨ ៨៦០-៩ ៨៧៤-៦ ១០៦៦ ១០៩៣ ១១២៣។

[760] ឯកសារ D256/7 កថាខណ្ឌ ២០៥-៦ ៧៩៩ ៨២១-៤៤ ១០៩១ ១១២៥។

[761] ឯកសារ D256/7 កថាខណ្ឌ ៨៤៥-៧៧។

ត្រូវរបស់ មាស មុត នៅពេលពិចារណាថាតើគាត់ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬទេ។

201. ការបន្ថយការទទួលខុសត្រូវរបស់ មាស មុត នៅក្នុងដីកាលើកលែងការចោទប្រកាន់ក៏ត្រូវបានផ្តល់ទឡ្ហីករណ៍ដោយផ្អែកលើការវិភាគអង្គច្បាប់ដែលមានកំហុសអំពីអានុភាពនៃបញ្ហារបស់ថ្នាក់លើចំពោះការសន្និដ្ឋានថាតើបុគ្គលម្នាក់ស្ថិតនៅក្នុងប្រភេទជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" លើទឧក្រិដ្ឋដែលមិនស៊ីសង្វាក់ជាមួយនឹងយុត្តិសាស្ត្រជាធរមានរបស់ អ.វ.ត.ក ពីក្នុងសំណុំរឿង ០០១។ ការវិភាគយុត្តាធិការបុគ្គលនេះក៏ផ្អែកលើកំហុសអង្គច្បាប់ និងអង្គហេតុពាក់ព័ន្ធនឹងការចូលរួមដ៏សំខាន់របស់ មាស មុត នៅក្នុងបទឧក្រិដ្ឋនៃសម័យកម្ពុជាប្រជាធិបតេយ្យ។ គ្មានភ័ស្តុតាងណាមួយបង្ហាញថា មាស មុត ធ្លាប់បានតវ៉ាលើគោលនយោបាយរបស់ ប.ក.ក នោះឡើយ។ ផ្ទុយមកវិញ គាត់បានឱបក្រសោប និងអនុវត្តវាយ៉ាងពេញចិត្តពេញថ្លើម ហើយនៅតែស្មោះស្ម័គ្រចំពោះ ប.ក.ក អស់រយៈពេល ២ ទសវត្សរ៍ ក្រោយបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ[762]។

202. ដោយហេតុថា ការវិភាគលើយុត្តាធិការបុគ្គលរបស់ដីកាលើកលែងការចោទប្រកាន់បានសំអាងលើកំហុសអង្គច្បាប់ និងអង្គហេតុ ស.ព.អ ស្នើសុំអង្គបុរេជំនុំជម្រះឲ្យវាយតម្លៃឡើងវិញលើបញ្ហានេះ ហើយសន្និដ្ឋានថា មាស មុត ពិតជាស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក។ ដោយហេតុថា ដីកាដំណោះស្រាយរបស់ ស.ច.ស.អ បានចោទប្រកាន់បញ្ជូន មាស មុត ទៅជំនុំជម្រះលើបទឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួន ស្របជាមួយនឹងវិធានផ្ទៃក្នុង ស.ព.អ ស្នើសុំឲ្យ អ.ប.ជ បញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង។

---

[762] ឯកសារ D1.3.7.8 សេចក្តីថ្លែងការណ៍របស់ មាស មុត *ផ្តែផេកកុំដាស់ រើសចស់កុំកាយ* (ខែមបូខាដេលី) ថ្ងៃទី១-២ ខែមីនា ឆ្នាំ២០០៨ EN 00165821។ ឯកសារ D54/1.1 សេចក្តីថ្លែងការណ៍របស់ មាស មុត *ជំហរចុងក្រោយ* (សោតអ៊ីសអេស៊ី ខ្លួប) ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១១ EN 00915789។ ឯកសារ D114/307.5 សេចក្តីថ្លែងការណ៍របស់ មាស មុត ប្រតិចារឹករបស់ "បងធំទី១" (ចននីម៉ែន ធីវី) ឆ្នាំ២០១៣ EN 01389356។

202. ដោយហេតុថា ការវិភាគលើយុត្តាធិការបុគ្គលរបស់ដីកាលើកលែងការចោទប្រកាន់បានសំអាងលើកំហុសអង្គច្បាប់ និងអង្គហេតុ ស.ព.អ ស្នើសុំអង្គបុរេជំនុំជម្រះឲ្យវាយតម្លៃឡើងវិញលើបញ្ហានេះ ហើយសន្និដ្ឋានថា មាស មុត ពិតជាស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក។ ដោយហេតុថា ដីកាដំណោះស្រាយរបស់ ស.ច.ស.អ បានចោទប្រកាន់បញ្ជូន មាស មុត ទៅជំនុំជម្រះលើបទឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួន ស្របជាមួយនឹងវិធានផ្ទៃក្នុង ស.ព.អ ស្នើសុំឲ្យ អ.ប.ជ បញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង។

## VII. ដំណោះស្រាយដែលស្នើឡើង

203. អាស្រ័យដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើដោយគោរពឲ្យអង្គបុរេជំនុំជ្រានចោលការសន្និដ្ឋានដោយមានកំហុសនៅក្នុងដីកាលើកលែងការចោទប្រកាន់ថា មាស មុត មិនមែនជាកម្មវត្ថុនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក សន្និដ្ឋានថា មាស មុត គឺជាបុគ្គលម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ជូន មាស មុត ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ៕

សូមចៅក្រមអង្គបុរេជំនុំជម្រះពិនិត្យពិចារណាដោយក្ដីអនុគ្រោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ | **លោក** Nicholas KOUMJIAN **សហព្រះរាជអាជ្ញាអន្តរជាតិ** | ភ្នំពេញ | |